ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ







# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍ប្រចាំឆ្នាំ២០២២

ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ

# របាយការណ៍ប្រចាំឆ្នាំ២០២២

## (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

# របស់កំពង់ផែស្វយ័តភ្នំពេញ

# ទស្សនវិស័យ
# និងបេសកកម្ម

## ទស្សនវិស័យ

- ទស្សនវិស័យរបស់ ក. ស. ភ. គឺរក្សាភាពជាអ្នកគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេមេគង្គ និងដើរតួនាទីជាបណ្ដាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងតម្លាភាព ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មក្រៅប្រទេស។

## បេសកកម្ម

- បេសកកម្មរបស់ ក. ស. ភ. គឺគ្រប់គ្រង អភិវឌ្ឍ ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និងបម្រើសេវាកម្មចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមាននិរន្តរភាព នៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីកចម្រើនក្នុងសង្គមជាតិទាំងមូល។

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប កម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា និងស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ

### ១.១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | | |
| ទ្រព្យសកម្មសរុប | | ១.០១២.៤៨១.៧០៩ | ៨៩៥.៨០៦.៩៥៣ | ៨៣៦.៣២០.៧១០ |
| បំណុលសរុប | | ២៤៤.០៨១.៨៣៨ | ១៩០.៣៦៤.៦៦៦ | ១៨៤.១៥៤.១៥៩ |
| មូលធនសរុប | | ៧៦៨.៣៩៩.៨៧១ | ៧០៥.៤៤២.២៨៧ | ៦៥២.១៦៦.៥៥១ |
| **លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)** | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| ចំណូលសរុប | | ១៤៨.៨១៥.៥៦៧ | ១២៥.២២៨.១៥២ | ១១០.៣០៣.៤២៤ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | | ៧៥.៤០៣.៧៣៣ | ៦៣.៩១៧.៧៩១ | ៥១.៤៧២.០១៥ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | | ៥៨.៤៩៨.៣៨៩ | ៥១.៦៩៥.៤៥៧ | ៤០.២១២.៦៤៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៥៩.៥២៧.៣៣២ | ៥១.៦០៩.៨៩១ | ៤១.១០៣.១០៩ |
| **អនុបាតហិរញ្ញវត្ថុ** | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| អនុបាតសាធនភាព (ភាគរយ) | | ៣០,៨៩ | ៣៤,២៧ | ២៨,៤០ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (ចំនួនដង) | ៣,៤៩ | ៣,៣៦ | ៣,៨៦ |
| | អនុបាតចរន្តលឿន (ចំនួនដង) | ៣,៤១ | ៣,៣៦ | ៣,៨៦ |
| | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ៥,៨៨ | ៥,៧៦ | ៤,៩១ |
| | អនុបាតចំណេញធៀបនឹងមូលធន(ភាគរយ) | ៧,៧៥ | ៧,៣២ | ៦,៣០ |
| | អនុបាតគម្លាតចំណេញដុល (ភាគរយ) | ៦៥,៨២ | ៦៨,១៣ | ៧០,៤១ |
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ៤០,០០ | ៤១,២១ | ៣៧,២៦ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ២.៨៧៧,៨៩ | ២.៤៩៥,១២ | ១.៩៨៧,១៦ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ២៥,១៥ | ១៩,៦១ | ១៤,៤៧ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | | - | ២១១,៦០ | ១៩៩,៥១ |

## ១.២. ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)






## ការបែងចែកប្រភេទចំណូលធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម




## ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២២ (ពាន់រៀល)



## អត្រាកំណើនចំណូលសរុប និង ប្រាក់ចំណេញ ប្រចាំឆ្នាំ សម្រាប់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ (ពាន់រៀល)




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ និងផែនការឆ្នាំ២០២២ (ពាន់រៀល)



## ១.៣. កម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

| ភាគហ៊ុន | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព |
|---|---|---|
| **ភាគហ៊ុនប្រភេទ ("គ")** | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | **៩៣.៧៦៩.១២០** | **១០០%** |
| **ភាគហ៊ុនធម្មតាប្រភេទ ("ខ")** | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | **១៦.៥៤៧.៤៩២** | **៨០%** |
| **ភាគហ៊ុនធម្មតាប្រភេទ ("ក")** | | |
| ១. ESOP | ២៤០.៣៤០ | ១,១៦% |
| ២. ភាគហ៊ុនិកឯកជន | ៣.៨៩៦.៥៣៣ | ១៨,៨៤% |
| **សរុបភាគហ៊ុនធម្មតាប្រភេទ ("ក")** | ៤.១៣៦.៨៧៣ | **២០%** |

** ភាគហ៊ុនធម្មតាប្រភេទ ("ក") និង ("ខ") សរុបចំនួន ២០.៦៨៤.៣៦៥ ភាគហ៊ុន។*



**តម្លៃជួញដូរភាគហ៊ុនជាមធ្យម (គិតជារៀល) និងបរិមាណជួញដូរជាមធ្យម (ភាគហ៊ុន) នៃភាគហ៊ុនប្រភេទ "ក"**



## ១.៤. ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

### ស្ថិតិនាវាដឹកទំនិញឆ្លងកាត់ ក. ស. ភ.

**ឯកតា (គ្រឿង)**

| បរិយាយ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| នាវា-សាឡង់អន្តរជាតិ | ៣.២៨៧ | ១.៧៧០ | ១.៨២៤ |
| នាវាប្រេង | ៤៩៦ | ៥៣២ | ៥៣៩ |
| នាវាកម្ពុជា | 0 | 0 | 0 |
| សាឡង់កម្ពុជា | 0 | 0 | 0 |
| **សរុប** | **៣.៧៨៣** | **២.៣០២** | **២.៣៦៣** |

### ស្ថិតិកុងតឺន័រឆ្លងកាត់ ក. ស. ភ.

**ឯកតា (TEUs)**

| បរិយាយ | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|---|
| នាំចូល | គ្មានទំនិញ | ១២៩.៦៦២ | ៩៣.២៧៣ | ៥៨.០៤១ |
| | មានទំនិញ | ៦៣.១១៥ | ៦៩.៩៤០ | ៨០.៤៥៦ |
| សរុបនាំចូល | | ១៩២.៧៧៧ | ១៦៣.២១៣ | ១៣៨.៤៩៧ |
| នាំចេញ | គ្មានទំនិញ | ១៥.៦២៤ | ១៤.៦៣៧ | ២០.៩៩៤ |
| | មានទំនិញ | ២០៩.២៩៥ | ១៧១.០៤៨ | ១៣១.៣៦៦ |
| សរុបនាំចេញ | | ២២៤.៩១៩ | ១៨៥.៦៨៥ | ១៥២.៣៦០ |
| **សរុប** | | **៤១៧.៦៩៦** | **៣៤៨.៨៩៨** | **២៩០.៨៥៧** |

### ស្ថិតិនាវាទេសចរណ៍អន្តរជាតិឆ្លងកាត់ ក. ស. ភ.

**ឯកតា (គ្រឿង)**

| បរិយាយ | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|---|
| នាវាទេសចរណ៍អន្តរជាតិ | អ្នកដំណើរ (នាក់) | ៦.៩៤៧ | 0 | ៩.៧៣៣ |
| | នាវា (គ្រឿង) | ២០៦ | 0 | ២៥២ |

# ២. សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ហ៊ី បាវី**
**ប្រធានក្រុមប្រឹក្សាភិបាល**
និងជាអគ្គនាយក ក. ស. ភ.



**ឯកឧត្តម សួន រចនា**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម កែន សម្បត្តិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ប៉ែន សុវិជាតិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ្គី អានវ៉ានិថ**
**សមាជិកក្រុមប្រឹក្សាភិបាល**
អភិបាលឯករាជ្យ



**អ្នកស្រី ប៉ុក ភក្តី**
**សមាជិកក្រុមប្រឹក្សាភិបាល**
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន



**លោក គង់ សុធា**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងនិយោជិត ក. ស. ភ.

## ៣. សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល

សម្រាប់ការអនុវត្តក្នុងឆ្នាំ២០២២ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានចំនួនសរុប ១៤៨.៨១៥.៥៦៧ ពាន់រៀល (៣៦.៤១១.៩៣២ ដុល្លារអាមេរិក) សម្រេចបាន ១០១,៧៨% នៃការគ្រោងផែនការឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ កើនឡើងចំនួន ២៣.៥៨៧.៤១៥ ពាន់រៀល (៥.៦២៨.២១៧ ដុល្លារអាមេរិក) ឬស្មើនឹង ១៨,៨៤%។ ចំណែកប្រាក់ចំណេញសុទ្ធ ក្នុងការិយបរិច្ឆេទមានចំនួនសរុប ៥៨.៤៩៨.៣៨៩ ពាន់រៀល (១៤.៣១៣.២៨៣ ដុល្លារអាមេរិក) សម្រេចបាន ១០០,៥៣% នៃការគ្រោងផែនការឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ កើនឡើងចំនួន ៦.៨០២.៩៣២ ពាន់រៀល (១.៦០៥.៤៥២ ដុល្លារអាមេរិក) ឬស្មើនឹង ១៣,១៦% ។ ដោយឡែក ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិក្នុងឆ្នាំ២០២២ (Basic Earnings per Share) គឺចំនួន ២.៨៧៧,៨៩ រៀល (០,៧០ ដុល្លារអាមេរិក) ។

សមិទ្ធិផលខាងលើអាស្រ័យដោយ ក.ស. ភ. តែងប្រកាន់ភ្ជាប់នូវការយកចិត្តទុកដាក់ក្នុងការបម្រើ សេវាកម្មប្រតិបត្តិការផែជូនអតិថិជនប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទំនុកចិត្តខ្ពស់ចំពោះតម្រូវការរបស់អតិថិជន។ ជាក់ស្តែង ក.ស.ភ. បានប្រើប្រាស់គ្រប់យន្តការ តាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពលើកដាក់ និងផ្ទេរផ្ទុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការជួសជុលថែទាំ ការងារផលធារសាស្ត្រ និងការងារបំពាក់គ្រឿងចក្រ និងឧបករណ៍ថ្មីៗជាដើម។

### ៣.១. ទិសដៅការងារអនុវត្តបន្តរបស់ ក.ស.ភ

បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុក

ធានាគុណភាព តម្លៃ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្តល់សេវាកម្មជូនអតិថិជន

ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភស្តុភារកម្ម

ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីឆ្លើយតបនឹងការវិវឌ្ឍរបស់អង្គភាពស្របទៅនឹងការផ្លាស់ប្តូរចរន្តភាវូបនីយកម្ម និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព

ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយបណ្តាកំពង់ផែក្នុងតំបន់ និងបណ្តាកំពង់ផែដទៃទៀតនៅលើពិភពលោក

ខិតខំ និងបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដារ និងប្រព័ន្ធបច្ចេកវិទ្យា

បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុង និងក្រៅប្រទេស

បង្វិតសេវាកម្មកំពង់ផែឱ្យកាន់តែខិតជិតអ្នកប្រើប្រាស់

ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

## ៣.២. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

សម្រាប់ឆ្នាំ២០២២ ក.ស.ភ. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ៦ លើក ដូចខាងក្រោម៖

### ១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៣ អាណត្តិទី៧ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២

- បានពិនិត្យ និងពិភាក្សាលើករណីទឹកប្រាក់ជំពាក់របស់ក្រុមហ៊ុន ចៀន ឈីង ថៃ គ្រុប ទឹកប្រាក់ចំនួន ៤.៧៣១.៣៧៦ ដុល្លារអាមេរិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១) និងទឹកប្រាក់ចំនួន ១២៦.៥០១ ដុល្លារអាមេរិក (គិតត្រឹមថ្ងៃទី១០ ខែមករា ឆ្នាំ២០២២)
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក្រុមហ៊ុន មេគង្គ អូរីហ្សា ត្រេឌីង ផ្ទេរសិទ្ធិជួលដី ដែលបានជួលពី ក. ស. ភ. ឱ្យទៅក្រុមហ៊ុន PTLS Cooperation Co., Ltd. ដោយសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងរាល់លក្ខខណ្ឌនានា ដែលបានកំណត់នៅក្នុងកិច្ចសន្យាដើម ភាគីក្រុមហ៊ុន PTLS Cooperation Co., Ltd. ត្រូវបានបន្តអនុវត្ត។

### ២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៤ អាណត្តិទី៧ នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

- បានពិនិត្យ និងអនុម័ត លើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្ម ឆ្នាំ២០២១
- បានពិនិត្យ និងពិភាក្សាលើការបន្តអាណត្តិរបស់ក្រុមប្រឹក្សាភិបាល ក. ស. ភ.
- បានពិនិត្យ និងសម្រេចលើសំណើសុំសហការវិនិយោគជាមួយក្រុមហ៊ុន PTLS COOPERATION CO., LTD ដើម្បីអភិវឌ្ឍចំណតផែរណបពហុបំណងUM១ របស់ ក. ស. ភ. តាមគោលការណ៍ ដែលបានសម្រេចលើកិច្ចសហការវិនិយោគចំណតផែរណបពហុបំណងTS១១
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ចុះបញ្ជីជាសាខាចំណតផែកុងតឺន័រ LM១៧ និងចំណតផែរណបផ្សេងទៀត នៅពេលមានប្រតិបត្តិការអាជីវកម្ម
- បានពិនិត្យ និងសម្រេចឱ្យសាខាគយ និងរដ្ឋាករកំពង់ផែ អន្តរជាតិភ្នំពេញ ស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការស្នើសុំលើកលែងថ្លៃសេវា ស្កុកទុកកុងតឺន័ររបស់ ក. ស. ភ.
- បានពិនិត្យ និងពិភាក្សាលើការសាងសង់ស្ពានផែថ្មីទំហំ ១៦ ម៉ែត្រ x ១៤៩ ម៉ែត្រ ដែលស្ថិតក្នុងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធផែជំហានទី៣ ដំណាក់កាលទី២ នៅចំណតផែLM១៧ និងកិច្ចសហការជាមួយឯកជនលើការបំពាក់ជង្ហុយយោងFCC ចំនួន ៣ គ្រឿង
- បានពិនិត្យ និងសម្រេចលើការដាក់ប្រាក់ចំនួន ៥ លានដុល្លារអាមេរិក ជាប្រាក់បញ្ញើមានកាលកំណត់ ដើម្បីបង្គ្រប់ទឹកប្រាក់ ១៥ លានដុល្លារអាមេរិកវិញ នៅធនាគារ FTB និងស្នើសុំប្រើប្រាស់ Overdraft ក្នុងករណីមានតម្រូវការ។

### ៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាវិសាមញ្ញ លើកទី១៥ អាណត្តិទី៧ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ របស់ ក. ស. ភ.
- បានពិនិត្យ និងពិភាក្សាលើការបែងចែកប្រាក់ថ្លៃងសរសើរជូនបុគ្គលិក ក. ស. ភ. និងប្រាក់ចំណេញ ចូលមូលនិធិនានា សម្រាប់ឆ្នាំ២០២១

- បានពិនិត្យ និងពិភាក្សាលើគម្រោងបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" ប្រចាំឆ្នាំ២០២១
- បានពិនិត្យ និងសម្រេចលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៧ របស់ ក. ស. ក.
- បានពិនិត្យ និងពិភាក្សាលើការស្នើសុំលើកលែងថ្លៃឈ្នួល៥០% សម្រាប់ឆ្នាំ២០២១ និងបន្តលើកលែងថ្លៃឈ្នួល ៥០% សម្រាប់ឆ្នាំ២០២២ នៃថ្លៃឈ្នួលដីទីលានស្តុកសំបកកុងតឺន័រ (ICD) ទំហំ ៩,៣ ហិកតា របស់ក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន(ខេមបូឌា) ឯ.ក។

## ៤. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៦ អាណត្តិទី៧ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

- បានសម្រេចអនុម័តលើរបាយការណ៍អាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ របស់ ក. ស. ក.
- បានអនុម័តកិច្ចព្រមព្រៀងស្តីពី កិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង UM២ រវាង ក. ស. ក. និងក្រុមហ៊ុនភីធីអិលអេស ខូអបភើរេសិន (PTLS Cooperation Co.,Ltd.) ដើម្បីគោរពស្នើសុំការយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ
- បានពិនិត្យ និងសម្រេចជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យចំនួន ៣ រូប និងបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនចំនួន ២ រូប ដើម្បីឈរឈ្មោះបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៧ របស់ ក. ស. ក.។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១ អាណត្តិទី៨ នាថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២

- បានសម្រេចទទួលស្គាល់នូវសមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិទី៨ របស់ ក. ស. ក. និងសមាសភាពក្រុមលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាភិបាលអាណត្តិទី៨
- បានពិនិត្យ និងសម្រេចលើសំណើសុំសហការជាមួយក្រុមហ៊ុនឯកជន លើការសាងសង់អគាររដ្ឋបាលថ្មី របស់ ក. ស. ក. និងសាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall)
- បានពិនិត្យ និងសម្រេចលើសំណើសុំជ្រើសរើសក្រុមហ៊ុនសវនកម្មឯករាជ្យថ្មីរបស់ ក. ស. ក.
- បានពិនិត្យ និងសម្រេចលើសំណើសុំធ្វើការសិក្សាទីតាំងចំណតផែតាមដងទន្លេចំនួន ៦ ទីតាំង ដើម្បីអភិវឌ្ឍជាចំណតផែរណបរបស់ ក. ស. ក.

## ៦. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី២ អាណត្តិទី៨ នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

- បានសម្រេចអនុម័តរបាយការណ៍ ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុសម្រាប់រយៈពេល ៩ខែ ដើមឆ្នាំ២០២២ និងប៉ាន់ស្មានលទ្ធផលប្រចាំឆ្នាំ២០២២ និងគម្រោងផែនការអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣
- បានទទួលជ្រាបជារបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងសាងសង់សាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall)

- បានទទួលជ្រាបជារបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងសាងសង់របស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប និងក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក និងទឹកប្រាក់ ដែលក្រុមហ៊ុនទាំងពីរនៅជំពាក់ ក. ស. ភ.
- បានទទួលជ្រាបជារបាយការណ៍ស្តីពីការស្នើសុំជួលដីបន្តរបស់ក្រុមហ៊ុន PTLS Cooperation Co., Ltd. និងអ្នកស្រី លី ចាន់នី ដែលក្រុមហ៊ុន ហ៊ួយ បាង អ៊ិនធើណេសិនណល អ៊ិនវេសម៉ិន គ្រុប បានផ្ទេរមកឱ្យ ក. ស. ភ. ចំនួន ៥០% នៃផ្ទៃដីសរុបដែលបានជួលពី ក. ស. ភ.
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាបន្ថែមលើគោលការណ៍គ្រប់គ្រងមូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម។

## ៣.៣. ការកំណត់ទិសដៅសម្រាប់ ឆ្នាំ២០២៣

ទស្សនវិស័យទៅអនាគត ក. ស. ភ. នឹងកំណត់ទិសដៅសម្រាប់អនុវត្តរួមមាន៖

- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស
- បន្តជំរុញការបង្កើតមជ្ឈមណ្ឌលភ័ស្តុភារកម្ម ឃ្លាំងទំនើប និងឃ្លាំងត្រជាក់
- បន្តជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ
- បន្តជំរុញការបង្កើតសេវាកម្មដឹកជញ្ជូនតាមផ្លូវទឹក ទៅកាន់ផែមេដទៃ ក្រៅពីផែកែមម៉េប
- បន្តជំរុញការនាំចូលទំនិញដែលប្រើប្រាស់រួចមួយទឹក (ទំនិញជជុះ) តាមរយៈ ក. ស. ភ.
- បន្តយកចិត្តទុកដាក់លើការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ នៅចំណតផែកុងតឺន័រLM១៧
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញចាក់បារ និងបង្កើតចំណតផែសម្រាប់ទំនិញចាក់បារ
- អភិវឌ្ឍន៍ចំណតផែទេសចរណ៍អន្តរជាតិ (TS៣ និង TS១)
- បន្តជំរុញបង្កើតចំណតផែពហុបំណងតាមដងទន្លេបន្ថែមទៀត
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញកសិកម្ម តាមចំណតផែនៃបណ្តាខេត្តផ្នែកខាងលើនៃទន្លេមេគង្គ ចៃទាំផ្លូវនាវាចរណ៍ និងធ្វើការបូមស្តារទីតាំងប្រឡាយស្តៅ សម្រួលការដឹកជញ្ជូនទំនិញ រវាងខេត្តនានានៅតាមភូមិភាគឦសាន មកភ្នំពេញតាមទន្លេមេគង្គ និងតាមព្រំប្រទល់កម្ពុជា-វៀតណាម
- បន្តជំរុញការផ្តល់សេវាកម្មដឹកជញ្ជូនកុងតឺន័ររវាងចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ. និងរោងចក្រ/ឃ្លាំងរបស់អតិថិជន ឬពីរោងចក្រ/ឃ្លាំងរបស់អតិថិជនទៅកាន់ចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ.
- បន្តជំរុញការផ្តល់សេវាកម្មជាកញ្ចប់សម្រាប់ការនាំចេញផ្លែឈើត្រជាក់តាមចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ.។

ក. ស. ភ. មានជំនឿចិត្ត និងគោលជំហរយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងប្រតិបត្តិការនៅតាមបណ្តាចំណតផែនានា ឱ្យមានតម្លាភាព ឱ្យមានភាពឆាប់រហ័ស ដើម្បីបង្កើននូវទំនុកចិត្ត និងការទាក់ទាញនៃការផ្តល់សេវាកម្មកំពង់ផែប្រកបដោយស្តង់ដារជូនដល់អតិថិជន។

ក. ស. ភ. សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងនិយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលជានិច្ចជាកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ ក. ស. ភ. រៀងរហូតមក។

ថ្ងៃ សុក្រ ១០កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

ហ៊ី-បាវី

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម i

**១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប កម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា និងស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ ii**

១-១ ព័ត៌មានហិរញ្ញវត្ថុសង្ខេប ii

១-២ ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប iii

១-៣ កម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា vi

១-៤ ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ viii

**២.សមាសភាពក្រុមប្រឹក្សាភិបាល ix**

**៣.សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល x**

**ផ្នែកទី១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ ១**

ក-ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ ២

ខ-លក្ខណៈនៃធុរកិច្ច ២

គ-សម្ព័ន្ធភាពបុគ្គលចុះបញ្ជីលក់មូលបត្រ ១២

ឃ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ១២

ង-ស្ថានភាពទីផ្សារ ១៤

ច-ស្ថានភាពប្រកួតប្រជែង ១៨

ឆ-ផែនការអនាគត ២០

ជ-កត្តាហានិភ័យ ២៦

**ផ្នែកទី២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ២៧**

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ២៨

ខ-រចនាសម្ព័ន្ធចំណូល ៣៤

**ផ្នែកទី៣ : ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ៣៥**

ក-អង្គការលេខ ៣៦

ខ-ក្រុមប្រឹក្សាភិបាល ៣៧

គ-បុគ្គលិកជាន់ខ្ពស់ ៣៧

**ផ្នែកទី៤ : ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់ ក. ស. ភ. ៣៨**

១-ព័ត៌មានអំពីមូលបត្រ ៣៩

២-ថ្លៃ និងបរិមាណជួញដូរមូលបត្រ ៣៩

៣-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ៤០

៤-ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ៤០

**ផ្នែកទី៥ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ៤១**

**ផ្នែកទី៦ : របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ១០៩**

**ផ្នែកទី៧ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍ ១១១**

ក-ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ១១២

ខ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ១១២

គ-ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ១១២

ឃ-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និង ភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ១១២

ង-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ ក. ស. ភ. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ ក. ស. ភ. ១១២

ច-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ ជាអភិបាល ១១២

ឆ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាព មិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី ក. ស. ភ. ១១២

ជ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី ក. ស. ភ. ទោះជា ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ១១២

**ផ្នែកទី៨ : ការវិភាគរបស់ថ្នាក់ដឹកនាំ ១១៣**

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ១១៤

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ១២៤

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ១២៧

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ១២៧

ង-ផលប៉ះពាល់ពីអតិផរណា ១២៨

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល ១២៨

**ផ្នែកទី៩ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន ១៣០**

**ហត្ថលេខាអភិបាលរបស់ ក. ស. ភ. ១៣៣**

**ឧបសម្ព័ន្ធ១៖ របាយការណ៍ស្តីពីអភិបាលកិច្ចសាជីវកម្ម ១៣៤**

**ឧបសម្ព័ន្ធ២៖ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ ១៧០**

# ផ្នែកទី១

# ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

## ក. ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ

ក្រុមហ៊ុនជាអក្សរខ្មែរ : **កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)**

ជាអក្សរឡាតាំង : **PHNOM PENH AUTONOMOUS PORT (PPAP)**

- អក្សរកូដ : **KH1000040001**
- អាសយដ្ឋាន : **អគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
- លេខទូរស័ព្ទ : **(៨៥៥) ២៣ ៤២៧ ៨០២** លេខទូរសារ : **(៨៥៥) ២៣ ៤២៧ ៨០២**
- គេហទំព័រ : **WWW.ppap.com.kh** អ៊ីម៉ែល : **ppapmpwt@online.com.kh**
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : **CO.៧១៧៥ Et/២០០៤**

  កាលបរិច្ឆេទ : **២៣/វិច្ឆិកា/២០០៤**
- លេខអាជ្ញាបណ្ណអាជីវកម្ម : **០០១៤ ពណ.ចបព**

  កាលបរិច្ឆេទ : **០៥/មករា/២០១៥**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ : **០៧៤/១៥/គ.ម.ក./ស.ស.រ**

  ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ : **ឯកឧត្តម ហ៊ី បាវី**

## ខ. លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមកំពង់ផែអន្តរជាតិទាំងពីររបស់ប្រទេសកម្ពុជា ដែលបម្រើសេវានាំចូល នាំចេញកុងតឺន័រ និងទំនិញទូទៅ។ ដូចនេះ ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ ក. ស. ភ. បាននិងកំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ដទៃទៀតដែលជាដំណើរការធុរកិច្ចរបស់ ក. ស. ភ. ។

### *១. ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ*

ក្នុងនាមជាប្រតិបត្តិករផែ ក. ស. ភ. មានភារកិច្ចបម្រើសេវាសំខាន់ៗរួមមាន៖

- ផ្តល់សេវាលើកដាក់ទំនិញ ការស្តុកទំនិញ ការច្រកនិងរើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រសម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស
- ផ្តល់សេវាកណ្ណធារកិច្ច នាំនាវាចេញ-ចូល
- ផ្តល់សេវាចំណតផែអ្នកដំណើរ និងទេសចរ TS១
- សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា។

### ២. ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ

ក្នុងនាមជាអាជ្ញាធរផែ ក. ស. ភ. មានតួនាទី៖

- ថែទាំផ្លូវនាវាចរណ៍ បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញាសម្គាល់ទិសនាវាចរណ៍ រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្ម ក. ស. ភ.
- ចាត់វិធានការជានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

### ៣. សេវាកម្ម/អាជីវកម្មផ្សេងទៀត

ជាមួយនឹងការផ្តល់សេវាកម្មស្នូលលើការងារប្រតិបត្តិការផែ និងអាជ្ញាធរផែ ក. ស. ភ. ក៏មានសេវាកម្ម/អាជីវកម្មបន្ទាប់បន្សំផ្សេងទៀត ដែលអាចបង្កើតឱ្យមានចំណូលបន្ថែមដូចជា៖

- សេវាកម្មបូមស្ការ៖ ក. ស. ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្ការចំនួន ២គ្រឿង សម្រាប់ផ្តល់សេវាកម្មបូមស្ការដើម្បីចាក់បំពេញខ្សាច់ជូនអតិថិជន
- សេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់៖ ក. ស. ភ. ទទួលបានអាជ្ញាបណ្ណបូមស្ការប្រឡាយនាវាចរណ៍ និងធ្វើអាជីវកម្មខ្សាច់នៅទីតាំងចំនួន ២ ដោយអនុលោមតាមប្រកាសលេខ ០១ និង០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល
- សេវាកម្មវាស់ស្ទង់ និងបំពាក់ពោង៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មវាស់ស្ទង់ និងបំពាក់ពោងតាមតម្រូវការរបស់អតិថិជន
- សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រ៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មថែទាំ/ជួសជុល សំបកកុងតឺន័រគ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជន
- ការជួលអចលនទ្រព្យ និងគ្រឿងចក្រផ្សេងៗ៖ ក្រៅពីការប្រើប្រាស់អចលនទ្រព្យ និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារអាជីវកម្ម និងប្រតិបត្តិការ អចលនទ្រព្យ និងគ្រឿងចក្រទាំងនោះក៏ត្រូវបានប្រើប្រាស់ និងចាត់ចែងសម្រាប់ការជួល ដើម្បីបង្កើនចំណូលបន្ថែមជូនដល់ ក. ស. ភ. ផងដែរ។

### ៤. មណ្ឌលអាជីវកម្មផែ

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ មណ្ឌលអាជីវកម្មរបស់ ក. ស. ភ. មានប្រវែង ១៦៦គីឡូម៉ែត្រ គិតចាប់ពីទន្លេបួនមុខ៖ ទន្លេមេគង្គលើ ១០០គីឡូម៉ែត្រ ទន្លេមេគង្គក្រោម ៦០គីឡូម៉ែត្រ និងទន្លេសាប ៦គីឡូម៉ែត្រ។ ក្នុងនាមអាជ្ញាធរ ក. ស. ភ. មានតួនាទីគ្រប់គ្រងចំណតផែឯកជននានា នៅក្នុងមណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក. ស. ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បងចំនួន ៦ រួមមាន៖

### ៤.១. ចំណតផែកុងតឺន័រ LM១៧

ក្នុងឆ្នាំ២០២២ ក. ស. ភ. បានបញ្ចប់គម្រោងពង្រីកទីលានផ្ទុកកុងតឺន័រ ជំហានទី៣ ដំណាក់កាលទី២ គម្រោងសាងសង់ស្ពានផែសម្រាប់ដំឡើងដងយោង FCC ចំនួន ២គ្រឿង និងការងារតបណ្តាញអគ្គីនីដើម្បីផ្គត់ផ្គង់ទីលានផ្ទុកកុងតឺន័រ ជំហានទី៣ ខាងលើ។ សម្រាប់ជំហានទី៣ទាំងមូល អាចពង្រីកសមត្ថភាពលើកដាក់កុងតឺន័របាន ២០០.០០០ TEUs ក្នុងមួយឆ្នាំបន្ថែមទៀត។ ដូចនេះបន្ទាប់ពីការសាងសង់គម្រោងខាងលើត្រូវបានបញ្ចប់ ចំណតផែកុងតឺន័រ LM១៧ មានសមត្ថភាពលើកដាក់កុងតឺន័រ បានរហូតដល់ ៥០០.០០០ TEUs ក្នុងមួយឆ្នាំ។ ចំណតផែកុងតឺន័រ LM១៧ បច្ចុប្បន្នមានស្ពានផែចំនួន២ ស្ពានផែទំហំ ៣០០ម៉ែត្រ គុណ ២២ម៉ែត្រ និងស្ពានផែ ទំហំ ១៤៩ម៉ែត្រ គុណ ១២ម៉ែត្រ និងបំពាក់ដោយដងយោង TCC ចំនួន ៤គ្រឿង ដងយោង FCC ចំនួន ២គ្រឿង រថស្ទូច RTG ចំនួន ១២គ្រឿង គ្រឿងចក្រលើកដាក់លើទីលាន Reach Stacker & Constacker ចំនួន ៥គ្រឿង Sky Stacker ចំនួន ៥គ្រឿង រថយន្តដឹកកុងតឺន័រ ៦៤គ្រឿង និងគ្រឿងចក្រផ្សេងៗ ដែលបាននិងកំពុងបំពេញការងារប្រតិបត្តិការ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងលិច ចម្ងាយ ២៥គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°២៨'២៣.៦" និងរយៈបណ្តោយខាងកើត ១០៥°០៨'៤៩.៨" |
| **ទំហំផ្ទៃដីសរុប** | ៣៨០.០០៧,២៥ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដី ចុះបញ្ជី** | ៣៧៧.៨៦៩ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីកំពុងធ្វើប្លង់កម្មសិទ្ធិ** | ២.១៣៨,២៥ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៧ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងបោះយុថ្កា របស់ចំណតផែកុងតឺន័រ LM១៧ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°២៨'២៨.១៤" និងរយៈបណ្តោយខាងកើត ១០៥°៩'២.៣២" ចន្លោះជម្រៅទឹកពី ៨ម៉ែត្រ ទៅ ១៧ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ហើយចរន្តទឹកមានកម្លាំងខ្លាំងនៅរដូវវស្សា |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ ខែមេសា ដោយកម្ពស់រលក មានចាប់ពី ០.២០ម៉ែត្រ ដល់ ០.៤៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤.៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥.៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែកុងតឺន័រ LM១៧ អាស្រ័យជម្រៅទឹក នៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោង (Traveling Cargo Crane, Fixed Cargo Crane) រថស្ទូច |

| | |
|---|---|
| | (Tyred Gantry) គ្រឿងចក្រលើកដាក់លើទីលាន (Folk Lift Reach Stacker Cont-Stacker, Sky Stacker, Empty Reach Stacker) រថយន្តដឹកកុងតឺន័រក្នុង/ក្រៅផែ (Truck & Terminal Tractor) |

*<u>សម្គាល់</u>៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### ៤.២. ចំណតផែពហុបំណង TS៣

ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទេសចរណ៍។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក. ស. ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ ចាប់តាំងពីចំណតផែកុងតឺន័រ LM១៧ ត្រូវបានស្ថាបនារួចរាល់ ចំណតផែពហុបំណង TS៣ ត្រូវបានក្លាយទៅជាចំណតផែពហុបំណងសម្រាប់បម្រើការលើកដាក់ទំនិញរាយ និងប្រើជាចំណតផែអ្នកដំណើរ និងទេសចរ។ បច្ចុប្បន្ន ក. ស. ភ. បាននិងកំពុងរៀបចំកែប្រែចំណតផែនេះឱ្យក្លាយទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិ ដោយបាននិងកំពុងសាងសង់សាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall) ដែលគ្រោងនឹងបញ្ចប់ការសាងសង់នៅខែមេសា ឆ្នាំ២០២៣។

| | |
|---|---|
| **អាសយដ្ឋាន** | អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេសាប ត្រើយខាងលិច ចម្ងាយ ៣,២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៣៤'៥៩,៦៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៥' ១៧,៤១" |
| **ទំហំផ្ទៃដីចុះបញ្ជី** | ៨៥.៨៤៦ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅទន្លេសាបខាងមុខចំណតផែ និងមួយកន្លែងទៀតនៅទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹង ខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៦'៣៤,៥៧" មានជម្រៅទឹកពី ៥ម៉ែត្រ ទៅ១៥ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ដែលអាចបោះយុថ្កាជាប់បានល្អ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវាប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែពហុបំណង TS៣ អាស្រ័យលើជម្រៅទឹក នៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | គ្រឿងចក្រលើកដាក់ (Fork-Lift) |

### ៤.៣. ចំណតផែរណបពហុបំណងទន្លេបិទ UM២

ដើម្បីជំរុញឱ្យលំហូរប្រតិបត្តិការលើកដាក់ទំនិញនៅចំណតផែរណបពហុបំណងទន្លេបិទ UM២ ឱ្យកាន់តែមានប្រសិទ្ធភាព និងទាក់ទាញអតិថិជនមកប្រើប្រាស់ ចំណតផែនេះត្រូវធ្វើការកែសម្រួល និងជំរុញឱ្យមានការអភិវឌ្ឍបន្ថែមទៀត ព្រោះថាទីតាំងនេះនៅជាប់ព្រំប្រទល់រវាងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលជាសរសៃឈាមតភ្ជាប់រវាងខេត្តនៅភាគខាងជើង និងឦសាននៃប្រទេសកម្ពុជា ដែលជាតំបន់កសិកម្ម និងកសិឧស្សាហកម្មយ៉ាងសំខាន់មកកាន់ទីប្រជុំជនខាងត្បូងប្រទេសរហូតដល់ប្រទេសវៀតណាម។ ដូចនេះ ចំណតផែនេះបានដើរតួនាទីយ៉ាងសំខាន់ដើម្បីជាកន្លែងប្រមូលផ្តុំសកម្មភាពដឹកជញ្ជូនតាមផ្លូវទឹក និងជាកន្លែងផ្លាស់ប្តូរទំនិញនៅក្នុងស្រុក និងក្រៅស្រុក។ អាស្រ័យហេតុនេះ បច្ចុប្បន្ន ក. ស. ភ. បានបញ្ចប់ការសាងសង់ស្ពានផែទំហំ ១២ម៉ែត្រ គុណ ៤៦,៩ម៉ែត្រ ហើយបាន និងកំពុងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជំហានទី១ និងគ្រោងនឹងអនុវត្តគម្រោងជំហានទី២ នៅឆ្នាំ២០២៣ ជាបន្តបន្ទាប់។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទីតាំងចំណតផែ** | ចំណតផែទន្លេបិទ UM២ ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៥៧'៤៧,៧៣" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៣៣,១៣" |
| **ទំហំផ្ទៃដីចុះបញ្ជី** | ១៦០.៧២៥ ម៉ែត្រក្រឡា |
| **ចំណតនាវា** | ចំនួន ១ (ប៉ុងតុងបណ្តែតទំហំ ៦ម៉ែត្រ x ២៨ម៉ែត្រ)<br>មាន ១ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំង ដែលអាចបោះយុថ្កានៅចំណតផែទន្លេបិទ UM២ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៥៨'៤៣,៤១" និងរយៈបណ្តោយខាងកើត ១០៥°២៨'៩,៥៨" ក្នុងចន្លោះជម្រៅទឹកពី ៦ម៉ែត្រ ទៅ ២០ម៉ែត្រ។ នារដូវវស្សា នៅបាតទន្លេមានដីភក់ និងខ្សាច់ ហើយមានចរន្តទឹកមានកម្លាំងខ្លាំង។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៩,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែទន្លេបិទ UM២ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីវ) |
| **ជម្រៅទឹកផ្លូវនាវាចរ** | ចាប់ពីទន្លេចតុមុខទៅដល់ខេត្តត្បូងឃ្មុំ តាមប្រឡាយស្តៅមានទទឹង៦០ម៉ែត្រ និងបណ្តោយ ៣.៥០០ម៉ែត្រ។ ជម្រៅទឹក មានជម្រៅ ៥ម៉ែត្រ ក្នុងរដូវប្រាំង (ដោយមានការថែទាំទៀងទាត់) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) និងប៉ុងតុង |

### ៤.៤. ចំណតអ្នកដំណើរ និងទេសចរណ៍ TS១

ចំណតផែអ្នកដំណើរ និងទេសចរ TS១ ជាចំណតផែអ្នកដំណើរចម្បងរបស់ ក. ស. ភ.។ ចំណតផែនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើជាចំណតផែអ្នកដំណើរក្នុងស្រុក ក៏ដូចជាទៅកំពង់ផែនៃប្រទេសវៀតណាម។ ក្នុងឆ្នាំ២០២២ មានអ្នកដំណើរឆ្លងកាត់ចំណតផែអ្នកដំណើរ និងទេសចរ TS១ ចំនួន ៧៩.៦៦២ នាក់។ តួលេខនេះរាប់បញ្ចូលទាំងអ្នកដំណើរពីភ្នំពេញទៅចំណតផែក្នុងស្រុកនានា និងពីភ្នំពេញទៅប្រទេសវៀតណាម ព្រមទាំងអ្នកទេសចរដែលធ្វើដំណើរឆ្លងកាត់តាមដងទន្លេមេគង្គក្បែររាជធានីភ្នំពេញ។

| | |
|---|---|
| **អាសយដ្ឋាន** | វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតអ្នកដំណើរ និងទេសចរ TS១ ស្ថិតនៅតាមដងទន្លេសាបត្រើយខាងលិច ចម្ងាយ ២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងរយៈទទឹងខាងជើង ១១° ៣៤'៣២,៤៥" និងរយៈបណ្ដោយខាងកើត ១០៤°៥៥'៣៦,៨៨។ |
| **ទំហំផ្ទៃដីចុះបញ្ជី** | ៦.៦៣៧ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មានប៉ង់តុងចំនួន ៣គ្រឿង |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាននៅខាងមុខចំណតផែតំបន់ទន្លេសាប និងមួយទីតាំងទៀតនៅតំបន់ទន្លេចតុមុខ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៦'២៤,៥៧" ចន្លោះជម្រៅទឹកពី ៥ម៉ែត្រ ទៅ ១៥ម៉ែត្រ។ នារដូវវស្សា បាតទន្លេមានដីភក់ និងខ្សាច់ ដែលជាផ្ទៃមានកម្លាំងទប់ជាប់ល្អ ហើយជម្រើសទីតាំងទី២ ដើម្បីបោះយុថ្កាមានចរន្តទឹកខ្លាំង។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹក** | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតអ្នកដំណើរ និងទេសចរ TS១ គឺអាស្រ័យទៅលើជម្រៅស៊ីទឹកនៅច្រកគួទីវ) |
| **ប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | មានប៉ុងតុងចំនួន ៣គ្រឿង ដោយមានស្ពានតភ្ជាប់ទៅច្រាំងទន្លេ |

### ៤.៥. ចំណតផែរណបពហុបំណង TS១១

ចំណតផែរណបពហុបំណង TS១១ មានទីតាំងស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានចម្ងាយប្រហែល ៦,៦គីឡូម៉ែត្រ ឬរយៈពេល ២០នាទី បើគិតពីចំណុចវត្តភ្នំទៅចំណតផែនេះ។ ចំណតផែនេះ គឺជាទីតាំងយុទ្ធសាស្ត្រសំខាន់បំផុតសម្រាប់ចែកចាយ និងប្រមូលផ្ដុំទំនិញរវាងអ្នកផលិត និងអ្នកប្រើប្រាស់យ៉ាងសំខាន់ក្នុងតំបន់ ដោយហេតុថាទីតាំងនេះស្ថិតនៅក្បែរនឹងទីប្រជុំជនក្នុងរាជធានីភ្នំពេញ។

ការអភិវឌ្ឍចំណតផែនេះ នឹងសម្រួលដល់ការកកស្ទះនៃការដឹកជញ្ជូនផ្លូវគោកចេញ-ចូលទីប្រជុំជន។ ម៉្យាងវិញទៀត ចំណតផែពហុបំណង TS៣ មិនអាចធ្វើប្រតិបត្តិការឱ្យអស់លទ្ធភាពបានឡើយ ដោយហេតុថាទីតាំងនេះស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ ដែលសាលារាជធានីភ្នំពេញមិនអនុញ្ញាតឱ្យរថយន្តធុនធ្ងន់ធ្វើចរាចរណ៍នៅពេលថ្ងៃបានឡើយ។ ដូចនេះ ដើម្បីជំរុញឱ្យមានការដឹកជញ្ជូនតាមផ្លូវទឹក ក៏ដូចជាសេវាកម្ម Door to Door Service ការអភិវឌ្ឍចំណតផែវណបពហុបំណង TS១១ ពិតជាសំខាន់ និងចាំបាច់បំផុតក្នុងការតភ្ជាប់ទំនិញរវាងបណ្តាខេត្តផ្សេងៗ និងរាជធានីភ្នំពេញ ឱ្យមានជម្រើស និងមានតម្លៃដឹកជញ្ជូនកាន់តែទាប។

| | |
|---|---|
| **អាសយដ្ឋាន** | ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតផែវណបពហុបំណង TS១១ ស្ថិតនៅតាមដងទន្លេសាប ចម្ងាយប្រហែល ៦ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៣៧'៣៤,៦" និងរយៈបណ្តោយខាងកើត ១០៤°៥៤' ២៩,៤" |
| **ទំហំផ្ទៃដី** | ១២.៥៣៣ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ១ ចំណត សម្រាប់នាវាចំណុះ ៥ ០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងដែលអាចបោះយុថ្កានៅចំណតផែវណបពហុបំណង TS១១ មាន២ទីតាំង<br>- ទីតាំងទី១៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៣៤'២៦,៦" និងរយៈបណ្តោយខាងកើត ១០៤°៥៥'៥០,៤"<br>- ទីតាំងទី២៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៣៣'៣៩,៩" និងរយៈបណ្តោយខាងកើត ១០៤°៥៦'៥០,៧"<br>ស្ថិតនៅតំបន់ទន្លេចតុមុខ ពីព្រោះស្ថានភាពទន្លេនៅតំបន់ចំណតផែវណបពហុបំណង TS១១ មានសភាពតូចចង្អៀតពិបាកអោយនាវាបោះយុថ្ការង់ចាំ។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹក** | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតផែវណបពហុបំណង TS១១ គឺអាស្រ័យទៅលើជម្រៅស៊ីទឹកនៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane), ដងយោង (Fixed Cargo Crane) គ្រឿងចក្រលើកដាក់លើទីលាន (Constacker, Fork-Lift) រថយន្តដឹកកុងតឺន័រក្នុង/ក្រៅផែ (Truck & Terminal Tractor) |

### ៤.៦. ចំណតផែរណបពហុបំណងកោះរកា LM២៦

ចំណតផែរណបពហុបំណងកោះរកា LM២៦ មានទីតាំងស្ថិតនៅឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង ផ្នែកខាងត្បូងនៃប្រទេសកម្ពុជា និងមានចម្ងាយប្រមាណត្រឹមតែជាង ៣គីឡូម៉ែត្រប៉ុណ្ណោះពីព្រំដែនខេត្តដុងថាប់ នៃប្រទេសវៀតណាម។ ចំណតផែនេះជាទីតាំងដែលមានសក្តានុពលសម្រាប់ប្រជាជនកម្ពុជាក្នុងការដឹកជញ្ជូនទំនិញកសិផលចេញទៅប្រទេសវៀតណាម និងនាំចូលមកវិញនូវទំនិញវត្ថុធាតុដើម និងទំនិញជាគ្រឿងសំណង់។ មិនតែប៉ុណ្ណោះចំណតផែនេះ នឹងតភ្ជាប់វិស័យទេសចរណ៍តាមបណ្តាខេត្តជិតខាងរវាងប្រទេសទាំងពីរផងដែរ។ បច្ចុប្បន្នចំណតផែមួយនេះ បានពង្រីកហេដ្ឋារចនាសម្ព័ន្ធ ចាក់ខ្សាច់បំពេញទីលាន បំពាក់កុងវ៉េយ័រ (Conveyor) និងរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃលំហូរទំនិញចេញចូលរបស់ប្រទេសទាំងពីរ និងការតភ្ជាប់ការដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីធ្វើការនាំចេញទៅកាន់ទីផ្សារសកលលោកឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាចូលរួមចំណែកកាត់បន្ថយការចំណាយភស្តុភារកម្ម និងការប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគោក។ នៅពេលបច្ចុប្បន្នចំណតផែរណបពហុបំណងកោះរកា LM២៦ បានបញ្ចប់ការសាងសង់ទីលានរួចហើយ ដែលគ្រោងដាក់ឱ្យប្រើប្រាស់សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយជាបណ្តើរៗសិន រហូតដល់មានការលើកដាក់ទំនិញជាកុងតឺន័រនៅជំហានបន្ទាប់។

ក. ស. ភ. បានបំពាក់ Conveyor ចំនួន ១០គ្រឿង ដើម្បីសម្រួលលំហូរប្រតិបត្តិការ ក្នុងការនាំចេញទំនិញកសិផល ដែលបាននិងកំពុងអនុវត្តដាក់ឱ្យប្រើប្រាស់ជាជំហានៗនៅឆ្នាំ២០២២ នេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ឃុំកោះរកា ស្រុកពាមជរ នៃខេត្តព្រៃវែង |
| **ទីតាំងចំណតផែ** | ចំណតផែរណបពហុបំណងកោះរកា LM២៦ ស្ថិតនៅតាមដងទន្លេមេគង្គក្រោម ត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១០°៥៥'៤០,៥" និងរយៈបណ្តោយខាងកើត ១០៥°១១' ៣០,៦" |
| **ទំហំផ្ទៃដី** | ១៤៤.៧៥០ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដី ចុះបញ្ជី** | ១០៥.១៩២ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីកំពុងធ្វើប្លង់កម្មសិទ្ធិ** | ៣៩.៥៥៨ ម៉ែត្រការ៉េ |
| **ទីតាំងបោះយុថ្កា** | ទីតាំងដែលអាចបោះយុថ្កានៅចំណតផែរណបពហុបំណងកោះរកា LM២៦ មាន២ទីតាំង<br>-ទីតាំងទី១៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១០°៥៦'០១,៩" និងរយៈបណ្តោយខាងកើត ១០៥°១១'១៧,៦"<br>-ទីតាំងទី២៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១០°៥៥'១០,១" និងរយៈបណ្តោយខាងកើត ១០៥°១១'២៤,៤" |
| **រលក** | មិនមានផលប៉ះពាល់ |

| | |
|---|---|
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |
| គ្រឿងចក្រលើកដាក់ | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និង កុងវ៉េយ័រ (Conveyer) |

*សម្គាល់៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### ៤.៧. ចំណតផែដែលគ្រោងអភិវឌ្ឍន៍នាពេលអនាគត

#### ៤.៧.១. ចំណតផែរណបពពហុបំណង UM ១

ចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១ មានផ្ទៃដីទំហំផ្ទៃដី ៣,៨ ហិចតា ដែលជាទីតាំងយុទ្ធសាស្ត្រ ស្ថិតនៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ ចំណតផែរណបពហុបំណងមួយនេះ គ្រោងនឹងបង្កើតឡើង ដើម្បីជំរុញឱ្យមានការដឹកជញ្ជូនតាមផ្លូវទឹក, ជំរុញកំណើនទំនិញឆ្លងកាត់ ក. ស. ភ. កាត់បន្ថយចំណាយដឹកជញ្ជូន និងភស្តុភារកម្ម, ស្វែងរកប្រភពចំណូលបន្ថែម, បង្កើតជាកន្លែងប្រមូលផ្តុំ និងចែកចាយទំនិញតាមរយៈការតភ្ជាប់ការ ដឹកជញ្ជូនរវាងផ្លូវទឹក និងផ្លូវគោក, បង្កើនភាពប្រកួតប្រជែងរបស់ ក. ស. ភ. បង្ខិតសេវាកំពង់ផែ និងដឹកជញ្ជូនតាម ផ្លូវទឹកឱ្យទៅជិតអ្នកប្រើប្រាស់, សម្រួលដល់ការធ្វើពាណិជ្ជកម្មឱ្យបានកាត់តែល្អប្រសើរ, ជួយជំរុញឱ្យមានកំណើន សេដ្ឋកិច្ចជាតិ និងទាក់ទាញការវិនិយោគ, ជួយសម្រួល និងកាត់បន្ថយការប្រើប្រាស់ផ្លូវថ្នល់ ស្ពាន និងបង្កើតឱកាស ការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ដូចនេះ ចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១ បានដើរតួនាទី យ៉ាងសំខាន់ដែលជាកន្លែងប្រមូលផ្តុំសកម្មភាពដឹកជញ្ជូនតាមផ្លូវទឹក និងជាកន្លែងផ្លាស់ប្តូរទំនិញក្នុងស្រុក និងក្រៅស្រុក។ ដោយពិនិត្យមើលឃើញអំណោយផល និងសក្តានុពលពីទីតាំងអភិវឌ្ឍចំណតផែនេះ ហេតុនេះ ក. ស. ភ. គ្រោងនឹង អភិវឌ្ឍចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១ សម្រាប់ជំហានទី១ នៅឆ្នាំ២០២៣ ខាងមុខនេះផងដែរ។

| | |
|---|---|
| អាសយដ្ឋាន | ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល |
| ទំហំផ្ទៃដី | ៣៨.៣៦២ ម៉ែត្រក្រឡា |
| វលក | ចាប់ពី ០,២ម៉ែត្រ ដល់ ០,៤ម៉ែត្រ |
| ជម្រៅស៊ីទឹកនាវា | ៤,៥ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ ម៉ោង |
| គ្រឿងចក្រលើកដាក់ | ដងយោងចល័ត (Mobile crane) និងប៉ុងតុង |

#### ៤.៧.២. ចំណតផែរណបពហុបំណងឆ្លូង (ក្រចេះ)

| | |
|---|---|
| អាសយដ្ឋាន | ភូមិព្រែកតាអាំ ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ |
| ទំហំផ្ទៃដីសរុប | ៥០០.០០០ ម៉ែត្រក្រឡា |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

#### ៤.៧.៣. ចំណតផែរណបពហុបំណងបឹងកេត (កំពង់ចាម)

| | |
|---|---|
| អាសយដ្ឋាន | ភូមិបឹងកេតក្រោម ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម |

| | |
|---|---|
| ទំហំផ្ទៃដីសរុប | ២០០.០០០ ម៉ែត្រក្រឡា |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

### ៤.៧.៤. ចំណតផែរណបពហុបំណងភ្នំក្រោម (សៀមរាប)

| | |
|---|---|
| អាសយដ្ឋាន | ភូមិទី៥ សង្កាត់ចុងឃ្នៀស ក្រុងសៀមរាប ខេត្តសៀមរាប |
| ទំហំផ្ទៃដីសរុប | ១០០.០០០ ម៉ែត្រក្រឡា |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

### ៤.៧.៥. ចំណតផែរណបពហុបំណងកំពង់ឆ្នាំង

| | |
|---|---|
| អាសយដ្ឋាន | ភូមិកណ្ដាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង |
| ទំហំផ្ទៃដីសរុប | ៣.១៥០.០០០ ម៉ែត្រក្រឡា |
| រលក | ០,១០ម៉ែត្រ ទៅ ០,៣ ម៉ែត្រ |
| ជម្រៅស៊ីទឹកនាវា | ៤,៥០ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

### ៤.៧.៦. ចំណតផែរណបពហុបំណងកំពង់ឆ្នាំង-កំពង់ធំ

| | |
|---|---|
| អាសយដ្ឋាន | ភូមិកំពង់បឹង ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង |
| ទំហំផ្ទៃដីសរុប | ២៥០.០០០ ម៉ែត្រក្រឡា |
| រលក | ០,១ម៉ែត្រ ទៅ ០,៣ម៉ែត្រ |
| ជម្រៅស៊ីទឹកនាវា | ៤,៥០ ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

### ៤.៧.៧. ចំណតផែរណបពហុបំណងព្រែកក្ដាម

| | |
|---|---|
| អាសយដ្ឋាន | ភូមិពាមជំនីក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល |
| ទំហំផ្ទៃដីសរុប | ៤០០ ០០០ ម៉ែត្រក្រឡា |
| រលក | ០,១ម៉ែត្រ ទៅ ០,៣ម៉ែត្រ |
| ជម្រៅស៊ីទឹកនាវា | ៤,៥០ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

### ៤.៧.៨. ចំណតផែរណបពហុបំណងសុវណ្ណភូមិ LM២៥

| | |
|---|---|
| អាសយដ្ឋាន | ភូមិសំរោងក្អែរ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល |
| ទំហំផ្ទៃដីសរុប | ១៥៦ ០០០ម៉ែត្រក្រឡា |
| រលក | ០,១ម៉ែត្រ ទៅ ០,៤០ម៉ែត្រ |

| | |
|---|---|
| ជម្រៅស៊ីទឹកនាវា | ៤,៥០ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

*៤.៧.៩. ចំណតផែរណបពហុបំណង រោងចក្រក្ដារបន្ទះ LM៥*

| | |
|---|---|
| អាសយដ្ឋាន | ភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល |
| ទំហំផ្ទៃដីសរុប | ៨៥ ៤៣៨ម៉ែត្រក្រឡា |
| វលក | ០,១ម៉ែត្រ ទៅ ០,៤០ម៉ែត្រ |
| ជម្រៅស៊ីទឹកនាវា | ៤,៥០ម៉ែត្រ |
| ម៉ោងប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |

## គ. សម្ព័ន្ធភាពបុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមឆ្នាំ២០២២ នេះ ក. ស. ភ. ពុំមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ។

## ឃ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

ក. ស. ភ. ទទួលបាននូវវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស" ពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានសុពលភាពរយៈពេល ២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២១ ដល់ ឆ្នាំ២០២២។



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

TCG2020120011
លេខ ២៨២៤២ អពដ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២០
Phnom Penh, 29th, Dec 2020

## អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

## វិញ្ញាបនបត្រ
## អនុលោមភាពសារពើពន្ធ

(ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦)

អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា ៖

ឈ្មោះក្រុមហ៊ុន ៖ **កំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"**

លេខអត្តសញ្ញាណកម្មសារពើពន្ធ ៖ L001-100044999

ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ កាលបរិច្ឆេទធ្វើបច្ចុប្បន្នភាព ៖ ២៦ សីហា ២០១៥

សកម្មភាពអាជីវកម្ម ៖ សេវាកម្មលើកដាក់ និងដឹកជញ្ជូនទំនិញ

អាសយដ្ឋាន ៖ #៦៤៩ ផ្លូវ ព្រះស៊ីសុវត្ថិ ភូមិ ១២ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ **មាស**

មានសុពលភាពរយៈពេល ២ ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២១ ដល់ ឆ្នាំ២០២២។

## CERTIFICATE OF TAX COMPLIANCE

(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :

Company's name : PHNOM PENH AUTONOMOUS PORT "PPAP"

Tax Identification Number (TIN) : L001-100044999

Under : Department of large Taxpayers    Date of Information Update : 26 Aug 2015

Business activity(ies) : Handle, load, discharge and transport cargoes service

Tax Compliance Type awarded : GOLD

Validity period of **2 years** for the tax year of **2021** and **2022**.

ចម្លងជូន ៖

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
Delegate of Royal Government in charge as Director
General of General Department of Taxation

**គង់ វិបុល**

## ខ. ស្ថានភាពទីផ្សារ

នៅក្នុងឆ្នាំ ២០២២ នេះ ស្ថានភាពទីផ្សាររបស់ ក. ស. ភ. ហាក់ដូចជាមានសភាពធូរស្បើយជាងឆ្នាំមុន សម្រាប់ចរាចរណ៍នៃការដឹកជញ្ជូនទំនិញឆ្លងកាត់ ដោយសារការរីករាលដាលនៃជម្ងឺកូវីដ-១៩ បានធូរស្រាលដែលបានរុញច្រានឱ្យកំណើនសេដ្ឋកិច្ចនៅទូទាំងសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរមានការកើនឡើងវិញ។ ទីផ្សារសំខាន់របស់ ក. ស. ភ. គឺពឹងផ្អែកទៅលើកំណើននៃវិស័យអចលនទ្រព្យ និងទេសចរណ៍ក្នុងប្រទេស និងការបញ្ជាទិញទំនិញវាយនភណ្ឌពីក្រៅប្រទេស ជាពិសេស សហរដ្ឋអាមេរិក។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២២ នេះ ទោះបីជាវិស័យអចលនទ្រព្យ និងវិស័យវាយនភណ្ឌហាក់ដូចជាមានភាពមិនច្បាស់លាស់ ក៏ស្ថានភាពទីផ្សាររបស់ ក. ស. ភ. នៅតែបន្តមានកំណើនរហូតដល់ ១៩,៧២% បើធៀបទៅនឹងឆ្នាំ២០២១ ខណៈដែលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងសកលលោកបានជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

ស្ថានភាពកំណើននៃទំនិញឆ្លងកាត់ ក. ស. ភ. សម្រាប់ឆ្នាំ២០២២ នេះ គឺបណ្តាលមកពីការបន្តនាំចូលទំនិញជាវត្ថុធាតុដើមវាយនភណ្ឌដែលមានចំនួន ១០% បើធៀបទៅនឹងការនាំចូលសរុប តែបើធៀបទៅនឹងឆ្នាំ២០២១ វិញមានការកើនឡើង ១៥%។ ចំណែកឯការនាំចេញវិញ ទំនិញវាយនភណ្ឌកាត់ដេរនៅតែបន្តឈានមុខគេគឺ ៧៤% បើធៀបទៅនឹងការនាំចេញសរុប ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០២១ មានការកើនឡើង ១៧,៥៨%។ (យោងតាមក្រាហ្វិកលេខ១ លេខ២ លេខ៣ និងលេខ៤ របស់នាយកដ្ឋានផែនការ/ទីផ្សារ)។

ការនាំចូលទំនិញតាមចំណតផែរបស់ ក. ស. ភ. សម្រាប់ឆ្នាំ២០២២ ពីក្រៅប្រទេសគឺមានប្រទេសវៀតណាមមានការថយចុះ ៣៣% ប៉ុន្តែការនាំចូលពីប្រទេសម៉ាឡេស៊ីកើនឡើង ១៣% ប្រទេសជប៉ុនថយចុះ ៣៨% សហភាពអឺរ៉ុបកើនឡើង ៧% និងប្រទេសចិនកើនឡើង ១% បើធៀបទៅនឹងឆ្នាំ២០២១។ ដោយឡែក សម្រាប់ការនាំចេញវិញគឺការនាំចេញទៅប្រទេសចិនមានការកើនឡើង ២៤% សហភាពអឺរ៉ុបកើនឡើង ៥០% សហរដ្ឋអាម៉េរិកកើនឡើង ១៧% និងប្រទេសវៀតណាមកើនឡើង ៤៦% បើធៀបទៅនឹងឆ្នាំ២០២១។

ជារួម ទោះបីជាប្រទេសកម្ពុជា ក៏ដូចជាប្រទេសនៅទូទាំងសកលលោកបានបន្តរងគ្រោះដោយការរីករាលដាលនៃជម្ងឺកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏ស្ថានភាពទីផ្សាររបស់ ក. ស. ភ. នៅតែបន្តមានកំណើន និងរក្សាបានភាពល្អប្រសើរដដែល។ ទាំងនេះក៏ដោយសារតែការគ្រប់គ្រងស្ថានភាពសេដ្ឋកិច្ច និងការដាក់ចេញនូវវិធានការផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩ បានយ៉ាងមានប្រសិទ្ធភាព។

## *ក្រាហ្វិកលេខ១*

**ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ភ. ប្រចាំឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ គិតជា** (TEUs)




*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២១ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ភ.)*

## *ក្រាហ្វិកលេខ២*

**ស្ថិតិកុងតឺន័រនាំចូល-នាំចេញតាមច្រក ក. ស. ភ. ប្រចាំឆ្នាំ២០២២ គិតជា** (TEUs)







*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ភ.)*

## *ក្រាហ្វិកលេខ២៣*

**ស្ថិតិទំនិញនាំចូលតាមច្រក ក.ស.ត. ប្រចាំឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១**
**គិតជា (TEUs)**




| | គ្រឿងសំណង់ | ម្ហូបអាហារ និងភេសជ្ជៈ | វត្ថុធាតុដើម វាយនភណ្ឌ | សម្ភារប្រើប្រាស់ ក្នុងផ្ទះ | គ្រឿងបន្លាស់ | ថ្នាំពេទ្យ |
|---|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០២១ | ២៨៩០៨ | ១១១៦៩ | ៥៤៩០ | ៧៧៦៤ | ២៧៩២ | ១២៥១ |
| ប្រចាំឆ្នាំ ២០២២ | ២៨៣៦០ | ៧២៩៣ | ៦៣២៤ | ៦៥៣៥ | ២៧២៩ | ១៦៤៩ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២១និងប្រចាំឆ្នាំ២០២២ | -២% | -៣៥% | ១៥% | -១៦% | -២% | ៣២% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២២ និងប្រចាំឆ្នាំ២០២១ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## *ក្រាហ្វិកលេខ២៤*

**ស្ថិតិទំនិញនាំចេញតាមច្រក ក.ស.ត. ប្រចាំឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១**
**គិតជា (TEUs)**




| | វាយនភណ្ឌ | អង្ករ |
|---|---|---|
| ប្រចាំឆ្នាំ ២០២១ | ១៣១៣២១ | ២៩៤៨ |
| ប្រចាំឆ្នាំ ២០២២ | ១៥៤៤០៧ | ៤៤០៦ |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២១ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## *ក្រាហ្វិកលេខ៥*

**ចំណែកទីផ្សារនាំចូលទំនិញតាមច្រក ក. ស. ភ. ប្រចាំឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ គិតជា** (TEUs)




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសម៉ាឡេស៊ី | ប្រទេសជប៉ុន | សហភាពអឺរ៉ុប |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០២១ | ៣២៦៦១ | ១៣៥១៧ | ២១០៨ | ១២២២ | ៤៣៩២ |
| ប្រចាំឆ្នាំ ២០២២ | ៣២៨៤៧ | ៩០៨២ | ២៣៩២ | ៧៥២ | ៤៦៩៧ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២១ និងប្រចាំឆ្នាំ២០២២ | ១% | -៣៣% | ១៣% | -៣៨% | ៧% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ២០២១ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ភ.)*

## *ក្រាហ្វិកលេខ៦*

**ចំណែកទីផ្សារនាំចេញទំនិញតាមច្រក ក. ស. ភ. ប្រចាំឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១ គិតជា** (TEUs)




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសជប៉ុន | សហភាពអឺរ៉ុប | សហរដ្ឋអាម៉េរិក |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ២០២១ | ១៣៦៦៦ | ១៩៤៧ | ១៤៤៩៩ | ៦៣៥១ | ១១១១៧២ |
| ប្រចាំឆ្នាំ២០២២ | ១៦៨៩៧ | ២៨៤៧ | ១៧៤៤៧ | ៩៥៣៨ | ១២៩៩០២ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២១និងប្រចាំឆ្នាំ២០២២ | ២៤% | ៤៦% | ២០% | ៥០% | ១៧% |

## ច. ស្ថានភាពប្រកួតប្រជែង

ក. ស. ភ. គឺជាចំណតផែអន្តរជាតិតាមដងទន្លេ ដែលមានការផ្តល់សេវាកម្មចំណតនាវា និងសេវាកម្មលើកដាក់ទំនិញជាកុងតឺន័រ និងទំនិញទូទៅជូនអតិថិជន។ នៅក្នុងឆ្នាំ២០២១ នេះ ទោះបីជាសកលលោកទាំងមូល រួមទាំងប្រទេសកម្ពុជា បានជួបនូវវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរដោយសារការរីករាលដាលនៃជំងឺកូវីត-១៩ យ៉ាងណាក៏ដោយក៏ ក. ស. ភ. នៅតែអាចរក្សាបាននូវកំណើនកុងតឺន័រឆ្លងកាត់ ក. ស. ភ. ចំនួន ១៩,៧២% ធៀបនឹងឆ្នាំ២០២១។ ប៉ុន្តែបើធៀបទៅនឹងផែនការឆ្នាំ២០២២ កំណើននេះ មានការកើនឡើង ៥,៨៣%។ កំណើនវិជ្ជមាននេះ បានបញ្ជាក់យ៉ាងច្បាស់ថា ចរាចរណ៍កុងតឺន័រឆ្លងកាត់ច្រកទ្វារ ក. ស. ភ. នៅតែមានកំណើន និងមានភាពល្អប្រសើរ បើធៀបទៅនឹងកំពង់ផែមួយចំនួននៅក្នុងតំបន់ ។

ប្រសិនបើពិនិត្យទៅលើស្ថានភាពប្រកួតប្រជែងវិញ កំពង់ផែស្វយ័តភ្នំពេញ នៅតែដើរតួនាទីសំខាន់ និងរឹងមាំបំផុតក្នុងវិស័យកំពង់ផែដែលជាច្រកសំខាន់សម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់នៅតាមដងទន្លេ។ កត្តាសំខាន់ៗដែលនៅតែជម្រុញ ក. ស. ភ. ឱ្យនៅតែរក្សាបានកំណើន និងឧត្តមភាពក្នុងការប្រកួតប្រជែង មានដូចខាងក្រោម៖

### ១. *ទីតាំងភូមិសាស្ត្រ*

ក. ស. ភ. ស្ថិតនៅទីតាំងភូមិសាស្ត្រប្រកបដោយសក្តានុពល និងយុទ្ធសាស្ត្រ ដោយស្ថិតនៅចំបេះដូងនៃរាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម រោងចក្រ អ្នកប្រើប្រាស់ និងជាកន្លែងប្រមូលផ្តុំទៅដោយកម្លាំងពលកម្ម។ ការដឹកជញ្ជូនតាម ក. ស. ភ. ផ្តល់ភាពងាយស្រួល ឆាប់រហ័ស និងចំណាយតិចក្នុងការចែកចាយ និងការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះដែរ ទីតាំងរបស់ ក. ស. ភ. គឺនៅជិត និងមានរយៈចម្ងាយនៃការដឹកជញ្ជូនជិតជាងចំណតផែដទៃទៀត នៅក្នុងប្រទេសកម្ពុជា ដូចជាការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម ប្រទេសចិន និងសហរដ្ឋអាមេរិកជាដើម ដែលប្រទេសទាំងនេះ គឺមានទំហំពាណិជ្ជកម្មធំជាមួយប្រទេសកម្ពុជាបើធៀបទៅនឹងប្រទេសដទៃទៀត។

### ២. *សេវាកម្ម*

ក. ស. ភ. នៅតែរក្សាបាននូវគោលការណ៍របស់ ក. ស. ភ. ដោយផ្តោតទៅលើ គុណភាពល្អ សុវត្ថិភាព សេវាកម្មរហ័ស២៤ម៉ោង និងតម្លៃមានភាពប្រកួតប្រជែងជូនដល់អតិថិជន។ ជាមួយគ្នានេះ ក. ស. ភ. បានបង្កើតសេវាកម្មភស្តុភារកម្ម ដែលជាសេវាកម្មជាកញ្ចប់ជូនអតិថិជន ដើម្បីទាក់ទាញអ្នកប្រើប្រាស់ និងផ្តល់ភាពងាយស្រួលដល់អ្នកនាំចេញ និងនាំចូល។

ក. ស. ភ. ក៏បានបង្វិតសេវាកម្មរបស់ខ្លួនទៅកៀកនឹងអតិថិជន តាមរយៈការបង្កើតចំណតផែតូចៗ នៅតាមដងទន្លេ ជាពិសេសការបង្កើតចំណតផែរណបពហុបំណងទន្លេបិទ UM២ ចំណតផែរណបពហុបំណង UM១ ចំណតផែរណបពហុបំណង TS១១ និងចំណតផែរណបពហុបំណង LM២៦ ។

## ៣. តម្លៃសេវាកម្ម

នៅក្នុងបរិបទនៃជំងឺកូវីដ-១៩ នេះ ក. ស. ភ. នៅរក្សាបន្តផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ និងការរក្សាទុកកុងតឺន័រដែលផ្ទុកទំនិញ ប្រភេទជាផលិតផលកសិផល។ ជាពិសេស ក. ស. ភ. បានផ្តល់តម្លៃអនុគ្រោះពុំគិតថ្លៃចំពោះថ្លៃច្រកទ្វាររថយន្តដែលដឹកជញ្ជូនកុងតឺន័រផ្ទុកទំនិញជាអង្គរឆ្លងកាត់ ក. ស. ភ.។

ជាមួយគ្នានេះដែរ ក. ស. ភ. នៅតែរក្សាផ្តល់តម្លៃដែលមានភាពបត់បែនដល់អតិថិជនដែលបានទទួលសេវាកម្មពី ក. ស. ភ.។ យុទ្ធសាស្ត្រតម្លៃដែលមានភាពបត់បែននេះហើយជាចំនុចខ្លាំងរបស់ ក. ស. ភ. ក្នុងការទាក់ទាញអតិថិជន។

លើសពីនេះ ក. ស. ភ. នៅតែបន្តផ្តល់សេវាកម្មប្រតិបត្តិការផែ ២៤ម៉ោង/៧ថ្ងៃ ដោយពុំគិតកម្រៃសេវាបន្ថែមម៉ោងនោះទេ។

## ៤. ការផ្សព្វផ្សាយរបស់ ក. ស. ភ.

ក. ស. ភ. នៅតែរក្សាបន្តការផ្សព្វផ្សាយ និងប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីផ្តល់ព័ត៌មានដល់អតិថិជនឱ្យបានគ្រប់គ្រាន់ និងស្គាល់កាន់តែច្បាស់អំពី ក. ស. ភ. ដើម្បីងាយស្រួលដល់ការសម្រេចចិត្តក្នុងការប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ.។ ជាក់ស្តែង អតិថិជនអាចទទួលនូវព័ត៌មានសេវាកម្មរបស់ ក. ស. ភ. តាមរយៈមធ្យោបាយផ្តល់ព័ត៌មានជាច្រើន រួមមាន៖

- ទី១. ការចុះផ្សាយព័ត៌មាន តាមគេហទំព័រ ប្រតិទិន នាមប័ណ្ណ ខិតប័ណ្ណ វត្តអនុស្សាវរីយ៍ និងសៀវភៅព័ត៌មានពាណិជ្ជកម្ម (របស់សភាពាណិជ្ជកម្មកម្ពុជា)
- ទី២. ការផ្សព្វផ្សាយព័ត៌មាន នៅតាមសិក្ខាសាលា ក្នុងវគ្គបណ្តុះបណ្តាល និងការប្រជុំផ្សេងៗ
- ទី៣. ការផ្សព្វផ្សាយព័ត៌មានសាជីវកម្មរបស់ ក. ស. ភ. តាមរយៈផ្សារមូលបត្រកម្ពុជា
- ទី៤. យុទ្ធសាស្ត្រចុះផ្សព្វផ្សាយដោយផ្ទាល់ជាមួយអតិថិជនដែលជាក្រុមហ៊ុនដឹកជញ្ជូននានា មធ្យោបាយផ្សព្វផ្សាយទាំងនេះជាប្រភពព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលជួយឱ្យអតិថិជនបានស្គាល់ និងទាក់ទាញការប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ. នៅលើទីផ្សារ។
- ទី៥. ការបន្តដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងលើការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនលើសទម្ងន់នៅតាមផ្លូវគោក។ ការចាត់វិធានការនេះ ជាឱកាសមួយដែលបានជំរុញឱ្យមានកំណើននៃការដឹកជញ្ជូនតាមផ្លូវទឹកព្រោះថា ការដឹកជញ្ជូនតាមផ្លូវគោក អតិថិជនត្រូវចំណាយច្រើន និងដឹកជញ្ជូនបានចំនួនតិច ជាពិសេស គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដែលអាចជំរុញឱ្យអតិថិជនចំណាយថ្លៃដឹកជញ្ជូនកាន់តែច្រើន ខណៈពេលដែលការដឹកជញ្ជូនតាមផ្លូវទឹក នឹងផ្តល់ផលចំណេញច្រើនដល់អតិថិជនដូចជាការដឹកជញ្ជូនបានបរិមាណច្រើន ចំណាយថ្លៃដើមតិច និងពុំប៉ះពាល់ខ្លាំងដល់បរិស្ថានដូចការដឹកជញ្ជូនតាមផ្លូវគោកឡើយ។

ដូចនេះ ស្ថានភាពប្រកួតប្រជែងរបស់ ក. ស. ភ. សម្រាប់ ឆ្នាំ២០២២ នេះ នៅតែមានភាពរឹងមាំ ទាក់ទាញ និងឈានទៅមុខជានិច្ច ដើម្បីទាក់ទាញអតិថិជនឱ្យនៅតែបន្តប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ.។

## ឆ. ផែនការអនាគត

### *១. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែជំហានទី៤ (ដំណាក់កាលទី១) នៃចំណតផែកុងតឺន័រ LM១៧*

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែជំហានទី៤ (ដំណាក់កាលទី១) |
|---|---|
| **បរិយាយ** | ចន្លោះពី ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ១៨% រៀងរាល់ឆ្នាំ។ ដោយសារតែ កុងតឺន័រដែលបច្ចុប្បន្នឆ្លងកាត់នៅ LM១៧ មានចំនួន ៤១៧.៣៤១ ធីអ៊ីយូ ក្នុងឆ្នាំ២០២២ ក. ស. ភ. ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ៤៧០.០០០ ធីអ៊ីយូ ក្នុងឆ្នាំ២០២៣។ ដើម្បីទទួលបានកំណើននេះ ក. ស. ភ. ត្រូវធ្វើការពង្រីកបបនីយភណ្ឌផែ និងបរិក្ខារបន្ថែមទៀត។ |
| **ជំហានទី៤ នៃដំណាក់កាលទី១ ពីឆ្នាំ២០២២-២០២៣** | |
| **គោលបំណង** | ធានាសមត្ថភាពលើកដាក់របស់ផែក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ |
| **លទ្ធផលរំពឹងទុក** | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រ LM១៧ ដល់កម្រិត ៦០០.០០០ ធីអ៊ីយូ ក្នុងមួយឆ្នាំ |
| **ទីតាំងគម្រោង** | ភាគខាងជើងចំណតផែកុងតឺន័រ LM១៧ |
| **ទំហំនៃគម្រោង** | ១០ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | សាងសង់ទីលានផ្ទុកកុងតឺន័រជំហានទី៤ ដំណាក់កាលទី១ គ្រោងចំណាយទឹកប្រាក់ប្រមាណ ២២.៥៥០.០០០.០០០ រៀល ដែលមានគម្រោងដូចជា៖<br>- សាងសង់ច្រាំងទន្លេ<br>- សាងសង់ផ្លូវកៅស៊ូ<br>- ទីលានកុងតឺន័រ<br>- ផ្លូវ RTG ២ខ្សែ |
| **ប្រភពហិរញ្ញវត្ថុ** | ទុនអភិវឌ្ឍន៍សហគ្រាសរបស់ ក.ស.ភ. |
| **រយៈពេលអនុវត្តគម្រោង** | ២០២២-២០២៣ |
| **កម្មសិទ្ធិដី** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **បញ្ហាសង្គម** | ការអនុវត្តគម្រោងជំហានទី៤ ដំណាក់កាលទី១ នៃចំណតផែកុងតឺន័រ LM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| **បញ្ហាបរិស្ថាន** | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| **សកម្មភាពតាមដាន** | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

## ២. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងទន្លេបិទ UM២

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី២ ដំណាក់កាលទី១ ចំណតផែរណបពហុបំណងទន្លេបិទ UM២ |
|---|---|
| **បរិយាយ** | តាមរយៈគោលនយោបាយលើកទឹកចិត្ត របស់រាជរដ្ឋាភិបាលលើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក និងជម្រុញការនាំចេញកសិផលដែលចំណតផែរណបពហុបំណងទន្លេបិទ UM២ ជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រមូលផ្តុំកសិផលពីបណ្តាខេត្តស្ថិតនៅប៉ែកឥសាន្តនៃប្រទេសកម្ពុជា។ |
| **គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី២ ដំណាក់កាលទី១ ចំណតផែរណបពហុបំណងទន្លេបិទ UM២** | |
| **គោលបំណង** | បង្កើតជាកន្លែងប្រមូលផ្តុំកសិផល និងលើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក ហើយពង្រីកហេដ្ឋារចនាសម្ព័ន្ធថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងបង្កភាពងាយស្រួលក្នុងការការលើកដាក់ទំនិញរាយ ទំនិញជាកុងតឺន័រ និងជំរុញការនាំចេញទិន្នផលកសិផល។ |
| **លទ្ធផលរំពឹងទុក** | - ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកមានការកើនឡើង<br>- ក្លាយជាកន្លែងប្រមូលផ្តុំ និងចែកចាយកសិផល សម្ភារសំណង់<br>- ការប្រើប្រាស់សេវាកម្មដឹកជញ្ជូនផ្លូវទឹកមានការកើនឡើង ព្រោះថ្លៃដឹកជញ្ជូនមានតម្លៃទាប ដោយហេតុថា ខ្សែដឹកជញ្ជូនខ្លីតាមរយៈការដឹកជញ្ជូនដោយផ្ទាល់ទៅកាន់កំពង់ផែមេ<br>- បង្កើតការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ |
| **ទីតាំងគម្រោង** | ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទំហំនៃគម្រោង** | ១៨ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី២ ដំណាក់កាលទី១ នៃចំណតផែរណបពហុបំណងទន្លេបិទ UM២ គ្រោងចំណាយទឹកប្រាក់សរុបចំនួន ១៨.៣៦៥.៩៨៧.៨៧១ រៀល ដែលមានគម្រោងសាងសង់ដូចជា៖<br>- ហេដ្ឋារចនាសម្ព័ន្ធទីលាន គ្រោងចំណាយទឹកប្រាក់ចំនួន ៧.៤៨២. ៧៩១.៤០០ រៀល<br>- សំណង់អគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ គ្រោងចំណាយទឹកប្រាក់ចំនួន ៥.១៧២.៩៧២.០០០ រៀល<br>- បណ្តាញទឹក និងអគ្គិសនី គ្រោងចំណាយទឹកប្រាក់ចំនួន ៣.១០២. ៥៤០.០០០ រៀល |

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី២ ដំណាក់កាលទី១ ចំណតផែរណបពហុបំណងទន្លេបិទ UM២ |
|---|---|
| | - ការងារវុះរើ ចំណាយឥតព្រាងទុក និងចំណាយផ្សេងៗ |
| ប្រភពហិរញ្ញវត្ថុ | ទុនអភិវឌ្ឍន៍របស់ដៃគូវិនិយោគ |
| រយៈពេលអនុវត្តគម្រោង | ២០២៣-២០២៤ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| បញ្ហាសង្គម | ពុំមានផលប៉ះពាល់ |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| សកម្មភាពតាមដាន | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

*៣. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១*

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី១ ចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១ |
|---|---|
| បរិយាយ | តាមរយៈគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលលើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក និងជំរុញការនាំចេញកសិផល សម្ភារៈសំណង់ និងទំនិញរាយផ្សេងៗ ដែលចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១ ជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រមូលផ្តុំកសិផលពីបណ្តាខេត្តស្ថិតនៅប៉ែកឦសាន នៃប្រទេសកម្ពុជា។ |
| **គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី១ ចំណតផែរណបពហុបំណងព្រែកអញ្ចាញ UM១** | |
| គោលបំណង | បង្កើតជាកន្លែងប្រមូលផ្តុំ និងចែកចាយទំនិញតាមរយៈការតភ្ជាប់ការដឹកជញ្ជូនរវាងផ្លូវទឹក និងផ្លូវគោក, បង្កើនភាពប្រកួតប្រជែងរបស់ ក.ស.ភ. បង្វិតសេវាកំពង់ផែ និងដឹកជញ្ជូនតាមផ្លូវទឹកឱ្យទៅជិតអ្នកប្រើប្រាស់។ |
| លទ្ធផលរំពឹងទុក | - ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកមានការកើនឡើង<br>- ក្លាយជាកន្លែងប្រមូលផ្តុំ និងចែកចាយកសិផល សម្ភារសំណង់ និងទំនិញរាយផ្សេងៗ<br>- ការប្រើប្រាស់សេវាកម្មដឹកជញ្ជូនផ្លូវទឹកមានការកើនឡើង ព្រោះថ្លៃដឹកជញ្ជូនមានតម្លៃទាប ដោយហេតុថា ខ្សែដឹកជញ្ជូនខ្លីតាមរយៈការដឹកជញ្ជូនដោយផ្ទាល់ទៅកាន់កំពង់ផែមេ<br>- បង្កើតការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ |
| ទីតាំងគម្រោង | ខេត្ត កណ្តាល |

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី១ ចំណតផែរណបពហុបំណង ព្រែកអញ្ចាញ UM១ |
|---|---|
| **ទំហំនៃគម្រោង** | ៤ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី១ នៃចំណតផែរណបពហុបំណង ព្រែកអញ្ចាញ UM១ គ្រោងចំណាយទឹកប្រាក់សរុបចំនួន ៣៣.៨៣៣.៨៧៥.៨៤៥ រៀល ដែលមានគម្រោងសាងសង់ដូចជា៖<br>- ហេដ្ឋារចនាសម្ព័ន្ធស្ពានផែ គ្រោងចំណាយទឹកប្រាក់ចំនួន ១៦.៨០៩.៤៤០.០០០ រៀល<br>- ហេដ្ឋារចនាសម្ព័ន្ធទីលាន គ្រោងចំណាយទឹកប្រាក់ចំនួន ៩.២៨៣.៥៥៩.០០០ រៀល<br>- បណ្តាញទឹក និងអគ្គិសនី គ្រោងចំណាយទឹកប្រាក់ចំនួន ៣.១៥៨.៤០០.០០០ រៀល<br>- ការងាររុះរើ និងចំណាយផ្សេងៗ |
| **ប្រភពហិរញ្ញវត្ថុ** | ទុនអភិវឌ្ឍន៍របស់ដៃគូវិនិយោគ |
| **រយៈពេលអនុវត្តគម្រោង** | ២០២៣-២០២៤ |
| **កម្មសិទ្ធិដី** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **បញ្ហាសង្គម** | ពុំមានផលប៉ះពាល់ |
| **បញ្ហាបរិស្ថាន** | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែក បរិស្ថានឡើយ |
| **សកម្មភាពតាមដាន** | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

### *៤. គម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណង TS៣*

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែពហុបំណង TS៣ |
|---|---|
| **បរិយាយ** | ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក. ស. ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ បច្ចុប្បន្ន ក.ស.ភ. បាននិងកំពុងរៀបចំកែប្រែចំណតផែនេះ ឱ្យក្លាយទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិ។ |
| **គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែពហុបំណង TS៣** | |

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែពហុបំណង TS៣ |
|---|---|
| **គោលបំណង** | បង្កើតចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិមានលក្ខណៈស្តង់ដារ |
| **លទ្ធផលរំពឹងទុក** | - លើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់មធ្យោបាយផ្លូវទឹក<br>- អ្នកដំណើរនិងភ្ញៀវទេសចរកាន់តែច្រើនធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនតាមដងទន្លេ |
| **ទីតាំងគម្រោង** | សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទំហំនៃគម្រោង** | ៤ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | - សាងសង់អគាររដ្ឋបាល និងសាលទេសចរណ៍អន្តរជាតិ គ្រោងចំណាយទឹកប្រាក់ចំនួន ៤៩.២០០.០០០.០០០ រៀល |
| **ប្រភពហិរញ្ញវត្ថុ** | ទុនអភិវឌ្ឍន៍សហគ្រាសរបស់ ក.ស.ភ. |
| **រយៈពេលអនុវត្តគម្រោង** | ២០២៣-២០២៤ |
| **កម្មសិទ្ធិដី** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **បញ្ហាសង្គម** | ពុំមានផលប៉ះពាល់ |
| **បញ្ហាបរិស្ថាន** | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| **សកម្មភាពតាមដាន** | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

### *៥. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងកោះរកា LM២៦*

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងកោះរកា LM២៦ |
|---|---|
| **បរិយាយ** | តាមរយៈគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលលើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក និងជំរុញការនាំចេញកសិផលដែលចំណតផែរណបពហុបំណងកោះរកា LM២៦ ជាទីតាំងយុទ្ធសាស្រ្តក្នុងការប្រមូលផ្តុំកសិផលពីបណ្តាខេត្តនៃប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ចំណតផែរនេះក៏មានសក្តានុពលក្នុងវិស័យទេសចរណ៍ផងដែរ។ |
| **គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងកោះរកា LM២៦** | |
| **គោលបំណង** | - បង្កើតចំណតផែដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការលើកដាក់ ផ្ទេរផ្ទុក<br>- ជម្រុញការនាំចេញទិន្នផលកសិផលជាពិសេស ស្រូវ ពោត ...<br>- ទទួលបានកំណើនភ្ញៀវទេសចរ |
| **លទ្ធផលរំពឹងទុក** | - ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកមានការកើនឡើង<br>- ក្លាយជាកន្លែងប្រមូលផ្តុំ និងចែកចាយកសិផល សម្ភារសំណង់ ... |

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណងកោះរកា LM២៦ |
|---|---|
| | - ការប្រើប្រាស់សេវាកម្មដឹកជញ្ជូនផ្លូវទឹកមានការកើនឡើង ព្រោះថ្លៃដឹកជញ្ជូនមានតម្លៃទាប ដោយហេតុថា ខ្សែដឹកជញ្ជូនខ្លីតាមរយៈការដឹកជញ្ជូនដោយផ្ទាល់ទៅកាន់កំពង់ផែមេ<br>- បង្កើតការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ |
| **ទីតាំងគម្រោង** | ស្ថិតនៅឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង |
| **ទំហំនៃគម្រោង** | ១២ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | - ពង្រីកហេដ្ឋារចនាសម្ព័ន្ធចំណតផែទំហំ ២០.០០០ម² គ្រោងចំណាយទឹកប្រាក់ ៤ .១០០.០០០.០០០ រៀល<br>- សាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការ គ្រោងចំណាយទឹកប្រាក់ ១០.២២៩.៥០០.០០០ រៀល |
| **ប្រភពហិរញ្ញវត្ថុ** | ក. ស. ភ. |
| **រយៈពេលអនុវត្តគម្រោង** | ២០២៣-២០២៤ |
| **កម្មសិទ្ធិដី** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **បញ្ហាសង្គម** | ពុំមានផលប៉ះពាល់ |
| **បញ្ហាបរិស្ថាន** | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| **សកម្មភាពតាមដាន** | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

### *៦. គម្រោងអភិវឌ្ឍន៍ចំណតផែរណបពហុបំណង TS១១*

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង TS១១ |
|---|---|
| **បរិយាយ** | ជាចំណតផែរណបលើកដាក់ទំនិញរាយ និងកុងតឺន័រ |
| **គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការ ជំហានទី២ ចំណតផែរណបពហុបំណង TS១១** | |
| **គោលបំណង** | បង្កើតចំណតផែដើម្បីបង្កភាពងាយស្រួលសម្រាប់ការលើកដាក់ទំនិញរាយ និងទំនិញជាកុងតឺន័រ |
| **លទ្ធផលរំពឹងទុក** | បង្កើនសមត្ថភាពលើកដាក់របស់ ក.ស.ភ. |
| **ទីតាំងគម្រោង** | ស្ថិតសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| **ទំហំនៃគម្រោង** | ៤ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| **ថវិកាត្រូវចំណាយ** | សាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការ ជំហានទី២ គ្រោងចំណាយទឹកប្រាក់ |

| ឈ្មោះ | គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង TS១១ |
|---|---|
| | ចំនួន ១៥.៦៨៦.៦២៤.០០០ រៀល |
| ប្រភពហិរញ្ញវត្ថុ | ទុនអភិវឌ្ឍន៍របស់ដៃគូវិនិយោគ |
| រយៈពេលអនុវត្តគម្រោង | ២០២៣-២០២៤ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) |
| បញ្ហាសង្គម | ពុំមានផលប៉ះពាល់ |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| សកម្មភាពតាមដាន | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

## ៨. ភត្តាហានិភ័យ

សម្រាប់ឆ្នាំ២០២២ នេះ ក. ស. ភ. ពុំមានការវិភាគអំពីហានិភ័យនោះទេ។

# ផ្នែកទី២
# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

### ១. តារាងស្ថិតិបរិមាណទំនិញ និងនាវាឆ្លងកាត់ ក.ស.ភ.

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០២២ | អនុវត្ត ឆ្នាំ២០២២ | អនុវត្ត ឆ្នាំ២០២១ | អនុវត្ត ឆ្នាំ២០២០ | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=២/១ | ៦=(២/៣)-១០០% | ៧=(៣/៤)-១០០% |
| I | បរិមាណទំនិញ និង ប្រេងឥន្ធនៈឆ្លងកាត់ | តោន | ៤.៧១៩.៣៨៧ | ៤.០៤៤.២៨៩ | ៣.៨៩១.៤៥៣ | ៣.៧៨០.៥២១ | ៨៥,៧០% | +៥,០១% | +១,៨៨% |
| | **ក. បរិមាណទំនិញឆ្លងកាត់** | - | ២.៧៣៦.៦៩៥ | ២.៤៣៧.១៣៧ | ២.១១៥.៥៣១ | ២.០៦៥.២៧៧ | ៨៩,០៥% | +១៥,២០% | +២,៤៣% |
| | - ទំនិញនាំចូល | - | ១.៧៥៥.៦២៤ | ១.២៥៥.៩៨៧ | ១.២២១.៦១៣ | ១.៣៦៦.៧៤៩ | | | |
| | - ទំនិញនាំចេញ | - | ៩៨១.០៧១ | ១.១៨១.១៥០ | ៨៩៣.៩១៨ | ៦៩៨.៥២៨ | | | |
| | **ខ. បរិមាណទំនិញលើកដាក់ចល័ត** | - | ៩៦០.៦៤១ | ៧៨៩.៩២១ | ៨៣៦.១៤៨ | ៨៦៥.៣៦៨ | ៨២,២៣% | -៥,៥៣% | -៣,៣៨% |
| | - ទំនិញលើកដាក់ក្នុងផែ | - | ៦៨.១៦១ | ៧១.៥៩៧ | ៤៦.៤៥០ | ៥០.៨១២ | | | |
| | - ទំនិញលើកដាក់ក្រៅផែ | - | ៨៩២.៤៨០ | ៧១៨.៣២៤ | ៧៨៩.៦៩៨ | ៨១៤.៥៥៦ | | | |
| | **គ.បរិមាណប្រេងឥន្ធនៈ និងហ្គាសឆ្លងកាត់** | - | ១.០២២.០៥១ | ៨១៧.២៣២ | ៨៩៩.៧៣៤ | ៨៤៩.៨៧៦ | ៧៩,៩៦% | -៩,១៧% | +៥,៨៧% |
| | **បរិមាណកុងតឺន័រឆ្លងកាត់** | TEU | ៣៩៤.៦៧៩ | ៤១៧.៦៩៦ | ៣៤៨.៨៩៨ | ២៩០.៨៥៧ | ១០៥,៨៣% | +១៩,៧២% | +១៩,៩៦% |
| | -មានទំនិញ | - | ២៨១.៧៥៥ | ២៧២.៤១០ | ២៤០.៩៨៨ | ២១១.៨២២ | | | |
| | -គ្មានទំនិញ | - | ១១២.៩២៤ | ១៤៥.២៨៦ | ១០៧.៩១០ | ៧៩.០៣៥ | | | |
| II | **បរិមាណទំនិញលើកដាក់** | តោន | ៣.៦៩៧.៣៣៦ | ៣.២២៧.០៥៨ | ២.៩៥១.៦៧៩ | ២.៩៣០.៦៤៥ | ៨៧,២៨% | +៩,៣៣% | +០,៧២% |
| | -ប្រគល់ផ្ទាល់ | - | ៩៦០.៦៤១ | ៧៨៩.៩២១ | ៨៣៦.១៤៨ | ៨៦៥.៣៦៨ | | | |
| | -ឆ្លងកាត់ឃ្លាំង-ទីលាន | - | ២.៧៣៦.៦៩៥ | ២.៤៣៧.១៣៧ | ២.១១៥.៥៣១ | ២.០៦៥.២៧៧ | | | |
| III | **បរិមាណនាវាសរុប** | គ្រឿង | ២.៤៨៥ | ៣.៧៨៣ | ២.៣០២ | ២.៣៦៣ | ១៥២,២៣% | +៦៤,៣៤% | -២,៥៨% |
| | -នាវា-សាឡង់បណ្តាប្រទេសផ្សេងៗ | - | ១.០៤៤ | ៣.២៨៧ | ១.៧៧០ | ១.៨២៤ | | | |

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០២២ | អនុវត្ត | | | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | | | |
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=២/១ | ៦=(២/៣)-១០០% | ៧=(៣/៤)-១០០% |
| | -នាវា-សាឡង់កម្ពុជា | - | ៨៤៣ | - | - | - | | | |
| | -នាវា-សាឡង់ប្រេងឥន្ទនៈ | - | ៥៩៨ | ៤៩៦ | ៥៣២ | ៥៣៩ | | | |
| IV | **បរិមាណនាវាអ្នកដំណើរទេសចរក្នុងស្រុក (ចេញ-ចូល)** | ជើង | **១.៩១៥** | **១០.២៣៦** | **៥.០០៤** | **១.៨២៨** | **៥៣៤,៥២%** | **+១០៤,៥២%** | **+១៧៣,៧៤%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | - | - | - | - | | | |
| | - នាវាទេសចរណ៍ក្នុងក្រុង | - | ១.៩១៥ | ១០.២៣៦ | ៥.០០៤ | ១.៨២៨ | | | |
| V | **បរិមាណអ្នកដំណើរ និងទេសចរក្នុងស្រុក (ចេញ-ចូល)** | នាក់ | **២១.៣៤៨** | **៦៩.០៦២** | **២៨.៥២៣** | **១១.៩៣២** | **៣២៣,៥១%** | **+១៤២,១៣%** | **+១៣៩,០៥%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | - | - | - | - | | | |
| | - ទេសចរណ៍ក្នុងក្រុង | - | ២១.៣៤៨ | ៦៩.០៦២ | ២៨.៥២៣ | ១១.៩៣២ | | | |
| VI | **បរិមាណនាវាអ្នកដំណើរបរទេស និងទេសចរ ឆ្លងកាត់កម្ពុជា-វៀតណាម** | ជើង | **៦៩២** | **៥៣៤** | - | **៦៩២** | **៧៧,១៧%** | **+៥៣៤,០០%** | **-១០០,០០%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៤៤០ | ៣២៨ | - | ៤៤០ | | | |
| | - ចំនួននាវាទេសចរណ៍ | - | ២៥២ | ២០៦ | - | ២៥២ | | | |
| VII | **បរិមាណអ្នកដំណើរបរទេស និងទេសចរ ឆ្លងកាត់កម្ពុជា-វៀតណាម** | នាក់ | **១៨.៣៣៤** | **១០.៦០០** | - | **១៨.៣៣៤** | **៥៧,៨២%** | **+១០៦០០,០០%** | **-១០០,០០%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៨.៦០១ | ៣.៦៥៣ | - | ៨.៦០១ | | | |
| | - ចំនួនភ្ញៀវទេសចរណ៍ | - | ៩.៧៣៣ | ៦.៩៤៧ | - | ៩.៧៣៣ | | | |

*(ប្រភព៖នាយកដ្ឋានផែនការ/ទីផ្សារ)*

- បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់ ក. ស. ភ. នៅក្នុងឆ្នាំ២០២២ សរុបមានចំនួន ៤.០៤៤.២៨៩ តោន កើនឡើង ៥,០១% ធៀបនឹងការអនុវត្តឆ្នាំ២០២១ (៣.៨៥១.៤៥៣ តោន) សម្រាប់ ឆ្នាំ២០២២ នេះ ក. ស. ភ. សម្រេចបាន ៨៥,៧០% ធៀបនឹងផែនការឆ្នាំ២០២២ (៤.៧១៩.៣៨៧ តោន)
- នាវាឆ្លងកាត់ ក. ស. ភ. ក្នុងឆ្នាំ២០២២ សរុបមានចំនួន ៣.៧៨៣ គ្រឿង កើនឡើង ៦៤,៣៤% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០២១ (២.៣០២ គ្រឿង) សម្រាប់ឆ្នាំ ២០២២ ក. ស. ភ. សម្រេចបាន ១៥២,២៣% ធៀបនឹងផែនការឆ្នាំ២០២២ (២.៤៨៥ គ្រឿង)។
- នាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិក្នុងឆ្នាំ២០២២ សរុបមានចំនួន ៥៣៤ ជើង កើនឡើង ៥៣៤,00% ធៀបនឹងការអនុវត្ត ឆ្នាំ២០២១ (0 ជើង) សម្រាប់ឆ្នាំ ២០២២ នេះ ក. ស. ភ. សម្រេចបាន ៧៧,១៧% ធៀបនឹងផែនការឆ្នាំ២០២២ (៦៩២ ជើង)
- បរិមាណកុងតឺន័រក្នុងឆ្នាំ២០២២ មានចំនួន ៤១៧.៦៩៦ TEUs កើនឡើង ១៩,៧២% ធៀបនឹងការអនុវត្តឆ្នាំ២០២១ (៣៤៨.៨៩៨ TEUs) សម្រាប់ឆ្នាំ ២០២២ នេះ ក. ស. ភ. សម្រេចបាន ១០៥,៨៣% ធៀបនឹងផែនការឆ្នាំ២០២២ (៣៩៤.៦៧៩ TEUs)
- បរិមាណអ្នកដំណើរ និងទេសចរឆ្លងកាត់ ក. ស. ភ. ក្នុងឆ្នាំ២០២២ សរុបមានចំនួន ១០.៦០០ នាក់ កើនឡើង ១០៦០០,00% ធៀបនឹងការអនុវត្តឆ្នាំ២០២១ (0 នាក់) សម្រាប់ឆ្នាំ២០២២ ក. ស. ភ. សម្រេចបាន ៥៧,៨២% ធៀបនឹងផែនការឆ្នាំ២០២២ (១៨.៣៣៤ នាក់)។

## ក្រាហ្វិក ស្តីពីការប្រៀបធៀបការអនុវត្ត ឆ្នាំ ២០២២ - ឆ្នាំ២០២១ - ឆ្នាំ២០២០ និងផែនការឆ្នាំ២០២២



## ២. ការអនុវត្តការងារជលធារសាស្ត្រ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងចក្រ

❖ *ការងារជលធារសាស្ត្រ*

- បានធ្វើការបូមស្តារប្រឡាយនាវាចរណ៍ស្តៅ ដើម្បីសម្រួលដល់ផ្លូវនាវាចរណ៍ អនុវត្តបាន ១០០% នៃផែនការឆ្នាំ ២០២២
- បានធ្វើការថែទាំ និងបោះបង្គោលសញ្ញានាវាចរណ៍ចាប់ពីក្អមសំណ ដល់ចំណតផែទន្លេបិទ ខេត្តត្បូងឃ្មុំ អនុវត្តបាន ១០០% នៃផែនការឆ្នាំ ២០២២
- បានធ្វើការសិក្សាវាស់វែងជម្រៅទឹកតាមដងទន្លេ នៅតាមទីតាំងចំណតផែផ្សេងៗ ដើម្បីសម្រួលដល់ការធ្វើនាវាចរណ៍ អនុវត្តបាន ១០០% នៃផែនការឆ្នាំ ២០២២

❖ *ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ*

**ចំណតផែកុងតឺន័រ LM១៧**

- ការងារសាងសង់ទីលានផ្ទុកកុងតឺន័រជំហានទី៣ ដំណាក់កាលទី២ (ប្លង់B) ដែលមានតម្លៃគម្រោង ៤.៦១៧.៦០០ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់ច្រកទ្វារទី៣ នៅទីលានជំហានទី៤ ទំហំ ២១ម៉ែត្រ x ៣០ម៉ែត្រ កម្ពស់ ១០ម៉ែត្រ ផ្លូវ AC ទំហំ ១.០៥៥ ម៉ែត្រក្រឡា និងតប្រព័ន្ធអគ្គិសនីដែលមានតម្លៃគម្រោង ៣៧៥. ៦០៧ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់រោងស្តេនរថយន្តដឹកកុងតឺន័រទំហំ ១៦ម៉ែត្រ x ៤០ម៉ែត្រ ដែលមានតម្លៃគម្រោង ១៦១.៩៧៤ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់បន្ថែមជើងគ្រឹះ ដើម្បីបំពាក់ម៉ាស៊ីន RPM និងប្រព័ន្ធការពាររន្ទះនៅច្រកទ្វារទី៣ ដែលមានតម្លៃគម្រោង ៣០.៧៣១ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់ស្ពានផែទំហំ ១៦ម៉ែត្រ x ១៤៩ម៉ែត្រ (ស្ពានផែទី៣) ដែលមានតម្លៃគម្រោង ៦.៨៧៦.៣៤១ ដុល្លារអាមេរិក សម្រេចបាន ១២% នៃគម្រោង
- ការងារសាងសង់ឃ្លាំង LCL ទំហំ ២៤,៤ម៉ែត្រ x ៦០ម៉ែត្រ និងចាក់សាបបេតុងអាម៉េ ទំហំ ១.៥១០ម៉ែត្រក្រឡា ស្ថិតនៅខាងជើងច្រកចេញជំហានទី៣ ដែលមានតម្លៃគម្រោង ៣៧៩ .៦៦៩ ដុល្លារអាមេរិក សម្រេចបាន ៧% នៃគម្រោង។

**ចំណតផែវណបពហុបំណងកោះរកា LM២៦**

- ការងារសាងសង់ទីលានថ្មម៉ិចទំហំ ១៤.៨៤២ ម៉ែត្រក្រឡា ដែលមានតម្លៃគម្រោង ៣០២.១០៤ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់ស្ពានដែក និងបេតុងចំនួន ៣ និងគ្រឹះដៃស្ទាចំនួន ៤គ្រឿង សម្រាប់បំពាក់ប៉ុងតុង ដែលមានតម្លៃគម្រោង ១៥៣.៥៦០ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង

- ការងារសាងសង់ផ្លូវថ្មម៉ិចដែលប្រវែងសរុប ៨៣២ ម៉ែត្រ ទីលានថ្មម៉ិចទំហំ ២.៦៣៨ ម៉ែត្រ និងតបណ្តាញលូប្រវែងសរុប ២០០ ម៉ែត្រ ដែលមានតម្លៃគម្រោង ៣២៤.៥៧៩ ដុល្លារអាមេរិក សម្រេចបាន ៥៥% នៃគម្រោង។

**ចំណតផែរណបពហុបំណងទន្លេបិទ UM២**

- ការងារសាងសង់ស្ពានផែទំហំ ១២ម៉ែត្រ x ៤៦,៩ម៉ែត្រ ជើងគ្រឹះដងយោង FCC ទំហំ ៩ម៉ែត្រ x ៩ម៉ែត្រ ចំនួន ១, Dolphin ទំហំ ៩ម៉ែត្រ x ៥ម៉ែត្រ ចំនួន ១, Dolphin ទំហំ ១២ម៉ែត្រ x ១០ម៉ែត្រ ចំនួន១ និងជ្រាំងទន្លេប្រវែង ៥០ ម៉ែត្រ ដែលមានតម្លៃគម្រោងចំនួន ៣.៥៥០. ០០០ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារចាក់ថ្មផុយបំពេញកូដ ចំនួន ៥.៤៩៥ ម៉ែត្រគូប ដែលមានតម្លៃគម្រោង ៤១.៤៨១ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារចាក់ថ្មផុយបំពេញកូដ ចំនួន ៥.៤៩៥ ម៉ែត្រគូប ដែលមានតម្លៃគម្រោង ៤១.៤៨១ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង។

**ចំណតផែពហុបំណង TS៣**

- ការងារសាងសង់ស្ពានផែទេសចរណ៍ចំនួន ៣ ទីតាំង ដែលមានតម្លៃគម្រោងសរុបចំនួន ៣០៧.៨៧៧ ដុល្លារអាមេរិក សម្រេចបាន ១០០% នៃគម្រោង
- ការងារសាងសង់សាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall) ដែលមានតម្លៃគម្រោង ៦៤៦.៥៨៥ ដុល្លារអាមេរិក សម្រេចបាន ៣២% នៃគម្រោង។

❖ ***ការទិញ/បំពាក់គ្រឿងចក្រ ឬឧបករណ៍ថ្មី***

- ទិញចង្កៀងសូឡា ២៦ គ្រឿង សម្រាប់បម្រើការងារជួសជុល និងថែទាំពោងសញ្ញាចំណាយថវិកាអស់ចំនួន ២៩.០០០ ដុល្លារអាមេរិក ស្មើនឹង ៨៩% នៃផែនការឆ្នាំ ២០២២
- បានបញ្ជាទិញកាណូតចម្លងកណ្តាល ចំនួន ១ គ្រឿង ទំហំបណ្តោយ ២០,១០ម៉ែត្រ ទទឹង ៤,៤០ ម៉ែត្រ ប្រភេទសំបកឈើ (បានមកដល់) ចំណាយថវិកាអស់ចំនួន ៣៥.០០០ដុល្លារអាមេរិក
- បាននិងកំពុងសិក្សាក្នុងការទិញឬជួល RTG ចំនួន ៣ គ្រឿង
- បាននិងកំពុងសិក្សាក្នុងការទិញឬជួល Reach-Stacker ចំនួន ៤ គ្រឿង
- ទិញប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពកុំព្យូទ័រ (Firewall) ចំណាយថវិកាចំនួន ២៩.១៥០ ដុល្លារអាមេរិក ស្មើនឹង ៦៨% នៃផែនការឆ្នាំ២០២២
- ទិញឧបករណ៍តបណ្តាញ (Network) ចំណាយថវិកាអស់ចំនួន ៥.៦០០ដុល្លារអាមេរិក ស្មើនឹង ៧៨% នៃផែនការឆ្នាំ២០២២
- បំពាក់ឧបករណ៍វាស់ស្ទង់ Software (Dongle license) ចំណាយថវិកាអស់ចំនួន ១៦.១២៩ ដុល្លារអាមេរិក ស្មើនឹង ៧៧% នៃផែនការឆ្នាំ២០២២។

## ខ. រចនាសម្ព័ន្ធចំណូល

| បរិយាយ | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ៦៥.៥២៧.៦១១ | ៤៤,០៣% | ៥៥.៤២៤.១៤៩ | ៤៤,២៦% | ៤៧.៩៧៦.៥១៦ | ៤៣,៥០% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ៥១.៩០១.១២៤ | ៣៤,៨៨% | ៤៥.១៨១.៨៦០ | ៣៦,០៨% | ៤០.០៧៦.៨១៤ | ៣៦,៣៣% |
| ចំណូលពីកិច្ចការផែ | ១៧.៦៩៥.៨៩៧ | ១១,៨៩% | ១៤.៤៧៧.៩១០ | ១១,៥៦% | ១៤.៨៨៩.១៣៣ | ១៣,៥០% |
| ចំណូលពីច្រកទ្វារ | ៤.៣៥៤.០៦៥ | ២,៩៣% | ៣.៦១៤.៦៥៨ | ២,៨៩% | ២.៨៤៤.៤៨២ | ២,៥៨% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៤.០៧៦.៧០១ | ២,៧៤% | ៣.៣៥៦.៤៩៥ | ២,៦៨% | ២.៥៩៣.០៤១ | ២,៣៥% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ៨០.១៥៨ | ០,០៥% | ៤១.១៣៦ | ០,០៣% | ១៨.៧១៤ | ០,០២% |
| ចំណូលពីការរើរៀបទំនិញ | ១០៦.២៦២ | ០,០៧% | ១៣០.១២៧ | ០,១១% | ១២៥.៩៤៩ | ០,១១% |
| ចំណូលពីការដឹកជញ្ជូន | ៣.៨៩០.៣៩១ | ២,៦១% | ១.៧៣៣.១៧៥ | ១,៣៨% | ៩៨១.៥៧១ | ០,៨៩% |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ១.១៧២.៥១៩ | ០,៧៩% | ១.១២៩.៩៦៨ | ០,៩០% | ២៤៥.៤០២ | ០,២២% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ១០.៨៣៩ | ០,០១% | ១២៦.៤៧០ | ០,១០% | ៥៥១.៨០២ | ០,៥០% |
| ចំណូលពីការវាស់ស្ទង់ | - | ០,០០% | ១២.២០៤ | ០,០១% | - | ០,០០% |
| **សរុប:** | **១៤៨.៨១៥.៥៦៧** | **១០០ %** | **១២៥.២២៨.១៥២** | **១០០ %** | **១១០.៣០៣.៤២៤** | **១០០ %** |

# ផ្នែកទី៣

# ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## រចនាសម្ព័ន្ធគ្រប់គ្រងកំពង់ផែស្វយ័តភ្នំពេញ




**សម្គាល់:**
- ប្រធានការិយាល័យ និងប្រធានសេវាដ្ឋាន ជាជំនួយការឲ្យប្រធាននាយកដ្ឋាន (ស្មើអនុប្រធាននាយកដ្ឋាន)
- ប្រធានការិយាល័យ = ប្រធានសេវាដ្ឋាន = ប្រធានអង្គភាពលទ្ធកម្ម
- ប្រធានអង្គភាព = អនុប្រធានការិយាល័យ = អនុប្រធានសេវាដ្ឋាន

## ២. ក្រុមប្រឹក្សាភិបាល

*សមាសភាពក្រុមប្រឹក្សាភិបាល*

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ី បារី** | ប្រធាន | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ២. | ឯកឧត្តម **សួន រចនា** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ៣. | ឯកឧត្តម **កែន សម្បត្តិ** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ៤. | ឯកឧត្តម **ប៉ែន សុវិជាតិ** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ៥. | លោក **ហ៊្គី អានវ៉ានិច** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ៦. | លោកស្រី **ប៉ុក ភក្ដី** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |
| ៧. | លោក **គង់ សុធា** | សមាជិក | ២៧ មិថុនា ២០២២ | ២៧ មិថុនា ២០២៥ |

*ឈ្មោះលេខាធិការរបស់កំពង់ផែស្វយ័តភ្នំពេញ គឺលោក **គង់ ចាន់នី** ប្រធានលេខាធិការដ្ឋាន។*

## ៣. បុគ្គលិកជាន់ខ្ពស់

*សមាសភាពបុគ្គលិកជាន់ខ្ពស់*

| ល.រ | ឈ្មោះ បុគ្គលិកជាន់ខ្ពស់ | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម **ហ៊ី បារី** | ប្រុស | ប្រធានអគ្គនាយក |
| ២ | លោកជំទាវ **ជួន សុខេម** | ស្រី | អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ |
| ៣ | លោក **កុយ ប៊ុនធន** | ប្រុស | អគ្គនាយករងបច្ចេកទេស |
| ៤ | លោក **ហៀក ភិរុណ** | ប្រុស | អគ្គនាយករងកិច្ចការផែ |
| ៥ | អ្នកស្រី **ហ៊ី ផានិន** | ស្រី | អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ |
| ៦ | លោក **គង់ ចាន់នី** | ប្រុស | ប្រធានលេខាធិការដ្ឋាន |
| ៧ | លោក **កែវ សុផាណ្ណារ៉ា** | ប្រុស | នាយកសវនកម្មផ្ទៃក្នុង |
| ៨ | លោក **គង់ សុធា** | ប្រុស | នាយករដ្ឋបាល |
| ៩ | អ្នកស្រី **សេង គន្ធា** | ស្រី | នាយកបុគ្គលិក/ធនធានមនុស្ស |
| ១០ | កញ្ញា **ឈាវ វណ្ណធា** | ស្រី | នាយកគណនេយ្យ/ហិរញ្ញវត្ថុ |
| ១១ | លោក **សាយ ចន្ថា** | ប្រុស | នាយកគ្រប់គ្រងគ្រឿងចក្រ |
| ១២ | លោក **ជៀប វីរ៉ាយ៉ា** | ប្រុស | នាយកជលធារសាស្ត្រ |
| ១៣ | លោក **តុល សុខុម** | ប្រុស | នាយកសេវាកម្មនាវាចរណ៍ |
| ១៤ | លោក **ឈីវ សុងកាំង** | ប្រុស | នាយកចំណតផែរណបពហុបំណង UM១ |
| ១៥ | លោក **ហ៊ុន សុខាល័យ** | ប្រុស | នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ |
| ១៦ | លោក **ហ៊ី សុង** | ប្រុស | នាយកប្រតិបត្តិការចំណតផែ TS៣ |
| ១៧ | លោក **អ៊ឹម ដាវីដ** | ប្រុស | នាយកស្ដីទីវិស្វកម្ម |
| ១៨ | លោក **ប្រាក់ សាមិត្ត** | ប្រុស | នាយកស្ដីទីមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក |
| ១៩ | អ្នកស្រី **មាស វិសាល** | ស្រី | នាយកស្ដីទីផែនការ/ទីផ្សារ |

*សម្គាល់៖ ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។*

# ផ្នែកទី ៤

# ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុននិក របស់កំពង់ផែស្វយ័តភ្នំពេញ

## ក. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ឈ្មោះមូលបត្រកម្មសិទ្ធិ : **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"**

និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ : **KH1000040001**

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"**

តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **៤.០០០ រៀល**

ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **៥.១២០ រៀល**

បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ : **៤.១៣៦.៨៧៣ មូលបត្រ**

មូលធនូបនីយកម្មទីផ្សារ : **១០៥.៩០៣.៩៤៨.៨០០ រៀល**

ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : **ផ្សារមូលបត្រកម្ពុជា**

កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : **ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥**

## ខ. ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ១៤.៩៨០ | ១៥.២០០ | ១៥.៧៦០ | ១៥.៦០០ | ១៥.៩៨០ | ១៥.៨០០ | ១៥.៣៤០ | ១៤.៩៦០ | ១៤.៧៨០ | ១៤.៤២០ | ១៤.០០០ | ១៤.០០០ |
| | អប្បបរមា | ១៤.៥៦០ | ១៤.៨៦០ | ១៤.៩០០ | ១៥.២០០ | ១៥.៤០០ | ១៥.០០០ | ១៤.៧០០ | ១៤.៦២០ | ១៤.២៨០ | ១៣.៩៨០ | ១៣.៩៦០ | ១៣.៩៤០ |
| | មធ្យម | ១៤.៨៥៩ | ១៤.៩៥៦ | ១៥.២៩៧ | ១៥.៤៦៦ | ១៥.៧៨៥ | ១៥.៦១២ | ១៥.០៩០ | ១៤.៨២៣ | ១៤.៥០៨ | ១៤.២៤៦ | ១៣.៩៩២ | ១៣.៩៨១ |
| បរិមាណជួញដូរ | អតិបរមា | ៣.០១៦ | ១.៩៦៧ | ២៤.៧៤៤ | ៤.១៩៩ | ៤១.៦៣៩ | ៧៥១ | ៣៥០.០៩២ | ៨៩២ | ២៤៤.១៥៦ | ៤.៣៧០ | ៩៩១ | ៦៦៦ |
| | អប្បបរមា | ៩ | ៦ | ១០៨ | ៧៧ | ៥ | ២ | ១ | ២ | ៤ | ១ | ២ | ១០ |
| | មធ្យម | ៣៥៥ | ៥៣៩ | ១.៩៣០ | ៥៨៩ | ២.៤៣៨ | ១៩៤ | ១៧.៣១២ | ២០៧ | ១២.៥៩៧ | ៤៩៦ | ២១២ | ២១៧ |

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ខ្មែរ | ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | គ្មាន | ១៦.៥៤៧.៤៩២ | ៨០% |
| **សរុប** | | | | | **១៦.៥៤៧.៤៩២** | **៨០%** |

## ឃ. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|---|
| ១ | ចំណេញសុទ្ធ (រៀល) | ៥១.៦៩៥.៤៥៧.០០០ | ៤០.២១២.៦៤៩.០០០ | ៤៦.៨០៦.២៤៤.០០០ |
| ២ | ភាគលាភជាសាច់ប្រាក់សរុប (រៀល) | ៤.៣៧៦.៧៥១.៣៣៤ | ៤.១២៦.៧៥១.៣៣៤ | ៤.១២៦.៧៥១.៣៣៤ |
| ៣ | ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន | គ្មាន |
| ៤ | ភាគលាភផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |
| ៥ | អនុបាតនៃការបែងចែកភាគលាភ (%) | ៨,៤៦% | ១០,២៦% | ៨,៨២% |
| ៦ | ទិន្នផលភាគលាភ (%) | ១,៤៤% | ១,៧១% | ១,៦០% |
| ៧ | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ២១១,៦០ | ១៩៩,៥១ | ១៩៩,៥១ |

# ផ្នែកទី ៥

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង លើការត្រួតពិនិត្យផ្ទៃក្នុង សម្រាប់ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង
# ឆ្នាំ២០២២

លេខ: ០១៣ ន. ស. ផ. ក.

ខែ កុម្ភៈ ឆ្នាំ ២០២៣

# ព័ត៌មានស្ដីពីឯកសារ

## ឯកសារសម្ងាត់៖

| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | កំពង់ផែស្វយ័តភ្នំពេញ |
|---|---|
| ចំណងជើង | របាយការណ៍សវនកម្មស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០២២ |
| ថ្នាក់ដឹកនាំនាយកដ្ឋានសវនកម្មផ្ទៃក្នុង | លោក កែវ សុផាណ្ណារ៉ា |
| អ្នកត្រួតពិនិត្យ | លោក អ៊ុន ទូច និងមន្ត្រី បុគ្គលិក នាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| សវនដ្ឋាន | **ត្រីមាសទី១**<br>- នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧<br>- ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ<br>- សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ<br>- អង្គភាពរៀបផែនប្រតិបត្តិការ LM១៧<br>**ត្រីមាសទី២**<br>- នាយកដ្ឋានរដ្ឋបាល<br>- ការិយាល័យរដ្ឋបាល<br>- ការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera<br>**ត្រីមាសទី៣**<br>- អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧<br>- អង្គភាពវិក្កយបត្រ LM១៧<br>**ត្រីមាសទី៤**<br>- នាយកដ្ឋានសេវាកម្មនាវាចរណ៍<br>- ការិយាល័យកណ្ដូធារ |
| ទីកន្លែងឯកសាររឹង (Hard Copy) | **ត្រីមាសទី១**<br>- នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧<br>- ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ<br>- សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ<br>- អង្គភាពរៀបផែនប្រតិបត្តិការ LM១៧<br>**ត្រីមាសទី២**<br>- នាយកដ្ឋានរដ្ឋបាល<br>- ការិយាល័យរដ្ឋបាល |

| | |
|---|---|
| | - ការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera<br>**ត្រឹមសទី៣**<br>- អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧<br>- អង្គភាពវិក្កយបត្រ LM១៧<br>**ត្រឹមសទី៤**<br>- នាយកដ្ឋានសេវាកម្មនាវិចរណ៍<br>- ការិយាល័យកណ្តូធារ |
| ទីកន្លែងឯកសារទន់ (Soft Copy) | **ត្រឹមសទី១**<br>- នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧<br>- ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ<br>- សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ<br>- អង្គភាពរៀបផែនប្រតិបត្តិការ LM១៧<br>**ត្រឹមសទី២**<br>- នាយកដ្ឋានរដ្ឋបាល<br>- ការិយាល័យរដ្ឋបាល<br>- ការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera<br>**ត្រឹមសទី៣**<br>- អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧<br>- អង្គភាពវិក្កយបត្រ LM១៧<br>**ត្រឹមសទី៤**<br>- នាយកដ្ឋានសេវាកម្មនាវិចរណ៍<br>- ការិយាល័យកណ្តូធារ |

**ការចែកចាយឯកសារ៖**

| ឈ្មោះ | មុខតំណែង/តួនាទី | កន្លែងទទួលឯកសារ |
|---|---|---|
| ឯកឧត្តម ហ៊ី អានវិនិច | ប្រធានគណៈកម្មាធិការសវនកម្ម | កំពង់ផែស្វយ័តភ្នំពេញ |

# មាតិកា


| | ទំព័រ |
|---|---|
| **ផ្នែក ក : ខ្លឹមសារសង្ខេប** | ១ |
| ១.សាវតារ | ១ |
| ២.ហានិភ័យគន្លឹះ | ១ |
| ៣.វិសាលភាពសវនកម្ម | ២ |
| ៤.គោលបំណងសវនកម្មនិងការត្រួតពិនិត្យ | ២ |
| ៥.អភិក្រមសវនកម្ម | ៣ |
| ៦.សង្ខេបលទ្ធផលគន្លឹះ | ៣ |
| ៧.សេចក្តីសន្និដ្ឋាន | ៥ |
| ៨.វិធានការកែលម្អ | ៦ |
| ៩.អំណរគុណ | ៨ |
| **ផ្នែក ខ : លទ្ធផលសវនកម្មលម្អិត** | ៨ |
| ១.សមាសភាពចូលរួម | ៨ |
| ២.ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង | ១៣ |
| ៣.ពិនិត្យការគ្រប់គ្រងផ្ទៃក្នុង | ១៣ |
| ៤.ព័ត៌មានអំពីសវនដ្ឋាន | ១៣ |
| ៥.លទ្ធផលសវនកម្ម (ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ) | ១៤ |
| ៦.លទ្ធផលសវនកម្ម (ផ្នែកអនុលោមភាព) | ២៥ |
| ៧.សេចក្តីសន្និដ្ឋានរួម | ៣៤ |
| ៨.ផែនការសកម្មភាពកែលម្អ | ៣៤ |


## ឧបសម្ព័ន្ធ


- ឧបសម្ព័ន្ធទី ១ ការអនុវត្តតាមអនុសាសន៍គ្រាមុន
- ឧបសម្ព័ន្ធទី ២ ផែនការសកម្មភាពកែលម្អ

# របាយការណ៍សវនកម្មផ្ទៃក្នុង
# នៅកំពង់ផែស្វយ័តភ្នំពេញ
# សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ

## ផ្នែក ក: ខ្លឹមសារសង្ខេប

### ១.សាវតារ

ការធ្វើសវនកម្មនៅ នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបចំប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តូធារ សម្រាប់ការិយបរិច្ឆេទ ២០២២ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងដែលទទួលបានការយល់ព្រមពី ឯកឧត្តមប្រធានគណៈកម្មាធិការសវនកម្ម។ របាយការណ៍ នេះមានព័ត៌មានលម្អិតអំពីលទ្ធផលការងារសវនកម្ម និងការផ្តល់អនុសាសន៍កំឡុងជាផែនការរបស់ថ្នាក់គ្រប់គ្រងដែលបានឯកភាពគ្នា។

### ២.ហានិភ័យគន្លឹះ

ជាទូទៅហានិភ័យអាចរាប់បញ្ចូលនូវ

- **ហានិភ័យប្រតិបត្តិការ:**ជាហានិភ័យលើការបាត់បង់ដែលជាលទ្ធផលបរាជ័យនៃដំណើរការមនុស្ស និងប្រព័ន្ធឬពីហេតុការណ៍ពីខាងក្រៅ។
- **ហានិភ័យហិរញ្ញវត្ថុ:**ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុត្រូវបានរៀបចំឡើងមិនត្រឹមត្រូវ ធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប។
- **ហានិភ័យអនុលោមភាព:**ជាលទ្ធភាពដែលសកម្មភាពមិនអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។

ដោយឡែក ការងារសវនកម្មនៅនាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/ បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបចំប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តូធារ សវនករកំណត់បាននូវហានិភ័យមួយចំនួនក្នុងនោះហានិភ័យគន្លឹះមាន៖

-លទ្ធភាពប៉ះពាល់លើគុណភាពនៃការផ្តល់សេវាសាធារណៈ

-លទ្ធភាពប៉ះពាល់ដល់ឯកសារដែលរក្សាទុកមានលក្ខណៈពុំទាន់ត្រឹមត្រូវ និងប្រសិទ្ធិភាពការងារ

-អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

**៣.វិសាលភាពសវនកម្ម**

សវនកម្មនេះគ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងប្រតិបត្តិការទាំងឡាយដែលបានដំណើរការដោយ នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបវេនប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តាល សម្រាប់ការិយបរិច្ឆេទ២០២២។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើតេស្តសវនកម្មត្រូវបានប្រព្រឹត្តទៅតាម នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបវេនប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តាល ។

**៤.គោលបំណងសវនកម្មនិងការត្រួតពិនិត្យ**

គោលបំណងសវនកម្មរួម គឺវាយតម្លៃនិងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ចក្នុងទីសវនកម្មដែលស្ថិតនៅក្នុងវិសាលភាពសវនកម្ម។

ជាទូទៅការងារសវនកម្មបានផ្តោតទៅលើការបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្តល់នូវការធានាសមហេតុផលមួយសំដៅសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

-**គោលបំណងប្រតិបត្តិការ:** ការសម្រេចបានប្រកបដោយប្រសិទ្ធភាពនៃគោលបំណងប្រតិបត្តិការ

-**គោលបំណងព័ត៌មាន:** ភាពជឿទុកចិត្តនិងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ

-**គោលបំណងអនុលោមភាព:** អនុលោមតាមច្បាប់បទប្បញ្ញត្តិគោលការណ៍នីតិវិធីជាធរមាន។

ដោយឡែកនៅក្នុងសវនកម្មនេះសវនករបានកំណត់នូវគោលបំណងសំខាន់ៗមួយចំនួនដើម្បីគ្រប់គ្រងហានិភ័យដូចជា៖

- ពង្រឹងប្រសិទ្ធិភាពនៃការអនុវត្ត និងការផ្តល់សេវាជូនអតិថិជន
- ពង្រឹងការគ្រប់គ្រងបុគ្គលិក និយោជិត វិន័យ និងប្រសិទ្ធិភាពការងារ
- ពង្រឹងការគ្រប់គ្រងចំណូលគ្រប់ប្រភេទ
- ពង្រឹងប្រសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ

- ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

**៥. អភិក្រមសវនកម្ម**

អភិក្រមសវនកម្មផ្ដោតលើដំណើរការមានហានិភ័យ ត្រូវបានប្រើប្រាស់នៅក្នុងការងារសវនកម្មនេះ។ អភិក្រមសវនកម្មនេះរាប់បញ្ចូល ៖

- កត់ត្រាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងតាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធនិងសម្ភាសន៍មន្ត្រី /បុគ្គលិក
- ការកំណត់នូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងជាគន្លឹះនិងធ្វើការប្រៀបធៀបជាមួយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលបានរំពឹងទុក
- តេស្តសវនកម្មនូវប្រសិទ្ធភាពប្រតិបត្តិការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។

តាមរយៈការងារសវនកម្មប្រតិភូសវនកម្មបានសហការកំណត់ការរំពឹងទុករួមជាមួយថ្នាក់គ្រប់គ្រងនិងថ្នាក់ដឹកនាំសវនដ្ឋាន។

**៦.សង្ខេបលទ្ធផលគន្លឹះ**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានកត់សម្គាល់ឃើញនូវចំណុចខ្វះចន្លោះមួយចំនួនដូចខាងក្រោម៖

**ផ្នែកប្រសិទ្ធិភាពប្រតិបត្តិការ**

**ត្រីមាសទី១**

- កង្វះខាតក្នុងការអនុវត្តតួនាទី និងភារកិច្ច
- កង្វះខាតឯកសារពាក់ព័ន្ធការងារថែទាំរថយន្ត RTG
- កង្វះខាតការរៀបចំបទដ្ឋានបច្ចេកទេសជួសជុលគ្រឿងចក្រ
- អំពីរបាយការណ៍អនុវត្តការងារប្រចាំខែ
- ការរៀបចំបែងចែកតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិកក្នុងសេវាដ្ឋាន។

**ត្រីមាសទី២**

- កង្វះខាតក្នុងការគ្រប់គ្រងលើការងារថែទាំសោភ័ណភាពទូទៅ និងអនាម័យ នៅអគាររដ្ឋបាលចំណតផែកុងតឺន័រ LM១៧
- កង្វះខាតក្នុងការផ្គត់ផ្គង់សម្ភារជួសជុលអគ្គីសនី និងទឹកក្នុង ក. ស. ភ.
- អំពីរបាយការណ៍ស្ថានភាព CCTV Camera នៅចំណតផែកុងតឺន័រ LM១៧

- អំពីការចុះលេខស្តុនឡា និងមិនចុះហត្ថលេខាលើបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភពី LOLO SCAN

**ត្រីមាសទី៣**

- អំពីការចារលើលិខិតស្នើសុំទូកុងតឺន័រចូលស្តុក និងដំណើរការខុសគណនីយភាព (Unaccountability) ក្នុងប្រព័ន្ធ Terminal Operating System (TOS) ក្នុងនីតិវិធីបញ្ចូលទិន្នន័យទូកុងតឺន័រដែលត្រូវប្រើប្រាស់រថយន្ត ក. ស. ភ. ដើម្បីធ្វើ LOLO Scan
- អំពីទំនិញគ្រោះថ្នាក់និងការរក្សាទុកកុងតឺន័រដែលនៅយូរក្នុងចំណតផែ LM១៧
- អំពីការចេញវិក្កយបត្រលើស្តុកទូកុងតឺន័រសម្រាប់នាំចេញ (Storage Export)

**ត្រីមាសទី៤**

- អំពីកង្វះមន្ត្រីបំពេញការងារផ្នែកកណ្ណធារ
- អំពីកង្វះខាតឧបករណ៍វិទ្យុទំនាក់ទំនង Portable Radio Phone សម្រាប់កណ្ណធារ

**ផ្នែកអនុលោមភាព**

**ត្រីមាសទី១**

- អំពីគម្រោងផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
- ការអនុវត្តគម្រោងផែនការឆ្នាំ២០២២ របស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ
- អំពីរបាយការណ៍ប្រចាំឆ្នាំ
- អំពីកង្វះខាតលើការរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសគ្រឿងចក្រ កំណត់ការផ្លាស់ប្តូរប្រេង និងតម្រងប្រេងរបស់រថយន្ត និងគ្រឿងចក្រឱ្យស្របតាមបែបបទរដ្ឋបាល។

**ត្រីមាសទី២**

- អំពីរបាយការណ៍ចំណាយប្រចាំខែ
- កង្វះខាតនីតិវិធីក្នុងការគ្រប់គ្រងរថយន្តប្រើប្រាស់របស់ការិយាល័យរដ្ឋបាល
- អំពីការខ្វះចន្លោះមន្ត្រីក្នុងរចនាសម្ព័ន្ធការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera
- អំពីកង្វះខាតក្នុងការកំណត់អត្តសញ្ញាណអ្នកបើកបររថយន្តដឹកទំនិញចូល-ចេញ ក្នុងបរិវេណប្រតិបត្តិការចំណតផែរបស់ ក. ស. ភ.

**ត្រីមាសទី៣**

- ការស្នើសុំសម្ភារការិយាល័យប្រើប្រាស់ប្រចាំខែនីមួយៗនៃឆ្នាំ២០២២
- អំពីកង្វះការរៀបចំធ្វើបច្ចុប្បន្នភាពនៃការកំណត់តួនាទី និងភារកិច្ច របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧
- អំពីរចនាសម្ព័ន្ធ របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧
- អំពីរចនាសម្ព័ន្ធ របស់អង្គភាពវិក្កយបត្រ LM១៧

**ត្រីមាសទី៤**

- អំពីវគ្គបណ្តុះបណ្តាលកណ្តុធារក្រៅប្រទេស
- អំពីកង្វះនាតច្បងការធ្វើរបាយការណ៍បូកសរុបសកម្មភាពនាំនាវាប្រចាំឆ្នាំ របស់ការិយាល័យកណ្តុធារ

**៧.សេចក្តីសន្និដ្ឋាន**

ក្នុងអំឡុងពេលធ្វើសវនកម្មការត្រួតពិនិត្យផ្ទៃក្នុងមួយចំនួនត្រូវបានសង្កេតឃើញថា មានការរៀបចំបានល្អ និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងពិនិត្យឃើញថា ថ្នាក់ដឹកនាំ និង មន្ត្រី បុគ្គលិក នៅនាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបផែនប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តុធារ បានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទីភារកិច្ចដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។ ទោះជាយ៉ាងណា ក៏នៅទីសវនកម្មមួយចំនួនត្រូវបានកត់សម្គាល់ថាការតាក់តែង ការត្រួតពិនិត្យផ្ទៃក្នុងត្រូវការ ការកែលម្អបន្ថែម និងប្រសិទ្ធភាពប្រតិបត្តិការនៃការត្រួតពិនិត្យខ្លះនៅមិនទាន់បានល្អគ្រប់ជ្រុងជ្រោយនៅឡើយមានដូចខាងក្រោម៖

**ត្រីមាសទី១**

នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ នៅមិនបានរៀបចំចងក្រង និងរក្សាទុកបណ្តាផែនការប្រចាំឆ្នាំតាមសេវាដ្ឋានអង្គភាពក្រោមឱវាទនៅឡើយ ចំពោះការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ បានអនុវត្តគម្រោងផែនការឆ្នាំ២០២២មកដល់បច្ចុប្បន្នពុំទាន់បាន៥០%នៃផែនការ។ ចំណែក សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រនៅពុំទាន់មានឯកសារអះអាងបញ្ជាក់ច្បាស់លាស់ដូចជា ភស្តុតាង បើការងារថែទាំ និងជាធាតុបញ្ចូលក្នុងរបាយការណ៍ប្រចាំខែ និងពុំទាន់មានឧបករណ៍ប៉ុងលើករថយន្ត លើកម៉ាស៊ីន ប្រអប់លេខ និងគ្រឿងបង្គុំគ្រឿងចក្រ

ដោយនៅប្រើ Elevator សម្រាប់លើក។ ដោយឡែកអង្គភាពរៀបផែនប្រតិបត្តិការផែ LM១៧ មិនទាន់បានបូកសរុបរបាយការណ៍ប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ។

**ត្រីមាសទី២**

ការិយាល័យរដ្ឋបាល នៅមិនទាន់បង្កើនប្រសិទ្ធិភាពនៃការធ្វើរបាយការណ៍ចំណាយប្រចាំខែឱ្យបានទាន់ពេលវេលា ការផ្គត់ផ្គង់សម្ភារផ្ទុសផុលអគ្គិសនី និងទឹកក្នុង ក. ស. ភ. នៅជួបកង្វះខាត និងភាពខ្វះខាតការតាមដាន និងពិនិត្យរថយន្តបន្ទាប់ពីប្រើប្រាស់ហើយមិនទាន់គ្រប់ជ្រុងជ្រោយ។ ចំណែកការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera វិញ នៅមានកង្វះខាតក្នុងការកំណត់អត្តសញ្ញាណអ្នកបើកបររថយន្តដឹកទំនិញ ចូល-ចេញ ក្នុងបរិវេណប្រតិបត្តិការចំណតផែរបស់ ក. ស. ភ. ដើម្បីពង្រឹងសុវត្ថិភាពផ្នែកសន្តិសុខ និងស្ថានភាព CCTV Camera នៅចំណតផែកុងតឺន័រ LM១៧ ក្នុងការត្រួតពិនិត្យសុវត្ថិភាពតាមប្រព័ន្ធ CCTV Camera ចេញពីបន្ទប់ត្រួតពិនិត្យមិនទាន់បានគ្រប់គ្រាន់ពីសន្តិសុខគ្រប់ជ្រុងជ្រោយក្នុងបរិវេណចំណតផែកុងតឺន័រ LM១៧ ដែលអាចកើតមានឡើងគ្រប់ពេលវេលា ។

**ត្រីមាសទី៣**

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ នៅមិនទាន់បង្កើនប្រសិទ្ធិភាពនៃ ការស្នើសុំសម្ភារការិយាល័យប្រើប្រាស់ប្រចាំខែនីមួយៗនៃឆ្នាំ២០២២ អំពីកង្វះការរៀបចំធ្វើបច្ចុប្បន្នភាពនៃការកំណត់តួនាទី និងភារកិច្ច របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អំពីរចនាសម្ព័ន្ធ របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អំពីការចារលើលិខិតស្នើសុំទូរកុងតឺន័រចូលស្អេន និងដំណើរការខុសគណនីយភាព (Unaccountability) ក្នុងប្រព័ន្ធ Terminal Operating System (TOS) ក្នុងនីតិវិធីបញ្ចូល ទិន្នន័យទូកុងតឺន័រដែលត្រូវប្រើប្រាស់រថយន្ត ក. ស. ភ. ដើម្បីធ្វើ LOLO Scan អំពីទំនិញគ្រោះថ្នាក់ និងការរក្សាទុកកុងតឺន័រដែលនៅយូរនៅចំណតផែ LM១៧។ ចំណែកអង្គភាពវិក្កយបត្រ LM១៧ វិញ នៅមានកង្វះខាតអំពីរចនាសម្ព័ន្ធ របស់អង្គភាពវិក្កយបត្រ LM១៧ អំពីការចេញវិក្កយបត្រលើស្តុកទូរកុងតឺន័រសម្រាប់នាំចេញ (Storage Export) ។

**ត្រីមាសទី៤**

នាយកដ្ឋានសេវាកម្មនាវាចរណ៍ អំពីវគ្គបណ្តុះបណ្តាល កញ្ញាធរក្រៅប្រទេស អំពីកង្វះមន្ត្រីបំពេញការងារផ្នែកកញ្ញាធរ អំពីកង្វះខាតឧបករណ៍វិទ្យុទំនាក់ទំនង Portable Radio Phone សម្រាប់កញ្ញាធរ។ ចំណែក ការិយាល័យកញ្ញាធរវិញ នៅមានកង្វះខាតក្នុងការធ្វើរបាយការណ៍បូកសរុបសកម្មភាពនាំនាវាប្រចាំឆ្នាំរបស់ការិយាល័យកញ្ញាធរ ។

**៨.ទិដ្ឋភាពការកែលម្អ**

អនុសាសន៍ដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក. ស. ភ. បានផ្តល់ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការ

អនុវត្តដំណើរការរៀបចំមានដូចតទៅ៖

**ត្រីមាសទី១**

ផែនការលើកដាក់ ផ្ទុកទំនិញ ការថែទាំមធ្យោបាយគ្រឿងចក្រធំៗ រថយន្តដឹកជញ្ជូន និងការងារជួសជុលគ្រប់ប្រភេទ។ ដោយឡែកតាមនាយកដ្ឋាន ការិយាល័យ សេវាដ្ឋាន អង្គភាព រាល់លិខិតនិងឯកសារផ្សេងៗ ត្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពឱ្យកាន់តែរឹងមាំ ហើយត្រូវកែលំអនូវចំណុចខ្វះខាតខាងលើ ដោយអនុវត្តតាមអនុសាសន៍សវនកម្មដែលបានបង្ហាញក្នុងលទ្ធផលដែលបានលម្អិតនៅ (ផ្នែក-ខ) ក៏មាននូវលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

**ត្រីមាសទី២**

ការរៀបចំការចំណាយផ្នែករដ្ឋបាល រៀបចំធ្វើគម្រោងទិញសម្ភារអគ្គិសនី និងទឹករក្សាទុកក្នុងឃ្លាំងសម្រាប់យកមកប្រើប្រាស់បានទាន់ពេល និងការត្រួតពិនិត្យតាមប្រព័ន្ធ CCTV Camera ដើម្បីចាត់វិធានការការពារឱ្យមានសុវត្ថិភាពខ្ពស់ក្នុងបរិវេណផែ LM១៧។ ដោយឡែកតាមការិយាល័យ សេវាដ្ឋាន អង្គភាព រាល់លិខិតនិងឯកសារផ្សេងៗ ត្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពឱ្យកាន់តែរឹងមាំ ហើយត្រូវកែលំអនូវចំណុចខ្វះខាតខាងលើ ដោយអនុវត្តតាមអនុសាសន៍សវនកម្មដែលបានបង្ហាញក្នុងលទ្ធផលដែលបានលម្អិតនៅ (ផ្នែក-ខ) ក៏មាននូវលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

**ត្រីមាសទី៣**

ការស្នើសុំសម្ភារការិយាល័យ ការរៀបចំធ្វើបច្ចុប្បន្នភាពនៃការកំណត់តួនាទី និងភារកិច្ចរចនាសម្ព័ន្ធ របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ការចារលើលិខិតស្នើសុំទូរកុងតឺន័រចូលស្តុក និងដំណើរការខុសពេលវេលា ទំនិញគ្រោះថ្នាក់និងការរក្សាទុកកុងតឺន័រដែលនៅយូរនៅចំណតផែ LM១៧ រចនាសម្ព័ន្ធរបស់អង្គភាព វិក្កយបត្រ LM១៧ ការចេញវិក្កយបត្រលើស្តុកទូរកុងតឺន័រសម្រាប់នាំចេញ (Storage Export)។ ដោយឡែកតាមការិយាល័យ សេវាដ្ឋាន អង្គភាព រាល់លិខិតនិងឯកសារផ្សេងៗ ត្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពឱ្យកាន់តែរឹងមាំ ហើយត្រូវកែលំអនូវចំណុចខ្វះខាតខាងលើ ដោយអនុវត្តតាមអនុសាសន៍សវនកម្មដែលបានបង្ហាញក្នុងលទ្ធផលដែលបានលម្អិតនៅ (ផ្នែក-ខ) ក៏មាននូវលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

**ត្រីមាសទី៤**

អំពីវគ្គបណ្តុះបណ្តាលកណ្តាលក្រៅប្រទេស អំពីកង្វះមន្ត្រីបំពេញការងារផ្នែកកណ្តាល អំពីកង្វះខាតឧបករណ៍វិទ្យុទំនាក់ទំនង Portable Radio Phone និងកង្វះខាតក្នុងការធ្វើរបាយការណ៍បូកសរុបសកម្មភាពនាំនាវាប្រចាំឆ្នាំ

របស់ការិយាល័យគណនេយ្យ ដោយឡែក តាមនាយកដ្ឋាន ការិយាល័យ រាល់លិខិតនិងឯកសារផ្សេងៗ ត្រូវអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និតិវិធីជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពឱ្យកាន់តែរឹងមាំ ហើយត្រូវកែលំអនូវចំណុចខ្វះខាតខាងលើ ដោយអនុវត្តតាមអនុសាសន៍សវនកម្មដែលបានបង្ហាញក្នុងលទ្ធផលដែលបានលម្អិតនៅ (ផ្នែក"ខ") ក៏មានរំលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

វិធានការកែលម្អរបស់ថ្នាក់ដឹកនាំ បានរំលេចក្នុងឧបសម្ព័ន្ធទី២ ដូចមានភ្ជាប់មកជាមួយ ត្រូវបានសវនដ្ឋានឯកភាពរាល់ចំណុចខ្វះខាតទទួលយកមកអនុវត្ត។

### ៥.អំណរគុណ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក. ស. ភ. ដែលដឹកនាំដោយលោក កែវ សុផាណ្ណារ៉ា សូមថ្លែងអំណរគុណចំពោះលោកនាយក លោកប្រធានការិយាល័យ លោកប្រធានសេវាដ្ឋាន និងប្រធានអង្គភាពរួមទាំងសហការី ដែលបានជួយបង្កលក្ខណៈងាយស្រួល សហការផ្តល់ព័ត៌មាន ឯកសារ និងមតិយោបល់មានតម្លៃ ដែលបានជំរុញឱ្យការងារសវនកម្មនេះទទួលបានជោគជ័យ និងតាមពេលវេលា។

## ផ្នែក ខ : លទ្ធផលសវនកម្មលម្អិត

### ១. សមាសភាពចូលរួម

#### ១.១. សមាជិកប្រតិភូសវនកម្ម

នៅក្នុងការងារសវនកម្មនេះថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងសវនកម្មមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក | អ៊ុន ទូច | ប្រធានការិយាល័យសវនកម្មផ្ទៃក្នុង |
| ២. លោកស្រី | រ៉ា ស្រីរ័ត្ន | អនុប្រធានការិយាល័យសវនកម្មផ្ទៃក្នុង |
| ៣. លោក | សូ ស៊ីណារិទ្ធិ | អនុប្រធានការិយាល័យសវនកម្មបច្ចេកវិទ្យាព័ត៌មាន |
| ៤. លោកស្រី | ម៉ាន់ ស្រីអន | ប្រធានផ្នែកការិយាល័យសវនកម្មផ្ទៃក្នុង |
| ៥. លោក | កង វិសុតរិទ្ធ | បុគ្គលិកការិយាល័យសវនកម្មផ្ទៃក្នុង |

#### ១.២. សមាសភាពសវនដ្ឋាន

**ត្រីមាសទី១**

| | | |
|---|---|---|
| ១. លោក | យឹម ជឿន | នាយកប្រតិបត្តិការផែកុងតឺន័រ LM១៧ |
| ២. លោក | អ៊ែ សំណាង | ប្រធានការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ |
| ៣. លោក | មៀច យោធិន្ទ | អនុប្រធានការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ |

៦៥

| | | |
|---|---|---|
| ៤. លោក | ឃុន វុទ្ធី | ប្រធានផ្នែកការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ |
| ៥. លោក | ហេង សុខា | ប្រធានផ្នែកការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ |
| ៦. លោក | ហ៊ឹម ឡា | អនុប្រធានផ្នែកការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ |
| ៧. លោក | ប៉ួយ ការ៉ាវុធ | ប្រធានសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ៨. លោក | ជឹក យិត | អនុប្រធានសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ៩. លោក | យ៉ុង ឡាម៉ូ | អនុប្រធានសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១០. លោក | ឯន ឌីម៉ង់ | អនុប្រធានសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១១. លោក | អ៊ុំ រដ្ឋា | ប្រធានផ្នែកសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១២. លោក | លាង កុសល | ប្រធានផ្នែកសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១៣. លោក | យ៉ាន់ កុល | ប្រធានផ្នែកសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១៤. លោកស្រី | ប្រាក់ ច័ន្ទសិលា | បុគ្គលិកសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១៥. លោក | សួន ឪណាល់ | ជាងម៉ាស៊ីនសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ |
| ១៦. លោក | លឹម វឌ្ឍនា | ប្រធានអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ១៧. លោក | អ៊ុក ស៊ីន | អនុប្រធានអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ១៨. លោក | ចក់ មាន | ប្រធានផ្នែកអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ១៩. លោក | ឡឹក វ៉ាន់ណែន | ប្រធានផ្នែកអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២០. លោក | អ៊ុក ច័ន្ទពេញបូរមី | ប្រធានផ្នែកអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២១. លោកស្រី | មៀច សំប៉ុលីន | បុគ្គលិកអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២២. លោក | រស់ សេង | មេការអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៣. លោក | សួន ឈុយ | មេការអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៤. លោក | ឃឹម មនោ | ប្រធានក្រុមកម្មករអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៥. លោក | សុខ គឹមសេង | ជំនួយការមេការអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៦. លោក | ទូច ស៊ីដែន | ប្រធានក្រុមកម្មករអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៧. លោក | កែវ ស៊ិនតារា | កម្មករអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |
| ២៨. លោក | ឌិន រ៉ាជ | កម្មករសេរីអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ |

**ត្រីមាសទី២**

| | | |
|---|---|---|
| ២៩. លោក | គង់ សុធា | នាយករដ្ឋបាល |

៣០. លោកស្រី ខូវ ចាន់សុម៉ា ប្រធានការិយាល័យរដ្ឋបាល

៣១. លោក កៅ សុគុណា ប្រធានការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera

៣២. លោក កែវ វណ្ណដេត អនុប្រធានការិយាល័យរដ្ឋបាលទទួលបន្ទុកការងារគ្រប់គ្រងរថយន្ត

៣៣. កញ្ញា សេង បុផ្ផា អនុប្រធានការិយាល័យរដ្ឋបាលទទួលបន្ទុកការងារពិធីការ

៣៤. លោក ទិត្យ ចាន់វាសនា អនុប្រធានការិយាល័យរដ្ឋបាលទទួលបន្ទុកការងារនីតិកម្ម

៣៥. លោកស្រី ញៀម ប៉ាភិនី អនុប្រធានការិយាល័យរដ្ឋបាលទទួលបន្ទុកការងារទូទៅ

៣៦. លោក តាន់ ណាងចាន់ អនុប្រធានការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera

៣៧. លោក នៅ ណុយ អនុប្រធានការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera

៣៨. លោកស្រី ឃ្លោក ស៊ីណែត ប្រធានផ្នែកការិយាល័យរដ្ឋបាលទទួលបន្ទុកការងារចំណាយ

៣៩. លោក យ៉ែម ម៉ាប់ ប្រធានផ្នែកការិយាល័យរដ្ឋបាលទទួលបន្ទុកការងារទឹក និងភ្លើង

៤០. លោក អ៊ុក សត្យា ប្រធានផ្នែកការិយាល័យរដ្ឋបាល (LM១៧) ទទួលបន្ទុកការងារទូទៅ

៤១. លោក ខួង អេង ប្រធានផ្នែកការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera (LM១៧)

៤២. លោក ស សុវណ្ណ ប្រធានក្រុមការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera (TS៣)

៤៣. លោក ឃឹម បូរិន បុគ្គលិកការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera (TS៣)

**ត្រីមាសទី៣**

៤៤. លោក ឡុង ឈុនឌី ប្រធានអង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧

៤៥. លោក ទូច សុភ័ក្ត្រ អនុប្រធានអង្គភាព

៤៦. លោក ឡៅ អំម៉ារ៉ុង ប្រធានផ្នែក

៤៧. លោក រឿន រតនៈ ប្រធានផ្នែក

៤៨. អ្នកស្រី ស៊ិន កល្យាណ អនុប្រធានផ្នែក

៤៩. កញ្ញា វង ស្រីលីន បុគ្គលិកការិយាល័យ

៥០. លោក អ៊ួច មុន្នីរ័ត្ន Tally/Weight

៥១. លោក ទឹម សារិន ពិនិត្យទូរ

៥២. លោក ចែម សុភា Yard Planning

៥៣. លោក ឡឿន ច័ន្ទណារ៉េត Vessel Plan/LCL

៥៤. លោក សាន់ លីស៊ីន Reefer/LCL

៥៥. លោក សួង ចំរើន ICD

| | | |
|---|---|---|
| ៥៦. លោក | ធី វិចិត្រ | Gate IN/OUT |
| ៥៧. លោក | ឃុត សារិទ្ធ | General Cargo |
| ៥៨. លោក | ពាង សុធា | VS/TR Tally |
| ៥៩. លោក | សួង សុខា | ពិនិត្យផ្ទេរ |
| ៦០. លោក | ប៉ាង ឡៃហួង | Vessel Plan/LCL |
| ៦១. លោក | សុខ វ៉ាន់ | General Cargo |
| ៦២. លោក | វ៉ាត់ សុម៉ាណាន់ | VS/Tally/weight |
| ៦៣. លោក | ឡឿន រតនា | VS/TR Tally |
| ៦៤. កញ្ញា | វ៉ាង ម៉ាលើន | Gate IN/OUT |
| ៦៥. លោក | ហៃ ម៉ាភិនី | អនុប្រធានអង្គភាពវិក្កយបត្រ LM១៧ |
| ៦៦. លោក | កែន ចំរើង | អនុប្រធានអង្គភាព |
| ៦៧. លោក | យឹម សារុន | ប្រធានផ្នែក |
| ៦៨. លោក | ហើន បញ្ញា | ប្រធានផ្នែក |
| ៦៩. លោក | នូ ស៊ីណែត | ប្រធានផ្នែក |
| ៧០. លោក | ហៀន សុវណ្ណារតន៍ | អនុប្រធានផ្នែក |
| ៧១. លោក | ង៉ី ប៉ុលិន | អនុប្រធានផ្នែក |
| ៧២. លោក | ទៅ គីភ៊ា | អនុប្រធានផ្នែក |
| ៧៣. អ្នកស្រី | ជាម សុភី | បុគ្គលិក |
| ៧៤. លោក | កែវ ប៊ន | បុគ្គលិក |
| ៧៥. លោក | រួន ពិសិដ្ឋ | បុគ្គលិក |

**ត្រីមាសទី៤**

| | | |
|---|---|---|
| ៧៦. លោក | គុណ សុខុម | នាយកសេវាកម្មនាវាចរណ៍ |
| ៧៧. លោក | ច័ន្ទ ចំណា | អនុប្រធានការិយាល័យកណ្ណធារ |
| ៧៨. លោក | នូ វណ្ណៈ | អនុប្រធានការិយាល័យកណ្ណធារ |
| ៧៩. លោក | ស៊ុយ បញ្ញាបុត្រ | អនុប្រធានការិយាល័យកណ្ណធារ |
| ៨០. លោក | លោក ហួត មាន | ប្រធានផ្នែក |
| ៨១. លោក | លោក កៅ ប៊ុនឈឿ | ប្រធានផ្នែក |

៨២.លោក លោក អ៊ុប សំណាង មន្ត្រីលិខិតទទួលការងាររដ្ឋបាល
៨៣.លោក លោក តែម បូណា កណ្ណធារ

## ១.៣. ខណៈគោល

ខាងក្រោមគឺជាខណៈគោលសំខាន់ៗនៅក្នុងដំណើរការសវនកម្មតាមត្រីមាសនីមួយៗមានដូចខាងក្រោម៖

**ត្រីមាសទី១**

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២
- សេចក្តីព្រាងលើកទី១បានបញ្ចប់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២
- របាយការណ៍ស្ថាពរបានបញ្ចប់ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២

**ត្រីមាសទី២**

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២
- សេចក្តីព្រាងលើកទី១បានបញ្ចប់ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២
- របាយការណ៍ស្ថាពរបានបញ្ចប់ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

**ត្រីមាសទី៣**

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២
- សេចក្តីព្រាងលើកទី១បានបញ្ចប់ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២
- របាយការណ៍ស្ថាពរបានបញ្ចប់ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

**ត្រីមាសទី៤**

- ការធ្វើសវនកម្មបានបញ្ចប់ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២
- សេចក្តីព្រាងលើកទី១បានបញ្ចប់ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២
- ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២
- របាយការណ៍ស្ថាពរបានបញ្ចប់ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២

## ២.ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុងគឺជួយថ្នាក់ដឹកនាំធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវដំណើរការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំ និងមន្ត្រីដទៃទៀតដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

-របាយការណ៍សកម្មភាពការងារ និងការផ្ដល់សេវាកម្មផ្នែកលើកដាក់ ដឹកជញ្ជូនកុងតឺន័រគួរឱ្យទុកចិត្ត

-ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសន្សំសំចៃ

-ការអនុវត្តតាមច្បាប់ និងបទដ្ឋាន បទប្បញ្ញត្តិ និងនីតិវិធីជាធរមាននានា។

របាយការណ៍នេះ រួមមានការត្រួតពិនិត្យលើការតាក់តែង និងប្រតិបត្តិការនៃការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម ហើយក៏ពិនិត្យផងដែរលើការរៀបចំ និងប្រព្រឹត្តទៅនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។

## ៣. ពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយធ្វើការពិនិត្យលើសមត្ថភាពនៃដំណើរការគ្រប់គ្រងនីមួយៗដើម្បីសម្រេចឱ្យបានគោលបំណងគ្រប់គ្រងចំនួនប្រាំពីរមាន : ការផ្ដល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព សុវត្ថិភាពរូបវន្ត ការដោះស្រាយកំហុស និងការបែងចែកតួនាទី ។

## ៤. ព័ត៌មានអំពីសវនដ្ឋាន

កំពង់ផែស្វយ័តភ្នំពេញ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ ជាសហគ្រាសសាធារណៈដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន និងអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក. ស. ភ. អនុវត្តសកម្មភាពរបស់ខ្លួនដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស.រកម. ០៦៩៦/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៦ និងលក្ខន្តិកៈបុគ្គលិកនៃកំពង់ផែស្វយ័តភ្នំពេញ ។

ក្នុងសៀវភៅផែនការនាយកដ្ឋានសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២២ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះអនុវត្តសវនកម្មមានដូចខាងក្រោម៖

- នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ មាន៖
  - នាយកប្រតិបត្តិការផែកុងតឺន័រ LM១៧ (ត្រីមាសទី១)
  - អង្គភាពរៀបវេនប្រតិបត្តិការ LM១៧ (ត្រីមាសទី១)
  - អង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ (ត្រីមាសទី៣)
  - អង្គភាពវិក្កយបត្រ LM១៧ (ត្រីមាសទី៣)

- នាយកដ្ឋានគ្រប់គ្រងគ្រឿងចក្រ៖
  - សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ (ត្រីមាសទី១)
- នាយកដ្ឋានរដ្ឋបាល មាន៖
  - នាយកដ្ឋានរដ្ឋបាល (ត្រីមាសទី២)
  - ការិយាល័យរដ្ឋបាល (ត្រីមាសទី២)
  - ការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera (ត្រីមាសទី២)
- នាយកដ្ឋានសេវាកម្មនាវាចរណ៍មាន៖
  - នាយកដ្ឋានសេវាកម្មនាវាចរណ៍ (ត្រីមាសទី៤)
  - ការិយាល័យកណ្ដឹងធារ (ត្រីមាសទី៤)
  - ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ (ត្រីមាសទី១)

ក្នុងនោះមានថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង និយោជិត កម្មករ ទាំង៤ត្រីមាស សរុបចំនួន ២៦៨នាក់ ស្រី ២៣នាក់ បុគ្គលិកជាប់កិច្ចសន្យាចំនួន ១២នាក់ ស្រី ០២នាក់។

**៥.លទ្ធផលសវនកម្ម**

**ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ**

**ត្រីមាសទី១**

**៥.១.១. កង្វះខាតក្នុងការអនុវត្តតួនាទី និងភារកិច្ច**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺពង្រឹងការអនុវត្តតួនាទី និងភារកិច្ច។

តាមការជួបធ្វើសវនកម្មជាមួយប្រធានការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ការពិនិត្យទៅលើរបាយការណ៍ប្រចាំត្រីមាស និងក្នុងតួនាទីភារកិច្ចរបស់ការិយាល័យ សវនករសង្កេតឃើញថា មាន ២ចំណុច ដែលការិយាល័យមិនទាន់បានធ្វើការអនុវត្តនៅឡើយមានដូចជា ៖

- ត្រួតពិនិត្យការងារគ្រប់អង្គភាពទាំងអស់ ដើម្បីវាយតម្លៃពីហានិភ័យ និងធ្វើការកែទម្រង់
- ធ្វើរបាយការណ៍ពីហានិភ័យគ្រប់អង្គភាពទាំងអស់ជូនថ្នាក់ដឹកនាំ និងសុំគោលការណ៍ដើម្បីកែទម្រង់។

ករណីនេះ ពុំទាន់ស្របទៅនិងការអនុវត្តតួនាទីភារកិច្ច របស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ដែលការិយាល័យបានរៀបចំឡើង នៅឡើយទេ ។

កង្វះខាតនេះ កើតឡើងដោយសារ Covid-19 បានកើតមានពីឆ្នាំ២០១៩ ជាលក្ខណៈសកល ។

កត្តានេះ អាចនាំឲ្យដំណើរការនៃការអនុវត្តការងាររបស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ពុំសូវមានប្រសិទ្ធភាព ។

ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ គួរតែអនុវត្តតួនាទី និងភារកិច្ច ឲ្យបានគ្រប់ចំណុចស្រប តាមការរៀបចំ និងប្រព្រឹត្តិទៅតាមតួនាទី និងភារកិច្ចរបស់ការិយាល័យក្រោយពីស្ថានភាពជម្ងឺ Covid-19 បានធូរស្រាល។

ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សូមឯកភាពតាមអនុសាសន៍របស់សវនករបានលើកឡើង ។

សវនកម្មផ្ទៃក្នុងបានឃើញការឆ្លើយតបរបស់សវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍បន្តទៅឆ្នាំក្រោយៗទៀត ។

**៥.១.២. កង្វះខាតឯកសារពាក់ព័ន្ធការងារថែទាំរថស្ទូច RTG**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យ គឺពង្រឹងលើការថែទាំគ្រឿងចក្រជាប្រចាំអោយមានប្រសិទ្ធភាព ជៀសវាងការខូចខាតច្រើន ខាតពេលវេលាផលិតកម្ម និងមានការចំណាយខ្ពស់លើការជួសជុល។

តាមការសាកសួរ និងពិនិត្យសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ ការថែទាំរថស្ទូច RTG មានការពិនិត្យ ១សប្តាហ៍ម្តង គឺរៀងរាល់ថ្ងៃសៅរ៍ជាប្រចាំ ទៅតាមឯកសារណែនាំលើការថែទាំរបស់ក្រុមហ៊ុន Kalmar ដែលជាក្រុមហ៊ុនផ្គត់ផ្គង់រថស្ទូច RTG ។ ការរៀបចំជាកាលវិភាគ និង តារាងត្រួតពិនិត្យ (Check list) ជាមូលដ្ឋាន ក្នុងការពិនិត្យមើលថែទាំតាមដំណាក់កាល និងមានប្រសិទ្ធិភាព ក៏ប៉ុន្តែ សេវាដ្ឋានពុំមានឯកសារអះអាងបញ្ជាក់ច្បាស់លាស់ដូចខាងលើ ដែលឯកសារទាំងនោះជាភស្តុតាងលើការងារថែទាំ និងជាធាតុបញ្ចូលក្នុងរបាយការណ៍ ប្រចាំខែស្តីពីការថែទាំគ្រឿងចក្រជាប្រចាំជូនថ្នាក់លើ។

ករណីនេះ ពុំទាន់ស្របតាមសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ និងឆ្នាំ ។

កង្វះខាតនេះ កើតឡើងដោយសារចន្លោះប្រហោងរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ។

កត្តានេះ អាចនាំឲ្យដំណើរការនៃការអនុវត្តការងារថែទាំគ្រឿងចក្ររបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រពុំទាន់មានឯកសារតាមដានការងារដើម្បីបញ្ចូល ក្នុងរបាយការណ៍ស្តីពីការថែទាំគ្រឿងចក្រ។

សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ គួរតែរៀបចំ និងបញ្ចូលក្នុងរបាយការណ៍ស្តីពីការថែទាំគ្រឿងចក្រជាប្រចាំជូនថ្នាក់ដឹកនាំបានជ្រាប។

ចំពោះកង្វះខាតឯកសារពាក់ព័ន្ធដូចជាកាលវិភាគ និងតារាងត្រួតពិនិត្យ (Check list) ជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍ប្រចាំខែរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ សូមទទួលយកតាមការណែនាំរបស់សវនករ ហើយនឹងធ្វើអោយបានល្អប្រសើរនាពេលខាងមុខ។

សវនករបានឃើញ ការឆ្លើយតបរបស់សេវាដ្ឋាន នឹងបន្តតាមដានការអនុវត្តតាម អនុសាសន៍នាយកដ្ឋានសវនកម្មផ្ទៃក្នុងបន្តទៀត។

**៥.១.៣. កង្វះខាតការរៀបចំបទដ្ឋានបច្ចេកទេសផ្ទុកផុលគ្រឿងចក្រ**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺពង្រឹងលើប្រសិទ្ធភាពការផ្ទុកផុល និងសុវត្ថិភាពក្នុងរោងជាងផ្ទុកផុលគ្រឿងចក្រ។

តាមការចុះពិនិត្យជាក់ស្តែងនៅរោងជាងផ្ទុកផុល សវនករសង្កេតឃើញថា សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ ពុំទាន់មានឧបករណ៍ប៉ុងលើករថយន្ត លើកម៉ាស៊ីន ប្រអប់លេខ និងគ្រឿងបង្គុំគ្រឿងចក្រនៅឡើយ ដោយជាទូទៅប្រើប្រាស់ Elevator លើក ។

ករណីនេះ ពុំទាន់ស្របតាមបទដ្ឋានបច្ចេកទេសផ្ទុកផុលគ្រឿងចក្រ។

កើតឡើងដោយកង្វះខាតរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រដោយពុំបានសហការជាមួយនិងការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ។

កត្តានេះ អាចនាំឲ្យការងារផ្ទុកផុលគ្រឿងចក្រខ្វះប្រសិទ្ធភាព យឺតយូរ និងបង្កគ្រោះថ្នាក់ដល់បុគ្គលិកផ្នែកផ្ទុកផុលរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ ។

សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ គួរតែពិភាក្សាជាមួយការិយាល័យ សុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ក្នុងការធ្វើសំណើសុំរៀបចំប៉ុង និងម៉ាស៊ីនលើកគ្រឿងបង្គុំគ្រឿងចក្រ។

សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ បានឯកភាពតាមអនុសាសន៍របស់ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានលើកឡើងនូវចំណុចខ្វះខាតខាងលើ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងតាមពិនិត្យនូវអនុសាសន៍សវនដ្ឋានបានលើកឡើងខាងលើបន្តទៀត។

**៥.១.៤. អំពីរបាយការណ៍អនុវត្តការងារប្រចាំខែ**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីស្វែងយល់អំពីសកម្មភាពការងារប្រចាំខែរបស់សេវាដ្ឋានបច្ចេកទេស គ្រឿងចក្រ ។

តាមការសាកសួរ និងត្រួតពិនិត្យលើឯកសារជាក់ស្តែង សវនករសង្កេតឃើញថា ការបរិយាយក្នុងរបាយការណ៍ប្រចាំខែរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ មានការបូកទិន្នន័យមិនទាន់ត្រឹមត្រូវដូចជា៖ (របាយការណ៍ខែមករា ឆ្នាំ២០២២ ត្រង់ចំណុច II.១.ការងារប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេង ២.ការងារប្តូរសំបកកង់)។

ករណីនេះ បណ្តាលអោយមានបញ្ហាក្នុងការបូកទិន្នន័យពុំទាន់ច្បាស់លាស់ ។

កង្វះខាតក្នុងការធ្វើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តការងារ ដោយសារ ខ្វះចន្លោះក្នុងការត្រួតពិនិត្យរបស់សវនដ្ឋាន។

កត្តានេះ ធ្វើឱ្យការធ្វើរបាយការណ៍អនុវត្តការងារប្រចាំខែមានភាពពុំទាន់ច្បាស់លាស់ ។

សវនដ្ឋានគួរតែធ្វើការកែលម្អលើការធ្វើរបាយការណ៍ប្រចាំខែអោយបានត្រឹមត្រូវ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប ពីសកម្មភាពការងាររបស់សេវាដ្ឋាន ។

ចំពោះកង្វះខាតក្នុងការធ្វើរបាយការណ៍ប្រចាំខែរបស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ សូមទទួលយកតាមការណែនាំរបស់សវនករ ហើយនឹងធ្វើអោយបានល្អប្រសើរនាពេលខាងមុខ។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ សវនករ នឹងបន្តតាមដានអនុសាសន៍សវនដ្ឋានបន្តទៀតនាពេលខាងមុខ។

**៥.១.៥. ការរៀបចំបែងចែកតួនាទី និងភារកិច្ចរបស់ មន្ត្រី បុគ្គលិកក្នុងសេវាដ្ឋាន**

គោលបំណងនៃការត្រួតពិនិត្យ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ។

តាមការធ្វើសវនកម្ម និងពិនិត្យឯកសារ សវនករសង្កេតឃើញថា សេវាដ្ឋាននៅពុំទាន់បានធ្វើបច្ចុប្បន្នភាពរៀបចំបែងចែក ការកំណត់តួនាទី និងភារកិច្ច របស់ មន្ត្រី បុគ្គលិក នៅក្នុងសេវាដ្ឋាននៅឡើយ ។

ករណីនេះ ធ្វើឲ្យការអនុវត្តការងារ ពុំសូវទទួលបានប្រសិទ្ធភាព ។

កង្វះខាតនេះកើតឡើងដោយសារ ចន្លោះប្រហោងរបស់ សវនដ្ឋាន ។

កត្តានេះ ធ្វើអោយប៉ះពាល់ដល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ មន្ត្រី បុគ្គលិក ក្នុងភារកិច្ចរបស់ខ្លួនត្រូវអនុវត្តតាមមុខងារនិងតួនាទី។

សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ គួរតែរៀបចំបែងចែកការកំណត់តួនាទី និងភារកិច្ច របស់មន្ត្រី បុគ្គលិកក្នុងសេវាដ្ឋាន ដើម្បីឲ្យមានភាពទទួលខុសត្រូវក្នុងការអនុវត្តការងារ ។

សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ សូមឯកភាព និងអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

សវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តពិនិត្យការអនុវត្តអនុសាសន៍នេះបន្តទៀត ។

**ត្រីមាសទី២**

**៥.២.១. កង្វះខាតក្នុងការគ្រប់គ្រងលើការងារថែទាំសោភ័ណភាពទូទៅ និងអនាម័យ នៅអាគាររដ្ឋបាលចំណតផែគុងតឺន័រ LM១៧**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីពង្រឹងការងាររដ្ឋបាលទូទៅ របស់ការិយាល័យរដ្ឋបាល។

សវនករបានពិនិត្យ និងសង្កេតឃើញថា បន្ទប់អនាម័យនៅអាគារចំណតផែគុងតឺន័រLM១៧ មានសភាពចាស់។

ករណីនេះនៅមានខ្វះចន្លោះ ក្នុងការងារគ្រប់គ្រងលើសោភ័ណភាពបន្ទប់ទឹកអនាម័យនៅអាគាររដ្ឋបាល

ចំណតផែកុងតឺន័រLM១៧ ដែលជាទីតាំងទទួលបដិសណ្ឋារកិច្ច និងទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិញឹកញាប់។

កង្វះខាតនេះ ដោយសារការប្រើប្រាស់មានរយៈពេលយូរ។

កត្តានេះ បណ្តាលមកពីកង្វះខាតក្នុងការជួសជុល និងផ្លាស់ប្តូរសម្ភារបន្ទប់ទឹក។

ការិយាល័យរដ្ឋបាល គួរតែរៀបចំស្នើសុំជួសជុលតាមរយៈការធ្វើផែនការប្រចាំឆ្នាំទៅថ្នាក់ដឹកនាំ។

ការិយាល័យរដ្ឋបាល បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យរដ្ឋបាល ទៅឆ្នាំបន្ទាប់ទៀត។

**៥.២.២. កង្វះខាតក្នុងការផ្គត់ផ្គង់សម្ភារជួសជុលអគ្គីសនី និងទឹកក្នុង ក. ស. ភ.**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីស្វែងយល់អំពីសកម្មភាពថែទាំ និងជួសជុលក្នុង ក.ស.ភ.។

តាមការសាកសួរដោយផ្ទាល់លើអ្នកទទួលបន្ទុកថែទាំ និងជួសជុលបច្ចេកទេសអគ្គីសនី និងទឹក សវនករបានពិនិត្យនិងសង្កេតឃើញថា ផ្នែកនេះមិនមានស្តុកទុកនូវសម្ភារសម្រាប់ជួសជុល ដូចជា អំពូលភ្លើង ក្បាលដំ ក្បាលរាក់ស្អាតទឹក ។ល។ ពេលមានតម្រូវការធ្វើការផ្លាស់ប្តូរ អ្នកទទួលបន្ទុកថែទាំ និងជួសជុលបច្ចេកទេសអគ្គីសនី និងទឹក ត្រូវចំណាយទិញមុនដើម្បីធ្វើការផ្លាស់ប្តូរ បន្ទាប់មកទើបធ្វើជាសំណើសុំតាមក្រោយ។

ករណីនេះធ្វើអោយអ្នកទទួលបន្ទុកថែទាំ និងជួសជុលបច្ចេកទេសអគ្គីសនី និងទឹក ជួបភាពលំបាកដោយមិនមានសម្ភារស្តុកទុកក្នុងឃ្លាំង។

ចំណុចនេះ កើតឡើងដោយកង្វះខាតគំរោងផែនការសម្ភារជួសជុលអគ្គីសនី និងទឹក។

កត្តានេះ បណ្តាលអោយការងារជួសជុលថែទាំជួបផលវិបាក។

ការិយាល័យរដ្ឋបាល គួរតែធ្វើការរៀបចំ និងធ្វើជាគំរោងផែនការសម្រាប់ចំណាយលើការទិញសម្ភារដែលចាំបាច់សម្រាប់ជួសជុល។

ការិយាល័យរដ្ឋបាល បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។ ការិយាល័យរដ្ឋបាលបានរៀបចំសំណើសុំ និងទទួលបានចំណារឯកភាពពី **ឯកឧត្តមប្រតិភូ** លើករណីនេះរួចរាល់សម្រាប់ឆ្នាំ២០២៣ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យរដ្ឋបាល ទៅឆ្នាំបន្ទាប់ទៀត។

**៥.២.៣. អំពីរបាយការណ៍ស្ថានភាព CCTV Camera នៅចំណតផែកុងតឺន័រ LM១៧**

**គោលបំណងសវនកម្ម** ៖ បង្កើនសុវត្ថិភាពការការពាររបស់ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅចំណតផែកុងតឺន័រ LM១៧។

សវនករបានពិនិត្យ និងសាកសួរឃើញថា ការបកស្រាយរបាយការណ៍ពីស្ថានភាព CCTV Camera ពីខែមករា ដល់ខែសីហា ឆ្នាំ២០២២ នៅចំណតផែកុងតឺន័រ LM១៧ មានខ្លឹមសារដូចខាងក្រោម៖

១-<u>កាមេរ៉ាច្រកចូលផែ</u>: មាន២៤គ្រាប់ ២គ្រាប់ មើលអត់ឃើញ និង៤គ្រាប់ទៀតមើលអត់ច្បាស់

២-<u>កាមេរ៉ាទីលានចាស់</u>: មាន១៥គ្រាប់ មានបញ្ហា ផ្ញើសជុលហើយ ៨គ្រាប់ និងតម្លើងថ្មី២១គ្រាប់ ដំណើរការធម្មតា តាមរបាយការណ៍ខែសីហា កាមេរ៉ា ៨គ្រាប់ដែលផ្ញើសជុលហើយ បានខូច ២គ្រាប់វិញ និង២១គ្រាប់តម្លើងថ្មី បានខូច ៨គ្រាប់។ មានតែ១៣គ្រាប់ទេដំណើរការ

៣-<u>កាមេរ៉ាអគាររដ្ឋបាល</u>: មាន១២គ្រាប់ ខូច ១គ្រាប់

៤-<u>កាមេរ៉ាទីលានថ្មី</u>: មានចំនួន ៦គ្រាប់ដំណើរការធម្មតាដែលតម្លើងដោយក្រុមហ៊ុនចិន។

ដូចនេះ កាមេរ៉ានៅចំណតផែកុងតឺន័រ LM១៧ សរុបចំនួន ៧៨គ្រាប់: ១៣គ្រាប់ ខូចមិនដំណើរការ និងមើលមិនច្បាស់ចំនួន ៤គ្រាប់។

ករណីនេះ ធ្វើឱ្យការត្រួតពិនិត្យសុវត្ថិភាពតាមប្រព័ន្ធ CCTV Camera ចេញពីបន្ទប់ត្រួតពិនិត្យមិនទាន់ទទួលបានគ្រប់គ្រាន់ពីស្ថានភាពសន្តិសុខគ្រប់ជ្រុងជ្រោយក្នុងបរិវេណចំណតផែកុងតឺន័រ LM១៧ ដែលអាចកើតមានឡើងគ្រប់ពេលវេលា។

ការិយាល័យ បានធ្វើការស្នើសុំរៀងរាល់ខែ តែគ្មានដំណោះស្រាយ។

កត្តានេះ បណ្តាលមកពីកង្វះខាតមិនបានបញ្ចូលរបាយការណ៍ស្ថានភាព CCTV Camera ក្នុងរបាយការណ៍ប្រចាំខែរបស់ការិយាល័យ។

ការិយាល័យ សន្តិសុខ/ប្រព័ន្ធ CCTV Camera ត្រូវតែលើកជាសំណូមពរស្តីពីស្ថានភាព CCTV Camera ដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំខែដើម្បីដាក់ជូនផ្នែកពាក់ព័ន្ធ និងថ្នាក់ដឹកនាំបានជ្រាបពីបញ្ហានេះ ដើម្បីមានដំណោះស្រាយបន្ទាន់។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera ទៅឆ្នាំបន្ទាប់ទៀត ។

**៥.២.៤. អំពីការចុះលេខស្ទួនគ្នា និងមិនចុះហត្ថលេខាលើបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភពី LOLO SCAN**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីពង្រឹងការងារដល់មន្ត្រីទទួលបន្ទុក។

សវនករបានពិនិត្យ និងសង្កេតឃើញថា លើបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភពី LOLO SCAN របស់ការិយាល័យ/ប្រព័ន្ធ CCTV Camera មានចំណុចមួយចំនួនដូចខាងក្រោម៖

- ការចុះលេខស្ទួនគ្នា ដូចជាលេខ(០៦/២២ស.ស) សម្រាប់ខែមិថុនា-កក្កដា និងខែសីហា ឆ្នាំ២០២២
- មិនមានចុះហត្ថលេខារបស់ប្រធានការិយាល័យសម្រាប់ខែមករា និងកុម្ភៈ ឆ្នាំ២០២២។

ករណីនេះធ្វើឲរាយខុសនីតិវិធីបែបបទរដ្ឋបាល។

- ការចុះលេខស្ទួនគ្នាក្នុងបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភបានធ្វើឡើងតាមប្រព័ន្ធកុំព្យូទ័រ ជាហេតុធ្វើឱ្យមន្ត្រីទទួលបន្ទុកការងារមិនបានត្រួតពិនិត្យឱ្យបានច្បាស់មុនដាក់ជូនប្រធានការិយាល័យចុះហត្ថលេខា។
- មិនមានចុះហត្ថលេខារបស់ប្រធានការិយាល័យលើបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភ មកពីមន្ត្រីទទួលបន្ទុកការងារមិនបានរៀបចំទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ។

កត្តានេះ បណ្តាលមកពីការធ្វេសប្រហែស របស់មន្ត្រីទទួលបន្ទុកការងារ។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែត្រួតពិនិត្យលើបញ្ជីរាយនាមសន្តិសុខទទួលប្រាក់ឧបត្ថម្ភ ឱ្យបានត្រឹមត្រូវមុនដាក់ជូនប្រធានការិយាល័យចុះហត្ថលេខា ព្រមទាំងថតចម្លងឯកសារច្បាប់ដើម និងរក្សាទុកឱ្យបានត្រឹមត្រូវមុននឹងបញ្ជូនឯកសារចេញទៅអង្គភាព ឬនាយកដ្ឋានដែលពាក់ព័ន្ធ។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅឆ្នាំបន្ទាប់ទៀត។

**ត្រីមាសទី៣**

**៥.៣.១. អំពីការចារលើលិខិតស្នើសុំទូរកុងតឺន័រចូលស្តុក និងដំណើរការខុសគណនីយភាព (Unaccountability) ក្នុងប្រព័ន្ធ Terminal Operating System (TOS) ក្នុងនីតិវិធីបញ្ចូល ទិន្នន័យទូកុងតឺន័រដែលត្រូវប្រើប្រាស់រថយន្ត ក. ស. ភ. ដើម្បីធ្វើ LOLO Scan។**

**គោលបំណងសវនកម្ម៖** គោលបំណងសវនកម្ម គឺបង្កើនប្រសិទ្ធភាពឱ្យកាន់តែប្រសើរ នៃនីតិវិធីគ្រប់គ្រងទិន្នន័យទូកុងតឺន័រដែលត្រូវប្រើប្រាស់រថយន្ត ក. ស. ភ. ដើម្បីធ្វើ LOLO Scan តាមប្រព័ន្ធ TOS។

តាមការពិនិត្យ និងសាកសួរ សវនករសង្កេតឃើញថា អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ មានការ

ចារលើលិខិតស្នើសុំខ្សែកុងតឺន័រចូលស្តុក (ជាលិខិតពុំមានទម្រង់ផ្លូវការ) ដែលលិខិតនេះ ជានីតិវិធីដល់អតិថិជនក្នុងការជូនដំណឹងដល់មេការ និងអង្គភាពវិក្កយបត្រ LM១៧ ចំពោះខ្សែកុងតឺន័រដែលត្រូវចូលស្តុកក្នុងរោងស្តុក ។

ករណីនេះ ធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធ TOS ពុំទាន់មានប្រសិទ្ធភាពដោយនៅផ្អែកលើឯកសាររឹង (ជាលិខិតពុំមានទម្រង់ផ្លូវការ) និងពុំទាន់បានអនុវត្តការប្រើប្រាស់ប្រព័ន្ធ TOS តាមមុខងារឱ្យបានត្រឹមត្រូវ ជាពិសេសខ្វះការ Booking ពីខាងអតិថិជន (Unaccountability) ដែលអាចបង្កឱ្យមានការខ្វះទំនួលខុសត្រូវ និងភាពយឺតយូរ។

កង្វះខាតនេះ បណ្តាលមកពីការរៀបចំនីតិវិធីការងាររវាងអង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ និងអង្គភាពពាក់ព័ន្ធលើកង្វះខាតរបស់ប្រព័ន្ធ TOS និងតម្រូវការប្រើប្រាស់ក្នុងប្រព័ន្ធ។

កត្តានេះ នាំឲ្យការអនុវត្តការងារពុំទាន់មានប្រសិទ្ធិភាព ។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរតែសិក្សាឡើងវិញជាមួយអង្គភាព និងការិយាល័យពាក់ព័ន្ធដើម្បីពិភាក្សាលើការជម្រុញឱ្យអតិថិជនជាអ្នកធ្វើការ Booking ក្នុងមុខងាររបស់ប្រព័ន្ធ TOS ដើម្បីធ្វើ LOLO Scan ហើយអង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ជាអ្នកបញ្ជាក់ភាពត្រឹមត្រូវ (Confirm) រីឯមេការជាអ្នកកត់ចំណាំទិន្នន័យ (Remark) រាល់ខ្សែកុងតឺន័រដែលប្រើប្រាស់រថយន្ត ក. ស. ភ. តាមរយៈឧបករណ៍ RDT និងអង្គភាពវិក្កយបត្រជាអ្នកគណនាថ្លៃ LOLO Scan រួចពិនិត្យផ្ទៀងផ្ទាត់ និងអនុម័តឱ្យធ្វើការបង្កើតវិក្កយបត្រតាមព័ត៌មាន និងទិន្នន័យតាមលំដាប់លំដោយនៃនីតិវិធីនៅក្នុងប្រព័ន្ធ TOS ។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

សវនករបានឃើញ ការឆ្លើយតបរបស់សេវាដ្ឋាន នឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍នាយកដ្ឋានសវនកម្មផ្ទៃក្នុងបន្តទៀត។

**៥.៣.២. អំពីទំនិញគ្រោះថ្នាក់និងការរក្សាទុកកុងតឺន័រដែលនៅយូរក្នុងចំណតផែ LM១៧**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការពិនិត្យអង្កេតគឺដើម្បីកុំឱ្យមានឧបទ្ទវហេតុណាមួយកើតមានឡើងជាយថាហេតុ និងប៉ះពាល់ដល់ប្រាក់ចំណូល ក.ស.ភ. ទៀតផង។

សវនករ បានពិនិត្យ និងសង្កេតឃើញថា មានទំនិញគ្រោះថ្នាក់និងទំនិញដែលអតិថិជនបានបោះបង់ចោលមួយចំនួនដែលរក្សាទុកក្នុងទីលានជាយូរមកហើយ។

ករណីនេះ ស្របពេលរាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់លេខ ០៨ សសរ ចុះថ្ងៃសុក្រ ៦កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ ដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានដូចជា៖

- សិក្សាស្រាវជ្រាវនិងលើកយោបល់ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់
- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់ឱ្យបានគ្រប់ជ្រុងជ្រោយ មានតម្លាភាពនិងប្រសិទ្ធិភាពក្នុងការអនុវត្តដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងម្រេច។
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។
- ទំនិញដែលអតិថិជនបានបោះបង់ចោលជាយូរមកហើយ។

កត្តានេះ ធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលដែលអតិថិជនមិនបានបង់ចូល ក.ស.ភ. និងអាចមានឧបទ្ទវហេតុណាមួយកើតឡើងជាយថាហេតុ។ ម្យ៉ាងទៀត ក.ស.ភ. ក៏បានចំណាយថ្លៃដើមលើផ្នែក លើក ដាក់ ដឹកជញ្ជូន និងការរក្សាទុកទៀតផង។

ករណីនេះ ដោយសារពុំទាន់មានច្បាប់គ្រប់គ្រងការនាំចូលនៅទំនិញមានគ្រោះថ្នាក់ដល់អតិថិជន។ ដូចនេះ អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរលើកជាវិធានការ ការពារពីផលប៉ះពាល់ដល់បរិស្ថាន និងប្រាក់ចំណូលមក ក.ស.ភ. ។

ដូចនេះ អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរតែធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ និងរាជធានីមានសមត្ថកិច្ចពាក់ព័ន្ធបានជ្រាបដើម្បីមានជាដំណោះស្រាយផ្សេងៗ ដែលអាចធ្វើបាន ជៀសវាងការកើតឡើងនៅឧប្បត្តិហេតុណាមួយ។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានឃើញការឆ្លើយតបរបស់សវនដ្ឋាន និងបន្តតាមដានអនុសាសន៍តទៅទៀត។

**៥.៣.៣. អំពីការចេញវិក្កយបត្រលើស្តុកទូកុងតឺន័រសម្រាប់នាំចេញ (Storage Export)**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីជំរុញការទូទាត់តាមវិក្កយបត្រឱ្យកាន់តែមានប្រសិទ្ធិភាព។

តាមការពិនិត្យ និងសាកសួរ សវនករសង្កេតឃើញថា អង្គភាពវិក្កយបត្រ LM១៧ នៅតែវាយបញ្ចូលដោយដៃចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ នៅពេលបង្កើតស្តុកសម្រាប់ទូកុងតឺន័រនាំចេញ។

ករណីនេះ ធ្វើឱ្យការអនុវត្តការងារចំពោះស្តុកសម្រាប់កុងតឺន័រនាំចេញ និងប្រព័ន្ធ Terminal Operating System (TOS) នៅខ្វះចន្លោះ។

បញ្ហានេះ បណ្តាលមកពីភាពខ្វះចន្លោះរបស់អង្គភាពវិក្កយបត្រដែលមិនបានស្នើសុំអង្គភាពពាក់ព័ន្ធពិភាក្សារកដំណោះស្រាយ។

កត្តានេះធ្វើឱ្យការធ្វើវិក្កយបត្រមានហានិភ័យទាក់ទិននឹងការបំពេញទិន្នន័យខុស ដូចជាលេខទូកុងតឺន័រ

៦៥

ទំហំកុងតឺន័រ ការទូទាត់ប្រាក់ ដោយសារកង្វះខាតភាពស្វ័យប្រវត្តិនៃប្រព័ន្ធ។

ដូចនេះ សវនដ្ឋានគួរតែសហការជាមួយការិយាល័យ អង្គភាព ដែលពាក់ព័ន្ធក្នុងការងារនេះ ដើម្បីរកដំណោះស្រាយក្នុងការដាក់ឱ្យដើរនូវការទូទាត់វិក្កយបត្រតាមរយៈប្រព័ន្ធ TOS ដើម្បីងាយស្រួលតាមដានដំណើរការទូទាត់វិក្កយបត្រនេះ។

អង្គភាពវិក្កយបត្រ ធ្លាប់បានលើកយកនូវបញ្ហាប្រឈមនៃការផលិតវិក្កយបត្រស្តុក (Storage) ដោយវាយបញ្ចូលដោយដៃចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ក្នុងកិច្ចប្រជុំពិភាក្សាអំពីការធ្វើទំនើបកម្មប្រព័ន្ធ TOS ។ បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសរបស់ ក.ស.ភ. កំពុងធ្វើតេស្តសាកល្បងទៅលើប្រព័ន្ធថ្មី ដែលក្នុងនោះការចាប់ស្តុកសម្រាប់កុងតឺន័រនាំចេញគឺត្រូវធ្វើដោយប្រព័ន្ធជាស្វ័យប្រវត្តិ។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀត ។

**ត្រីមាសទី៤**

**៥.៤.១. អំពីកង្វះមន្ត្រីបំពេញការងារផ្នែកកណ្តូធារ**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីពង្រឹងប្រសិទ្ធភាពការងារ។

តាមការពិនិត្យ និងធ្វើសនវកម្ម ជាមួយលោកនាយកសេវាកម្មនាវាចរណ៍ បានឱ្យដឹងថា បច្ចុប្បន្នមន្ត្រីដែលចុះបំពេញការងារផ្នែកកណ្តូធារមានចំនួន ២៨នាក់ ដែលចំនួននេះនៅពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ ការងារជាក់ស្តែង។

ករណីនេះ ធ្វើឱ្យផ្នែកកណ្តូធារមានភាពលំបាកក្នុងការអនុវត្តការងារ។

បញ្ហានេះ បណ្តាលមកពីកង្វះខាតរបស់នាយកដ្ឋានក្នុងការស្នើសុំបន្ថែមបុគ្គលិកកណ្តូធារ។

កត្តានេះ ធ្វើឱ្យនាយកដ្ឋានសេវាកម្មនាវាចរណ៍ ពុំទាន់ទទួលបានកណ្តូធារគ្រប់គ្រាន់ក្នុងការបំពេញការងារ។

ដូចនេះ នាយកដ្ឋានសេវាកម្មនាវាចរណ៍ គួរលើកជាគម្រោងផែនការប្រចាំឆ្នាំក្នុងការជ្រើសរើសកណ្តូធារបន្ថែម ពីព្រោះនាពេលបច្ចុប្បន្ននេះ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) កំពុងតែអភិវឌ្ឍន៍លើចំណតផែក្នុងស្រុកចំនួន ៤បន្ថែមទៀតនៅតាមដងទន្លេមេគង្គលើគឺ ចំណតផែពហុបំណង UM២ (ទន្លេបិទ) ចំណតផែពហុបំណងUM១ (ព្រែកអញ្ចាញ) ទន្លេមេគង្គក្រោមមានចំណតផែពហុបំណង LM២៦ (ផែកោះរកា) រួមទាំងដងទន្លេសាបមានដូចជា៖ ចំណតផែពហុបំណង TS១១ (គីឡូម៉ែត្រលេខ៦)។

នាយកដ្ឋានសេវាកម្មនាវាចរណ៍ សូមធ្វើការឆ្លើយតប ចំពោះមូលហេតុការកង្វះខាតកណ្តូធារ សម្រាប់បំពេញការងារកណ្តូធារកិច្ច ដោយហេតុថា កន្លងមក កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) យើងមានបញ្ជូនមន្ត្រីបណ្តុះបណ្តាលជំនាញកណ្តូធារ បានបណ្តុះបណ្តាល កណ្តូធារ ចំនួន ២វគ្គ រួចមកហើយ។ ចំពោះវគ្គទី ៣ ដែលមានគម្រោងជ្រើសរើសតាមតម្រូវការ ចំនួន ២៥នាក់ នោះមានការអាក់ខានមិនបានបើកវិញ ដោយសារជម្ងឺកូវីត-១៩។ នៅ

ឆ្នាំ២០២១ វិទ្យាស្ថាននាវាចរណ៍កម្ពុជា Cambodia Maritime Institute (CMI) បានផ្ទេរទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន ក្រោមក្រសួងសាធារណការ និងដឹកជញ្ជូនមក កំពង់ផែស្វយ័តភ្នំពេញ មិនបាន បណ្តុះបណ្តាលសិស្សកណ្តូធារ ទៅតាមតម្រូវការរបស់អង្គភាពបាន។ បច្ចុប្បន្ន មានសិស្សកណ្តូធារនៅវិទ្យាស្ថាន តេជោសែនសារធារណការ និងដឹកជញ្ជូន វគ្គទី១ ជំនាន់ទី១ ចំនួន ៩នាក់ ដែលជាសិស្សកណ្តូធារ ក្រៅពីសិស្ស កណ្តូធាររបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ។ នាយកដ្ឋានសេវាកម្មនាវាចរណ៍ បានធ្វើសំណើសុំឱ្យ ក.ស.ភ. ជួយឧបត្ថម្ភសិស្សកណ្តូធារ ទាំងអស់នោះ ដូចខាង កសស ដែរ និងធ្វើកិច្ចសន្យាដើម្បីនៅពេលបញ្ចប់ការសិក្សាកណ្តូធារ ទាំងនោះនឹងចូលមកបំរើការងារនៅ ក.ស.ភ. តែរហូតមកដល់ពេលនេះមិនទាន់ទទួលបានលទ្ធផលនៅឡើយ។

សំណូមពរ នាយកដ្ឋានបុគ្គលិក និង ធនធានមនុស្ស ពិនិត្យលទ្ធភាពជ្រើសរើសយកសិស្សកណ្តូធារ ជំនាន់ទី១ ទាំង ៩នាក់ ដែលមិនមែនជាសិស្សកណ្តូធារ របស់ កសស និង សិស្សកណ្តូធារ ជំនាន់ទី២ និង ជំនាន់ទី៣ ដើម្បីត្រៀម បំពេញសេចក្តីត្រូវការ របស់ ក.ស.ភ. នៅពេលបច្ចុប្បន្ន និង ពេលខាងមុខ ។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្ត អនុសាសន៍នេះបន្តទៀតតាមផែនការ។

**៥.៤.២. អំពីកង្វះខាតឧបករណ៍វិទ្យុទំនាក់ទំនង Portable Radio Phone សម្រាប់កណ្តូធារ**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។

តាមការពិនិត្យ និងសាកសួរ សវនករសង្កេតឃើញថា ការិយាល័យកណ្តូធារនៅមានការខ្វះខាតឧបករណ៍ វិទ្យុទំនាក់ទំនង Portable Radio Phone។

ករណីនេះ ធ្វើឱ្យការអនុវត្តការងារជាប្រចាំរបស់ការិយាល័យកណ្តូធារនៅមានភាពលំបាក។

បញ្ហានេះ កើតឡើងដោយសារកង្វះខាតការស្នើសុំ និងជម្រុញរបស់សវនដ្ឋាន។

កត្តានេះ អាចធ្វើឱ្យការអនុវត្តការងារមានភាពលំបាក និងមានចន្លោះ ។

ដូចនេះ នាយកដ្ឋាន គួរតែធ្វើសំណើសុំទៅថ្នាក់ដឹកនាំ ក្នុងការពិនិត្យលទ្ធភាពក្នុងការផ្គត់ផ្គង់ឧបករណ៍វិទ្យុ ទំនាក់ទំនង Portable Radio Phone ដើម្បីអាចប្រើប្រាស់បានគ្រប់គ្នាក្នុងការបង្កើនប្រសិទ្ធភាពការងារ និងអនុវត្តការងារ។

នាយកដ្ឋានសេវាកម្មនាវាចរណ៍ សូមធ្វើការឆ្លើយតប ចំពោះឧបករណ៍សម្រាប់ទំនាក់ទំនងបំពេញការងារ កណ្តូធារកិច្ច កន្លងមកយើងប្រើប្រាស់ ICOM VFH/UHF& Repeater ឃើញថាមានការលំបាក ដោយការប្រើប្រាស់ មានរយៈពេលយូរឆ្នាំហើយ ម៉ាស៊ីន Repeater ចាស់ហួសាស៊ី មិនមានគ្រឿងបន្លាស់សម្រាប់ជួសជុល ដែលបណ្តាល ឱ្យប្រើប្រាស់មិនបានល្អ មានការជួសជុលជាញឹកញាប់ ចំណាយថវិកាច្រើន។ បច្ចុប្បន្ន នាយកដ្ឋានបានស្នើសុំ ICOM ប្រភេទថ្មីមួយចំនួន គឺប្រភេទ UHF/4G ដើម្បីប្រើប្រាស់សាកល្បង ឃើញថាមានលក្ខណៈប្រសើរជាង ICOM ប្រភេទមុនៗ អាចទំនាក់ទំនងបានទូទាំងប្រទេស។ ដូចនេះ នាយកដ្ឋាននឹងស្នើសុំបន្ថែម បំពេញសេចក្តីត្រូវការ សម្រាប់

៧៥

ប្រើប្រាស់ដើម្បីនិរន្តភាពការងារគណ្ណនេយ្យការកិច្ច និង នាវាចរណ៍។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀតតាមផែនការ។

**៦.លទ្ធផលសវនកម្ម**

**ផ្នែកអនុលោមភាព**

**ក្រឹមាសទី១**

**៦.១.១. អំពីគម្រោងផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧**

**គោលបំណងសវនកម្ម ៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីស្វែងយល់អំពីការរៀបចំគម្រោងផែនការប្រចាំឆ្នាំ សម្រាប់នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧។

សវនករបានពិនិត្យ និងសង្កេតឃើញថា នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ នៅមិនទាន់បានរៀបចំចងក្រង និងរក្សាទុកបណ្ដុំផែនការប្រចាំឆ្នាំ តាមសេវាដ្ឋាន អង្គភាព ក្រោមឱវាទ នៅឡើយទេ។

ករណីនេះនៅពុំទាន់អនុលោមតាម សំណើសុំនាយកដ្ឋានពាក់ព័ន្ធដើម្បីផ្ដល់ធាតុចូលសម្រាប់ រៀបចំផែនការអាជីវកម្ម សេវាកម្ម ហិរញ្ញវត្ថុ របស់កំពង់ផែស្វយ័តភ្នំពេញ ប្រចាំឆ្នាំ២០២១ លេខ ០២៧ ផស/កសក. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ឱ្យបានទាន់ពេលវេលា។

ការប្រមូលរៀបចំចងក្រង និងរក្សាទុកផែនការប្រចាំឆ្នាំតាម សេវាដ្ឋាន អង្គភាព ក្រោមឱវាទ ពុំទាន់បានសមស្របតាមសំណើសុំខាងលើដោយសារភាពខ្វះចន្លោះនិងកង្វះខាតធនធានមនុស្ស។

កត្តានេះ បណ្ដាលឱ្យមានភាពយឺតយូរដល់ការរៀបចំផែនការប្រចាំឆ្នាំរបស់ ក.ស.ភ. បានចប់សព្វគ្រប់មុនថ្ងៃទី៣០ ខែកញ្ញា តាមកាលកំណត់របស់នាយកដ្ឋានផែនការ/ទីផ្សារ។

នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ត្រូវតែប្រមូលរៀបចំចងក្រង និងរក្សាទុកផែនការ តាមសេវាដ្ឋាន និងអង្គភាពក្រោមឱវាទ ឱ្យបានរួចរាល់មុនកាលកំណត់របស់នាយកដ្ឋានផែនការ/ទីផ្សារ។

នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានអនុសាសន៍របស់នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ទៅឆ្នាំបន្ទាប់ទៀត។

**៦.១.២. ការអនុវត្តគំរោងផែនការឆ្នាំ២០២២ របស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យគឺពង្រឹង និងតាមដានការអនុវត្តការធ្វើរបាយការណ៍

២៥

ប្រចាំឆ្នាំ។

សវនករសង្កេតឃើញថា គិតមកដល់បច្ចុប្បន្ន ការអនុវត្តតាមគំរោងផែនការពុំទាន់បាន៥០%នៅឡើយ។

ករណីនេះ យោងលើផែនការរបស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ លេខ 01A/ស.ស.ប និងយោងលើការឆ្លើយតបរបស់ប្រធានការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ បានអនុវត្តបានគំរោងដូចខាងក្រោម៖

- ចំណុចទី១០ ស្នើសុំទិញឧបករណ៍ប្រមូលប្រេង
- ចំណុចទី១៣ ស្នើសុំរទេះរុញសំរាម
- ចំនុចទី១៤ ស្នើសុំម៉ាស៊ីនកាត់ស្មៅធន់តូច ។

មូលហេតុនៃការអនុវត្តផែនការមិនទាន់បាន៥០%នៃគម្រោងផែនការរបស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ដោយសារខ្វះធនធានមនុស្សផ្នែកបរិស្ថាន និងដោយសារស្ថានភាពCovid-19 នេះបន្តអូសបន្លាយតាំងពីឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន។

កត្តានេះ អាចនាំរោយដំណើរការអនុវត្តការងារផែនការរបស់ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ពុំទាន់បានតាមផែនការគ្រោងទុក។

សវនករបានពិនិត្យ និងសាកសួរឃើញថា សវនដ្ឋានគួរពន្លឿនការងារដែលនៅមិនទាន់បំពេញដើម្បីឱ្យស្របតាមផែនការប្រចាំឆ្នាំដែលបានស្នើសុំរួចរាល់។

ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានឃើញការឆ្លើយតបរបស់សវនដ្ឋាន និងបន្តតាមដានតទៅទៀត។

**៦.១.៣. អំពីរបាយការណ៍ប្រចាំឆ្នាំ**

**គោលបំណងសវនកម្ម** ៖ គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីស្វែងយល់អំពីសកម្មភាពការងារប្រចាំឆ្នាំរបស់អង្គភាពរៀបវេនប្រតិបត្តិការ LM១៧ ។

តាមការសាកសួរ សវនករសង្កេតឃើញថា អង្គភាពរៀបវេនប្រតិបត្តិការ LM១៧ មិនបានបូកសរុបធ្វើរបាយការណ៍ប្រចាំឆ្នាំ។

ករណីនេះមិនបានអនុវត្តតាមសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ និងឆ្នាំ ។

កង្វះខាតក្នុងការធ្វើរបាយការណ៍ប្រចាំឆ្នាំកើតឡើងដោយសារខ្វះចន្លោះក្នុងការត្រួតពិនិត្យ។

កត្តានេះ ធ្វើឱ្យការអនុវត្តតួនាទី និងភារកិច្ចរបស់អង្គភាព នៅមានកង្វះខាត ។

សវនដ្ឋាន គួរតែធ្វើរបាយការណ៍ ឬកសរុបសកម្មភាពការងារប្រចាំឆ្នាំ ដើម្បីជាក់ជូនថ្នាក់ដឹកនាំពិនិត្យ និង ជ្រាបពីសកម្មភាពការងារផ្សេងៗរបស់អង្គភាព ។

អង្គភាពរៀបចំផែនប្រតិបត្តិការផែ LM១៧ នឹងរៀបចំឬកសរុបនូវរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំឱ្យបាន ល្អប្រសើរ ។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍ នេះបន្តទៀត ។

**៦.១.៤. រកឃើញកង្វះខាតលើការរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសគ្រឿងចក្រ កំណត់ការផ្លាស់ប្តូរប្រេង និងតម្រងប្រេង របស់រថយន្ត និងគ្រឿងចក្រ ឲ្យស្របតាមបែបបទរដ្ឋបាល**

**គោលបំណងសវនកម្ម** ៖ គោលបំណងសវនកម្ម ដើម្បីឲ្យការចងក្រងសៀវភៅ ស្របតាមបែបបទរដ្ឋបាល ។

តាមការពិនិត្យឯកសារ និងជួបធ្វើសវនកម្មផ្ទាល់ជាមួយសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ សវនករសង្កេតឃើញថា សវនដ្ឋានបានរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេស ក្នុងការកំណត់ការផ្លាស់ប្តូរប្រេង តម្រងប្រេង របស់រថយន្ត និងគ្រឿងចក្រ។ ប៉ុន្តែពុំទាន់ស្របតាមបែបបទរដ្ឋបាល ដោយពុំទាន់បានដាក់ជូន អគ្គនាយករងបច្ចេកទេស ពិនិត្យ កែសម្រួល និងចុះហត្ថលេខាប្រើប្រាស់ជាផ្លូវការ ។

ករណីនេះ ធ្វើឲ្យការចងក្រងសៀវភៅពុំទាន់បានអនុលោមតាមបែបបទរដ្ឋបាល ។

កង្វះខាតនេះ កើតឡើងដោយសារកង្វះខាត របស់សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ ។

កត្តានេះ អាចបណ្តាលឲ្យមានការភ័ន្តច្រឡំលើពេលវេលានៃការប្តូរប្រេង និងតម្រងប្រេងម៉ាស៊ីនរថយន្ត និង គ្រឿងចក្រនាពេលណាមួយ។

សវនដ្ឋាន គួរតែរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសគ្រឿងចក្រ កំណត់ការត្រូវផ្លាស់ប្តូរប្រេង តម្រង ប្រេងម៉ាស៊ីន ឱ្យស្របទៅតាមបែបបទរដ្ឋបាល ដើម្បីអាចយកមកប្រើប្រាស់ជាផ្លូវការ ដើម្បីឱ្យរថយន្ត និងគ្រឿងចក្រ ពុំសូវមានបញ្ហាផ្នែកម៉ាស៊ីន និងប្រព័ន្ធផ្សេងៗ ដើម្បីការប្រើប្រាស់បានយូរអង្វែង។

ចំពោះកង្វះខាតក្នុងការរៀបចំចងក្រងសៀវភៅបទដ្ឋានបច្ចេកទេសគ្រឿងចក្រ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ សូមទទួលយកតាមការណែនាំរបស់សវនករនឹងបន្តអនុវត្តតាមអនុសាសន៍របស់សវនកម្មនៅពេលខាងមុខឲ្យបានល្អ ប្រសើរ។

សវនករបានឃើញ ការឆ្លើយតបរបស់សេវាដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តតាម អនុសាសន៍សវនកម្មបន្តទៀត។

**ត្រីមាសទី២**

**៦.២.១. អំពីរបាយការណ៍ចំណាយប្រចាំខែ**

**គោលបំណងសវនកម្ម** ៖ គោលបំណងសវនកម្ម គឺបង្កើនប្រសិទ្ធភាព នៃការធ្វើរបាយការណ៍ឱ្យបានទាន់ពេលវេលា ។

តាមការពិនិត្យ លើរបាយការណ៍ចំណាយប្រចាំខែ របស់ការិយាល័យរដ្ឋបាល ឃើញថាចំពោះរបាយការណ៍ចំណាយប្រចាំខែមានភាពយឺតយ៉ាវ ភាគច្រើនបញ្ចប់នៅសប្តាហ៍ទី២ នៃខែបន្ទាប់ ។

ករណីនេះ ពុំទាន់បានអនុលោមតាមសេចក្តីណែនាំលេខ១២២៥ ក.ស.ភ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់ ក. ស. ភ. ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែសំដៅដល់ការធ្វើរបាយការណ៍ប្រចាំខែឱ្យបានរួចរាល់យ៉ាងយូរត្រឹមសប្តាហ៍ទី១ នៃខែបន្ទាប់ ។

កង្វះខាតក្នុងការធ្វើរបាយការណ៍ចំណាយប្រចាំខែ កើតឡើងដោយសារភាពយឺតយូរ របស់អ្នកអនុវត្តការងារ ។

កត្តានេះ បណ្តាលឱ្យរបាយការណ៍ចំណាយប្រចាំខែមិនទាន់ពេលវេលា ។

ដូចនេះការិយាល័យរដ្ឋបាល គួររៀបចំធ្វើរបាយការណ៍ចំណាយប្រចាំខែ ឱ្យបានទៀងទាត់ និងស្របតាមសេចក្តីណែនាំ លេខ ១២២៥ របស់ ក.ស.ភ. ដើម្បីបង្កើន ប្រសិទ្ធភាពការងារ ។

ការិយាល័យរដ្ឋបាល បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យរដ្ឋបាល ទៅឆ្នាំបន្ទាប់ទៀត។

**៦.២.២. កង្វះខាតនីតិវិធីក្នុងការគ្រប់គ្រងរថយន្តប្រើប្រាស់របស់ការិយាល័យរដ្ឋបាល**

**គោលបំណងសវនកម្ម** ៖ គោលបំណងសវនកម្ម គឺបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងរថយន្តរដ្ឋបាលឱ្យកាន់តែប្រសើរ ។

តាមការពិនិត្យ និងសាកសួរឃើញថា ការិយាល័យរដ្ឋបាលមានភារកិច្ចលើការងារគ្រប់គ្រងពិនិត្យ តាមដាន និងរៀបចំរថយន្តរដ្ឋបាលសម្រាប់ដឹកជញ្ជូនបុគ្គលិកដែលត្រូវបំពេញបេសកកម្មនៅខាងក្រៅផែ និងភ្ញៀវរបស់ ក. ស. ភ. ។ ការតាមដានរថយន្តគឺអ្នកបើកបររថយន្តនីមួយៗ ជាអ្នកពិនិត្យមើលជាប្រចាំ និងរាយការណ៍ដោយផ្ទាល់មាត់ទៅថ្នាក់គ្រប់គ្រងដូចជា ការខូចខាតផ្នែកគ្រឿងបន្លាស់ណាមួយ ប្រេងម៉ាស៊ីន សំបកកង់ ប្រេងហ្វ្រាំង ទឹកស្អំ និងកង្វះខាតផ្សេងៗ របស់រថយន្ត ។

ករណីនេះ ធ្វើឱ្យការងារគ្រប់គ្រងរថយន្តពុំទាន់ស្របតាមលក្ខណៈបច្ចេកទេស និងពុំបានអនុលោមតាមសេចក្តីណែនាំលេខ១២២៥ ក.ស.ភ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់ ក.ស.ភ. ស្តីពីរបៀបការធ្វើរបាយការណ៍ជា

ប្រចាំ ពីថ្នាក់ក្រោមទៅថ្នាក់ដឹកនាំអង្គភាព ដើម្បីអាចក្ដាប់បានការគ្រប់គ្រងការងារ និងលើកទិសដៅឱ្យថ្នាក់ក្រោមអនុវត្តតាម។

កង្វះខាតនេះ ធ្វើឱ្យការតាមដាន និងពិនិត្យរថយន្តបន្ទាប់ពីប្រើប្រាស់ហើយមិនទាន់គ្រប់ជ្រុងជ្រោយ ។

កត្តានេះ អាចនាំឱ្យការអនុវត្តការងារមានភាពខ្វះចន្លោះ ។

ការិយាល័យរដ្ឋបាល គួររៀបចំធ្វើជាសៀវភៅតាមដានថែទាំរថយន្តដូចជា៖ ពិនិត្យប្រវត្តិការខូចខាត ការប្ដូរប្រេងម៉ាស៊ីន សំបកកង់ ប្រេងហ្វ្រាំង ទឹកស្អំ និងកង្វះខាតផ្សេងៗទៀតរបស់រថយន្ត និងធ្វើរបាយការណ៍ប្រៀបធៀបប្រចាំខែជូនថ្នាក់ដឹកនាំ ឱ្យបានទៀងទាត់ដើម្បីបង្កើនប្រសិទ្ធភាពការតាមដានពិនិត្យរថយន្តជាប់ជាប្រចាំ។

ចំពោះកង្វះខាតឯកសារដូចជាសៀវភៅតាមដានថែទាំរថយន្ត និងរបាយការណ៍ប្រៀបធៀបប្រចាំខែផ្នែករថយន្តរដ្ឋបាល ការិយាល័យរដ្ឋបាល សូមទទួលយកតាមការណែនាំរបស់សវនករ ហើយនឹងធ្វើឱ្យបានល្អប្រសើរនាពេលខាងមុខ។

សវនករបានឃើញ ការឆ្លើយតបរបស់សេវាដ្ឋាន នឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍នាយកដ្ឋានសវនកម្មផ្ទៃក្នុងបន្តទៀត។

**៦.២.៣. អំពីការខ្វះចន្លោះមន្ត្រីក្នុងរចនាសម្ព័ន្ធការិយាល័យសន្តិសុខ /ប្រព័ន្ធ CCTV Camera**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យ គឺដើម្បីពង្រឹងរចនាសម្ពន្ធ័ ក្នុងការិយាល័យសន្តិសុខ /ប្រព័ន្ធCCTV Camera។

សវនករបានពិនិត្យ និងសង្កេតឃើញថាការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera មិនទាន់បានធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរបស់ការិយាល័យនៅឡើយ ។

ករណីនេះ នៅមានខ្វះចន្លោះក្នុងរចនាសម្ពន្ធ័ការិយាល័យសន្តិសុខ/ប្រព័ន្ធCCTV Camera (មិនទាន់មានអនុប្រធានផ្នែកសណ្ដាប់ធ្នាប់)។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅមានកង្វះខាតអ្នកបំពេញតួនាទី។

កត្តានេះ បណ្ដាលមកពីកង្វះខាតមន្ត្រីទទួលបន្ទុកការងារ។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែរៀបចំស្នើសុំបុគ្គលិកតាមរយៈការធ្វើផែនការប្រចាំឆ្នាំទៅថ្នាក់ដឹកនាំដើម្បីបំពេញចន្លោះខ្វះខាត។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅឆ្នាំបន្ទាប់ទៀត។

**៦.២.៤. អំពីកង្វះខាតក្នុងការកំណត់អត្តសញ្ញាណអ្នកបើកបររថយន្តដឹកទំនិញចូល-ចេញ ក្នុងបរិវេណប្រតិបត្តិការចំណតផែរបស់ ក. ស. ភ.**

**គោលបំណងសវនកម្ម ៖** គោលបំណង ដើម្បីពង្រឹងសុវត្ថិភាពនៅក្នុងតំបន់បរិវេណប្រតិបត្តិការ របស់ ក. ស. ភ.។

តាមការសាកសួរ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានឱ្យដឹងថាគឺពុំទាន់បានធ្វើការកំណត់អត្តសញ្ញាណលើអ្នកបើកបររថយន្តដឹកទំនិញ ចូល-ចេញក្នុងបរិវេណប្រតិបត្តិការរបស់ ក.ស.ភ. នៅឡើយទេ ។

ករណីនេះ គឺពុំទាន់ស្របទៅនឹងតួនាទីភារកិច្ចរបស់ការិយាល័យសន្តិសុខប្រព័ន្ធ/CCTV Camera ត្រង់ចំណុចទី១ ស្តីពីការទទួលខុសត្រូវលើកិច្ចការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ទូទៅ សណ្តាប់ធ្នាប់ចំណតរថយន្តចរាចរណ៍ក្នុងបរិវេណ ក. ស. ភ. ចុះថ្ងៃចន្ទ ៧រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ។

កង្វះខាតក្នុងការកំណត់អត្តសញ្ញាណ អ្នកបើកបររថយន្តដឹកទំនិញចូល-ចេញ ។

កត្តានេះ អាចបណ្តាលឱ្យមានការលំបាកក្នុងការស្វែងរកមុខសញ្ញាប្រសិនបើកើតឡើងនូវ ឧបទ្ទវហេតុចៃដន្យដោយប្រការណាមួយដែលបង្កឡើងដោយអ្នកបើកបររថយន្តទាំងនោះ ។

ការិយាល័យ សន្តិសុខ/ប្រព័ន្ធ CCTV Camera គួរសហការជាមួយបណ្តានាយកដ្ឋានដែលមានទិន្នន័យពាក់ព័ន្ធនិងក្រុមហ៊ុននានា ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ អ្នកបើកបររថយន្តចូល-ចេញ ក្នុងបរិវេណប្រតិបត្តិការចំណតផែ របស់ ក.ស.ភ. ។

ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានឯកភាពតាមការលើកឡើងរបស់សវនករ និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានឃើញការឆ្លើយតបរបស់សវនដ្ឋាន។នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងបន្តតាមដានអនុសាសន៍របស់ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅឆ្នាំបន្ទាប់ទៀត ។

**ត្រីមាសទី៣**

**៦.៣.១. ការស្នើរសុំសម្ភារការិយាល័យប្រើប្រាស់ប្រចាំខែនីមួយៗនៃឆ្នាំ២០២២**

**គោលបំណងសវនកម្ម៖** គោលបំណងនៃការត្រួតពិនិត្យគឺពង្រឹងនិងតាមដានការប្រើប្រាស់ការធ្វើសម្ភារការិយាល័យ។

សវនករពិនិត្យឃើញថា គិតមកដល់បច្ចុប្បន្នការស្នើសុំសម្ភារការិយាល័យប្រើប្រាស់ប្រចាំខែរបស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ មានចំនួនតួលេខដដែល។

ករណីនេះ និងយោងលើសំណើសុំសម្ភារការិយាល័យ ប្រើប្រាស់សម្រាប់ប្រចាំខែនីមួយៗគ្មានការប្រែប្រួលចំនួនស្នើរសុំ ហើយចំនួនមានច្រើនផងដែរ។

មូលហេតុនៃការស្នើសុំសម្ភារការិយាល័យប្រើប្រាស់មានចំនួនដដែលៗ។ រហូតមកដល់បច្ចុប្បន្ន ពុំទាន់ឃើញមានការស្នើសុំសម្ភារការិយាល័យប្រើប្រាស់តួលេខជាក់ស្តែង។

កត្តានេះ អាចនាំអោយការប្រើប្រាស់សម្ភារការិយាល័យ មិនមានការប្រើប្រាស់ជាក់ស្តែង។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរតែពិនិត្យឡើងវិញសំរាប់ការស្នើសុំប្រើប្រាស់សម្ភារ និងស្រង់តួលេខនៃការប្រើប្រាស់ចាំបាច់ជាក់ស្តែង។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានឃើញការឆ្លើយតបរបស់សវនដ្ឋាន នឹងបន្តតាមដានតទៅទៀត។

**៦.៣.២. អំពីកង្វះការរៀបចំធ្វើបច្ចុប្បន្នភាពនៃការកំណត់តួនាទី និងភារកិច្ច របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង។

តាមការពិនិត្យ សវនករសង្កេតឃើញថា អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ពុំទាន់បានធ្វើបច្ចុប្បន្នភាពអំពីតួនាទី និងភារកិច្ចឡើងវិញរបស់ មន្ត្រី និយោជិត ក្នុងអង្គភាពរបស់ខ្លួននៅឡើយ។

ករណីនេះ មិនទាន់ស្របតាមលក្ខន្តិកៈរបស់កំពង់ផែស្វយ័តភ្នំពេញ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ផ្នែកទី៣ អង្គការប្រតិបត្តិការរបស់ ក.ស.ភ. ប្រការ៤៧ អំពីនាយកដ្ឋាននានា ។

បញ្ហានេះ អាចនាំឱ្យមានកង្វះខាតភាពទទួលខុសត្រូវរបស់អង្គភាព។

កត្តានេះ អាចធ្វើឱ្យការគ្រប់គ្រងពុំទាន់មានប្រសិទ្ធភាព។

ដូចនេះ អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរតែរៀបចំធ្វើបច្ចុប្បន្នភាពអំពីតួនាទី និងភារកិច្ចរបស់មន្ត្រី និយោជិត ឡើងវិញដើម្បីបង្កើនប្រសិទ្ធភាព ការងារ និងទំនួលខុសត្រូវរបស់បុគ្គលិកទទួលបន្ទុក។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀតតាមផែនការ។

**៦.៣.៣. អំពីរចនាសម្ព័ន្ធ របស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និង អនុវត្តការងារ។

តាមការពិនិត្យ រចនាសម្ព័ន្ធរបស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឃើញថា នៅមានខ្វះមន្ត្រីជំនាញបម្រើការងារតួនាទីជា អនុប្រធានអង្គភាពទទួលបន្ទុកគ្រប់គ្រងការងាររៀបចំប្លង់កុងតឺន័រទីលាន/នាវា និង

អនុប្រធានអង្គភាពទទួលបន្ទុកគ្រប់គ្រងការងារអង្គភាពផែស្ងួត (ICD)/ជញ្ជូន។

ករណីនេះ ធ្វើឱ្យការអនុវត្តការងារពុំទាន់ស្របទៅនឹងរចនាសម្ព័ន្ធ របស់អង្គភាព។

បញ្ហានេះ កើតឡើងដោយសារមានការផ្លាស់ប្តូរមន្ត្រី នៅក្នុងអង្គភាព។

កត្តានេះ អាចធ្វើឱ្យការអនុវត្តការងារពុំមានកាតព្វកិច្ចទទួលខុសត្រូវច្បាស់លាស់។

ដូចនេះ អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ គួរតែធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីការខ្វះចន្លោះនៅក្នុងរចនាសម្ព័ន្ធខាងលើ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តការងារ។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀតតាមផែនការ។

**៦.៣.៤. អំពីរចនាសម្ព័ន្ធ របស់អង្គភាពវិក្កយបត្រ LM១៧**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និង អនុវត្តការងារ។

តាមការពិនិត្យ រចនាសម្ព័ន្ធរបស់អង្គភាព វិក្កយបត្រ LM១៧ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ឃើញថានៅមានចន្លោះតួនាទីជា ប្រធានអង្គភាព អនុប្រធានទទួលបន្ទុករដ្ឋបាល/ចំណូល និងអនុប្រធានទទួលបន្ទុក Import / LoLo Scan,Stuffing/Unstuffing ។

ករណីនេះ ធ្វើឱ្យការអនុវត្តការងារពុំទាន់ស្របទៅនឹងរចនាសម្ព័ន្ធ របស់អង្គភាព។

បញ្ហានេះ កើតឡើងដោយសារមានការផ្លាស់ប្តូរមន្ត្រី នៅក្នុងអង្គភាព។

កត្តានេះ អាចធ្វើឱ្យការអនុវត្តការងារពុំមានកាតព្វកិច្ចទទួលខុសត្រូវច្បាស់លាស់។

ដូចនេះ អង្គភាពវិក្កយបត្រ LM១៧ គួរតែធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីការខ្វះចន្លោះនៅក្នុងរចនាសម្ព័ន្ធខាងលើ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តការងារ។

អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀតតាមផែនការ។

**ត្រីមាសទី៤**

**៦.៤.១. អំពីវគ្គបណ្តុះបណ្តាលកណ្តូតារក្រៅប្រទេស**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីឱ្យផ្នែកកណ្តូតារមានជំនាញនិងទទួលបាននូវ

បច្ចេកវិទ្យាថ្មីៗបន្ថែមទៀតអនុលោម ទៅតាមកម្មវិធីអង្គការដែនសមុទ្រអន្តរជាតិ IMO (International Maritime Organization)។

តាមការពិនិត្យនិងធ្វើសវនកម្ម សវនករសង្កេតឃើញថា បន្ទាប់ពីសិក្ខាកាមបានបញ្ចប់ការសិក្សាផ្នែកកណ្ដូលការក្នុងប្រទេសនៅកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) រួចមក គឺការយល់ដឹងជំនាញកណ្ដូលការកិច្ចនៅមានកំរិត។

ករណីនេះ ធ្វើឱ្យបុគ្គលិកកណ្ដូលការពុំទាន់ទទួលបាននៅចំណេះដឹងលើជំនាញថ្មីៗដែលអនុលោមតាមកម្មវិធីអង្គការដែនសមុទ្រអន្តរជាតិ IMO ដូចខាងក្រោម ៖

១.វគ្គហ្វឹកហ្វឺនមូលដ្ឋានដោយយោងតាម STCW '78, Table A-V1/1
(Basic Training, according to the STCW '78, Table A-V1/1)
-បច្ចេកទេសសង្គ្រោះជីវិត (Personal Survival Techniques)
-ការទប់ស្កាត់និងការពន្លត់អគ្គីភ័យ (Fire Prevention And Fire Fighting)
-សង្គ្រោះបឋម (Elementary First Aid)
-ទំនួលខុសត្រូវរួមនិងខ្លួនឯង (Personal Safety and Social Responsibility)

២.ការយល់ដឹងសន្តិសុខនាវា ដោយយោងតាម STCW 78,Table A-A1/6
(Ship Security Awareness, according to the STCW '78, Table A-V1/6)

បណ្ដាលមកពីកង្វះខាតរបស់នាយកដ្ឋានសេវាកម្មនាវាចរណ៍ ពុំបានបញ្ចូលការបណ្ដុះបណ្ដាលវគ្គសិក្សាថ្មីៗទៅក្រៅប្រទេស ពិសេសប្រទេសជិតខាងយើងដែលបិតក្នុងកិច្ចសហប្រតិបត្តិការ ផ្នែកនាវាចរណ៍សមុទ្រ ដូចជា កម្មវិធី IMO (International Maritime Organization) នៅប្រទេសវៀតណាម និងបណ្ដាប្រទេសផ្សេងៗទៀត។

កត្តានេះ បណ្ដាលឱ្យកណ្ដូលការ ពុំទាន់ទទួលបានបច្ចុប្បន្នភាពនៃជំនាញថ្មីៗបន្ថែមទៀត។

ដូចនេះ នាយកដ្ឋានសេវាកម្មនាវាចរណ៍ គួរតែបានចូលរួមសិក្សាវគ្គបណ្ដុះបណ្ដាលកណ្ដូលការលើបច្ចេកវិទ្យាថ្មីៗ និងជំនាញដែលអនុលោមតាមកម្មវិធីអង្គការដែនសមុទ្រអន្តរជាតិ IMO (International Maritime Organization) បានគ្រប់គ្នា ព្រោះមានសារប្រយោជន៍ហើយក៏បានចូលរួមបង្កើនសមត្ថភាពឱ្យមានការយល់ដឹងកាន់តែប្រសើរ។

នាយកដ្ឋានសេវាកម្មនាវាចរណ៍មានការឧកខាន មិនបានស្នើសុំឱ្យកណ្ដូលការបានទៅធ្វើបច្ចុប្បន្នភាពនូវចំណេះដឹងនិងជំនាញថ្មីបន្ថែម ដូចជា៖ ទៅធ្វើបច្ចុប្បន្នភាព លើ Certificate STCW ដោយសារតែជម្ងឺកូវីត-១៩ ដែលបណ្ដាលឱ្យ Certificate STCW អស់សុពលភាព ពីឆ្នាំ ២០២១ ។ នាយកដ្ឋានសេវាកម្មនាវាចរណ៍ នឹងរៀបចំស្នើសុំឱ្យកណ្ដូលការទាំងអស់បានទៅធ្វើបច្ចុប្បន្នភាព Certificate STCW ដើម្បីពង្រឹងសមត្ថភាពចំណេះដឹង និងស្របទៅតាមនិយាមអន្តរជាតិ ។

សវនករបានឃើញការឆ្លើយតប របស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងបន្តតាមដានអនុសាសន៍នេះបន្តទៀតនាឆ្នាំខាងមុខ។

**៦.៤.២. អំពីកង្វះខាតក្នុងការធ្វើរបាយការណ៍បូកសរុបសកម្មភាពនាំនាវាប្រចាំឆ្នាំ របស់ការិយាល័យ កណ្តូធារ**

**គោលបំណងសវនកម្ម៖** គោលបំណងរបស់សវនករ គឺដើម្បីឱ្យការិយាល័យកណ្តូធារមានរបាយការណ៍ប្រចាំឆ្នាំ។

តាមការពិនិត្យ របាយការណ៍របស់ការិយាល័យកណ្តូធារ សវនករសង្កេតឃើញថា ការិយាល័យបានធ្វើរបាយការណ៍សកម្មភាពនាំនាវាប្រចាំខែ តែមិនបានធ្វើរបាយការណ៍បូកសរុបសកម្មភាពនាំនាវាប្រចាំឆ្នាំ។

ករណីនេះ ពុំទាន់ស្របតាមសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍។

បញ្ហានេះ ធ្វើឱ្យការតាមដានចំនួននាវាដែលឆ្លងកាត់ប្រចាំឆ្នាំពុំទាន់មានរបាយការណ៍។

កត្តានេះ ធ្វើឱ្យការអនុវត្តតួនាទី និងភារកិច្ចរបស់ការិយាល័យនៅមានកង្វះខាត។

ដូចនេះ ការិយាល័យគួររៀបចំធ្វើរបាយការណ៍បូកសរុបទិន្នន័យសកម្មភាពនាវាប្រចាំឆ្នាំ ដើម្បីដាក់ជូនថ្នាក់ដឹកនាំងាយស្រួលក្នុងការពិនិត្យ និងជ្រាប។

ការិយាល័យកណ្តូធារ ឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

សវនករបានឃើញ ការឆ្លើយតបរបស់សវនដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងបន្តតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀតតាមផែនការ។

## ៧.សេចក្តីសន្និដ្ឋានរួម

តាមលទ្ធផលចុះធ្វើសវនកម្មជាក់ស្តែងសម្រាប់ត្រីមាសទី១ ឆ្នាំ២០២២ និងឆ្នាំពាក់ព័ន្ធ សវនករពិនិត្យឃើញថា នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបផែនប្រតិបត្តិការ LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្តូធារ បានអនុវត្តការងាររបស់ខ្លួនកន្លងមកបានល្អប្រសើរគួរជាទីមោទនភាព ដោយខិតខំបំពេញប្រតិបត្តិការប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព និងសម្រេចបាននូវគោលដៅជាអាទិភាពរបស់ខ្លួន ក្នុងសកម្មភាពមន្ត្រី និយោជិត មានការកែសម្រួលបែបបទឯកសារតាមលិខិតបទដ្ឋានគតិយុត្ត ការផ្តល់ទំនុកចិត្ត និងសេវាកម្មសមស្របទៅនឹងទីផ្សារ។ ទន្ទឹមនឹងនេះ ក៏មានចំណុចខ្វះខាតដែលសវនករបានកត់សម្គាល់ឃើញផងដែរនូវភាពអសកម្ម និងកង្វះខាតមួយចំនួនក្នុងការបំពេញការងារ។ ហើយនាយកដ្ឋាន ការិយាល័យ សេវាដ្ឋាន និងអង្គភាពទាំង ១១ ខាងលើក៏ខិតខំកែលម្អឱ្យមានលក្ខណៈល្អនាពេលខាងមុខ ។

## ៨.ផែនការសកម្មភាពកែលម្អ

ផែនការសកម្មភាពកែលម្អនូវចំណុចខ្វះខាតខាងលើ ត្រូវបាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/ បរិស្ថានផែ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ អង្គភាពរៀបផែនប្រតិបត្តិការ

៦៥

LM១៧ នាយកដ្ឋានរដ្ឋបាល ការិយាល័យរដ្ឋបាល ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ អង្គភាពវិក្កយបត្រ LM១៧ នាយកដ្ឋានសេវាកម្មនាវាចរណ៍ និងការិយាល័យកណ្ដាលបានឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ឱ្យមានការកែលម្អនាឆ្នាំបន្តបន្ទាប់ ដូចបានបង្ហាញក្នុងឧបសម្ព័ន្ធទី២។

នាឆ្នាំខាងមុខ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងជូនដំណឹងដល់ការិយាល័យកោសល្យវិច័យលើវិភាគកម្ម ដើម្បីពិនិត្យឡើងវិញ ពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្មកន្លងមក ជាចំណែកមួយនៃការធ្វើសវនកម្មឡើងវិញ ។

ថ្ងៃ សុក្រ ១២រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២៣
**នាយកសវនកម្មផ្ទៃក្នុង**

**កែវ សុផាណ្ណារ៉ា**

**បានឃើញ និងឯកភាព**
ថ្ងៃ ពុធ ៣រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២៣
**ប្រធានគណៈកម្មាធិការសវនកម្ម**

**ង៉ី អានរ៉ាវិធ**

<u>កន្លែងទទួល</u>
-អាជ្ញាធរសវនកម្មជាតិ
-នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសាធារណការ និងដឹកជញ្ជូន
-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជាការជូនដំណឹង"
-គណៈកម្មាធិការសវនកម្មផ្ទៃក្នុង ក.ស.ភ.ព
-គ្រប់អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ ប្រធានសេវាដ្ឋាន ប្រធានអង្គភាព ក្រោមឱវាទ កំពង់ផែស្វយ័តភ្នំពេញ
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១ - ការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន**

**សវនដ្ឋាន៖**

**ត្រីមាសទី១**

- ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ
- អង្គភាពរៀបផែនប្រតិបត្តិការ
- សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ

**ត្រីមាសទី២**

- នាយកដ្ឋានរដ្ឋបាល
- ការិយាល័យរដ្ឋបាល
- ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera

**ត្រីមាសទី៣**

- អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧
- អង្គភាពវិក្កយបត្រ LM១៧

**ត្រីមាសទី៤**

- នាយកដ្ឋានសេវាកម្មនាវាចរណ៍
- ការិយាល័យកណ្ដូចារ

*អាទិភាព

- ខ្ពស់៖ ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលអាចនាំឱ្យខូចខាត ដោយសម្ភារៈ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន
- មធ្យម៖ ដើម្បីដោះស្រាយការរកឃើញដែលមិនទាន់កាត់បន្ថយ[illegible] និងដែលសំខាន់សម្រាប់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិ
- ទាប៖ ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ ឬដោះស្រាយឯកសារក្នុងចំណុចដែលមិនសូវសំខាន់

**វឌ្ឍនភាពនៃការអនុវត្តតាមការផ្ដល់អនុសាសន៍

- អន៖ បានអនុវត្តតាមអនុសាសន៍ពេញលេញ និងបានកាត់បន្ថយហានិភ័យឱ្យដល់កម្រិតដែលអាចទទួលយកបាន
- អផ៖ បានអនុវត្តតាមផ្នែកអនុសាសន៍ខ្លះ និងហានិភ័យសំណល់ស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន
- មអ៖ មិនបានអនុវត្តតាមអនុសាសន៍ និងហានិភ័យនៅតែមាន
- មព៖ មិនមានហានិភ័យពាក់ព័ន្ធ និងមិនមានហានិភ័យសំណល់ទៀតទេ

| លេខអនុសាសន៍ | អនុសាសន៍សវនកម្ម | *អាទិភាព | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទបញ្ចប់ដែលឲ្យ | កាលបរិច្ឆេទតាមដាន | **វឌ្ឍនភាព | សម្គាល់ (ភស្តុតាងគាំទ្រ) |
|---|---|---|---|---|---|---|---|
| | **ត្រីមាសទី១**<br>**សវនដ្ឋាន៖ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ (ឆ្នាំ២០១៦)** | | | | | | |
| ១ | យោងតាមអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្ដីពីការគ្រប់គ្រងសំណល់រឹង នៃជំពូកទី២ មាត្រា៤ | មធ្យម | លោក ងៃ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | របស់ក្រសួងបរិស្ថាន ការិយាល័យគួរតែមានរបាយការណ៍ត្រួតពិនិត្យទាំងលើការប្រមូល សម្រាមទាំងអស់ពីគ្រប់នាវា ទាំងនាវាទេសចរណ៍ នាវាកុងតឺន័រ និងតាមបញ្ជាទីលាន ក.ស.ភ. ដើម្បីកុំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ។ | | | | | | ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែកាបផ្សឹក ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ២ | យោងទៅតាមលិខិតលេខ ៥៤៥ ក.ស.ភ. PPAP ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០១៥ ស្ដីពីក្រុមប្រឹក្សាសុវត្ថិភាព និងបរិស្ថាន និងលិខិតលេខ ៥៤៦ ក.ស.ភ. PPAP ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីគណៈកម្មាធិការសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ សវនករសង្កេតឃើញថា មិនមានរបាយការណ៍ស្ដីពី បាតិភ័យដែលត្រូវជួបប្រជុំគ្នារៀងរាល់បីខែម្ដងនោះទេដែលផ្ដោតទៅលើការត្រួតពិនិត្យចំណតផែ ឯកសារបញ្ជាក់អត្តសញ្ញាណគ្រោះថ្នាក់ស៊ើបអង្កេតរបាយការណ៍ ស្ដីពីឧបទ្ទវហេតុលើកកម្ពស់ការយល់ដឹង ផ្នែកសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ។ | មធ្យម | លោក ង៉ៅ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែកាបផ្សឹក ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ៣ | គ្រប់សៀវភៅដែលបានចងក្រង ការិយាល័យគួរតែបកប្រែជាខេមរភាសា និងផ្សព្វផ្សាយគ្រប់បណ្ដានាយកដ្ឋាន ការិយាល័យ សេវាផ្ទាន និងអង្គភាពក្រោមឱវាទ ក.ស.ភ ដើម្បីឱ្យបានយល់ដឹងពីប្រព័ន្ធគ្រប់គ្រង សុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ។ | មធ្យម | លោក ង៉ៅ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែកាបផ្សឹក ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| | **ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ (ឆ្នាំ២០១៩)** | | | | | | |
| ៤ | **កង្វះខាតក្នុងការធ្វើរបាយការណ៍ប្រចាំខែ** | មធ្យម | លោក ង៉ៅ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តាមការពិនិត្យ សវនករសង្កេតឃើញថា ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ បានធ្វើរបាយការណ៍សរុបប្រាំបីខែឆ្នាំ២០១៩ តែមិនបានធ្វើរបាយការណ៍ប្រចាំខែស្ដីពីសកម្មភាពការងារ ដាក់ជូននាយក ដើម្បីឱ្យនាយកធ្វើរបាយការណ៍បូកសរុប ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងស្របតាមសេចក្ដីណែនាំលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែឧ្ទ ឆ្នាំ២០១៦ ស្ដីពីការរៀបធ្វើរបាយការណ៍ប្រចាំខែ។ | | | | | | ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ៥ | **និតិវិធានសម្ភារបស់ ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ** តាមការពិនិត្យវិធានសម្ភារបស់ការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ ឃើញមានចំណុចខ្វះខាតខ្លះមិនអាចយកទៅប្រើប្រាស់ជាផ្លូវការបានឡើយ ព្រោះពុំទាន់មានការចុះហត្ថលេខាពីនាយកមុខជំនាញ/ធនធានមនុស្ស និងដាក់ជូនឯកឧត្តមប្រតិភូ ពិនិត្យ និងឯកភាព។ | មធ្យម | លោក អៃ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើតខែមាឃឆ្នាំកុរ ឯកស័កព.ស.២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ៦ | យោងតាមអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្ដីពីការគ្រប់គ្រងសំណល់រឹង នៃជំពូកទី២ មាត្រាទី៤ របស់ក្រសួងបរិស្ថាន ការិយាល័យគួរតែមានរបាយការណ៍ត្រួតពិនិត្យទៅលើការប្រមូល សម្រាមទាំងអស់ពីគ្រប់នាវា ទាំងនាវាទេសចរណ៍ នាវាក្នុងតំបន់ និងតាមបណ្ដាទីលាន ក.ស.ភ. ដើម្បីកុំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ។ | មធ្យម | លោក អៃ សំណាង | ២០១៩ | ២០២២ | អន | របាយការណ៍សវនកម្ម ស្ដីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើតខែមាឃឆ្នាំកុរ ឯកស័កព.ស.២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| | **សវនដ្ឋាន៖ អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ (ឆ្នាំ ២០១៧)** | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | សវនករសង្កេតឃើញថា អង្គភាពគួរតែពិនិត្យ និងរៀបចំគ្រប់ទឹកដឹកជញ្ជូនកុងតឺន័រ ក្រោមដងយោងមករៀបទុកដាក់នៅលើទីលានបរិវេណផែដែលមិនទាន់ឲ្យចំនៃផែកសងខាង ដើម្បីជៀសវាងគ្រោះថ្នាក់ធ្លាក់ទូកុងតឺន័រ ជាយថាហេតុ។ | មធ្យម | លោក ហ៊ើម វណ្ណា | ២០២០ | ២០២២ | មអ | របាយការណ៍សវនកម្ម ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ៨ | អង្គភាពគួរតែមានវគ្គបណ្តុះបណ្តាលជំនាញផែទាំ និងបច្ចេកទេសជួសជុលបឋមបន្ថែមទៀតដល់បុគ្គលិកបើករថយន្ត និងគ្រឿងចក្រគ្រប់ប្រភេទ ជៀសវាងបញ្ហាកើតមានឡើង បណ្តាលឱ្យមានគ្រោះថ្នាក់ ឬការបាក់បែកខូចខាតទំនិញ និងទូកុងតឺន័រ។ ហើយគឺបង្កើនកិច្ចសហការជាមួយអ្នកបើកដងយោង នាងភ្នាក់ងារកម្ពុជានាវាចរណ៍ (កាំសាប) ក្រុមហ៊ុនគូរ៉េ និងក្រុមហ៊ុន Sovereign ឱ្យមានការប្រុងប្រយ័ត្នកំរិតខ្ពស់ព្រោះបញ្ហាគ្រោះថ្នាក់កើតការឡើងលោងកំពង់ផែស្វយ័តភ្នំពេញជាអ្នកទទួលបន្ទុកមុនគេ។ | មធ្យម | លោក ហ៊ើម វណ្ណា | ២០២០ | ២០២២ | មអ | របាយការណ៍សវនកម្ម ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ៩ | សវនករសង្កេតឃើញថាចំពោះ "សៀវភៅសម្រាប់ប្រើប្រាស់មធ្យោបាយ" ដែលប្រើសំរាប់តាមដានប្រើប្រាស់ ថែទាំជួសជុល និងចំណាយប្រេងរបស់គ្រឿងចក្រ អង្គភាពគួរតែសរសេរបំពេញបន្ថែមទៀតឱ្យបានគ្រប់អត្ថន័យលក្ខណៈបច្ចេកទេសគ្រឿងចក្រនៃមធ្យោបាយនោះ ដោយមានហត្ថលេខាប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ដើម្បីឱ្យត្រូវតាមទម្រង់ស្តង់ដារ និងលក្ខណៈគតិយុត្ត និង ងាយស្រួលក្នុងការត្រួតពិនិត្យតាមដានសកម្មភាពការងារនៃគ្រឿងចក្រនោះ ដែលកំពុងប្រតិបត្តិការឬមិនប្រតិបត្តិការ។ | មធ្យម | លោក ហ៊ើម វណ្ណា | ២០២០ | ២០២២ | មអ | របាយការណ៍សវនកម្ម ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **អង្គភាពរៀបចំផែនប្រតិបត្តិការចំណតផែ LM១៧ (ឆ្នាំ២០១៩)** | | | | | | |
| ១០ | **ការធ្វើបច្ចុប្បន្នភាពតំពីទ្ធនាទី និងភារកិច្ចរបស់មន្ត្រី កម្មករ**<br>តាមការសាកសួរ ប្រធានអង្គភាពរៀបចំផែន-ប្រតិបត្តិការ សវនករសង្កេតឃើញថាអង្គភាពពុំទាន់បានធ្វើបច្ចុប្បន្នភាពតំពីទ្ធនាទី និងភារកិច្ចថ្មីៗរបស់ មន្ត្រី-កម្មករ ដែលបានផ្ទេរភារកិច្ចពីអង្គភាពផ្សេងនៅឡើយ។ | បញ្ចប់ | លោក<br>ជើម វណ្ណា | ២០២០ | ២០២២ | អន | របាយការណ៍សវនកម្ម ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| ១១ | **កង្វះខាតកន្លែងស្នាក់នៅសម្រាប់បុគ្គលិក កម្មករ ដែលបំពេញការងារវេនយប់**<br>តាមការសាកសួរ និងពិនិត្យជាក់ស្តែងកន្លែងស្នាក់នៅ សម្រាប់បុគ្គលិក-កម្មករ ដែលបំពេញការងារ វេនយប់នៅចំណតផែកុងតឺន័រ LM១៧ (អគារចិន) មានសភាពចាស់ទ្រុឌទ្រោម មានម្លប់ស្នាក់នៅតិចមិនទាន់បំពេញតម្រូវការជាក់ស្តែងសម្រាប់ បុគ្គលិក-កម្មករនៅឡើយ។ | បញ្ចប់ | លោក<br>ជើម វណ្ណា | ២០២០ | ២០២២ | អន | របាយការណ៍សវនកម្ម ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ លេខ ០០៨/២០ ន.ស.ផ.ក.ចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។ |
| | **សវនដ្ឋាន៖ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ (ឆ្នាំ ២០២២)** | | | | | | |
សម្រាប់ឆ្នាំ២០២២ ចំណាយរដ្ឋបាលទូទៅ និងការលក់ បានកើនឡើងចំនួន ៩.០៧៣.០០៣ ពាន់រៀល (២.១៨៥.៣២៦ ដុល្លារអាមេរិក) ឬស្មើនឹង ២៩,៩៣% បើធៀបនឹងឆ្នាំ២០២១។ ការកើនឡើងនៃចំណាយរដ្ឋបាលទូទៅ និងការលក់ ដោយសារតែមានការកើនឡើងនៃចំណាយទៅលើចំណាយទៅលើទឹក-ភ្លើង និងប្រេងឥន្ធនៈ ចំណាយលើការកំសាន្ត ចំណាយការធ្វើដំណើរ និងចំណាយផ្សេងៗជាដើម។

## *៤. ការវិភាគប្រាក់ចំណេញក្រោយបង់ពន្ធ*

ក. ស. ភ. ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ ក. ស. ភ. មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ក្នុងអត្រា ២០%។ ជាមួយគ្នានេះដែរ ចាប់ពីឆ្នាំ២០១៩ មក ក. ស. ភ. ឈប់ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ បន្ទាប់ពី ក. ស. ភ. ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចំនួន ៣ (បី) ឆ្នាំ រួចហើយ (ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨)។

<u>ដំណាច់ឆ្នាំ២០២២ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ប្រៀបធៀបនឹងដំណាច់ឆ្នាំ២០២១ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១</u>

| បរិយាយ | ឆ្នាំ២០២២ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ឆ្នាំ២០២១ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | បម្រែបម្រួល | | | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ១៨.៤៤៩.៦៥៣ | ៧៥.៤០៣.៧៣៣ | ១៥.៧១២.៣៣៨ | ៦៣.៩១៧.៧៩១ | ២.៧៣៧.៣១៥ | ១៧,៤២% | ១១.៤៨៥.៩៤២ | ១៧,៩៧% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | ៤.១៣៦.៣៧០ | ១៦.៩០៥.៣៤៤ | ៣.០០៤.៥០៧ | ១២.២២២.៣៣៤ | ១.១៣១.៨៦៣ | ៣៧,៦៧% | ៤.៦៨៣.០១០ | ៣៨,៣២% |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ១៤.៣១៣.២៨៣ | ៥៨.៤៩៨.៣៨៩ | ១២.៧០៧.៨៣១ | ៥១.៦៩៥.៤៥៧ | ១.៦០៥.៤៥២ | ១២,៦៣% | ៦.៨០២.៩៣២ | ១៣,១៦% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៤.៥៦៥.០៤៣ | ៥៩.៥២៧.៣៣២ | ១២.៦៨៦.៧៩៧ | ៥១.៦០៩.៨៩១ | ១.៨៧៨.២៤៦ | ១៤,៨០% | ៧.៩១៧.៤៤១ | ១៥,៣៤% |
| **អត្រាពន្ធមធ្យម(ខ)/(ក)** | **២២,៤២%** | **២២,៤២%** | **១៩,១២%** | **១៩,១២%** | | | | |

ក. ស. ភ. ទទួលបានប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំ២០២២ ចំនួន ៥៨.៤៩៨.៣៨៩ ពាន់រៀល (១៤.៣១៣.២៨៣ ដុល្លារអាមេរិក) និងសម្រាប់ឆ្នាំ២០២១ ចំនួន ៥១.៦៩៥.៤៥៧ ពាន់រៀល (១២.៧០៧.៨៣១ ដុល្លារអាមេរិក) ដែលបង្ហាញឱ្យឃើញការកើនឡើងនូវប្រាក់ចំណេញសុទ្ធមានចំនួន ៦.៨០២.៩៣២ ពាន់រៀល (១.៦០៥.៤៥២ ដុល្លារអាមេរិក) ឬស្មើនឹង ១៣,១៦%។ ការកើនឡើងនៃអត្រាពន្ធមធ្យមចំនួន ៣,៣០% ពី ១៩,១២% ក្នុងឆ្នាំ២០២១ ដល់ ២២,៤២% ក្នុងឆ្នាំ២០២២ ដោយសារប្រាក់ចំណេញមុនបង់ពន្ធមានការកើនឡើងចំនួន ១៧,៩៧% និងចំណាយពន្ធលើប្រាក់ចំណេញកើនឡើងចំនួន ៤.៦៨៣.០១០ ពាន់រៀល (១.១៣១.៨៦៣ ដុល្លារអាមេរិក) ឬស្មើនឹង ៣៨,៣២%។

## ៥. ការវិភាគពីកត្តានិងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ

### ៥.១. កម្រិតនៃការជួញដូរក្នុងតំបន់និងជាសកលនិងសកលភាវូបនីយកម្ម

ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ ក. ស. ភ. អាស្រ័យលើបរិមាណកុងតឺន័រឆ្លងកាត់ និងសកម្មភាពដឹកជញ្ជូនឆ្លងកាត់កំពង់ផែដែលពឹងផ្អែកលើទំហំពាណិជ្ជកម្មក្នុងស្រុក និងទូទាំងពិភពលោក ព្រមទាំងបរិមាណនៃការនាំចេញ និងការនាំចូលក្នុងតំបន់ដែលត្រូវបានធ្វើប្រតិបត្តិការ។ បរិមាណនៃការជួញដូរក្នុងស្រុក និងទូទាំងពិភពលោក និងបរិមាណនៃការនាំចេញ និងនាំចូលក្នុងស្រុកដែលបានធ្វើប្រតិបត្តិការនេះទទួលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងនយោបាយ ក្នុងតំបន់និងសកលដែលហួសពីការគ្រប់គ្រងរបស់ ក. ស. ភ.។

### ៥.២. សមត្ថភាពទទួលកុងតឺន័រនៅចំណតផែកុងតឺន័រ LM ១៧

ការលើកដាក់ចម្បងៗ ត្រូវបានធ្វើឡើងនៅចំណតផែកុងតឺន័រ LM១៧។ ក. ស. ភ. មានសមត្ថភាពលើកដាក់ទំនិញជាកុងតឺន័រប្រមាណ ៤១៧.៦៩៦ TEUs ក្នុងមួយឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ក. ស. ភ. ដើម្បីឆ្លើយតបនឹងកំណើននាឆ្នាំបន្ទាប់ ក. ស. ភ. មានគម្រោងនឹងបញ្ចប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែជំហានទី៣ ដែលនឹងបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅចំណតផែកុងតឺន័រ LM១៧ បន្ថែមចំនួន ២០០.០០០ TEUs ។

| បរិយាយ | សមត្ថភាពលើកដាក់ | | | | |
|---|---|---|---|---|---|
| | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ផែនការ ឆ្នាំ២០២២ |
| ចំណតផែកុងតឺន័រ LM១៧ (TEUs) | ២៨១.០៤៥ | ២៩០.៨៥៧ | ៣៥៨.៨៩៨ | ៤១៧.៦៩៦ | ៣៩៤.៦៧៩ |

### ៥.៣. ប្រសិទ្ធភាពនៃប្រតិបត្តិការ

ដើម្បីបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការ ក. ស. ភ. មានគោលការណ៍ក្នុងការកាត់បន្ថយចំណាយថ្លៃដើមដោយប្រើធនធានដែលមានស្រាប់ និងការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗសម្រាប់បម្រើឱ្យប្រតិបត្តិការ។ ជាក់ស្តែង ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការ ក. ស. ភ. បានអនុវត្តនូវវិធានការដូចខាងក្រោម៖

- បន្តបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ ដើម្បីបង្កើនល្បឿននៃការលើកដាក់ទំនិញនិងកាត់បន្ថយការរង់ចាំដោយសារការខូចខាតគ្រឿងចក្រ
- បន្តជម្រុញសមត្ថភាពផ្នែកប្រតិបត្តិការតាមរយៈការបណ្តុះបណ្តាល
- ពង្រីកចំណតផែដើម្បីធានាថានាវាដឹកកុងតឺន័រអាចដឹកជញ្ជូនចេញ-ចូលបានលឿន និងប្រកបដោយប្រសិទ្ធភាព
- ការពង្រីកទីលានស្តុកកុងតឺន័រជំហានទី៣ នៅចំណតផែកុងតឺន័រ LM១៧

- គ្រប់គ្រងទីលានស្តុកកុងតឺន័រឱ្យមានប្រសិទ្ធភាព ដោយកាត់បន្ថយការរក្សាទុកកុងតឺន័រនៅលើទីលានក្នុងរយៈពេលយូរ
- ប្រើប្រាស់ចំណតផែឲ្យមានប្រសិទ្ធភាព ដោយការរៀបចំទីតាំងចូលចតនាវាទៅតាមផែនការច្បាស់លាស់។

### ៥.៤. តម្លៃ

ក្នុងគោលបំណងដើម្បីរក្សាអតិថិជនដែលមានស្រាប់ និងទាក់ទាញអតិថិជនថ្មី បន្ថែមទៀត ក. ស. ភ. បានផ្តល់តម្លៃអនុគ្រោះលើថ្លៃពន្ធនាវាដល់នាវាទេសចរណ៍ នាវាដឹកជញ្ជូនទំនិញរាយ និងនាវាដឹកជញ្ជូនកុងតឺន័រ និងប្រភេទនាវាដឹកជញ្ជូនទំនិញផ្សេងៗទៀត។ ជាមួយគ្នានេះដែរ ក. ស. ភ. ក៏បានផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ទំនិញរាយទាំងនៅចំណតផែកុងតឺន័ររបស់ ក. ស. ភ. និងនៅក្រៅចំណតផែរបស់ ក. ស. ភ.។ ក្រៅពីការអនុគ្រោះថ្លៃសេវាកម្មលើកដាក់ទំនិញរាយ ក. ស. ភ. ក៏បានផ្តល់តម្លៃអនុគ្រោះជាកញ្ចប់សម្រាប់សេវាកម្មលើកដាក់កុងតឺន័រ (Stevedore) ដល់ក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រទាំងអស់ ដោយផ្អែកតាមបរិមាណកុងតឺន័រដែលដឹកជញ្ជូនបាន។ នេះមានន័យថា បើនាវាដឹកជញ្ជូនកុងតឺន័ររបស់ក្រុមហ៊ុនណាមួយ ដែលដឹកជញ្ជូនកុងតឺន័របានកាន់តែច្រើន នឹងទទួលបានការបញ្ចុះតម្លៃលើកទឹកចិត្តកាន់តែច្រើន។

### ៥.៥. ការតភ្ជាប់រវាងផែរណប

ការតភ្ជាប់រវាងផែរណបដើរតួនាទីយ៉ាងសំខាន់ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការជ្រើសរើសកំពង់ផែសម្រាប់ការដឹកជញ្ជូនទំនិញ។ ការតភ្ជាប់រវាងផែរណបដែលមានប្រសិទ្ធភាពអាចជំរុញឱ្យ អ្នកដឹកជញ្ជូនកាត់បន្ថយពេលវេលាដឹកជញ្ជូន។ ប្រសិទ្ធភាពចរាចរណ៍រវាងផែរណប អាស្រ័យទៅលើសេវាកម្មផែរណបផ្សេងទៀតដែលគ្រប់គ្រងលើចរាចរណ៍នៃការដឹកជញ្ជូនទំនិញ ព្រោះថាទីតាំងរបស់ ក. ស. ភ. មានអំណោយផលសម្រាប់ការប្រមូលទំនិញដើម្បីដឹកជញ្ជូនតាមផ្លូវទឹក។

### ៥.៦. ការរំលស់

ការរំលស់កើតឡើងពីការរំលស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារកំពង់ផែ រួមទាំងចំណតនាវា អគារឃ្លាំង និងគ្រឿងចក្រលើកដាក់។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសំខាន់ៗមានដូចជា ចំណតនាវា អគារ (១០-៥០ឆ្នាំ) គ្រឿងចក្រគ្រឿងម៉ាស៊ីន (១០-១៥ឆ្នាំ) គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ (៥ឆ្នាំ) កុំព្យូទ័រ (៥-១៥ឆ្នាំ) សម្ភារការិយាល័យ និងផ្សេងៗ (៥-១៥ឆ្នាំ) និងយានយន្ត (៨-១៥ឆ្នាំ)។ វិធីសាស្ត្ររំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគលើលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

បរិមាណទំនិញឆ្លងកាត់ ក. ស. ភ. ទាក់ទងដោយផ្ទាល់ទៅនឹង កត្តាសេដ្ឋកិច្ចជាតិតំបន់ ឬ សកល។ ជាការចាំបាច់ដែល ក. ស. ភ. ត្រូវធ្វើការវិភាគសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបានដឹងនូវនិន្នាការ កំណើន ឬការធ្លាក់ចុះនៃតម្រូវការដឹកជញ្ជូន។ នេះជាមូលដ្ឋាន ដើម្បីរៀបចំឆ្លើយតបបានទាន់ពេលវេលា ក៏ដូចជាធ្វើផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬក៏បំពាក់គ្រឿងចក្របានសមស្រប។ នេះក៏អាចជួយឱ្យ ក. ស. ភ. ជៀសបានពីការ

វិនិយោគហួសតម្រូវការ ដែលធ្វើឱ្យខាតប្រយោជន៍ពីការប្រើប្រាស់ទុន ឬកប់ទុន ក្នុងករណីដែលតម្រូវការដឹកជញ្ជូនអាចធ្លាក់ចុះ។

## ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការរក្សាបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ជាកត្តាសំខាន់សម្រាប់និរន្តភាពនៃការរីកលូតលាស់របស់ ក. ស. ភ. ក្នុងនោះ គឺគុណភាពសេវាកម្ម និងតម្លៃសេវាកម្មសមរម្យ។ ដើម្បីធានាបាននូវតម្លៃថ្លៃដើមនៃសេវាកម្មប្រកួតប្រជែង ក. ស. ភ. យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយប្រតិបត្តិការមួយចំនួនដូចខាងក្រោម៖

### ២.១. ចំណាយបៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតលើបុគ្គលិក

ផ្នែកមួយនៃការចំណាយច្រើន គឺទៅលើបៀវត្សបុគ្គលិក និងអត្ថប្រយោជន៍ផ្សេងៗ ដែលស្មើនឹងអត្រា **១៧,៧៥%** (អត្រា ៥,៦៩% ជាបៀវត្សបុគ្គលិកផ្នែកប្រតិបត្តិការ និងអត្រា ១២,០៦% ជាបៀវត្សបុគ្គលិកផ្នែករដ្ឋបាល និងអត្ថប្រយោជន៍ផ្សេងៗ) ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០២២ ដែលបានកត់ត្រាជាចំណាយថ្លៃដើមនៃសេវាកម្ម និងចំណាយរដ្ឋបាលទូទៅ។ ទោះជាយ៉ាងណា ក. ស. ភ. បានរៀបចំផែនការធនធានមនុស្សត្រឹមត្រូវតាមទំហំការងារ និងការរៀបចំប្រាក់បៀវត្ស យោងតាមបរិមាណកុងតឺន័រឆ្លងកាត់ (ធីអ៊ីយូ) ដែលជួយឱ្យការចំណាយលើបុគ្គលិកមិនមានការប៉ះពាល់ខ្លាំងលើប្រាក់ចំណេញ។

### ២.២. ចំណាយថ្លៃដងយោង

ចំណាយថ្លៃដើមនៃសេវាកម្មដ៏ធំមួយផ្នែកទៀត គឺចំណាយថ្លៃដងយោងដែលស្មើនឹង **៨,៩៦%** បើធៀបទៅនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០២២។ ក. ស. ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាដៃគូអាជីវកម្មចំនួន ៣ ក្នុងការប្រើប្រាស់ដងយោងសម្រាប់សេវាកម្មលើកដាក់លើស្ពានផែ។ យោងតាមកិច្ចសន្យាភាគរយនៃការបែងចែកប្រាក់ចំណូលទៅកាន់ក្រុមហ៊ុនជាដៃគូនៅត្រឹម ៨០% បន្ទាប់ពីការធ្វើប្រតិបត្តិការបានរយៈពេល ៣ ទៅ ៤ឆ្នាំ។ ក. ស. ភ. រំពឹងថាចំណាយថ្លៃដងយោងនឹងបន្តកើនឡើង ព្រោះកំណើនបរិមាណទំនិញឆ្លងកាត់ត្រូវបានព្យាករណ៍ថាបន្តឡើងខ្ពស់ក្នុងពេលខាងមុខ។ យ៉ាងណាមិញ ការចំណាយនេះគឺប៉ះពាល់ដល់ផលចំណេញតិចតួចប៉ុណ្ណោះ ព្រោះការកើនឡើងនៃបរិមាណកុងតឺន័របានធ្វើឱ្យចំណូលរបស់ ក. ស. ភ. មានការកើនឡើងដូចគ្នាផងដែរ។ តារាងខាងក្រោមនេះបង្ហាញពីភាគរយនៃការបែងចែកប្រាក់ចំណូល៖

| ម្ចាស់ដងយោង | ឈ្មោះដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ដងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកិច្ចសន្យា |
|---|---|---|---|---|---|---|
| Sovereign | ដងយោងបណ្តែតទី១ | ១ | ៨០ | ៨០% | ២០% | ០១/០១/២០២២-៣១/១២/២០២៣ |
| | ដងយោងបណ្តែតទី២ | ១ | ៦០ | ៨០% | ២០% | |

| ម្ចាស់ផងយោង | ឈ្មោះផងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ផងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកិច្ចសន្យា |
|---|---|---|---|---|---|---|
| Jeong Myeong International Co..Ltd | ផងយោងចល័តទី១ | ១ | ៤១ | ៩០% | ១០% | ០១/០១/២០១៣-៣១/១២/២០១៣ |
| | | | | ៨៥% | ១៥% | ០១/០១/២០១៤-៣១/១២/២០១៤ |
| | | | | ៨០% | ២០% | *០១/០១/២០១៥-៣១/១២/២០២៤* |
| Port Stevedoring Company Limited | ផងយោង FCC | ៣ | ៤០ | ៩០% | ១០% | *០៧/០៩/២០២១- ០៧/០៩/២០២៤* |
| | | | | ៨៥% | ១៥% | *០៨/០៩/២០២៤- ០៨/០៩/២០២៥* |
| | | | | ៨០% | ២០% | *០៩/០៩/ ២០២៥-០៩/០៩/ ២០៤១* |

## ៣. កាតព្វកិច្ចពន្ធផ្សេងៗ

ក. ស. ភ.ស្ថិតក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងបញ្ហាពន្ធដារ។ ក. ស. ភ. ស្ថិតនៅក្រោមរបបស្វ័យប្រកាស និងចាត់ទុកជាអ្នកជាប់ពន្ធធំចំពោះការបង់ពន្ធ។ ដូចនេះ ក. ស. ភ. មានកាតព្វកិច្ចបង់ពន្ធ និងអាករតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ៣.១. ពន្ធលើប្រាក់ចំណេញ

ក. ស. ភ. មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% ដោយបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% នៃផលរបរប្រចាំខែ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែនឹងត្រូវទូទាត់កាត់កងជាមួយពន្ធលើប្រាក់ចំណេញ ២០% នៃចុងឆ្នាំសារពើពន្ធនីមួយៗ។ ក. ស. ភ. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់សម្រាប់រយៈពេល ៣ឆ្នាំគិតចាប់ពីថ្ងៃដែល អនុក្រឹត្យនេះចូលជាធរមាន។ ជាមួយគ្នានេះដែរ ចាប់ពីឆ្នាំ២០១៩ មក ក. ស. ភ. ឈប់ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចនេះ ក. ស. ភ. នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។

### ៣.២. អាករលើតម្លៃបន្ថែម

ក. ស. ភ. ជាក្រុមហ៊ុនដែលចុះបញ្ជីអាករលើតម្លៃបន្ថែម។ ក. ស. ភ. បានគិតអាករលើតម្លៃបន្ថែមតាមអត្រា១០% នៃចំនួនទឹកប្រាក់លើវិក្កយបត្រពេលដែលចេញវិក្កយបត្រទៅអតិថិជន។ ក. ស. ភ. ជាភ្នាក់ងារប្រមូលពន្ធនេះជូនរាជរដ្ឋាភិបាល ព្រោះនេះជាអាករលើធាតុចេញរបស់ ក. ស. ភ.។ អាករលើធាតុចេញនេះ នឹងត្រូវកាត់កងជាមួយអាករលើធាតុចូល ១០% នៅពេលដែល ក. ស. ភ. បង់ប្រាក់ទៅអ្នកផ្គត់ផ្គង់សម្រាប់ការទិញ។

### ៣.៣. ពន្ធកាត់ទុកលើចំណូលការប្រាក់

ក. ស. ភ. មានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់តាមអត្រា ៤% លើបញ្ញើទូទៅ និង ៦% លើបញ្ញើមានកាលកំណត់។ បច្ចុប្បន្ន ក. ស. ភ. មានបញ្ញើមានកាលកំណត់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ។

### ៣.៤. ពន្ធនាំចូល

ក. ស. ភ. មានកាតព្វកិច្ចបង់ពន្ធនាំចូលលើសម្ភារ និងវត្ថុធាតុដើមតាមអត្រាចន្លោះពី ៧% ទៅ ៣៥% អាស្រ័យលើប្រភេទទំនិញនីមួយៗ ដែលកំណត់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលបន្ទាប់នៅចំណតផែកុងតឺន័រ LM១៧ នៅឆ្នាំ២០២២ ក. ស. ភ. នឹងគ្រោងនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ ដូចនេះចំណាយលើពន្ធនាំចូលនឹងមានការកើនឡើង។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ ក. ស. ភ. រួមមានប្រាក់ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring) ការលើកដាក់នៅទីលាន (LOLO) និងចំណូលកិច្ចការផែដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកុងតឺន័រ ដែលស្មើប្រមាណ **៩១%** ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០២២។ កត្តាសំខាន់នៃការកើនឡើងប្រាក់ចំណូល គឺបានមកពីកំណើនចំនួនកុងតឺន័រ ទំនិញរាយ នាវាឆ្លងកាត់ និងចំណុះនាវា ស្របតាមការលូតលាស់វិស័យសំណង់ វិស័យកសិកម្ម វិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្មវាយនភណ្ឌ (សម្លៀកបំពាក់ និងស្បែកជើង)។ ជាមួយគ្នានេះដែរ ការដាក់ឱ្យដំណើរការនូវកំពង់ផែមេ **កៃម៉េប** ប្រទេសវៀតណាម ក៏ជាប្រភពនៃកំណើនបរិមាណកុងតឺន័រឆ្លងកាត់ ក. ស. ភ. ផងដែរ។ ជាក់ស្តែង ការដឹកជញ្ជូនឆ្លងកាត់ ក. ស. ភ. ទៅកាន់កំពង់ផែមេ **កៃម៉េប** មានការចំណេញពេលវេលាដោយដឹកជញ្ជូនផ្ទាល់ទៅកាន់ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកប៉ែកខាងកើត និងសហរដ្ឋអាមេរិកប៉ែកខាងលិច។

## ឃ.ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ១. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

ក. ស. ភ. បានកត់ត្រាបញ្ជីគណនេយ្យ ដោយប្រើប្រាស់រូបិយបណ្ណដុល្លារអាមេរិក ដោយសារចំណូលពីប្រតិបត្តិការអាជីវកម្ម និងសេវាកម្មភាគច្រើនជាប្រាក់ដុល្លារអាមេរិក និងការទូទាត់លើការងារជួសជុលគ្រឿងចក្រធំៗ ប្រេងឥន្ធនៈ និងចំណាយផ្សេងៗមួយចំនួនទៀត ក៏ជាប្រាក់ដុល្លារអាមេរិកដែរ លើកលែងតែការចំណាយលើប្រាក់បៀវត្ស និងការបង់ពន្ធ។ ហេតុដូចនេះផលប៉ះពាល់ពីអត្រាប្តូរប្រាក់សម្រាប់ ក. ស. ភ. គឺមានកម្រិតអប្បបរមា។

### ២. ផលប៉ះពាល់ពីអត្រាការប្រាក់

ក. ស. ភ. មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ថេរតាមតម្លៃទីផ្សារ ដោយសារភាពលម្អៀងត្រូវបានបញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាតនោះទេ ហើយ ក. ស. ភ. ក៏ពុំមានឧបករណ៍ហិរញ្ញវត្ថុដេរី

វេទិវ នាចុងការិយបរិច្ឆេទនេះដែរ។ ដូច្នេះ ការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយបរិច្ឆេទ ពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតរបស់ ក. ស. ភ. ឡើយ។

### ៣. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ប្រតិបត្តិការរបស់ ក. ស. ភ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រ ដែលមានតម្រូវការប្រើប្រាស់ប្រេងឥន្ធនៈខ្ពស់ ដូចនេះការប្រែប្រួលតម្លៃប្រេងឥន្ធនៈ នឹងប៉ះពាល់ដល់ថ្លៃដើមសេវាកម្ម។ អាស្រ័យហេតុនេះ ក. ស. ភ. បានពង្រឹងការគ្រប់គ្រងលើចំណាយប្រតិបត្តិការតាមរយៈការបង្កើនប្រសិទ្ធភាពការងារលើកដាក់ ការរៀបចំទីលានស្តុកកុងតឺន័រ ដែលអាចកាត់បន្ថយការលើកដាក់ និងការចល័តគ្រឿងចក្រច្រើនដែលមិនចាំបាច់។ ជាមួយគ្នានេះដែរ ក. ស. ភ. បានបំពាក់គ្រឿងចក្រទំនើបៗក្នុងការលើកដាក់ដែលប្រើប្រាស់ថាមពលអគ្គិសនីជំនួសវិញ។

## ខ. ផលប៉ះពាល់ពីអតិផរណា

កំណើននៃអត្រាអតិផរណាអាចមានផលប៉ះពាល់ដល់ការចំណាយ និងការវិនិយោគរបស់ ក. ស. ភ. ព្រោះតម្លៃទំនិញមានការកើនឡើង ហើយអំណាចទិញបានថយចុះ។ ប៉ុន្តែយោងតាមរបាយការណ៍របស់ធនាគារពិភពលោក កម្ពុជាមានអត្រាអតិផរណាជាមធ្យម ២,៦% ក្នុងឆ្នាំ២០២២ ដែលកម្រិតអតិផរណានេះ ពុំប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ ក. ស. ភ. នោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ក. ស. ភ. បាននិងកំពុងទទួលផលពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមានដូចខាងក្រោម៖

- គោលនយោបាយស្តីពីការជំរុញការនាំចេញអង្ករបាននិងកំពុងផ្តល់ផលវិជ្ជមានដល់កំណើននៃការនាំចេញផលិតផលនេះតាម ក.ស.ភ.
- គោលនយោបាយក្នុងការអនុគ្រោះពន្ធលើការនាំចូលឧបករណ៍/គ្រឿងចក្រកសិកម្ម នាំឱ្យមានការវិនិយោគខ្លាំងលើវិស័យកសិកម្ម
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកការអនុគ្រោះពន្ធ និងកូតាពីប្រទេសជាដៃគូ បាននិងកំពុងជំរុញឱ្យមានការនាំចេញខ្ពស់
- ការរៀបចំឱ្យមានតំបន់សេដ្ឋកិច្ចពិសេស និងភណ្ឌាគារគយមានដែនកំណត់ បាននិងកំពុងទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស
- គោលនយោបាយឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ បាននិងកំពុងទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅប្រទេសកម្ពុជា និងការបង្កើតរោងចក្រធុនធ្ងន់ព្រមទាំងសហគ្រាសធុនតូច និងមធ្យម
- គោលនយោបាយរបស់រាជរដ្ឋាភិបាលជំរុញការដឹកជញ្ជូនតាមផ្លូវទឹក
- ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុតឹងរឹង និងអត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង។ គោលនយោបាយនេះ បាននិងកំពុងរួមចំណែកក្នុងការបង្កើនទំនុកចិត្តសាធារណៈក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងជំរុញការធ្វើអាជីវកម្មពីវិស័យឯកជន

- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននិងកំពុងជម្រុញឱ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋចូលទីផ្សារមូលបត្រកាន់តែច្រើន ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ផ្នែកទី ៩

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

សម្រាប់ឆ្នាំ២០២២ ក. ស. ភ. មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម៖

- បានពិនិត្យ និងពិភាក្សាលើករណីទឹកប្រាក់ជំពាក់របស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប ទឹកប្រាក់ចំនួន ៤.៧៣១.៣៧៦ ដុល្លារអាមេរិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១) និងទឹកប្រាក់ចំនួន ១២៦.៥០១ ដុល្លារអាមេរិក (គិតត្រឹមថ្ងៃទី១០ ខែមករា ឆ្នាំ២០២២)
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន មេគង្គ អូរីហ្សា ត្រេឌីង ផ្ទេរសិទ្ធិជួលដី ដែលបានជួលពី ក. ស. ភ. ឱ្យទៅក្រុមហ៊ុន PTLS Cooperation Co., Ltd. ដោយសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងរាល់លក្ខខណ្ឌនានា ដែលបានកំណត់នៅក្នុងកិច្ចសន្យាដើម ភាគីក្រុមហ៊ុន PTLS Cooperation Co., Ltd. ត្រូវធានាបន្តអនុវត្ត
- បានពិនិត្យ និងអនុម័ត លើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្មឆ្នាំ២០២១
- បានពិនិត្យ និងពិភាក្សាលើការបន្តអាណត្តិរបស់ក្រុមប្រឹក្សាភិបាល ក. ស. ភ.
- បានពិនិត្យ និងសម្រេចលើសំណើសុំសហការវិនិយោគជាមួយក្រុមហ៊ុន PTLS Cooperation Co., Ltd. ដើម្បីអភិវឌ្ឍចំណតផែរណបពហុបំណង UM១ របស់ ក. ស. ភ. តាមគោលការណ៍ ដែលបានសម្រេចលើកិច្ចសហការវិនិយោគចំណតផែរណបពហុបំណង TS១១
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ចុះបញ្ជីជាសាខាចំណតផែកុងតឺន័រ LM១៧ និងចំណតផែរណបផ្សេងទៀត នៅពេលមានប្រតិបត្តិការអាជីវកម្ម
- បានពិនិត្យ និងសម្រេចសម្រេចឱ្យសាខាគយ និងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ ស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការស្នើសុំលើកលែងថ្លៃសេវាស្តុកទុកកុងតឺន័ររបស់ ក. ស. ភ.
- បានពិនិត្យ និងពិភាក្សាលើការសាងសង់ស្ពានផែថ្មីទំហំ ១៦ ម៉ែត្រ x ១៤៩ ម៉ែត្រ ដែលស្ថិតក្នុងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធផែជំហានទី៣ ដំណាក់កាលទី២ នៅចំណតផែកុងតឺន័រ LM១៧ និងកិច្ចសហការជាមួយឯកជនលើការបំពាក់ដងយោង FCC ចំនួន ៣ គ្រឿង
- បានពិនិត្យ និងសម្រេចលើការដាក់ប្រាក់ចំនួន ៥ លានដុល្លារអាមេរិក ជាប្រាក់បញ្ញើមានកាលកំណត់ ដើម្បីបង្គ្រប់ទឹកប្រាក់ ១៥ លានដុល្លារអាមេរិកវិញ នៅធនាគារ FTB និងស្នើសុំប្រើប្រាស់ Overdraft ក្នុងករណីមានតម្រូវការ
- បានពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ របស់ ក. ស. ភ.
- បានពិនិត្យ និងពិភាក្សាលើការបែងចែកប្រាក់ថ្លែងសរសើរជូនបុគ្គលិក ក. ស. ភ. និងប្រាក់ចំណេញចូលមូលនិធិនានា សម្រាប់ឆ្នាំ២០២១
- បានពិនិត្យ និងពិភាក្សាលើគម្រោងបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ “ក” និងប្រភេទ “ខ” ប្រចាំឆ្នាំ២០២១
- បានពិនិត្យ និងសម្រេចលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៧ របស់ ក. ស. ភ.
- បានពិនិត្យ និងពិភាក្សាលើការស្នើសុំលើកលែងថ្លៃឈ្នួល ៥០% សម្រាប់ឆ្នាំ២០២១ និងបន្តលើកលែងថ្លៃឈ្នួល ៥០% សម្រាប់ឆ្នាំ២០២២ នៃថ្លៃឈ្នួលដីទីលានស្តុកសំបកកុងតឺន័រ (ICD) ទំហំ ៩,៣ ហិកតា របស់ក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន(ខេមបូឌា) ឯ.ក
- បានសម្រេចអនុម័តលើរបាយការណ៍អាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២២ របស់ ក. ស. ភ.

- បានអនុម័តកិច្ចព្រមព្រៀងស្តីពី កិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង UM២ រវាង ក. ស. ភ. និងក្រុមហ៊ុនភីធីអិលអេស ខូអបភើរេសិន (PTLS Cooperation Co., Ltd.) ដើម្បីគោរពស្នើសុំការយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ
- បានពិនិត្យ និងសម្រេចជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យចំនួន ៣ រូប និងបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនចំនួន ២ រូប ដើម្បីឈរឈ្មោះបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៧ របស់ ក. ស. ភ.
- បានសម្រេចទទួលស្គាល់នូវសមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិទី៨ របស់ ក. ស. ភ. និងសមាសភាពក្រុមលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាភិបាលអាណត្តិទី៨
- បានពិនិត្យ និងសម្រេចលើសំណើសុំសហការជាមួយក្រុមហ៊ុនឯកជន លើការសាងសង់អគាររដ្ឋបាលថ្មីរបស់ ក. ស. ភ. និងសាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall)
- បានពិនិត្យ និងសម្រេចលើសំណើសុំជ្រើសរើសក្រុមហ៊ុនសវនកម្មឯករាជ្យថ្មីរបស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចលើសំណើសុំធ្វើការសិក្សាទីតាំងចំណតផែតាមដងទន្លេចំនួន ៦ ទីតាំង ដើម្បីអភិវឌ្ឍជាចំណតផែរណបរបស់ ក. ស. ភ.
- បានសម្រេចអនុម័តរបាយការណ៍ ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុសម្រាប់រយៈពេល ៩ខែ ដើមឆ្នាំ២០២២ និងប៉ាន់ស្មានលទ្ធផលប្រចាំឆ្នាំ២០២២ និងគម្រោងផែនការអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣
- បានទទួលជ្រាបជារបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងសាងសង់សាលរង់ចាំ និងស្ថានីយ៍អ្នកដំណើរ (Tourist Hall)
- បានទទួលជ្រាបជារបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងសាងសង់របស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប និងក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក និងទឹកប្រាក់ដែលក្រុមហ៊ុនទាំងពីរនៅជំពាក់ ក. ស. ភ.
- បានទទួលជ្រាបជារបាយការណ៍ស្តីពីការស្នើសុំជួលដីបន្តរបស់ក្រុមហ៊ុន PTLS Cooperartion Co., Ltd. និងអ្នកស្រី លី ចាន់នី ដែលក្រុមហ៊ុន ហ៊្វយ បាង អ៊ិនធើណេសិនណល អ៊ិនវេសម៉ិន គ្រុប បានផ្ទេរមកឱ្យ ក. ស. ភ. ចំនួន ៥០% នៃផ្ទៃដីសរុបដែលបានជួលពី ក. ស. ភ.
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាបន្ថែមលើគោលការណ៍គ្រប់គ្រងមូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម។

# ហត្ថលេខារបស់អភិបាលកំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ី បាវី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**សួន រចនា**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ភែន សម្បត្តិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ប៉ែន សុទិជាតិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ហ្គី អានន់ទ៉ានិថ**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ប៉ុក ភក្តី**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន

ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**គង់ សុធា**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងនិយោជិត ក.ស.ភ.

# ឧបសម្ព័ន្ធ ១

# របាយការណ៍អភិបាលកិច្ចសាជីវកម្ម ប្រចាំឆ្នាំ២០២២

## ឧបសម្ព័ន្ធ ១ នៃរបាយការណ៍ប្រចាំឆ្នាំ២០២២
## របស់កំពង់ផែស្វយ័តភ្នំពេញ
## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

### ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

#### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១.០៧៦ | ១.០៦៩.០៦៣ | ៥,១៧% |
| | | នីតិបុគ្គល | ៥ | ៥៣៦.៩៨៨ | ២,៦០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣០៧ | ១.០៥៤.៩០៥ | ៥,១០% |
| | | នីតិបុគ្គល | ៤ | ១.៤៧៥.៩១៧ | ៧,១៣% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១៦.៥៤៧.៤៩២ | ៨០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

#### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់កំពង់ផែស្វយ័តភ្នំពេញ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៥ | ១៣០.៥៣៥ | ០,៦៣% |
| បុគ្គលិកជាន់ខ្ពស់ | ៨ | ៦២.៨៥៦ | ០,៣០% |
| និយោជិត | ៤២ | ៤៦.៩៤៩ | ០,២៣% |
| ***សរុប*** | **៥៥** | **២៤០.៣៤០** | **១,១៦%** |

### ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

#### ១. សិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ក. ស. ភ. ត្រូវបានចែកចេញជា ៣ ប្រភេទរួមមាន៖

##### ១.១. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ក”

- **សិទ្ធិបោះឆ្នោត៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ក” មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ភាគហ៊ុន ស្មើនឹង ១សំឡេង។

- **សិទ្ធិទទួលបានភាគលាភ៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិទទួលបានភាគលាភដែលត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ" ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនក្នុងប្រភេទនីមួយៗ។ ភាគលាភអប្បបរមាត្រូវបានធានាចំពោះតែភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" តែប៉ុណ្ណោះ។ ភាគលាភអប្បបរមានេះ ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំ អាចជាសាច់ប្រាក់ ឬជាភាគហ៊ុនក្នុងអត្រា ៥% នៃចំនួនភាគហ៊ុនប្រភេទ "ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវីឌិនដ៍គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ ការបែងចែកភាគលាភអប្បបរមានេះត្រូវបានធានាក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីពេលដែល ក. ស. ភ. បានចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា។ ការធានាភាគលាភអប្បបរមាជូនភាគហ៊ុនិកប្រភេទ "ក" ត្រូវបានផ្ទេរចេញពីប្រាក់ចំណេញរក្សាទុកតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

(ភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ = ៥% x ចំនួនភាគហ៊ុនប្រភេទ "ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវីឌិនដ៍ x ថ្លៃ IPO)

ក្នុងករណី ក. ស. ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានាជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទនៅថ្ងៃជួញដូរ ១ ថ្ងៃ មុនថ្ងៃអិចឌីវីឌិនដ៍។

(ចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា = ភាគលាភអប្បរមាត្រូវបានធានា ÷ ថ្លៃបិទនៅថ្ងៃជួញដូរ ១ថ្ងៃ មុនថ្ងៃអិចឌីវីឌិនដ៍)

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណាមួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានា នឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

- **សិទ្ធិទទួលបានទ្រព្យសម្បត្តិ៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិទទួលទ្រព្យសម្បត្តិរបស់ ក. ស. ភ. ដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់អាជីវកម្ម ដោយត្រូវគោរពសិទ្ធិបុរិមារបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ"។

### ១.២. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ"

- **សិទ្ធិបោះឆ្នោត៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ ភាគហ៊ុន ស្មើនឹង ១សំឡេង។
- **សិទ្ធិទទួលបានភាគលាភ៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិទទួលបានភាគលាភ ដែលត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ" ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនក្នុងប្រភេទនីមួយៗ។ ប៉ុន្តែភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មិនមានសិទ្ធិទទួលបានភាគលាភជាភាគហ៊ុនទេ ក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីពេលដែល ក. ស. ភ. បានចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា និងក្នុងករណីភាគលាភអប្បបរមាត្រូវបានធានា មិនទាន់បានបែងចែកពេញលេញជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនិកប្រភេទ "ក"។

- **សិទ្ធិទទួលបានទ្រព្យសម្បត្តិ៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ខ” មានសិទ្ធិទទួលទ្រព្យសម្បត្តិរបស់ ក. ស. ភ. ដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់អាជីវកម្ម ដោយត្រូវគោរពតាមសិទ្ធិបុរិមារបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “គ”។

- **សិទ្ធិធ្វើបរិវត្តភាគហ៊ុន៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ខ” មានសិទ្ធិធ្វើបរិវត្ត ដើម្បីបំលែងភាគហ៊ុនទាំងអស់របស់ខ្លួនទៅជាភាគហ៊ុនប្រភេទ “ក” ដោយ ១ ភាគហ៊ុនប្រភេទ “ខ” អាចបំលែងទៅជា ១ ភាគហ៊ុនប្រភេទ “ក” ដោយគោរពលក្ខខណ្ឌដូចខាងក្រោម៖
    - ការបំលែងត្រូវធ្វើទាំងអស់ និងក្នុងពេលតែមួយ
    - ភាគលាភអប្បរមាដែលត្រូវធានាក្នុងរយៈពេល ៥ ឆ្នាំ ត្រូវបានបែងចែកពេញលេញដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ក”

- **សិទ្ធិលក់ភាគហ៊ុន៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ខ” មានសិទ្ធិលក់ភាគហ៊ុនប្រភេទ “ខ” លើផ្សារមូលបត្រកម្ពុជា ឬលក់ទៅតតិយជន លុះត្រាគោរពលក្ខខណ្ឌភាគលាភអប្បបរមាដែលត្រូវបានធានាក្នុងរយៈពេល ៥ ឆ្នាំ ត្រូវបានបែងចែកពេញលេញដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ក”។

### ១.៣. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “គ”

- **សិទ្ធិបោះឆ្នោត៖** ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “គ” ពុំមានសិទ្ធិបោះឆ្នោតឡើយ លើកលែងតែពាក់ព័ន្ធនឹងករណីណាមួយដូចខាងក្រោមនេះ៖
    - ការធ្វើវិសោធនកម្មលក្ខន្តិកៈ ដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើសិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទនៃភាគហ៊ុនរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “គ”
    - ការស្នើរួមបញ្ចូល ក. ស. ភ. ជាមួយនីតិបុគ្គលផ្សេងទៀត
    - ការស្នើរំលាយ ក. ស. ភ.។

- **សិទ្ធិទទួលបានទ្រព្យសម្បត្តិ៖** ក្នុងករណីរំលាយក្រុមហ៊ុនដោយឆន្ទៈ ឬដោយច្បាប់ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “គ” មានសិទ្ធិបុរិមាក្នុងការទទួលបានទ្រព្យសម្បត្តិរបស់ ក. ស. ភ. ដែលសល់បន្ទាប់ពីការជម្រះបញ្ជី មុនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ “ក” និងប្រភេទ “ខ” ដែលទទួលបាននូវការបែងចែក ឬទូទាត់ជាមុនស្មើនឹងចំនួនទឹកប្រាក់សរុបតាមចំនួនភាគហ៊ុនប្រភេទ “គ” ដែលគិតតាមតម្លៃចារឹកក្នុងមួយភាគហ៊ុន។

- បើទ្រព្យសម្បត្តិដែលសល់បន្ទាប់ពីការជម្រះបញ្ជីក្រុមហ៊ុន មានមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងគ្រប់ចំនួន ដូចបានកំណតឱ្យភាគហ៊ុនប្រភេទ “គ” ទ្រព្យសម្បត្តិទាំងអស់នឹងត្រូវបែងចែកតែម្ចាស់ភាគហ៊ុនប្រភេទ “គ” ប៉ុណ្ណោះ។

សិទ្ធិ និងលក្ខណៈរបស់ប្រភេទភាគហ៊ុននីមួយៗ ដែលបានកំណត់ដូចខាងលើ អាចត្រូវបានកែប្រែដោយសេចក្តីសម្រេច ពីរភាគបី របស់មហាសន្និបាតភាគហ៊ុនិក តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាភិបាល។

### ១.៤. សិទ្ធិផ្សេងទៀតរបស់ភាគហ៊ុនិក

- **សិទ្ធិបុព្វក្រ័យ៖** ភាគហ៊ុនិកទាំងអស់ មានសិទ្ធិបុព្វក្រ័យក្នុងការទិញបានមុននូវភាគហ៊ុនថ្មី ដែលបោះផ្សាយលក់ដោយ ក. ស. ភ. ស្របតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន ហើយដែលភាគហ៊ុនថ្មីទាំងនោះស្ថិតក្នុងប្រភេទតែមួយជាមួយនឹងភាគហ៊ុនដែលខ្លួនកំពុងកាន់កាប់។
- **សិទ្ធិទទួលព័ត៌មាន៖** ភាគហ៊ុនិកទាំងអស់ មានសិទ្ធិទទួលបានព័ត៌មានសាជីវកម្ម ដែលទាក់ទងនឹង ក. ស. ភ.
- តាមបែបបទកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- សិទ្ធិផ្សេងៗទៀតរបស់ភាគហ៊ុនិក ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

សម្រាប់ឆ្នាំ ២០២២ នេះ ភាគហ៊ុនិករបស់ ក. ស. ភ. បានចូលរួមក្នុងមហាសន្និបាតលើកទី ៧ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ដើម្បីទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២១ និងទិសដៅអនុវត្តការងារបន្តឆ្នាំ២០២២ ព្រមទាំងបានចូលរួមបោះឆ្នោតអនុម័ត លើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ ២០២១ និងការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាល ក. ស. ភ.។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត

ភាគហ៊ុនិកភាគតិចរបស់ ក. ស. ភ. ក៏ទទួលបានការការពារសិទ្ធិស្មើគ្នាៗដូចនឹងភាគហ៊ុនិកភាគច្រើនរបស់ ក. ស. ភ. ផងដែរ។

## គ. មហាសន្និបាតភាគហ៊ុនិក

### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

មហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើង ១ (មួយ) ឆ្នាំ ម្តងក្នុងអំឡុងត្រីមាសទី១ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធដែលកាលបរិច្ឆេទ និងរបៀបវារៈត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។

មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ អាចប្រព្រឹត្តទៅបានក្នុងករណីមានសេចក្តីស្នើសុំដែលកាន់កាប់ភាគហ៊ុនយ៉ាងតិចចំនួន ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនប្រភេទ “ក” និងប្រភេទ “ខ”។

សេចក្តីស្នើសុំកោះប្រជុំរបស់ភាគហ៊ុនិក ត្រូវផ្ញើជូនយ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃ មុនថ្ងៃប្រជុំ ទៅក្រុមប្រឹក្សាភិបាល ដោយមានចុះហត្ថលេខា និងភ្ជាប់របៀបវារៈជាមួយផង។

បើមហាសន្និបាតភាគហ៊ុនិក ពុំអាចប្រព្រឹត្តទៅបានតាមនីតិវិធី ដូចចែងខាងលើ នោះសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកណាម្នាក់ដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ឬក្រសួងពាណិជ្ជកម្ម អាចស្នើសុំតុលាការឱ្យចាត់ចែងកោះប្រជុំមហាសន្និបាតភាគហ៊ុនិក តាមនីតិវិធីណាមួយដែលតុលាការពិចារណាឃើញថាសមស្រប។

មហាសន្និបាតភាគហ៊ុនិកប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល។ ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន នោះអគ្គនាយកត្រូវធ្វើជាអធិបតី។

ប្រធានមហាសន្និបាតភាគហ៊ុនិក ពុំមានសិទ្ធិបោះឆ្នោតទេ លើកលែងទទួលការផ្ទេរសិទ្ធិពីភាគហ៊ុនិកណាម្នាក់ ឬខ្លួនជាភាគហ៊ុនិក។

មហាសន្និបាតភាគហ៊ុនិកត្រូវប្រព្រឹត្តទៅនៅទីស្នាក់ការចុះបញ្ជីរបស់ ក. ស. ភ. លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយក្រុមប្រឹក្សាភិបាល តាមកាលៈទេសៈតម្រូវ។

សេចក្តីជូនដំណឹងពីមហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវផ្ញើទៅភាគហ៊ុនិកតាមរយៈលិខិត ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬតាមគ្រប់មធ្យោបាយសមស្របណាមួយ ដោយមានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈ។

សេចក្តីជូនដំណឹង ត្រូវផ្ញើទៅភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោត ទៅអភិបាល ទៅសវនករផ្ទៃក្នុង និងសវនករឯករាជ្យរបស់ ក. ស. ភ. យ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃ មុនកាលបរិច្ឆេទរបស់មហាសន្និបាតភាគហ៊ុនិក។

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទនៃកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ | សាមញ្ញ | ៥០+១ | - លទ្ធផលការងារប្រចាំ ឆ្នាំ២០២១និងទិសដៅអនុវត្តការងារឆ្នាំ២០២២<br>- សំណើសុំពិនិត្យ និងអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១<br>- ការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាល ក. ស. ភ. | - ការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១ ដល់ភាគហ៊ុនិកប្រភេទ "ក" ចំនួន ៦,៥%<br>- មហាសន្និបាតភាគហ៊ុនិកបានធ្វើការបោះឆ្នោតជ្រើសរើស **លោក ហ៊ី អានវ៉ានិច** ជាអភិបាលឯករាជ្យ និង**អ្នកស្រី ប៉ុក ភក្តី** ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាល ក. ស. ភ. |

## ឃ. ការបែងចែកភាគលាភ

### ១. គោលនយោបាយបែងចែកភាគលាភ

ដើម្បីលើកទឹកចិត្តដល់វិនិយោគិនដែលទិញភាគហ៊ុនប្រភេទ "ក" របស់ ក. ស. ភ. ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយភាគលាភពិសេស ដែលធានានូវទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំ ស្មើនឹងចំនួន ៥% នៃ

ទំហំវិនិយោគដោយគិតតាមថ្លៃមូលបត្រនៃ IPO សម្រាប់រយៈពេល ៥ ឆ្នាំ បន្ទាប់ពីការចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះ គឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ "ក" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ "គ" មិនទទួលបានការធានាភាគលាភនេះទេ។ ភាគលាភអប្បបរមានេះ ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំ អាចជាសាច់ប្រាក់ ឬជាភាគហ៊ុន។

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ គឺស្មើនឹងអត្រា ៥% នៃចំនួនភាគហ៊ុនប្រភេទ "ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវិឌិនដ៍ (Ex-Dividend Date) គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

ប្រសិនបើភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណាមួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានានឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ក្នុងករណីដែល ក. ស. ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានាជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទការជួញដូរ១ថ្ងៃ នៅមុនថ្ងៃអិចឌីវិឌិនដ៍ (Ex-Dividend Date)។

ក្រោយពីបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយក្រុមប្រឹក្សាភិបាល បើពិនិត្យឃើញថាមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលនៃ ក. ស. ភ. អាចសម្រេចបែងចែកប្រាក់ចំណេញនោះដើម្បី៖

- ទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន
- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន ហើយប្រសិនបើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖
  - ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិតតាមលក្ខខណ្ឌខាងក្រោម៖
    - បើប្រាក់ចំណេញនៅសល់មានចំនួនចាប់ពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ ក. ស. ភ. សរុបក្នុងឆ្នាំ នោះប្រាក់ថ្លៃងសរសើរត្រូវស្មើនឹង ១ខែ នៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ សរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញនៅសល់មានចំនួនលើសពី១០% ដល់ ២០% នៃចំណាយដំណើការសរុបរបស់ ក. ស. ភ. ក្នុងឆ្នាំ នោះប្រាក់ថ្លៃងសសើរត្រូវស្មើនឹង ២ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំ និងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញលើសពី២០% នៃចំណាយដំណើរការសរុបរបស់ ក. ស. ភ. ក្នុងឆ្នាំនោះប្រាក់ថ្លៃងសសើរស្មើនឹង ៣ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ។
  - បង្កើតមូលនិធិបម្រុងតាមច្បាប់ចំនួន ៥% និងមូលនិធិបម្រុងសេរីចំនួន ៥% នៃប្រាក់ចំណេញសុទ្ធ
  - មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រត្តិការចំណាយនោះ

- ប្រាក់ចំណេញដែលសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភឱ្យភាគហ៊ុនិក ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ប្រាក់ចំណេញនៅសល់ចុងក្រោយ ត្រូវបង្វិលចូលមូលនិធិអភិវឌ្ឍន៍ ក. ស. ភ.។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ១១ ឧសភា ២០២២ | ៥ ឧសភា ២០២១ | ២៦ មិថុនា ២០២០ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ២៤ ឧសភា ២០២២ | ២០ ឧសភា ២០២១ | ១ កក្កដា ២០២០ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ២ មិថុនា ២០២២ | ២៨ ឧសភា ២០២១ | ៨ កក្កដា ២០២០ |

## ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

## ក. ក្រុមប្រឹក្សាភិបាល

### ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ី បាវី** | ប្រធាន | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ២. | ឯកឧត្តម **សួន រចនា** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ៣. | ឯកឧត្តម **កែន សម្បត្តិ** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ៤. | ឯកឧត្តម **ប៉ែន សុវិជាតិ** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ៥. | លោក **ហ៊ុំ អានវ៉ានិថ** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ៦. | លោកស្រី **ប៉ុក ភក្តី** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |
| ៧. | លោក **គង់ សុធា** | សមាជិក | ២៧ មិថុនា ២០២២ | ២៦ មិថុនា ២០២៥ |

### ២. ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ



**ឯកឧត្តម ហ៊ី បាវី**
**ប្រធានក្រុមប្រឹក្សាភិបាល**
**អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៥
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៧៤ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ
  - ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
  - ឆ្នាំ២០០៩ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាកម្ពុជា។
- **បទពិសោធន៍ការងារ**
  - ឆ្នាំ១៩៧៩ បានចាប់បម្រើការងារនៅ ក. ស. ភ. រហូតមកដល់បច្ចុប្បន្ន
  - ពីឆ្នាំ២០០០ - បច្ចុប្បន្ន ជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ក. ស. ភ.។



**ឯកឧត្តម សួន រចនា**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៥៤
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៧៣ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យ ១៨ មីនា (បច្ចុប្បន្នវិទ្យាល័យព្រះយុគន្ធរ)
  - ឆ្នាំ១៩៧៥ បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រ។
- **បទពិសោធន៍ការងារ**
  - ឆ្នាំ២០០៩ - បច្ចុប្បន្ន ជារដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន
  - ឆ្នាំ២០១៥ - បច្ចុប្បន្ន ជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក. ស. ភ.។



**ឯកឧត្តម កែន សម្បត្តិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៦៨
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៩៥ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសកលវិទ្យាល័យ Lomonosov State ប្រទេសរុស្ស៊ី

- ឆ្នាំ២០០០ បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ ពីសកលវិទ្យាល័យ Saitama ប្រទេសជប៉ុន
- ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីសកលវិទ្យាល័យ International ប្រទេសអង់គ្លេស។

❖ **<u>បទពិសោធន៍ការងារ</u>**

- ឆ្នាំ២០០៩ -២០១៣ បំពេញតួនាទីជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឆ្នាំ២០១៣-បច្ចុប្បន្ន +ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  + ជាសមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.។



**ឯកឧត្តម ប៉ែន សុវិជាតិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងពាណិជ្ជកម្ម**

❖ **<u>ជនជាតិ</u>** ខ្មែរ

❖ **<u>សញ្ជាតិ</u>** ខ្មែរ

❖ **<u>ថ្ងៃខែឆ្នាំកំណើត</u>** ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៣

❖ **<u>ប្រវត្តិនៃការសិក្សា</u>**

- ១៩៩០ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីវិទ្យាស្ថានសេដ្ឋកិច្ចប្រទេសកម្ពុជា
- ១៩៩៧ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យ New England ប្រទេសអូស្ត្រាលី។

❖ **<u>បទពិសោធន៍ការងារ</u>**

- ១៩៩៨ - ២០០០ បំពេញតួនាទីជា អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- ២០០០ - ២០០៧ ជាអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា
- ២០០៧ - ២០១២ ជាប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់នៃក្រសួងពាណិជ្ជកម្ម
- ដើមឆ្នាំ២០១២ - ២០១៤ បានបម្រើការងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- ២០១៤ - វិច្ឆិកា ២០១៩ អគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃ ក្រសួងពាណិជ្ជកម្ម
- ២០១៤ - បច្ចុប្បន្ន + ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
  + ជាសមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.

- វិច្ឆិកា ២០១៩ ជាអនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម
- ៥ មករា ២០២៣-បច្ចុប្បន្ន ជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម។



**លោក ហ៊ី អានវ៉ានិថ**
**សមាជិកក្រុមប្រឹក្សាភិបាល**
**អភិបាលឯករាជ្យ**

❖ **ជនជាតិ** ខ្មែរ

❖ **សញ្ជាតិ** ខ្មែរ

❖ **ថ្ងៃ ខែ ឆ្នាំកំណើត** ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៣

❖ **ប្រវត្តិនៃការសិក្សា**
- ១៩៥៩-១៩៧០ បានបញ្ចប់ការសិក្សានៅវិទ្យាល័យដេកាត (Lycée Descartes) រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- ១៩៧២ គណិតវិទ្យា ភាសាបារាំង នៅមហាវិទ្យាល័យ ស្តេនីឡា (Stanislas) ទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា
- ១៩៧៦ B.A.Sc. វិស្វកម្មឧស្សាហកម្ម, សាលាពហុបច្ចេកទេសនៃ សកលវិទ្យាល័យ ម៉ុងរ៉េអាល់ បាក់កាឡូរ៉េអា (Universite de Montreal Baccalaureat) ប្រទេសកាណាដា
- ឆ្នាំ១៩៨០ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ វេស្ទើនអុងតារីយ៉ូ (Western Ontario University) ទីក្រុងឡុង ប្រទេសកាណាដា។

❖ **បទពិសោធន៍ការងារ**
- សីហា ១៩៧៦-សីហា ១៩៧៨ ជំនួយការប្រធានផ្នែកបច្ចេកទេស នៃ Bechtel Quebec Ltd/James Bay Energy Corporation
- មិថុនា ១៩៨០-មីនា ១៩៨២ មន្ត្រីវិភាគឥណទាន នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូប្រទេសកាណាដា
- មីនា ១៩៨២-សីហា ១៩៨៣ មន្ត្រីតំបន់ នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ
- សីហា ១៩៨៣-ឧសភា ១៩៨៤ ជំនួយការនាយក នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ
- ឧសភា ១៩៨៤-ឧសភា ១៩៨៦ មន្ត្រីផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារតូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ

- មិថុនា ១៩៨៦-ធ្នូ ១៩៨៨ — នាយកផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារម៉ុងរ៉េអាល់ ក្រុងម៉ុងរ៉េអាល់
- ធ្នូ ១៩៨៨-ឧសភា១៩៩៤ — ជំនួយការរតនាភិបាល នៃ The Laurentian Group Corporation ក្រុងម៉ុងរ៉េអាល់
- មិថុនា ១៩៩៤ -មីនា២០០៤ — នាយក និងជាប្រធានផ្នែកសាជីវកម្មនៃធនាគារ Credit Agricole Indosuez ភ្នំពេញ
- មេសា ២០០៣-កក្កដា ២០០៤ — អគ្គលេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- កក្កដា ២០០៤-មិថុនា ២០០៥ — ប្រធានខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន
- មិថុនា ២០០៥-ធ្នូ ២០០៥ — នាយកជាន់ខ្ពស់នៃធនាគារ ANZ Royal ភ្នំពេញ
- ធ្នូ ២០០៥-មេសា ២០០៩ — អគ្គនាយករង និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)
- មេសា ២០០៩-មករា ២០១៩ — អគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)
- មីនា ២០០៣-បច្ចុប្បន្ន — សាស្ត្រាចារ្យគម្រោងមូលនិធិអភិវឌ្ឍន៍តំបន់ទន្លេមេគង្គ (MPDF)/IFC
- មិថុនា ២០១៦-បច្ចុប្បន្ន — សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.
- មករា ២០១៩-បច្ចុប្បន្ន — អនុប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)។



**លោកស្រី ប៉ុក តគ្គី**
**សមាជិកក្រុមប្រឹក្សាភិបាល**
**អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

- **ជនជាតិ** — ខ្មែរ
- **សញ្ជាតិ** — ខ្មែរ
- **ថ្ងៃ ខែ ឆ្នាំកំណើត** — ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៨២

**ប្រវត្តិនៃការសិក្សា**

- ឆ្នាំ២០០២ — បរិញ្ញាបត្រជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង
- ឆ្នាំ២០០៧ — ACCA (Association of Chartered Certified Accountants) F1-F6

- ឆ្នាំ២០២២ Associate Member of Chartered Certified Accountants, Australia
  Associate Member of Institute of Public Accountants, Australia

❖ **បទពិសោធន៍ការងារ**

- តុលា ២០០២ - មិថុនា ២០០៣ សវនករផ្ទៃក្នុងនៃ World Relief Cambodia/Credit Micro Finance
- កក្កដា ២០០៣ - ឧសភា ២០០៥ ជំនួយការសវនករ, KPMG Cambodia Ltd
- ឧសភា ២០០៦ - មីនា ២០០៨ ប្រធានប្រតិបត្តិផ្នែកទីផ្សារហិរញ្ញវត្ថុនៃក្រុមហ៊ុន British American Tobacco (កម្ពុជា)
- កក្កដា ២០០៦ - មីនា ២០០៨ ប្រធានផ្នែកគ្រប់គ្រងគណនេយ្យ នៃក្រុមហ៊ុន British American Tobacco (កម្ពុជា)
- មីនា ២០០៨ - វិច្ឆិកា ២០០៩ ប្រធានផ្នែកហិរញ្ញវត្ថុ នៃធនាគារ ANZ Royal (កម្ពុជា)
- វិច្ឆិកា ២០០៩ - មេសា ២០១០ ប្រធានផ្នែកគ្រប់គ្រងហិរញ្ញវត្ថុជាន់ខ្ពស់នៃធនាគារ ANZ Royal (កម្ពុជា)
- មេសា ២០១០ - សីហា ២០១៩ នាយកផ្នែកហិរញ្ញវត្ថុ (CFO) នៃធនាគារ ANZ Royal (កម្ពុជា)
- សីហា ២០១៩ - បច្ចុប្បន្ន នាយកផ្នែកហិរញ្ញវត្ថុ (CFO) នៃធនាគារ J Trust Royal Bank



**លោក គង់ សុធា**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងនិយោជិត គ. ស. ភ.**

❖ **ជនជាតិ** ខ្មែរ

❖ **សញ្ជាតិ** ខ្មែរ

❖ **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៨

❖ **ប្រវត្តិនៃការសិក្សា**

- ឆ្នាំ១៩៨៨ កំរិតចំណេះទូទៅ ជាប់សញ្ញាបត្រមធ្យមសិក្សាកំរិតសិក្សាទី II
- ឆ្នាំ១៩៩៣ បញ្ចប់បរិញ្ញាបត្ររងសាលាមធ្យមសិក្សាហិរញ្ញវត្ថុ/គណនេយ្យ
- ឆ្នាំ២០០២ បញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស
- ឆ្នាំ២០០៦ បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ១៩៨៩-១៩៩០ បុគ្គលិកសាលាបច្ចេកទេសគមនាគមន៍ នៃក្រសួងគមនាគមន៍
- ឆ្នាំ១៩៩៣-២០០៤ បុគ្គលិកគណនេយ្យ/ហិរញ្ញវត្ថុ នៃកំពង់ផែស្វយ័តភ្នំពេញ
- ឆ្នាំ២០០៤-២០១១ អនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ

- ឆ្នាំ២០១១-២០១៣ ប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
- ឆ្នាំ២០១៤-២០១៥ ប្រធានការិយាល័យបុគ្គលិក/ធនធានមនុស្ស
- ឆ្នាំ២០១៥-២០១៩ ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស
- ឆ្នាំ២០១៩-កុម្ភៈ ២០២៣ នាយករដ្ឋបាល
- កុម្ភៈ ២០២៣-បច្ចុប្បន្ន នាយកសវនកម្មផ្ទៃក្នុង។

## ៣. ករណីអភិបាលណាម្នាក់ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬ កម្មសិទ្ធករ ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោក **ហ៊ី អានវ៉ានិច** | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) | អនុប្រធានក្រុមប្រឹក្សាភិបាល |

## ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ក្រុមប្រឹក្សាភិបាលមានតួនាទី និងភារកិច្ចកំណត់ទិសដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យការគ្រប់គ្រងទូទៅរបស់ ក. ស. ភ.។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាលមានអំណាច៖

- សម្រេចលើផែនការអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃការតម្រង់ទិស កំណត់ដោយរាជរដ្ឋាភិបាល
- ពិនិត្យអនុម័តផែនការអាជីវកម្ម សេវាកម្ម ផែនការហិរញ្ញវត្ថុ និងវិនិយោគរបស់ ក. ស. ភ.
- អនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍គណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ ក. ស. ភ.
- ចាត់ចែងឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដូចមានកំណត់ដោយអនុក្រឹត្យស្តីពីការបង្កើត ក. ស. ភ. ឬដោយលក្ខន្តិកៈរបស់ ក. ស. ភ. និងបង្កើតបន្ថែមទៀតប្រសិនបើចាំបាច់
- សម្រេចចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ក. ស. ភ.
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់ នូវកម្រិតទំហំនៃការធ្វើឱ្យសម្រេចនូវគោលដៅដែលកំណត់ដោយ ក. ស. ភ. និងដាក់ចុះនូវវិធានការសម្រាប់កែលម្អចាំបាច់
- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ ក. ស. ភ. ព្រមទាំងលក្ខន្តិកៈ និងកាំបៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការសម្រាប់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- ជ្រើសរើស និងកំណត់លាភការសម្រាប់ផ្តល់ឱ្យស្នងការគណនី
- ធ្វើសំណើកែសម្រួលលក្ខន្តិកៈ
- កំណត់ថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មលើកំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទបញ្ញត្តិជាធរមាន

- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់ សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ ក. ស. ភ.
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណាដែលពុំអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មនៃសហគ្រាសសាធារណៈ ដែលអគ្គនាយកឆ្លងយោបល់ក្រុមប្រឹក្សាភិបាល។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ២ កុម្ភៈ ២០២២ | សាមញ្ញ | ឯកឧត្តម ហ៊ី បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្គី អានវ៉ានិច<br>លោក ឌិត សុចល<br>លោក យឹម ជឿន |
| ២ | ១០ មីនា ២០២២ | វិសាមញ្ញ | ឯកឧត្តម ហ៊ី បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្គី អានវ៉ានិច<br>លោក ឌិត សុចល<br>លោក យឹម ជឿន |
| ៣ | ២៣ មីនា ២០២២ | វិសាមញ្ញ | ឯកឧត្តម ហ៊ី បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្គី អានវ៉ានិច<br>លោក ឌិត សុចល<br>លោក យឹម ជឿន |
| ៤ | ២៩ មេសា ២០២២ | សាមញ្ញ | ឯកឧត្តម ហ៊ី បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្គី អានវ៉ានិច<br>លោក ឌិត សុចល<br>លោក យឹម ជឿន |

| | | | |
|---|---|---|---|
| ៥ | ៥ កក្កដា ២០២២ | សាមញ្ញ | ឯកឧត្តម ហ៊ឺ បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្ដី អានវ៉ានិច<br>លោកស្រី ប៉ុក ភក្ដី<br>លោក គង់ សុធា |
| ៦ | ២១ តុលា ២០២២ | សាមញ្ញ | ឯកឧត្តម ហ៊ឺ បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្ដី អានវ៉ានិច<br>លោកស្រី ប៉ុក ភក្ដី<br>លោក គង់ សុធា |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១.១. គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | អភិបាលឯករាជ្យ | ប្រធាន | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | ៥ ដង |
| ២ | មន្ត្រីត្រួតពិនិត្យរដ្ឋ | អនុប្រធាន | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |
| ៣ | អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |
| ៤ | នាយកផែនការ/ទីផ្សារ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |
| ៥ | នាយកគណនេយ្យ/ហិរញ្ញវត្ថុ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |
| ៦ | នាយកសវនកម្មផ្ទៃក្នុង | សមាជិក | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |
| ៧ | បុគ្គលិកនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង | លេខាកត់ត្រា | ២៨ វិច្ឆិកា ២០១៩ | ៥ ដង | |

**តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម**

- ពិនិត្យលើរបាយការណ៍ទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ
- ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យលើការធ្វើសវនកម្មខាងក្រៅ
- ពិនិត្យលើការគ្រប់គ្រងហានិភ័យ ករណីមិនមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ

- រាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាល
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម**

សម្រាប់ឆ្នាំ២០២២ គណៈកម្មាធិការសវនកម្មបានរៀបចំកិច្ចប្រជុំចំនួន ៥លើកដូចខាងក្រោម៖

**១. សម័យប្រជុំថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២**

- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រៀងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ ក្រោយពីការធ្វើសវនកម្មដោយសវនករឯករាជ្យ

**២. សម័យប្រជុំថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២២**

- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រៀងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ក្រោយពីការធ្វើសវនកម្មដោយសវនករឯករាជ្យ
- ពិនិត្យ និងឯកភាពលើរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសទី១ ឆ្នាំ២០២២

**៣. សម័យប្រជុំថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២**

- ពិនិត្យ និងឯកភាព លើការជ្រើសរើសយកក្រុមហ៊ុន KPMG ជាសវនករឯករាជ្យថ្មីរបស់ ក. ស. ភ. សម្រាប់រយៈពេល៥ឆ្នាំ (២០២៣-២០២៧) ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលរបស់ ក. ស. ភ. ពិនិត្យ និងសម្រេចចុងក្រោយ
- ពិនិត្យ និងឯកភាពលើរបាយការណ៍សវនកម្មផ្ទៃក្នុងត្រីមាសទី២ ឆ្នាំ២០២២

**៤. សម័យប្រជុំថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២**

- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រៀងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នដោយសវនករឯករាជ្យ សម្រាប់រយៈពេល៦ខែ ដើមឆ្នាំ២០២២
- ពិនិត្យ និងឯកភាពលើកាផ្លាស់ប្តូរទម្រង់របាយការណ៍សវនកម្មផ្ទៃក្នុង ឱ្យស្របតាមទម្រង់ស្តង់ដាររបាយការណ៍សវនកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យ និងឯកភាពលើរបាយការណ៍សវនកម្មផ្ទៃក្នុងត្រីមាសទី៣ ឆ្នាំ២០២២

**៥. សម័យប្រជុំថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២**

- ពិនិត្យ និងឯកភាពលើផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំ (២០២៣-២០២៥) របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ពិនិត្យ និងឯកភាពលើផែនការប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ពិនិត្យ លើលទ្ធផលការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង រយៈពេល ៩ខែ ដើមឆ្នាំ២០២២
- ពិនិត្យ និងពិភាក្សាទៅលើចំណុចសំខាន់ៗដែលផ្តោតជាបញ្ហា ដែលបានលើកឡើងដោយក្រុមហ៊ុនសវនកម្មឯករាជ្យ BDO
- ពិនិត្យ និងពិភាក្សាលើសេចក្តីព្រៀងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដោយសវនករឯករាជ្យសម្រាប់រយៈពេល ៩ខែ ដើមឆ្នាំ២០២២។

## ១.២. គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | អភិបាលតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ២ | អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៣ | អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៤ | អភិបាលតំណាងនិយោជិត ក. ស. ភ. | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៥ | នាយកបុគ្គលិក/ធនធានមនុស្ស | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៦ | បុគ្គលិកនៃនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | លេខាកត់ត្រា | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |

**តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ**

- ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវុឌ្ឍិ និងនីតិវិធីនៃការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
- វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើទៅក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល គណៈកម្មាធិការនានា យ៉ាងហោចណាស់ ១ដង ក្នុង១ឆ្នាំ
- រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬប្រាក់បំណាច់ សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- អនុវត្តកិច្ចការផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

**លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ**

សម្រាប់ឆ្នាំ២០២២ គណៈកម្មាធិការតែងតាំង និងលាភការពុំទាន់មានលទ្ធផលការងារនៅឡើយ។

## ១.៣. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | អភិបាលឯករាជ្យ | ប្រធាន | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ២ | អគ្គនាយក | អនុប្រធាន | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |

| | | | | | |
|---|---|---|---|---|---|
| ៣ | អភិបាលតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៤ | អភិបាលតំណាងក្រសួងពាណិជ្ជកម្ម | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៥ | អគ្គនាយករងកិច្ចការផែ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៦ | អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៧ | នាយកផែនការ/ទីផ្សារ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៨ | ប្រធានលេខាធិការដ្ឋាន | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ៩ | នាយកគណនេយ្យ/ហិរញ្ញវត្ថុ | សមាជិក | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |
| ១០ | បុគ្គលិកនៃលេខាធិការដ្ឋាន | លេខាកត់ត្រា | ២៨ វិច្ឆិកា ២០១៩ | N/A | N/A |

**តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

- ត្រួតពិនិត្យ វិភាគហានិភ័យ រួមមានការពិពណ៌នាហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យ ការប៉ាន់ស្មានអំពីហានិភ័យពាក់ព័ន្ធនឹងអាជីវកម្ម/ប្រតិបត្តិការ និងហិរញ្ញវត្ថុ
- ត្រួតពិនិត្យ វាយតម្លៃអំពីហានិភ័យពាក់ព័ន្ធនឹងអាជីវកម្ម/ប្រតិបត្តិការ និងហិរញ្ញវត្ថុ
- ត្រួតពិនិត្យ របាយការណ៍អំពីហានិភ័យពាក់ព័ន្ធនឹងអាជីវកម្ម/ប្រតិបត្តិការ និងហិរញ្ញវត្ថុ
- ត្រួតពិនិត្យ លើកវិធានការណ៍ទប់ទល់ហានិភ័យពាក់ព័ន្ធនឹងអាជីវកម្ម/ប្រតិបត្តិការ និងហិរញ្ញវត្ថុ
- ត្រួតពិនិត្យលើការតាមដានអំពីហានិភ័យពាក់ព័ន្ធនឹងអាជីវកម្ម/ប្រតិបត្តិការ និងហិរញ្ញវត្ថុ
- អនុវត្តកិច្ចការផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

**លទ្ធផលការងាររបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

សម្រាប់ឆ្នាំ២០២២ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ពុំទាន់មានលទ្ធផលការងារនៅឡើយ។

### ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

សម្រាប់ឆ្នាំ២០២២ ក. ស. ភ. ពុំមានការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការណាមួយឡើយ។

## គ. លាភការ ឬប្រាក់បំណាច់

### ១. គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

លាភការរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. មានចែងក្នុងលក្ខន្តិកៈបុគ្គលិក និងលក្ខន្តិកៈរបស់ ក. ស. ភ.។ ក្នុងនោះ សមាជិកក្រុមប្រឹក្សាភិបាលមានសិទ្ធិទទួលបានលាភការក្នុងចំនួនណាមួយដែលសម្រេចឡើងដោយមហាសន្និបាតភាគហ៊ុនិក តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាភិបាល។

### ២. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ ឆ្នាំ ២០២២ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បាវី | ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក | ២៧៩.១១៣ |

| | | | |
|---|---|---|---|
| ២ | ឯកឧត្តម សួន រចនា | អភិបាល | ១៤៤.០០០ |
| ៣ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ១៤៤.០០០ |
| ៤ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ១៤៤.០០០ |
| ៥ | លោក ហ៊្គី អានរ៉ានិច | អភិបាលឯករាជ្យ | ១៤៤.០០០ |
| ៦ | អ្នកស្រី ប៉ុក ភក្តី | អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | ៧២.០០០ |
| ៧ | លោក គង់ សុធា | អភិបាលតំណាងនិយោជិត | ៧២.០០០ |
| **សរុប** | | | **៩៩៩.១១៣** |

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាលប្រតិបត្តិ | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ ឆ្នាំ ២០២២ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បារី | ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក | ២៧៩.១១៣ |
| ២ | លោក គង់ សុធា | អភិបាលតំណាងនិយោជិត | ៧២.០០០ |
| **សរុប** | | | **៣៥១.១១៣** |

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះបុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បៀវត្សរ៍ និងលាភការ ឆ្នាំ២០២២ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បារី | ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក | ២៧៩.១១៣ |
| ២ | លោកជំទាវ ជួន សុខេម | អគ្គនាយករង | ៩៥.៣៩១ |
| ៣ | លោក កុយ ប៊ុនធន | អគ្គនាយករង | ៩៦.៥៧១ |
| ៤ | លោក ហៀក ភិរុណ | អគ្គនាយករង | ៩៥.៣៩១ |
| ៥ | អ្នកស្រី ហ៊ី ផានិន | អគ្គនាយករង | ៩៥.៣៩១ |
| ៦ | លោក គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៨៩.៧៩៣ |
| ៧ | លោក កែវ សុផាណ្ណារ៉ា | នាយកសវនកម្មផ្ទៃក្នុង | ៧១.៧៧៣ |
| ៨ | លោក គង់ សុធា | នាយករដ្ឋបាល | ១៤៤.០៩៣ |
| ៩ | អ្នកស្រី សេង គន្ធា | នាយកបុគ្គលិក/ធនធានមនុស្ស | ៣៥.៨៣៣ |
| ១០ | កញ្ញា ឈាវ វណ្ណធា | នាយកគណនេយ្យ/ហិរញ្ញវត្ថុ | ៨៣.៤៣៣ |
| ១១ | លោក សាយ ចន្ថា | នាយកគ្រប់គ្រងគ្រឿងចក្រ | ៨៣.៤៣៣ |
| ១២ | លោក ជៀប វីរ៉ាយ៉ា | នាយកជលធារសាស្ត្រ | ៧១.៥៥៣ |
| ១៣ | លោក តុល សុខុម | នាយកសេវាកម្មនាវាចរណ៍ | ៧១.៨៤២ |

| | | | |
|---|---|---|---|
| ១៤ | លោក ឈីវ សុងកាំង | នាយកចំណតផែរណបពហុបំណង UM១ | ៧១.៧៣៣ |
| ១៥ | លោក ហ៊ុន សុខាល័យ | នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៨៣.៦១៣ |
| ១៦ | លោក ហ៊ី សុង | នាយកប្រតិបត្តិការចំណតផែ TS៣ | ៧១.៦៧៣ |
| ១៧ | លោក អ៊ឹម ដាវីដ | នាយកស្តីទីវិស្វកម្ម | ២២.៨៩៨ |
| ១៨ | អ្នកស្រី មាស វិសាល | នាយកស្តីទីផែនការ/ទីផ្សារ | ១៩.៥០៤ |
| ១៩ | លោក ប្រាក់ សាមិត្ត | នាយកស្តីទីមណ្ឌលអាជីកម្មផែ/ផែក្នុងស្រុក | ៩.២៦២ |
| **សរុប** | | | **១.៥៩២.២៩៣** |

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះបុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥ រូប | មុខតំណែងក្នុងក.ស.ភ. | "ប្រាក់បៀវត្សរ៍ និងលាភការ" ឆ្នាំ២០២១ |
|---|---|---|---|
| ១ | លោក អ៊ុក ប៉ូលី | ប្រធានការិយាល័យបុគ្គលិក/បណ្តុះបណ្តាល | ៦១.៩១៣ |
| ២ | លោក អែ សំណាង | ប្រធានការិយាល័យសុវត្ថិភាព/សុខុមាលភាព/បរិស្ថានផែ | ៦១.៦១៣ |
| ៣ | លោក សុក ច័ន្ទណារ៉ា | ប្រធានសេវាដ្ឋាននាវាចរណ៍/ប្រព័ន្ធ AIS | ៥៥.៥៣០ |
| ៤ | លោក ឆេង ស៊្រុន | ប្រធានអង្គភាពត្រួតពិនិត្យ/អនុវត្តគម្រោង | ៥៥.៥០៦ |
| ៥ | លោក ភោគ ពិសិដ្ឋ | ប្រធានសេវាដ្ឋានបូមស្តារ/ថែទាំប្រឡាយ | ៥៥.៣៩៦ |
| **សរុប** | | | **២៨៩.៩៥៨** |

## ឃ.ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

សម្រាប់ឆ្នាំ២០២២ ក. ស. ភ. ពុំមានការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិនោះទេ។

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

សម្រាប់ឆ្នាំ២០២២ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ក. ស. ភ. បានចូលរួមការបណ្តុះបណ្តាលដូចខាងក្រោម៖

| ល.រ | ឈ្មោះ | វគ្គ/ជំនាញ | ថ្ងៃ ខែ ឆ្នាំចូលរួម | ទីកន្លែង |
|---|---|---|---|---|
| បណ្តុះបណ្តាលក្នុងប្រទេស | | | | |
| ១ | អ្នកស្រី សេង គន្ធា | វគ្គបណ្តុះបណ្តាល ស្តីពី លទ្ធកម្មសាធារណៈ | ១-៤ កុម្ភៈ ២០២២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Online) |
| ២ | លោក ហ៊ុន សុខាល័យ<br>លោក ហ៊ី សុង | វគ្គបណ្តុះបណ្តាល ស្តីពី Upgrade TOS System | ១៤-២៧ មីនា ២០២២ | ចំណតផែកុងតឺន័រ LM១៧ |

| | | | | |
|---|---|---|---|---|
| ៣ | លោក គង់ សុធា | សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការមេអន្តរកាល ស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្មនៅកម្ពុជា ឆ្នាំ២០២១ | ១៤ កក្កដា ២០២២ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៤ | លោក កុយ ប៊ុនធន<br>លោក ជៀប វីរ៉ាយ៉ា | សិក្ខាសាលាស្តីពី "Aids to Navigation: Capacity building" | ៣ សីហា ២០២២ | សណ្ឋាគារសូហ្វីតែល |
| ៥ | លោកជំទាវ ជួន សុខេម | សិក្ខាសាលាពិគ្រោះយោបល់អំពីសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | ៣១ សីហា ២០២២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦ | អ្នកស្រី ហ៊ី ផានិន<br>លោក ហ៊ុន សុខាល័យ | សិក្ខាសាលាពិគ្រោះយោបល់វិស័យឯកជន លើកទី២ លើគម្រោង The Digitizing Maritime Trade Project (DMTP) | ២៩ កញ្ញា ២០២២ | សាលាជាតិគយ |
| ៧ | លោក តុល សុខុម | សិក្ខាសាលា ស្តីពី Integration Workshops តាមរយៈវីដេអូពីចម្ងាយ | ១១ តុលា ២០២២ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៨ | អ្នកស្រី សេង គន្ធា<br>កញ្ញា ឈាវ វណ្ណធា<br>លោក គង់ សុធា | ចូលរួមការបណ្តុះបណ្តាល ស្តីពីនីតិវិធីក្នុងការបង់ភាគទាន និងការផ្តល់របាយការណ៍កម្មករនិយោជិត សម្រាប់របបសន្តិសុខសង្គម ផ្នែកប្រាក់សោធន | ១៣ តុលា ២០២២ | ចំណតផែពហុបំណង TS៣ |
| ៩ | កញ្ញា ឈាវ វណ្ណធា | ចូលរួមសិក្ខាសាលា ស្តីពីវឌ្ឍនភាពនៃការបោះផ្សាយមូលបត្របំណុល និងការវាយតម្លៃលទ្ធភាពសង | ១៧ តុលា ២០២២ | ទីស្តីការ ន. ម. ក. |
| ១០ | អ្នកស្រី ហ៊ី ផានិន<br>កញ្ញា ឈាវ វណ្ណធា<br>លោក គង់ ចាន់នី | សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ រៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៥ វិច្ឆិកា ២០២២ | ខេត្តសៀមរាប |
| **បណ្តុះបណ្តាលក្រៅប្រទេស** | | | | |
| ១ | អ្នកស្រី ហ៊ី ផានិន<br>លោក ហ៊ឺ សុង<br>លោក ជៀប វីរ៉ាយ៉ា | វគ្គសិក្ខាសាលា ស្តីពី Advanced Program for Maritime Safety Administration in the post stage of Covid-2019 | ៦-៨-១០ ឧសភា ២០២២ | ប្រទេសចិន (តាមប្រព័ន្ធ Zoom) |
| ២ | លោក អ៊ឹម ដាវិដ | វគ្គបណ្តុះបណ្តាល ស្តីពីផែនការថែរក្សាកំពង់ផែ (Port Maintenance Planning) | ១៣ មិថុនា-២៥ កក្កដា ២០២២ | ប្រទេសជប៉ុន |
| ៣ | កញ្ញា ឈាវ វណ្ណធា | ចូលរួមវគ្គសិក្សា ស្តីពី “Women in Port Management” | ២០ មិថុនា-១ កក្កដា ២០២២ | ប្រទេសបារាំង |
| ៤ | លោក តុល សុខុម | វគ្គបណ្តុះបណ្តាល ស្តីពី "Inland Waterway Aids to Navigation master plan" | ២៩ សីហា-៣ កញ្ញា ២០២២ | ប្រទេសកូរ៉េ |
| ៥ | លោក ហៀក ភិរុណ | ចូលរួមសិក្ខាសាលា ស្តីពី Countering Maritime Sanction Evasion | ១-២ ធ្នូ ២០២២ | ប្រទេសថៃ |

## ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

### ១. គោលការណ៍នៃក្រមសីលធម៌

ក្រមសីលធម៌នេះ ជាក្រមប្រតិបត្តិដែលត្រូវអនុវត្តចំពោះក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ.។

រាល់ការបំពានលើក្រមសីលធម៌នេះ អាចនឹងត្រូវទទួលទណ្ឌកម្មនានាទៅតាមនីតិវិធី ដែលប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ត្រូវបានតាក់តែងឡើងដោយអនុលោមតាមច្បាប់ជាធរមាន ដើម្បីឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. គោរពប្រតិបត្តិតាម។ ក្រមសីលធម៌នេះ មិនត្រូវបានប្រើ ដើម្បីជំនួសការដោះស្រាយវិវាទតាមផ្លូវតុលាការនោះទេ។

យន្តការតាមដាន និងរក្សាតុល្យភាព (Checks and Balances) ដែលមានក្នុងក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាតុល្យភាពក្នុងការគ្រប់គ្រង និងការគោរពកាតព្វកិច្ចកំណត់ដោយច្បាប់ ព្រមទាំងការពារក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ពីការចោទប្រកាន់មិនត្រឹមត្រូវ ឬគ្មានហេតុផលណាមួយ។ ការចោទប្រកាន់បែបនេះ នឹងអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ ក. ស. ភ. ឬប៉ះពាល់ផលប្រយោជន៍ដល់បុគ្គលណាម្នាក់។ សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ក. ស. ភ. អះអាង និងប្ដេជ្ញាថានឹងគោរពតាមគោលការណ៍ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ។

- **និយមន័យ**

| | | |
|---|---|---|
| **ក្រុមប្រឹក្សាភិបាល** | ៖ | សំដៅដល់ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ។ |
| **អភិបាល** | ៖ | សំដៅដល់សមាជិកនៃក្រុមប្រឹក្សាភិបាល ហើយអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬ អភិបាលឯករាជ្យ។ |
| **អភិបាលឯករាជ្យ** | ៖ | សំដៅដល់សមាជិកឯករាជ្យ ដែលបំពេញតាមលក្ខខណ្ឌនៃជំពូកទី៥ នៃប្រកាសស្ដីពី អភិបាលកិច្ចអាជីវកម្ម សម្រាប់សហគ្រាសសាធារណៈ បោះផ្សាយលក់មូលបត្រជាសាធារណៈ និងដែលជាទូទៅសំដៅដល់អភិបាល ដែលអាចមានភារកិច្ចដោយមិនមានទំនាស់ផលប្រយោជន៍ ដែលកើតឡើងពាក់ព័ន្ធជាមួយ ក.ស.ភ.។ |
| **អភិបាលប្រតិបត្តិ** | ៖ | សំដៅដល់អភិបាលដែលកាន់តំណែងជាបុគ្គលិកជាន់ខ្ពស់នៅក្នុង ក. ស. ភ.។ |
| **អភិបាលមិនប្រតិបត្តិ** | ៖ | សំដៅដល់អភិបាលដែលមិនអនុវត្តនូវប្រតិបត្តិការប្រចាំថ្ងៃក្នុង ក. ស. ភ. ឬក៏ជាអភិបាលមិនប្រតិបត្តិជាតំណាងភាគហ៊ុនិកឯកជននិងសាធារណៈ។ |
| **បុគ្គលិកជាន់ខ្ពស់** | ៖ | សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការរបស់ ក. ស. ភ. និងប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។ |

❖ **ការបំពេញកាតព្វកិច្ចតាមច្បាប់ និងតាមក្រមសីលធម៌**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែប្រតិបត្តិតាមក្រមសីលធម៌ និងគោរពតាមច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការធ្វើអាជីវកម្ម**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបំពេញការងារក្នុងអាជីវកម្មរបស់ ក. ស. ភ. ដោយស្មោះត្រង់ គោរពតាមច្បាប់។

ភាពស្មោះត្រង់ និងការបំពេញកាតព្វកិច្ចតាមច្បាប់ មានន័យថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវ៖

- បំពេញតួនាទីជាមួយនឹងព័ត៌មានពេញលេញទាក់ទងនឹងកម្មវត្ថុពាក់ព័ន្ធនឹងសេចក្ដីសម្រេចណាមួយ
- បំពេញតួនាទីប្រកបដោយសុចរិត និងក្នុងគោលបំណងត្រឹមត្រូវ
- បំពេញតួនាទីដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍អង្គភាព
- អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវមានគោលជំហរច្បាស់លាស់ក្នុងការបម្រើផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ ជាពិសេសក្នុងពេលធ្វើការសម្រេចចិត្ត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវជាប់ពាក់ព័ន្ធ ទោះបីដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬស៊ែហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើសេចក្ដីប្រកាសជាសាធារណៈមួយអំពីទំនាស់ផលប្រយោជន៍របស់ខ្លួន ដែលកើតមានឡើងពាក់ព័ន្ធនឹង ក. ស. ភ.។ អភិបាល និងបុគ្គលិកជាន់ខ្ពស់នៃ ក. ស. ភ. ពុំត្រូវបានអនុញ្ញាតឱ្យធ្វើការជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក. ស. ភ. ឡើយ ក្នុងកំឡុងពេលដូចខាងក្រោម៖

- ១០ថ្ងៃ នៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ និង
- ៧ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ អាចចូលរួមក្នុងកិច្ចការជំនួញក្នុងនាម ក. ស. ភ. ដែលពួកគេមានផលប្រយោជន៍ លុះត្រាតែអភិបាល ឬបុគ្គលិកជាន់ខ្ពស់ទាំងនោះ អនុវត្តតាមគោលការណ៍ និងបែបបទទាំងអស់ ដែលបានអនុម័ត ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការរក្សាការសម្ងាត់**

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ មានសិទ្ធិចែកចាយ ថតចម្លង ផលិតជាថ្មី បញ្ជូន បង្ហាញ ឬលាតត្រដាង រាល់ព័ត៌មានសម្ងាត់ណាមួយ ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ ក. ស. ភ.។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវរក្សាយ៉ាងម៉ឺងម៉ាត់ នូវការសម្ងាត់នៃកិច្ចប្រជុំទាំងអស់ និងការពិភាក្សាផ្សេងៗ ព្រមទាំងការទំនាក់ទំនងនៃក្រុមប្រឹក្សាភិបាល លើកលែងតែក្រុមប្រឹក្សាភិបាល ឬច្បាប់តម្រូវផ្សេងពីនេះ ។

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ប្រើប្រាស់នូវរាល់ព័ត៌មានណាមួយ ដែលផ្ដល់ដោយ ក. ស. ភ. ឬទទួលបានតាមរយៈការបំពេញការងារជាអភិបាលទៅឱ្យ ក. ស. ភ. ទោះបីក្រោមរូបភាពណាក៏ដោយលើកលែង

តែក្នុងគោលបំណងជួយសម្រួលដល់កាតព្វកិច្ចរបស់ខ្លួន នៅក្នុងក្រុមប្រឹក្សាភិបាល។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាពិសេស ក្នុងពេលបំពេញការងារទាក់ទងនឹងលទ្ធផលរបស់ក្រុមហ៊ុន ការប៉ាន់ស្មានព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត ចំណេះដឹង និងបច្ចេកវិទ្យា ព្រមទាំងព័ត៌មានធនធានមនុស្ស។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវគោរពកាតព្វកិច្ចរក្សាការសម្ងាត់ ទោះបីក្រោយពីបានបញ្ចប់ការងាររបស់ខ្លួននៅ ក. ស. ភ. ក៏ដោយ។

❖ **ការគោរពសិទ្ធិចំពោះបុគ្គលិក ក. ស. ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តអំណាចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងធ្វើការវិនិច្ឆ័យឱ្យបានល្អចំពោះបុគ្គលិករបស់ ក. ស. ភ. ព្រមទាំងត្រូវឆ្លើយតបទៅតាមតម្រូវការនៃសមាជិករបស់ ក. ស. ភ. ដោយភាពទទួលខុសត្រូវ ការគោរព និងដោយមានវិជ្ជាជីវៈខ្ពស់។

ទំនាក់ទំនងរវាងមន្ត្រី និយោជិត និងអភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឡើយដោយឈរលើគោលការណ៍នៃការជឿទុកចិត្ត ការគោរពគ្នាទៅវិញទៅមក និងស្មារតីគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ។

ក. ស. ភ. ត្រូវគោរពតាមគោលនយោបាយធនធានមនុស្សរបស់ខ្លួនដោយឥតលម្អៀង និងគោរពតាមច្បាប់ដោយមិនត្រូវបង្កាច់បង្ខូច ឬមានការរើសអើងឡើយ។ រាល់ការគាបសង្កត់ ការរំខាន ការធ្វើទុក្ខ បុកម្នេញ ឬការធ្វើទារុណកម្មខាងផ្លូវចិត្ត ឬផ្លូវកាយ ត្រូវបានហាមឃាត់។

គោលការណ៍ទាំងនេះ អនុវត្តលើអភិបាល និងបុគ្គលិកជាន់ខ្ពស់ ទាក់ទងនឹងការប្រព្រឹត្តរបស់ខ្លួន ចំពោះបុគ្គលិករបស់ ក. ស. ភ. និងបុគ្គលដែលមិនមែនជាបុគ្គលិកក្នុង ក. ស. ភ. ផងដែរ ។

❖ **ការការពារទ្រព្យសម្បត្តិ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវការពារទ្រព្យសម្បត្តិទាំងអស់របស់ ក. ស. ភ.។ ទ្រព្យសម្បត្តិទាំងនោះរួមមាន ទ្រព្យរូបី និងទ្រព្យអរូបី ដូចជាគំនិត ជំនាញ ចំណេះដឹង ចំណេះធ្វើ ដែលបង្កើតឡើងដោយ ក. ស. ភ.។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬធនធានរបស់ ក. ស. ភ សម្រាប់ហេតុផលផ្ទាល់ខ្លួន ឬដើម្បីផលប្រយោជន៍ដល់តតិយជនឡើយ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាទ្រព្យសម្បត្តិរបស់ ក. ស. ភ. ឱ្យបានល្អគង់វង្ស គ្រប់ពេលវេលា និងមិនត្រូវឱ្យបុគ្គលណាម្នាក់ដែលមិនទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិរបស់ ក. ស. ភ. ឡើយ។

❖ **សវនកម្មផ្ទៃក្នុង**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធានានូវតម្លាភាព និងភាពស្មោះត្រង់ នៅពេលបំពេញការងារទាក់ទងជាមួយនឹងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីធានាថាភាពទន់ខ្សោយ និងគុណវិបត្តិចម្បងៗ អាចត្រូវបានកំណត់ និងកែតម្រូវបាន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវធ្វើទង្វើណាមួយដែលនាំឱ្យរាំងស្ទះ ឬលាក់បាំងព័ត៌មានណាមួយដល់ការធ្វើសវនកម្ម ឬការធ្វើអធិការកិច្ចណាមួយឡើយ ទោះបីជាការធ្វើឡើងនោះជាលក្ខណៈផ្ទៃក្នុងដោយសវនករនៃ ក. ស. ភ. ក៏ដោយ។ រាល់ការប្រព្រឹត្តទង្វើទាំងនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមសីលធម៌នេះ ហើយត្រូវបានហាមឃាត់។

❖ **សកម្មភាពអភិវឌ្ឍន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវចូលរួមឱ្យអស់ពីលទ្ធភាពរបស់ខ្លួនជាប្រចាំ នៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈវិជ្ជាជីវៈ និងឱ្យបានទាន់ពេលវេលាទៅតាមការណែនាំ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។

❖ **ផលប្រយោជន៍របស់ ក. ស. ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើការលះបង់ ដើម្បីបំពេញតាមតម្រូវការរបស់ ក. ស. ភ.។

អភិបាល ត្រូវបំពេញតួនាទីគ្រប់ពេលទាំងអស់ ដើម្បីជាឧត្តមប្រយោជន៍របស់ ក. ស. ភ. ហើយមិនមែនដើម្បីផលចំណេញ ឬការបង្កើនប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬតតិយជនណាមួយឡើយ។ បុគ្គលិកទាំងអស់របស់ ក. ស. ភ. ដោយរាប់បញ្ចូលទាំងអភិបាល និងបុគ្គលិកជាន់ខ្ពស់ផង ត្រូវបំពេញនូវតួនាទី ដោយស្មោះត្រង់ និងដើម្បីផលប្រយោជន៍របស់ ក. ស. ភ. គ្រប់កាលៈទេសៈទាំងអស់។ បុគ្គលិកទាំងអស់ មិនត្រូវបរិហារជាសាធារណៈ និងវាយប្រហារណាមួយមកលើកិត្តិនាម និងភាពស្មោះត្រង់របស់ ក. ស. ភ. និងការវាយប្រហារមកលើវិជ្ជាជីវៈការងាររបស់បុគ្គលិក ក. ស. ភ.។

❖ **ទំនាស់ផលប្រយោជន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. ត្រូវធានាថាសកម្មភាពខាងក្រៅ និងផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវបានចែកឱ្យដាច់ពីតួនាទីនៅក្នុង ក. ស. ភ. និងមិនត្រូវប្រើឥទ្ធិពលទៅលើការសម្រេចអាជីវកម្មក្នុងនាម ក. ស. ភ. ឡើយ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ចាំបាច់ត្រូវប្រើនូវសុភវិនិច្ឆ័យ និងរក្សាផលប្រយោជន៍ ក. ស. ភ. ជាធំ។ ដើម្បីកុំឱ្យមានទំនាស់ផលប្រយោជន៍ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវចៀសវាងចេញពីស្ថានភាពណាមួយដែលអាចបណ្តាលឱ្យកើតមានទំនាស់ផលប្រយោជន៍។

នៅពេលដែលទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើង នោះអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. ត្រូវកំណត់ទំនាស់ផលប្រយោជន៍នោះ ហើយធ្វើការប្រកាសជាសាធារណៈ អំពីទំនាស់ផលប្រយោជន៍ និងធ្វើការដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតលើបញ្ហាទាំងនោះ (បើអនុវត្តបាន)។

❖ **អំពើពុករលួយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវផ្តល់ប្រាក់ឧបត្ថម្ភ ឬអំណោយដោយផ្ទាល់ ឬដោយប្រយោល មិនត្រូវធ្វើការសន្យា ឬផ្តល់ផលប្រយោជន៍ណាមួយទៅកាន់មន្ត្រីសាធារណៈ ឬប្រជាពលរដ្ឋ ដែលទទួលការទុកចិត្តក្នុងអាណត្តិសាធារណៈ តាមរយៈការបោះឆ្នោតដើម្បីឱ្យមន្ត្រីសាធារណៈនោះ ឬមន្ត្រីដែលជាប់ឆ្នោតនោះ (១) អនុវត្តសកម្មភាពណាមួយក្នុងតួនាទីរបស់គេ ឬក៏សម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ឬ (២) មិនអនុវត្តកាតព្វកិច្ច ឬសម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវទទួលយកអំណោយដែលត្រូវបានផ្តល់ឱ្យ ឬនឹងត្រូវផ្តល់ឱ្យ ដោយសារតែតួនាទីរបស់ខ្លួននៅក្នុង ក. ស. ភ.។

❖ **សកម្មភាពនយោបាយ**

ក. ស. ភ. គោរពតាមការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចង់ចូលរួមនៅក្នុងកិច្ចការសាធារណៈ ប៉ុន្តែ ក. ស. ភ. ត្រូវប្រកាន់គោលការណ៍អព្យាក្រឹតចំពោះវិស័យនយោបាយ។ ដូចនេះ អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. អាចអនុវត្តសេរីភាពបញ្ចេញមតិ និងធ្វើសកម្មភាពនយោបាយបាននៅក្រៅពីម៉ោងធ្វើការ ដោយចំណាយផ្ទាល់ខ្លួន និងផ្អែកលើគំនិតផ្ទាល់ខ្លួនប៉ុណ្ណោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. មិនត្រូវភ្ជាប់ ក. ស. ភ. ទៅនឹងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ពុំត្រូវពិភាក្សាពីសមាជិកភាពរបស់ ក. ស. ភ. ទៅក្នុងបរិបទនយោបាយណាមួយឡើយ។

❖ **ការបញ្ចប់អាណត្តិ**

ក្រោយពីបញ្ចប់ភារកិច្ចរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចូលនិវត្តត្រូវប្រគល់ភ្លាម ទៅឱ្យ ក. ស. ភ. វិញនូវឯកសារអេឡិចត្រូនិច និងឯកសារ ជាក្រដាស ឯកសារយោង និងឯកសារផ្សេងៗទៀតដែលត្រូវបានផ្តល់ជូនក្នុងគោលបំណងបំពេញការងារ។ ការប្រគល់ជូនទៅវិញនូវឯកសារទាំងនេះ គឺមិនបានលុបចោលនូវកាតព្វកិច្ចរក្សាការសម្ងាត់នូវព័ត៌មាន ដែលទទួលបានក្នុងរយៈពេលនៃការកាន់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល ឬតួនាទីជាន់ខ្ពស់នៅក្នុង ក. ស. ភ. នោះទេ។

❖ **ការបកស្រាយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានភារកិច្ចយល់ដឹងអំពីក្រមសីលធម៌នេះ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ដែលមានភាពស្រពិចស្រពិល ឬយល់មិនច្បាស់លើបទប្បញ្ញត្តិណាមួយ ត្រូវទាក់ទងទៅផ្នែកច្បាប់ ដោយផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យផ្នែកច្បាប់អាចផ្តល់យោបល់ ឬធ្វើការសម្រេចចិត្តសមស្របមួយ។

❖ **ការកែប្រែ**

ក្រមសីលធម៌នេះ អាចត្រូវបានធ្វើការកែប្រែ ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន។

## ២. ការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌នេះ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ និងមានអានុភាពចាប់ពីពេលក្រុមហ៊ុនទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយគណៈកម្មការមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រុមប្រឹក្សាភិបាល ត្រូវចាត់វិធានការសមស្រប ក្នុងករណីមានការបំពារបំពានក្រមសលធម៌នេះ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រមសីលធម៌របស់ ក. ស. ភ. មានបង្ហាញក្នុងរបាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២២ នេះ ដើម្បីផ្សព្វផ្សាយជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត សាធារណជន និងជាពិសេសវិនិយោគិនរបស់ ក. ស. ភ.។ ជាមួយគ្នានេះ ក. ស. ភ. ក៏បានធ្វើការផ្សព្វផ្សាយនូវក្រមសីលធម៌នេះ ជូនដល់និយោជិតទាំងអស់នៅពេលចូលធ្វើការដំបូងតាមរយៈវគ្គបណ្តុះបណ្តាលតម្រង់ទិស (Orientation) ដោយបានណែនាំអំពីលំហូរប្រតិបត្តិការ និងការងារ ព្រមទាំងបញ្ជាបនូវចំណុចសំខាន់ៗដែលមានចែងក្នុងលក្ខន្តិកៈបុគ្គលិក និងក្រមសីលធម៌របស់ ក. ស. ភ.។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

សម្រាប់ឆ្នាំ២០២២ ក. ស. ភ. ពុំទាន់មានយន្តការ និងនីតិវិធីសម្រាប់តាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចនៅឡើយទេ។ ករណីមានការអនុវត្តផ្ទុយពីក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់នេះ គឺក្រុមប្រឹក្សាភិបាល ជាអ្នកពិនិត្យ និងរកដំណោះស្រាយ។ ដោយឡែកចំពោះ កម្មករនិយោជិតដែលប្រព្រឹត្តកំហុសនានាប្រាសចាកពីលក្ខន្តិកៈបុគ្គលិក និងក្រមសីលធម៌ នឹងត្រូវទទួលបានការពិនិត្យ និងដាក់ពិន័យដោយក្រុមប្រឹក្សាវិន័យ របស់ ក. ស. ភ.។

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១. | ក្រុមហ៊ុនហ៊ូលឌីង | ពុំមាន |
| ២. | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | ពុំមាន |
| ៣. | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ពុំមាន |
| ៤. | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | ពុំមាន |
| ៥. | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | ពុំមាន |
| ៦. | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | ពុំមាន |

### ២. ប្រតិបត្តិការសំខាន់ៗ ជាមួយភាគីជាប់ពាក់ព័ន្ធ

សម្រាប់ឆ្នាំ២០២២ ពុំមានប្រតិបត្តិការនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

## ផ្នែកទី៤. ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

គិតត្រឹមឆ្នាំ២០២២ ក. ស. ភ. ពុំទាន់បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យជាផ្លូវការនោះទេ ដោយ ក. ស. ភ. កំពុងសិក្សាដើម្បីជួលសេវាអ្នកជំនាញមករៀបចំ។ ជាការអនុវត្តជាក់ស្តែង ករណីមានហានិភ័យណាមួយកើតឡើង គឺថ្នាក់ដឹកនាំ ក. ស. ភ. នឹងពិភាក្សាគ្នាដើម្បីរកដំណោះស្រាយ មុននឹងស្នើសុំការសម្រេចពីក្រុមប្រឹក្សាភិបាល។

### ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

គិតត្រឹមឆ្នាំ២០២២ ក. ស. ភ. ពុំទាន់បង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាផ្លូវការនោះទេ ដោយ ក. ស. ភ. កំពុងសិក្សាដើម្បីជួលសេវាអ្នកជំនាញមករៀបចំ។ ជាការអនុវត្តជាក់ស្តែង នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ ក. ស. ភ. ជាអ្នកត្រួតពិនិត្យ តាមដាន ធ្វើសវនកម្មជារៀងរាល់ត្រីមាស និងឆ្នាំ តាមបណ្តាសេវាដ្ឋាន អង្គភាព ការិយាល័យ និងនាយកដ្ឋានរបស់ ក. ស. ភ. ដោយពិនិត្យលើការអនុវត្តការងារស្របតាមផែនការលក្ខន្តិកៈ និងលិខិតបទដ្ឋានគតិយុត្តនានា។

### គ. ការធ្វើសវនកម្ម

#### ១. សវនកម្មផ្ទៃក្នុង

##### ១.១. កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល និងផែនការប្រចាំឆ្នាំ
- រៀបចំរបាយការណ៍សវនកម្មរៀងរាល់ ត្រីមាស និងឆ្នាំ
- ពិនិត្យឡើងវិញលើមុខងារ សកម្មភាពកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់ ក. ស. ភ. ក្នុងការិយបរិច្ឆេទ សមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រង ឱ្យបានត្រឹមត្រូវតាមគោលដៅរបស់ ក. ស. ភ.
- កំណត់នូវភាពសមស្របគ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់ ក. ស. ភ.
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់ នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានទៅតាមគោលការណ៍ផែនការ នីតិវិធីច្បាប់បទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍ ព្រមទាំងកំណត់ថាអង្គភាពដែលបានធ្វើសវនកម្មរួច អនុវត្តតាមអនុសាសន៍ និងបានធ្វើការកែលំអស្របតាមគោលការណ៍ណែនាំ
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែទាំ ការពារ និងធ្វើការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ

- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពលើការប្រើប្រាស់ធនធាននិងផ្ដល់អនុសាសន៍លើចំណុចខ្វះខាតដើម្បីដោះស្រាយបញ្ហាឱ្យបានសមស្រប
- ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគំរោងចំណាយមូលធន ដើម្បីធានាថាលទ្ធផលស្របតាមគោលបំណង និងទិសដៅដែលបានកំណត់
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឱ្យ៖
    - ក- តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់
    - ខ- ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ
    - គ- ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រត្រូវបានប្រព្រឹត្តិទៅក្នុងជំហានសមស្រប
    - ឃ- ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ
- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រ លើការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលតម្លើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុកហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់
- ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាកុំឱ្យមានការកេងបន្លំ ប្រសិនបើមានកេងបន្លំកើតឡើងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកបានទាន់ពេលវេលា
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់និងកាត់បន្ថយការងារស្ទួនគ្នា
- ធ្វើរបាយការណ៍ជូនប្រធានអគ្គនាយក ហើយត្រូវផ្ញើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះជូនអាជ្ញាធរសវនកម្មជាតិ
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អ លើចំណុចរកឃើញរបស់សវនករផ្ទៃក្នុង។ ប្រសិនបើសកម្មភាពកែលម្អនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីឱ្យសម្រេចបានតាមសំណូមពរដែលអាចទទួលយកបាន
- ផ្ដល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលំអលើអនុសាសន៍
- ប្រធានសវនកម្មផ្ទៃក្នុងជូនរបាយការណ៍ និងរាយការណ៍ដោយផ្ទាល់ជូនថ្នាក់ដឹកនាំ ក. ស. ភ. ឬគណៈកម្មាធិការសវនកម្ម
- ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវកម្ម ផ្ញើជូនដល់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក. ស. ភ. និងផ្ញើរជូនអាជ្ញាធរសវនកម្មជាតិ
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

### ១.២.ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

សម្រាប់ឆ្នាំ២០២២ ពុំមានការតែងតាំង និងដកហូត/លាលែងតំណែងរបស់ប្រធាន និងអនុប្រធានសវនកម្មផ្ទៃក្នុងរបស់ ក. ស. ភ. នោះទេ។

### ១.៣. ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនកម្មផ្ទៃក្នុង

សម្រាប់ឆ្នាំ២០២២ ពុំមានការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុងនោះទេ។

## ២. សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | ឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០ | • ឆ្នាំ២០១៨ តម្លៃ ២៤.០០០ ដុល្លារអាមេរិក<br>• ឆ្នាំ២០១៩ តម្លៃ ២៦.០០០ ដុល្លារអាមេរិក<br>• ឆ្នាំ២០២០ តម្លៃ ២៨.៥០០ ដុល្លារអាមេរិក | ពុំមាន |
| | | ឆ្នាំ២០២១ ដល់ឆ្នាំ ២០២២ | • ឆ្នាំ២០២១ តម្លៃ ៣១.០០០ ដុល្លារអាមេរិក<br>• ឆ្នាំ២០២២ តម្លៃ ៣២.០០០ ដុល្លារអាមេរិក | |

## ផ្នែកទី៥. ភាគីពាក់ព័ន្ធ

### ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខមាលភាពរបស់អតិថិជន | N/A | N/A |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | អនុវត្តតាមនីតិវិធីលទ្ធកម្មដែលកំណត់ដោយអនុក្រឹត្យលេ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ។ | ក. ស. ភ. បានធ្វើការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការតាមរយៈការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ/ក្នុងស្រុក (អាស្រ័យលើទំហំ ទឹកប្រាក់នៃគម្រោងចំណាយ) ការពិគ្រោះថ្លៃ និងការស្ទង់តម្លៃ។ |
| ៣ | ការគ្រប់គ្រងនិងការការពារនិយោជិត | កម្មករ និយោជិត ក. ស. ភ. ត្រូវបានគ្រប់គ្រង និងការពារដោយច្បាប់ស្តីពីការងារ និងលក្ខន្តិកៈបុគ្គលិក ក. ស. ភ.។ | ក្នុងពេលបំពេញការងារ កម្មករ និយោជិត ដែលមានជម្ងឺ ឬគ្រោះថ្នាក់ត្រូវបានពិនិត្យព្យាបាលជាបន្ទាន់នៅតាមបណ្តាមន្ទីរពេទ្យ ផ្សេងៗ បន្ទាប់មកត្រូវផ្ទេរទៅមន្ទីរពេទ្យ ដែលកំណត់ដោយ ប.ស.ស.។ |
| ៤ | ការគាំពារបរិស្ថាន | ក.ស.ភ. មានគោលការណ៍សុវត្ថិភាព សុខុមាលភាព និងបរិស្ថានផែ សម្រាប់អនុវត្តក្នុងកិច្ចគាំពារបរិស្ថាន។ | ក.ស.ភ. បានអនុវត្តតាមគោលការណ៍ដែលមានស្រាប់ ដោយបង្រួមឱ្យតូចបំផុតនូវផលប៉ះពាល់ បរិស្ថានជាអវិជ្ជមានដល់សហគមន៍ដែលនៅជុំវិញ។ |
| ៥ | អន្តរកម្មជាមួយសហគមន៍ | N/A | N/A |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | N/A | N/A |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | រាល់នីតិវិធីដេញថ្លៃរបស់ ក.ស.ភ. ត្រូវមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការអង្កេតពីមន្ត្រីនៃអង្គភាពប្រឆាំងអំពើរពុករលួយ។ | នៅពេល ក. ស. ភ. អនុវត្តនីតិវិធីដេញថ្លៃ គឺមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការអង្កេតពីមន្ត្រីនៃអង្គភាពប្រឆាំងអំពើរពុករលួយ។ |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

| ល.រ | អ្នកទទួលផលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|---|
| | | ដុល្លារអាមេរិក | រៀល | |
| ១ | សាខាកាកបាទក្រហមខេត្តកណ្តាល | | ១០.០០០.០០០ រៀល | |
| ២ | សាខាកាកបាទក្រហមខេត្តព្រៃវែង | | ១០.០០០.០០០ រៀល | |
| ៣ | ស្នាក់ការកណ្តាលកាកបាទក្រហម | ១០.០០០ ដុល្លារអាមេរិក | | |
| ៤ | ការសាងសង់ស្ពានសម្តេចតេជោ ស្ថិតនៅខេត្តកំពង់ធំ | ២០.០០០ ដុល្លារអាមេរិក | | |
| ៥ | ព្រឹត្តិការណ៍រាត្រីសមោសរសប្បុរស-ធម៌ នៃការដាក់បញ្ចូលរមណីយដ្ឋានអង្គរវត្ត ជាសម្បត្តិបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ ដើម្បីជួយដល់មន្ទីរពេទ្យគន្ធបុប្ផា | ៩.០០០ ដុល្លារអាមេរិក | | សប្បុរសធម៌ |
| ៦ | សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) | ៥.០០០ ដុល្លារអាមេរិក | | |
| ៧ | ទាហាន ស្ថិតនៅខេត្តព្រះវិហារ | | ៤៧.២០០.០០០ រៀល | |
| ៨ | កិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន ឆ្នាំ២០២២ | ១០.០០០ ដុល្លារអាមេរិក | | ឧបត្ថម្ភ |
| **សរុប** | | **៥៤.០០០ ដុល្លារអាមេរិក** | **៦៧.២០០.០០០ រៀល** | |

## ផ្នែកទី៦. ការបង្ហាញព័ត៌មាន និងតម្លាភាព

### ក. បង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ | មូលហេតុ |
|---|---|---|---|
| ១. | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មាន | |
| ២. | សូចនាករហិរញ្ញវត្ថុ | មាន | |
| ៣. | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន | |
| ៤. | កត្តាហានិភ័យសំខាន់ៗ | គ្មានបង្ហាញ | សម្រាប់ឆ្នាំ២០២២ ក. ស. ភ. ពុំមានវិភាគអំពីកត្តាហានិភ័យសំខាន់ៗនៅឡើយទេ។ |
| ៥. | គោលនយោបាយភាគលាភ | មាន | |
| ៦. | ជីវប្រវត្តិរបស់អភិបាល | មាន | |
| ៧. | ការបណ្តុះបណ្តាលអភិបាល | មាន | |
| ៨. | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន | |
| ៩. | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន | |
| ១០. | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន | |

### ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មានដោយរៀបរាប់ពីគោលនយោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ក. ស. ភ. បានធ្វើការបង្ហាញព័ត៌មានតាមរយៈក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងគេហទំព័រ (Website) របស់ ក. ស. ភ. ដោយក្នុងនោះរួមមានព័ត៌មានទាន់ពេល ព័ត៌មានសមាយិក និងព័ត៌មានស្ម័គ្រចិត្ត។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ ក. ស. ភ. គឺអ្នកស្រី ហ៊ឺ ផានិន អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ។

### គ. ទំនាក់ទំនងជាមួយវិនិយោគិន

#### ១. បង្ហាញពីយន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

ករណីវិនិយោគិនមានចម្ងល់ណាមួយពាក់ព័ន្ធនឹង ក. ស. ភ. វិនិយោគិនអាចធ្វើការទំនាក់ទំនងមកកាន់ ក. ស. ភ. តាមរយៈសារអេឡិចត្រូនិក (Email) និងទូរសព្ទ ឬអាចអញ្ជើញមកអគារទីស្នាក់ការកណ្តាលរបស់ ក. ស. ភ. ផ្ទាល់ ដែលមានអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

- សារអេឡិចត្រូនិក (Email) : ppapmpwt@online.com.kh
- លេខទូរសព្ទ : ០២៣ ៤២៧ ៨០២
- អាសយដ្ឋាន : អគារលេខ ៦៤៩ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

## ២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល ១ (មួយ) ឆ្នាំចុងក្រោយ

សម្រាប់ឆ្នាំ២០២២ ក. ស. ភ. បានធ្វើការទំនាក់ទំនងជាមួយវិនិយោគិនតាមរយៈការមកជួបប្រជុំនៅក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ក. ស. ភ.។

# ឧបសម្ព័ន្ធ ២

# របាយការណ៍ហិរញ្ញវត្ថុ និង
# របាយការណ៍របស់សវនករឯករាជ្យ
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ៧១៧៥ Et/២០០៤

# កំពង់ផែស្វយ័តភ្នំពេញ
# (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ហិរញ្ញវត្ថុ និង
## របាយការណ៍របស់សវនករឯករាជ្យ
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

របាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយ គឺជាការប្រែសម្រួលជាភាសាខ្មែរ ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ របាយការណ៍ជាភាសាអង់គ្លេសត្រូវបានយកជាគោល។

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ៧១៧៥ Et/២០០៤

**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ព័ត៌មានអំពី ក.ស.ត**

| | |
|---|---|
| ក្រុមប្រឹក្សាភិបាល៖ | ឯកឧត្តម ហ៊ី បាវី<br>ឯកឧត្តម សួន រចនា<br>ឯកឧត្តម កែន សម្បត្តិ<br>ឯកឧត្តម ប៉ែន សុវិជាតិ<br>លោក ហ្គី អានវ៉ានិច<br>លោក គង់ សុធា<br>អ្នកស្រី ប៉ុក ភក្តី |
| ទីស្នាក់ការ៖ | លេខ៦៤៩ តិវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក<br>ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ធនាគារ៖ | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់<br>ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ<br>ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក<br>ជីប ម៉ុង ខមមើសល ប៉ែង ម.ក<br>ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក<br>ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| សវនករ៖ | ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត |

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ៧១៧៥ Et/២០០៤

**ភ្នំពេញអង់តែសស្វយ័តផ្ទាំពេញ**

**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| របាយការណ៍របស់សវនករឯករាជ្យ | ៦ - ១០ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១១ - ១២ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ | ១៣ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៤ - ១៥ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៦ - ១៨ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១៩ - ៥៣ |

## កំពង់ផែស្វយ័តភ្នំពេញ
## (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ កំពង់ផែស្វយ័តភ្នំពេញ ហៅកាត់ថា “ក.ស.ភ” សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

### សកម្មភាពចម្បង

ក.ស.ភ គឺជានីតិបុគ្គលដែលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ហើយបេសកកម្មចម្បងគឺសេវាកម្មកំពង់ផែ និងសេវាដែលពាក់ព័ន្ធផ្សេងទៀត។

ក.ស.ភ មានគោលដៅទទួលរ៉ាប់រងក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកម្មកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍន៍ សម្រាប់តម្រូវការខាងពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ និងអ្នកដំណើរ និងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឱ្យ ក.ស.ភ រីកចម្រើនលូតលាស់ទៅមុខ។

ក.ស.ភ មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែ រួមមាន៖

- ផ្តល់កណ្តូធារកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង
- ធ្វើអាជីវកម្មបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- ត្រួតពិនិត្យការប្រតិបត្តិតាមលក្ខណៈបច្ចេកទេស និងជម្រុញកិច្ចការពារសុវត្ថិភាព បរិស្ថាន សណ្តាប់ធ្នាប់ក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែ
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែ រួមមាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភ័ស្តុភារកម្ម
- ចាត់វិធានការនានា ដើម្បីធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពាក់ព័ន្ធនឹងកំពង់ផែ និងមធ្យោបាយដឹកជញ្ជូននានាតាមផ្លូវទឹក
- លើកដាក់ ផ្ទេរ ផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរវាងកំពង់ផែ និងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវា ពាក់ និងដោះពួរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភ័ស្តុភារ ទឹកស្អាត អនាម័យដល់នាវា
- ផ្តល់សេវាកម្មរើ និងច្រកទំនិញដាក់កុងតឺន័រ
- ផ្តល់សេវាកម្មជួសជុល និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងមណ្ឌលសេវាកម្មផែក្នុងស្រុក

**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

**សកម្មភាពចម្បង (ត)**

ក.ស.ភ មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែ រួមមាន៖ (ត)

- ធ្វើប្រតិបត្តិការអាជីវកម្មបន្ថែមផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបម្រើដល់ការរីកចម្រើនរបស់ ក.ស.ភ។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ ក.ស.ភ នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ។

**លទ្ធផលនៃប្រតិបត្តិការ**

| | ដុល្លារអាមេរិក | គិតជាពាន់រៀល |
|---|---|---|
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | ១៤.៣១៣.២៨៣ | ៥៨.៤៩៨.៣៨៩ |

**ភាគលាភ**

ភាគលាភដែលបានបង់ ចាប់តាំងពីការិយបរិច្ឆេទមុនមានដូចខាងក្រោម៖

| | ដុល្លារអាមេរិក | គិតជាពាន់រៀល |
|---|---|---|
| សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ | | |
| ភាគលាភ ប្រភេទ “ក” ត្រូវបានទូទាត់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ | ៣៤០.១៩០ | ១.៣៩០.៣៥៧ |
| ភាគលាភ ប្រភេទ “ខ” ត្រូវបានទូទាត់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ | ៧៤១.២៩០ | ៣.០២៩.៦៥២ |
| | ១.០៨១.៤៨០ | ៤.៤២០.០០៩ |

**ទុនបម្រុង និងសំវិធានធន**

មានការផ្ទេរទឹកប្រាក់ចំនួន ១១.៦០៥.៣១៧ដុល្លារអាមេរិក ពីចំណេញរក្សាទុកទៅទុនបម្រុងតាមច្បាប់ទុនបម្រុងទូទៅ និងទុនបម្រុងអភិវឌ្ឍន៍ ដែលបានអនុម័តក្នុងអំឡុងពេលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

**បំណុលពិបាកទារ និង បំណុលជាប់សង្ស័យ**

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលនូវបំណុលពិបាកទារ និងការធ្វើសំវិធានធនចំពោះបំណុលជាប់សង្ស័យត្រូវបានធ្វើឡើងហើយជឿជាក់ថាមិនមានបំណុលពិបាកទារ និងបានធ្វើសំវិធានធនគ្រប់គ្រាន់សម្រាប់បំណុលជាប់សង្ស័យ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានភាពចាំបាច់ដើម្បីលុបចោលនូវបំណុលពិបាកទារ ឬក៏ធ្វើសំវិធានធនចំពោះបំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ឡើយ។

**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)**
**ទ្រព្យសកម្មចរន្ត**

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ និង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ ក.ស.ភ ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាមានភាពមិនត្រឹមត្រូវឡើយ។

**វិធីសាស្ត្រកំណត់តម្លៃ**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង បណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ឡើយ។

**បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ ក.ស.ភ ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយចាប់តាំងពីដំណាច់ឆ្នាំនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ឬ

(២) បំណុលយថាហេតុណាមួយកើតឡើងចំពោះ ក.ស.ភ ចាប់តាំងពីដំណាច់ឆ្នាំនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសងក្នុងអំឡុងពេល១២ខែ ក្រោយថ្ងៃការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ ក.ស.ភ ក្នុងការសងបំណុលរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

**ការផ្លាស់ប្តូរនៃហេតុការណ៍**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលឱ្យមានចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ មានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ ក.ស.ភ ក្នុងការិយបរិច្ឆេទនេះមិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុមកទល់នឹងថ្ងៃចេញរបាយការណ៍នេះពុំមានប្រតិបត្តិការ ឬហេតុការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើងដែលអាចប៉ះពាល់ដល់លទ្ធផលអាជីវកម្មក្នុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ត្រូវបានរៀបចំឡើងនោះទេ។

**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

**ដើមទុន**

ក.ស.ភ ពុំមានការបោះផ្សាយភាគហ៊ុន នៅក្នុងការិយបរិច្ឆេទនេះទេ។

ក.ស.ភ ពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុននៃ ក.ស.ភ នាចុងការិយបរិច្ឆេទទេ។

**សមាជិកក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីថ្ងៃចេញរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយរួមមាន៖

ឯកឧត្តម ហ៊ី បាវី

ឯកឧត្តម សួន រចនា

ឯកឧត្តម កែន សម្បត្តិ

ឯកឧត្តម ប៉ែន សុវិជាតិ

លោក ហ៊្គី អានវ៉ានិច

| | |
|---|---|
| លោក គង់ សុធា | (តែងតាំងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២) |
| អ្នកស្រី ប៉ុក ភក្តី | (តែងតាំងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២) |
| លោក យឹម ជឿន | (លាឈប់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២) |
| លោក ឱត សុចល | (លាឈប់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២) |

**អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល**

នៅក្នុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលមាន ក.ស.ភ ជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិត បំណុលពី ក.ស.ភ ឬពី ក.ស.ភ ទៅបុគ្គលដទៃទៀតឡើយ។

ចាប់តាំងពីការិយបរិច្ឆេទមុន ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយ ក.ស.ភ ឬដោយក្រុមហ៊ុនដែលពាក់ព័ន្ធ ណាមួយជាមួយនឹង ក.ស.ភ ដែលមានអគ្គនាយកជាសមាជិក ឬក៏ជាមួយ ក្រុមហ៊ុន ដែលអគ្គនាយកមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងសម្រាប់អត្ថប្រយោជន៍ផ្សេងទៀត ដែលអាចត្រូវបានចាត់ទុកថាបានកើតឡើងដោយសារគុណសម្បត្តិនៃប្រតិបត្តិការទាំងនោះដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ ក.ស.ភ សម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

ក. ជ្រើសរើសគោលការណ៍គណនេយ្យសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលការណ៍ទាំងនេះឱ្យបានស្របគ្នា។

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤



**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល(ត)**
ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)
ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖ (ត)

ខ. អនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ. ធានាឱ្យបាននូវភាពគ្រប់គ្រាន់នៃការកត់ត្រាគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក.ស.ភ នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង

ង. ត្រួតពិនិត្យ និងដឹកនាំ ក.ស.ភ ឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការ ក.ស.ភ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានបង្ហាញត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក.ស.ភ បានអនុវត្តតាមរាល់លក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទ**

ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣៣ នៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុ។

**ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនៃរបាយការណ៍**

ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនៃរបាយការណ៍ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣៤ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី១១ ដល់ ៥៣ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ ក.ស.ភ សម្រាប់ការិយបរិច្ឆេទនេះ។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល

**ឯកឧត្តម ហ៊ី បាទី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

**កញ្ញា ឈាង ចន្ធានា**
នាយកគណនេយ្យ/ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

BDO

Tel: +855 23 218 128
Fax: +855 23 993 225
www.bdo.com.kh

Suite 2B Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់
## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៧១៧៥ Et/២០០៤)

## សេចក្តីរាយការណ៍សវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តភ្នំពេញ ហៅកាត់ថា ("ក.ស.ភ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ និង សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញនៅលើទំព័រទី ១១ ដល់ ៥៣។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក")។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដារនេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

*ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌*

យើងខ្ញុំមានភាពឯករាជ្យពី ក.ស.ភ ដោយអនុលោមតាមក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ *ក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ)* ("ក្រមសីលធម៌ IESBA") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធទៅនឹងសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុរបស់យើងនៅក្នុងប្រទេសកម្ពុជា និងយើងបានបំពេញទំនួលខុសត្រូវផ្នែកសីលធម៌ផ្សេងទៀតរបស់យើងស្របតាមតម្រូវការទាំងនេះ និងក្រមសីលធម៌ IESBA។

### បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន ដោយយោងតាមការវិនិច្ឆ័យដោយវិជ្ជាជីវៈរបស់យើងខ្ញុំ។ បញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ទាំងមូល ហើយនៅក្នុងការបង្កើតមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ យើងខ្ញុំមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហាទាំងនេះឡើយ។

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៧១៧៥ Et/២០០៤) (ត)

បញ្ហាសវនកម្មសំខាន់ៗ (ត)

(ក) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានកំណត់ដោយផ្អែកលើចំនួនសន្មតនៃ actuarial និងការគណនាដែលមានឥទ្ធិពលទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មាន។ ការផ្លាស់ប្ដូរនៃការសន្មត អាចមានផលប៉ះពាល់ជាសារវន្តលើកម្រិតកាតព្វកិច្ចនៃការកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការប៉ាន់ស្មានរួមបញ្ចូល អត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាមរណភាព អត្រាពិការភាព និងអត្រាបម្រែបម្រួលបុគ្គលិក។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល បានជួលអ្នកជំនាញវិភាគលើ actuarial ដើម្បីបង្ហាញការប៉ាន់ស្មានបង្គរនៃបំណុលនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងដើម្បីផ្ដល់នូវការប៉ាន់ស្មាន នៃការចំណាយប្រាក់លើអត្ថប្រយោជន៍ដែលបានកំណត់សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ច អត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានកំណត់ដោយអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតដែលបានមកពីការប៉ាន់ស្មាន ដោយការប្រើប្រាស់អត្រាការប្រាក់ប្រាក់បញ្ញើរយៈពេលវែងជាមធ្យមរបស់ធនាគារចម្បងៗ នៅក្នុងប្រទេសកម្ពុជា តាមអត្រាការប្រាក់ ៦,៣០%ក្នុងមួយឆ្នាំ។

*ការឆ្លើយតបសវនកម្ម*

យើងខ្ញុំបានអនុវត្តនីតិវិធី ដោយពឹងផ្អែកលើរបាយការណ៍វាយតម្លៃការប៉ាន់ស្មានដែលរួមមាន ការវាយតម្លៃទៅលើសមត្ថភាព លក្ខណៈសម្បត្តិ និងភាពឯករាជ្យរបស់អ្នកជំនាញវាយតម្លៃ ក៏ដូចជាការប៉ាន់ប្រមាណថាតើការសន្មតនៃ actuarial អនុវត្តបានស្របគ្នា និងវាយតម្លៃលើហេតុផលនៃការផ្លាស់ប្ដូរវិធីសាស្ត្រ។

(ខ) ទឹកប្រាក់ដែលអាចប្រមូលមកវិញនៃគណនីអតិថិជនពាណិជ្ជកម្ម

គណនីអតិថិជនពាណិជ្ជកម្មរបស់ ក.ស.ភ ដែលមានតម្លៃពិតគណនេយ្យចំនួន ៤.០៨៧.៥៤៧ ដុល្លារអាមេរិក ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ៩ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

យើងបានកំណត់ថា នេះជាកត្តាបញ្ហាសវនកម្មសំខាន់ ព្រោះវាតម្រូវឱ្យគណៈគ្រប់គ្រងអនុវត្តការវិនិច្ឆ័យសំខាន់ៗក្នុងការកំណត់លទ្ធភាពនៃការខកខានការទូទាត់ប្រាក់ ពីគណនីអតិថិជនពាណិជ្ជកម្ម និងព័ត៌មាននាពេលខាងមុខ ("Forward looking information")។

*ការឆ្លើយតបសវនកម្ម*

យើងខ្ញុំបានអនុវត្តនីតិវិធី ដូចខាងក្រោម៖

(១) គណនាប្រូបាប៊ីលីតេលំនាំដើមឡើងវិញ ដោយប្រើទិន្នន័យអតីតកាល ("Historical data") និងការកែតម្រូវព័ត៌មាននាពេលខាងមុខ ដែលត្រូវបានប្រើប្រាស់ដោយ ក.ស.ភ

(២) គណនាឡើងវិញនូវ ការជាប់ទាក់ទងដែលមានឥទ្ធិពលរវាងសូចនាករម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានប្រើប្រាស់ដោយ ក.ស.ភ និងការបាត់បង់ពីអតីតកាលដើម្បីកំណត់ភាពសមស្របនៃព័ត៌មាននាពេលខាងមុខ ("Forward looking information") ដែលត្រូវបានប្រើប្រាស់ដោយ ក.ស.ភ និង

(៣) សាកសួរគណៈគ្រប់គ្រង ដើម្បីវាយតម្លៃហេតុផលដែលបង្ហាញពីទំនាក់ទំនង រវាងព័ត៌មាននាពេលខាងមុខ និងការខាតបង់ឥណទានរំពឹងទុក។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៧១៧៥ Et/២០០៤) (ត)

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ

ក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ មានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានព័ត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទេ។

មតិយោបល់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ មិនរួមបញ្ចូលព័ត៌មានផ្សេងៗ ហើយយើងខ្ញុំនឹងមិនផ្តល់នូវទម្រង់សន្និដ្ឋានជាបែបពានាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ឬក៏ចំណេះដឹងរបស់យើងខ្ញុំទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំតម្រូវឱ្យរាយការណ៍នូវហេតុការណ៍ទាំងនោះ។ យើងខ្ញុំពុំមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញ-វត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាល ក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ ដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃទៅលើលទ្ធភាពបន្តប្រតិបត្តិការរបស់ ក.ស.ភ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម រួមទាំងធ្វើការបង្ហាញពីកត្តាពាក់ព័ន្ធនឹងនិរន្តរភាពនៃដំណើរការអាជីវកម្មនោះ និងប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបនិរន្តរភាព លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយ ក.ស.ភ ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែអនុវត្តតាមលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺទទួលបានអំណះអំណាងយ៉ាងសមហេតុផលថា តើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនបានធានាថា ការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្តពេលដែលវាកើតមានឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្គុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

BDO



**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៧១៧៥ Et/២០០៤) (ត)

ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

ជាផ្នែកមួយនៃសវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃលើហានិភ័យកំហុសឆ្គងជាសារវន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាតើវាបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីជាមូលដ្ឋានដល់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនបានរកឃើញនូវកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនិតិវិធីសវនកម្មដែលត្រឹមត្រូវទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធិភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក.ស.ភ នោះឡើយ។
- វាយតម្លៃភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងកំណត់បង្ហាញដែលពាក់ព័ន្ធ ដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ដែលគណៈគ្រប់គ្រងប្រើប្រាស់ និងផ្អែកលើភស្តុតាងដែលទទួលបាន ថាតើមានភាពមិនប្រាកដប្រជាកើតឡើងជាសារវន្ត ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចប៉ះពាល់ដល់លទ្ធភាពបន្តប្រតិបត្តិការរបស់ ក.ស.ភ ក្នុងការបន្តនិរន្តភាព។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តមួយកើតឡើងយើងខ្ញុំត្រូវបានតម្រូវឱ្យទាញការយកចិត្តទុកដាក់ក្នុងរបាយការណ៍សវនកម្ម ភ្ជាប់នឹងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ប្រសិនបើការបង្ហាញទាំងនោះមិនត្រឹមត្រូវ នោះមតិយោបល់របស់យើងខ្ញុំនឹងកែប្រែ។ សេចក្តីសន្និដ្ឋានយើងខ្ញុំ គឺផ្អែកលើភស្តុតាងដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនកម្ម។ ប៉ុន្តែព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឱ្យ ក.ស.ភ បញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្មបាន។
- វាយតម្លៃលើបទបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ រួមទាំងកំណត់បង្ហាញ ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ បានតំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ នៅក្នុងលក្ខខណ្ឌមួយដែលបង្ហាញពីទិដ្ឋភាពសមស្របដែរឬទេ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៧១៧៥ Et/២០០៤) (ត)

ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលពាក់ពន្ធ័នឹងបញ្ហាដទៃទៀតក៏ដូចជា ផែនការទំហំការងារ និងពេលវេលានៃសវនកម្ម និងចំណុចសំខាន់ៗដែលបានរកឃើញ រួមមានកង្វះខាតលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងបានអនុវត្តទៅតាមតម្រូវការនៃក្រមសីលធម៌ពាក់ព័ន្ធផ្សេងៗ ដែលទាក់ទិននឹងឯករាជ្យភាព និងធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលពាក់ព័ន្ធ ហើយនិងចំនុចផ្សេងទៀតដែលអាចមានឥទ្ធិពលលើឯករាជ្យរបស់យើងខ្ញុំ និងការការពារដែលពាក់ព័ន្ធប្រសិនបើមាន។

អំពីបញ្ហាដែលយើងខ្ញុំបានទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល យើងខ្ញុំបានកំណត់ជាបញ្ហាទាំងនោះ គឺមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ក.ស.ភ សម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ដូច្នេះហើយវាជាបញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំនឹងពណ៌នាបញ្ហាទាំងនោះនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លុះត្រាតែមានច្បាប់ ឬបញ្ញត្តិ រារាំងការបង្ហាញជាសាធារណៈអំពីចំណុចទាំងនេះ ឬក៏ក្នុងកាលៈទេសៈដ៏កម្រ យើងខ្ញុំកំណត់ថាចំណុចនេះមិនគួរបង្ហាញនៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារតែផលវិបាកជាអវិជ្ជមានពីការបង្ហាញនោះអាចនឹងមានផលប៉ះពាល់ដល់អត្ថប្រយោជន៍សាធារណៈ។

បញ្ហាផ្សេងៗ

របាយការណ៍នេះត្រូវបានធ្វើឡើងចំពោះតែភាគហ៊ុនិក ក.ស.ភ ប៉ុណ្ណោះ។ យើងមិនទទួលខុសត្រូវចំពោះបុគ្គលណាម្នាក់សម្រាប់ខ្លឹមសារនៃរបាយការណ៍នេះទេ។

សម្រាប់ និងជំនួសឱ្យ
**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

លឹម សេងស៊ីវ
*គណនេយ្យករជំនាញ*

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

# កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសកម្មសម្បទាន | ៥ | ៨.១៣៥.០៩៣ | ៣៣.៤៩២.១៧៨ | - | - |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | ១០៧.៦៣២.៩៥០ | ៤៤៣.១២៤.៨៥៥ | ១០៣.៣២៨.៣៧៥ | ៤២០.៩៥៩.៨០០ |
| សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម | ៧ | ៥.៧៦៦.៩៩៥ | ២៣.៧៤២.៧១៨ | ៣.៦៦០.៩៩២ | ១៤.៩១៤.៨៨១ |
| ទ្រព្យសម្បត្តិវិនិយោគ | ៨ | ៨៤.២៣៤.៦៨៧ | ៣៤៦.៧៩៤.២០៦ | ៨៤.៦២៦.៨៦៣ | ៣៤៤.៧៦៩.៨៤០ |
| ភតិសន្យាត្រូវទទួល | ៧ | ៨.៨៣៥.៩៨៦ | ៣៦.៣៧៧.៧៥៤ | ៤.២៩៦.៥៨៨ | ១៧.៥០៤.៣០០ |
| គណនីត្រូវទទួលផ្សេងៗ | ៩ | ៧០.២៨៩ | ២៨៩.៣៨០ | ៦៧.៥៨៥ | ២៧៥.៣៤១ |
| ទ្រព្យសកម្មពន្ធពន្យារ | ១០ | - | - | ១៤០.៣៧៦ | ៥៧១.៨៩២ |
| | | ២១៤.៦៧៦.០០០ | ៨៨៣.៨២១.០៩១ | ១៩៦.១២០.៧៧៩ | ៧៩៨.៩៩៦.០៥៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ១១ | ៧១៤.៩៨២ | ២.៩៤៣.៥៨១ | - | - |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ៩ | ៨.២៩៨.៧៤៧ | ៣៤.១៦៥.៩៤១ | ៥.១៣៤.៥២១ | ២០.៩១៨.០៣៩ |
| ភតិសន្យាត្រូវទទួល | ៧ | ៣៤.៤៩៧ | ១៤២.០២៤ | ១៣.៨៨៦ | ៥៦.៥៧២ |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | ១២ | ២២.២០២.៨៣៥ | ៩១.៤០៩.០៧២ | ១៨.៦១៤.៧០០ | ៧៥.៨៣៦.២៨៨ |
| | | ៣១.២៥១.០៦១ | ១២៨.៦៦០.៦១៨ | ២៣.៧៦៣.១០៧ | ៩៦.៨១០.៨៩៩ |
| **ទ្រព្យសកម្មសរុប** | | ២៤៥.៩២៧.០៦១ | ១.០១២.៤៨១.៧០៩ | ២១៩.៨៨៣.៨៨៦ | ៨៩៥.៨០៦.៩៥៣ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ |
| បុព្វលាភភាគហ៊ុន | ១៤ | ១៥៥.៥០២ | ៦២២.០០៨ | ១៥៥.៥០២ | ៦២២.០០៨ |
| ទុនបម្រុង | ១៥ | ៥៧.៤៦៦.៦៩៧ | ២៣៦.៥៩០.៣៩១ | ៤៥.៨៦១.៣៨០ | ១៨៦.៨៣៩.២៦២ |
| ចំណេញរក្សាទុក | | ១៤.៥៦៥.០៤៣ | ៥៩.៥២៧.៣៣២ | ១២.៦៨៦.៧៩៧ | ៥១.៦៨៦.០១១ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | ១៣.៨៤៦.២០០ | - | ៨.៤៨១.០៦៦ |
| **មូលធនសរុប** | | ១៨៦.៦៤០.៧២៧ | ៧៦៨.៣៩៩.៨៧១ | ១៧៣.១៥៧.១៦៤ | ៧០៥.៤៤២.២៨៧ |

# គំពង់ផែស្វយ័តភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)**

| | កំណត់ សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ គិតជាពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|---|
| មូលធន និងបំណុល (ត) | | | | | |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| គណនីត្រូវបង់ផ្សេងៗ | ១៦ | ៣៥.១៤៥ | ១៤៤.៦៩២ | ៣៣.៧៩៣ | ១៣៧.៦៧៣ |
| ប្រាក់កម្ចី | ១៧ | ១៦.៥៥៩.៧៩៣ | ៦៨.១៧៦.៦៦៨ | ១៨.៦២៩.៧៦៧ | ៧៥.៨៩៧.៦៧១ |
| សំវិធានធនលើកាតព្វកិច្ចអត្ថប្រយោជន៍ សោធនិវត្តន៍ | ១៨ | ៣៦២.០២៣ | ១.៤៩០.៤៤៩ | ៥៥៥.៨២៩ | ២.២៦៤.៤៤៧ |
| បំណុលភតិសន្យា | ៧ | ១១.៥៦៦.៨០១ | ៤៧.៦២០.៥២០ | ៦.៧៧៨.៨៨៥ | ២៧.៦១៧.១៧៧ |
| កិច្ចសន្យាបំណុល | ១៩ | ១៣.៣៥០.០០០ | ៥៤.៩៦១.៩៥០ | ១៣.៦៥០.០០០ | ៥៥.៦១០.១០០ |
| ចំណូលពន្យារ | ២០ | ៨.១៧៨.២៩២ | ៣៣.៦៧០.០២៨ | - | - |
| បំណុលពន្ធពន្យារ | ១០ | ២៧១.២៣០ | ១.១១៦.៦៥៤ | - | - |
| | | ៥០.៣២៣.២៨៤ | ២០៧.១៨០.៩៦១ | ៣៩.៦៤៨.២៧៤ | ១៦១.៥២៧.០៦៨ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវ បង់ផ្សេងៗ | ១៦ | ៣.២៣៣.២០២ | ១៣.៣១១.០៩៣ | ២.៣៩៣.៩០៧ | ៩.៧៥២.៧៧៨ |
| ប្រាក់កម្ចី | ១៧ | ២.០៦៩.៩៧៤ | ៨.៥២២.០៨៣ | ២.០៦៩.៩៧៤ | ៨.៤៣៣.០៧៤ |
| បំណុលភតិសន្យា | ៧ | ៥៦.៣៩៦ | ២៣២.១៨២ | ៩.២៦១ | ៣៧.៧២៩ |
| កិច្ចសន្យាបំណុល | ១៩ | ៣០០.០០០ | ១.២៣៥.១០០ | ៣០០.០០០ | ១.២២២.២០០ |
| បំណុលពន្ធចរន្ត | | ៣.៣០៣.៤៧៨ | ១៣.៦០០.៤១៩ | ២.៣០៥.៣០៦ | ៩.៣៩១.៨១៧ |
| | | ៨.៩៦៣.០៥០ | ៣៦.៩០០.៨៧៧ | ៧.០៧៨.៤៤៨ | ២៨.៨៣៧.៥៩៨ |
| **បំណុលសរុប** | | ៥៩.២៨៦.៣៣៤ | ២៤៤.០៨១.៨៣៨ | ៤៦.៧២៦.៧២២ | ១៩០.៣៦៤.៦៦៦ |
| **មូលធន និងបំណុលសរុប** | | ២៤៥.៩២៧.០៦១ | ១.០១២.៤៨១.៧០៩ | ២១៩.៨៨៣.៨៨៦ | ៨៩៥.៨០៦.៩៥៣ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

# គំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ
### សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ គិតជាពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|---|
| ចំណូល | ២២ | ៣៦.៤១១.៩៣២ | ១៤៨.៨១៥.៥៦៧ | ៣០.៧៨៣.៧១៥ | ១២៥.២២៨.១៥២ |
| ថ្លៃដើមសេវាកម្ម | ២៣ | (១២.៤៤៣.៨១៨) | (៥០.៨៥៧.៨៨៥) | (៩.៨១១.៣១៧) | (៣៩.៩១២.៤៣៩) |
| ប្រាក់ចំណេញដុល | | ២៣.៩៦៨.១១៤ | ៩៧.៩៥៧.៦៨២ | ២០.៩៧២.៣៩៨ | ៨៥.៣១៥.៧១៣ |
| ចំណូលផ្សេងៗ | ២៤ | ៥.២០៤.៧៦៨ | ២១.២៧១.៨៨៧ | ៣.៣៣៤.០៩១ | ១៣.៥៦៣.០៨៣ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៥ | (៩.៦៣៦.៦៩១) | (៣៩.៣៨៥.១៥៥) | (៧.៤៥១.៣៦៥) | (៣០.៣១២.១៥២) |
| ចំណេញប្រតិបត្តិការ | | ១៩.៥៣៦.១៩១ | ៧៩.៨៤៤.៤១៤ | ១៦.៨៥៥.១២៤ | ៦៨.៥៦៦.៦៤៤ |
| ចំណាយហិរញ្ញវត្ថុ | ២៦ | (១.០៨៦.៥៣៨) | (៤.៤៤០.៦៨១) | (១.១៤២.៧៨៦) | (៤.៦៤៨.៨៥៣) |
| ចំណេញមុនបង់ពន្ធ | | ១៨.៤៤៩.៦៥៣ | ៧៥.៤០៣.៧៣៣ | ១៥.៧១២.៣៣៨ | ៦៣.៩១៧.៧៩១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៧ | (៤.១៣៦.៣៧០) | (១៦.៩០៥.៣៤៤) | (៣.០០៤.៥០៧) | (១២.២២២.៣៣៤) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ១៤.៣១៣.២៨៣ | ៥៨.៤៩៨.៣៨៩ | ១២.៧០៧.៨៣១ | ៥១.៦៩៥.៤៥៧ |
| ចំណូលផ្សេងៗ បន្ទាប់ពីគិតពន្ធរួច | | | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកឡើងវិញលើ ចំណេញ ឬខាត៖ | | | | | |
| ការកំណត់ឡើងវិញនូវសំវិធានធនលើអត្ថ-ប្រយោជន៍សោធនិវត្តន៍ | | ២៥១.៧៦០ | ១.០២៨.៩៤៣ | (២១.០៣៤) | (៨៥.៥៦៦) |
| ចំណូលលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | ១៤.៥៦៥.០៤៣ | ៥៩.៥២៧.៣៣២ | ១២.៦៨៦.៧៩៧ | ៥១.៦០៩.៨៩១ |

ចំណេញក្នុង១ភាគហ៊ុន របស់ភាគហ៊ុនិកនៃ ក.ស.ភ ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន | ២៨ | ០,៧០ | ២,៨៨ | ០,៦១ | ២,៥០ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ២៨ | ០,៧០ | ២,៨៨ | ០,៦១ | ២,៥០ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

## គំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | លម្អៀងនៃការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៤៥.៨៦១.៣៨០** | **១២.៦៨៦.៧៩៧** | - | **១៧៣.១៥៧.១៦៤** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ១៤.៣១៣.២៨៣ | - | ១៤.៣១៣.២៨៣ |
| ចំណេញពីការវាយតម្លៃកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | | - | - | - | ២៥១.៧៦០ | - | ២៥១.៧៦០ |
| ចំណេញលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | - | - | - | ១៤.៥៦៥.០៤៣ | - | ១៤.៥៦៥.០៤៣ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង | ១៥ | - | - | ១១.៦០៥.៣១៧ | (១១.៦០៥.៣១៧) | - | - |
| ភាគលាភ | ២៩ | - | - | - | (១.០៨១.៤៨០) | - | (១.០៨១.៤៨០) |
| សរុបប្រតិបត្តិការជាមួយភាគហ៊ុនិក | | - | - | ១១.៦០៥.៣១៧ | (១២.៦៨៦.៧៩៧) | - | (១.០៨១.៤៨០) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៥៧.៤៦៦.៦៩៧** | **១៤.៥៦៥.០៤៣** | - | **១៨៦.៦៤០.៧២៧** |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | *៦២២.០០៨* | *២៣៦.៥៩០.៣៩១* | *៥៩.៥២៧.៣៣២* | *១៣.៨៤៦.២០០* | *៧៦៨.៣៩៩.៨៧១* |

# កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | លម្អៀងនៃការប្តូររូបិយបណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៣៦.៥៣៩.៦០៦** | **១០.០៧៩.២៣២** | **-** | **១៦១.២២៧.៨២៥** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ១២.៧០៧.៨៣១ | - | ១២.៧០៧.៨៣១ |
| ខាតពីការវាយតម្លៃកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | | - | - | - | (២១.០៣៤) | - | (២១.០៣៤) |
| ចំណេញលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | - | - | - | ១២.៦៨៦.៧៩៧ | - | ១២.៦៨៦.៧៩៧ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង | ១៥ | - | - | ៩.៣២១.៧៧៤ | (៩.៣២១.៧៧៤) | - | - |
| ភាគលាភ | | - | - | - | (៧៥៧.៤៥៨) | - | (៧៥៧.៤៥៨) |
| សរុបប្រតិបត្តិការជាមួយភាគហ៊ុនិក | | - | - | ៩.៣២១.៧៧៤ | (១០.០៧៩.២៣២) | - | (៧៥៧.៤៥៨) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៤៥.៨៦១.៣៨០** | **១២.៦៨៦.៧៩៧** | **-** | **១៧៣.១៥៧.១៦៤** |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | *៦២២.០០៨* | *១៨៦.៨៣៩.២៦២* | *៥១.៦៨៦.០១១* | *៨.៤៨១.០៦៦* | *៧០៥.៤៤២.២៨៧* |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

# កំពង់ផែស្វយ័តភ្នំពេញ
## (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ គិតជាពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញសុទ្ធ មុនបង់ពន្ធ | | ១៨.៤៤៩.៦៥៣ | ៧៥.៤០៣.៧៣៣ | ១៥.៧១២.៣៣៨ | ៦៣.៩១៧.៧៩១ |
| និយ័តកម្មៈ | | | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | ៣.៧៣៩.៤៥៩ | ១៥.២៨៣.១៦៩ | ៣.១៨៩.៦០០ | ១២.៩៧៥.២៩៣ |
| រំលស់ទ្រព្យសម្បត្តិវិនិយោគ | ៨ | ៥១.៥១០ | ២១០.៥២១ | ៦០.១៣៧ | ២៤៤.៦៣៧ |
| រំលស់សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម | ៧ | ៩៤.៥២១ | ៣៨៦.៣០៨ | ១០០.៥៣២ | ៤០៩.៥៦៨ |
| ចំណាយហិរញ្ញវត្ថុ | | ១.០៨៥.១៨៦ | ៤.៤៣៥.១៥៥ | ១.១៤១.៤៨៦ | ៤.៦៤៣.៥៦៥ |
| ចំណូលពីការវិនិយោគសុទ្ធលើភតិសន្យាបន្ត | | (២.៧៦៣.៤២២) | (១១.២៩៤.១០៦) | - | - |
| ចំណូលការប្រាក់ | | (១.២៧១.០០៦) | (៥.១៩៤.៦០១) | (១.៤៦៤.៩៩៩) | (៥.៩៥៩.៦១៦) |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១១.៩៣០ | ៤៨.៧៥៨ | - | - |
| ការខាតបង់លើការបញ្ចប់ភតិសន្យាបន្ត | | ១.០៤៦.៩៦៦ | ៤.២៧៨.៩៥០ | - | - |
| ការខាតបង់ឱនភាពសុទ្ធលើគណនីត្រូវទទួល | | ៥៨៦.៧៤៦ | ២.៣៩៨.០៣១ | ១៩.១០៤ | ៧៧.៧១៥ |
| ផលប៉ះពាល់សុទ្ធនៃប្រាក់កក់រយៈពេលវែង | | (១.៣៥២) | (៥.៥២៦) | (១.២៩៩) | (៥.២៨៤) |
| ការជម្រះចេញពីបញ្ជីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ៨.៣០៩ | ៣៣.៩៥៩ | - | - |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ១៨ | ៨៧.៨៤៨ | ៣៥៩.០៣៥ | ៧៨.៣៩០ | ៣២១.០៨៧ |
| ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ២១.១២៦.៣៤៨ | ៨៦.៣៤៣.៣៨៦ | ១៨.៨៣៥.៨២៩ | ៧៦.៦២៤.៧៥៦ |
| បម្រែបម្រួលដើមទុនបង្វិលៈ | | | | | |
| សន្និធិ | | (៧១៤.៩៨២) | (២.៩២២.១៣១) | - | - |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (៣.០១៤.៩០១) | (១២.៣២១.៩០១) | ៦.៣៤១.១៣៥ | ២៥.៧៩៥.៧៣៧ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីផ្សេងៗ | | ៨៦៩.៨៨៤ | ៣.៥៥៥.២១៦ | (៤១៣.៧៨៦) | (១.៦៨៣.២៨១) |
| កិច្ចសន្យាបំណុល | | (៣០០.០០០) | (១.២២៦.១០០) | (៣០០.០០០) | (១.២២០.៤០០) |
| ចំណូលពន្យារ | | ៤៣.១៩៩ | ១៧៦.៥៥៤ | - | - |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ១៨.០០៩.៥៤៨ | ៧៣.៦០៥.០២៤ | ២៤.៤៦៣.១៧៨ | ៩៩.៥១៦.៨១២ |
| ចំណាយបង់ពន្ធ | | (២.៧២៦.៥៩២) | (១១.១៤៣.៥៨៣) | (២.៣១៩.៣៦៥) | (៩.៤៣៥.១៧៧) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | | (២៩.៨៩៤) | (១២២.១៧៧) | (២២.៥៥៨) | (៩១.៧៦៦) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ១៥.២៥៣.០៦២ | ៦២.៣៣៩.២៦៤ | ២២.១២១.២៥៥ | ៨៩.៩៨៩.៨៦៩ |

# គំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | (៧.៦៩៦.៩៦២) | (៣១.៤៥៧.៤៨៤) | (១៧.៦៨៨.១១២) | (៧១.៩៥៥.២៤០) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | | (៣០.០០០) | (១២២.៦១០) | - | - |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | | ៣.៣៥៥ | ១៣.៧១២ | - | - |
| ការប្រាក់ទទួលបាន | | ៥៦២.៨៤៣ | ២.៣០០.៣៣៧ | ៦០១.១០០ | ២.៤៤៥.២៧៥ |
| ការ(ដាក់)/ដកប្រាក់បញ្ញើជាមួយធនាគារដែល មានអាជ្ញាប័ណ្ណ | | (៤.១០០.០០០) | (១៦.៧៥៦.៧០០) | ៣.០០០.០០០ | ១២.២០៤.០០០ |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (១១.២៦០.៧៦៤) | (៤៦.០២២.៧៤៥) | (១៤.០៨៧.០១២) | (៥៧.៣០៥.៩៦៥) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភបានបង់ | | (១.០៨១.៤៨០) | (៤.៤២០.០០៩) | (១.០១៩.២៧២) | (៤.១៤៦.៣៩៨) |
| ការប្រាក់ដែលបានបង់ | | (៨០៧.២៩៩) | (៣.២៩៩.៤៣១) | (៨៩០.០៨៩) | (៣.៦២០.៨៨២) |
| ការបង់ប្រាក់លើបំណុលភតិសន្យា | | (៥៤៥.៤១០) | (២.២២៩.០៩០) | (១២៤.០៤៩) | (៥០៤.៦៣១) |
| ការបង់សងប្រាក់ដើមនៃកម្ចី | | (២.០៦៩.៩៧៤) | (៨.៤៥៩.៩៨៤) | (២.០៦៩.៩៧៤) | (៨.៤២០.៦៥៤) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (៤.៥០៤.១៦៣) | (១៨.៤០៨.៥១៤) | (៤.១០៣.៣៨៤) | (១៦.៦៩២.៥៦៥) |
| **(តំហយ)/កំណើនសាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធ** | | (៥១១.៨៦៥) | (២.០៩១.៩៩៥) | ៣.៩៣០.៨៥៩ | ១៥.៩៩១.៣៣៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើម ការិយបរិច្ឆេទ** | | ៦.៦១៤.៧០០ | ២៦.៩៤៨.២៨៨ | ២.៦៨៣.៨៤១ | ១០.៩៣៣.៩៦៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ២៦៩.០៧៩ | - | ២២.៩៨១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុង ការិយបរិច្ឆេទ** | ១២ | ៦.១០២.៨៣៥ | ២៥.១២៥.៣៧២ | ៦.៦១៤.៧០០ | ២៦.៩៤៨.២៨៨ |

# គំពង់ផែស្វយ័តភ្នំពេញ
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍លំហូរសាច់ប្រាក់
**សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)**

*ការផ្ទៀងផ្ទាត់នៃបំណុលដែលបានមកពីសកម្មភាពហិរញ្ញប្បទាន*

| | បំណុលភតិសន្យា (កំណត់សម្គាល់ លេខ៧) ដុល្លារអាមេរិក | កម្ចី (កំណត់សម្គាល់ លេខ១៧) ដុល្លារអាមេរិក |
|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ២.៨៨២.៥៥៩ | ២២.៧៦៩.៧១៥ |
| លំហូរសាច់ប្រាក់ | (១២៤.០៤៩) | (២.០៦៩.៩៧៤) |
| លំហូរមិនមែនសាច់ប្រាក់៖ | | |
| - បន្ថែម | ៣.៧៦១.៥២៤ | - |
| - ផលប៉ះពាល់នៃចំណាយការប្រាក់ | ២៦៨.១១១ | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៦.៧៨៨.១៤៥ | ២០.៦៩៩.៧៤១ |
| លំហូរសាច់ប្រាក់ | (៥៤៥.៤១០) | (២.០៦៩.៩៧៤) |
| លំហូរមិនមែនសាច់ប្រាក់៖ | | |
| - បន្ថែម | ៥.០៧១.៩៨៦ | - |
| - ផលប៉ះពាល់នៃចំណាយការប្រាក់ | ៣០៨.៤៧៦ | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ១១.៦២៣.១៩៧ | ១៨.៦២៩.៧៦៧ |
| *(គិតជាពាន់រៀល)* | *៤៧.៨៥២.៧០២* | *៧៦.៦៩៨.៧៥១* |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

## កំពង់ផែស្វយ័តភ្នំពេញ
## (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

### ១. ព័ត៌មានអំពី ក.ស.ភ

កំពង់ផែស្វយ័តភ្នំពេញ ("ក.ស.ភ") ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ៥១ អនក្រ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("ក.ស.ហ") និងក្រសួងសាធារណការ និងដឹកជញ្ជូន ("ក.ស.ដ")។ ក្រុមហ៊ុនបានចុះបញ្ជីនៅទីផ្សារមូលបត្រកម្ពុជា នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ដែលមានលេខចុះបញ្ជី ០០៣ CSX/SC និងប្រែក្លាយជាសហគ្រាសសាធារណៈ ដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ ក.ស.ភ ស្ថិតនៅផ្ទះលេខ៦៤៩ តិវវិថីផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឱ្យចេញផ្សាយ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

### ២. សកម្មភាពចម្បង

ក.ស.ភ គឺជានីតិបុគ្គលដែលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ហើយបេសកកម្មចម្បងគឺសេវាកម្មកំពង់ផែ និងសេវាដែលពាក់ព័ន្ធផ្សេងទៀត។

ក.ស.ភ មានគោលដៅទទួលរ៉ាប់រងក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍន៍ សម្រាប់តម្រូវការខាងពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ និងអ្នកដំណើរ និងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឱ្យ ក.ស.ភ រីកចម្រើនលូតលាស់ទៅមុខ។

ក. ស. ភ មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែ រួមមាន៖

- ផ្តល់កណ្ណធារកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង
- ធ្វើអាជីវកម្មបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- ត្រួតពិនិត្យការប្រតិបត្តិតាមលក្ខណៈបច្ចេកទេស និងជំរុញកិច្ចការពារសុវត្ថិភាព បរិស្ថាន សណ្តាប់ធ្នាប់ក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែ
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែ រួមមាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភ័ស្តុភារកម្ម

## ២. សកម្មភាពចម្បង (ត)

- ចាត់វិធានការនានា ដើម្បីជានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមានពាក់ព័ន្ធនឹងកំពង់ផែ និងមធ្យោបាយដឹកជញ្ជូននានាតាមផ្លូវទឹក
- លើកដាក់ ផ្ទេរ ផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរវាងកំពង់ផែ និងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវា ពាក់ និងដោះពួរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភ័ស្តុភារ ទឹកស្អាត អនាម័យដល់នាវា
- ផ្តល់សេវាកម្មរើ និងប្រេកទំនិញដាក់កុងតឺន័រ
- ផ្តល់សេវាកម្មជួសជុល និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងមណ្ឌលសេវាកម្មផែក្នុងស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្មបន្ថែមផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបម្រើដល់ការរីកចម្រើនរបស់ ក. ស. ភ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក.ស.ភ ត្រូវបានរៀបចំឡើងអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ហ.អ.ក”) ចេញផ្សាយដោយនិយ័តករគណនេយ្យ និងសវនកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៤. មូលដ្ឋានគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យដែលបានអនុវត្តគឺ ស្របតាមការិយបរិច្ឆេទមុន លើកលែងតែផលប៉ះពាល់នៃការអនុម័តវិសោធនកម្មថ្មីចំពោះ ស.រ.ហ.អ.ក ក្នុងការិយបរិច្ឆេទ។ ស.រ.ហ.អ.ក ថ្មីដែលត្រូវបានអនុវត្ត នៅក្នុងការិយបរិច្ឆេទត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣៦ នៃរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រសន្មតថ្លៃដើម (Historical cost) លើកលែងនូវអ្វីដែលបានបញ្ជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក (“US$”) ដែលជារូបិយប័ណ្ណគោលរបស់ ក.ស.ភ ផងដែរ។ ការបង្ហាញបន្ថែមក៏ត្រូវបានធ្វើឡើងជាប្រាក់រៀលខ្មែរ (“KHR”) ដើម្បីអនុលោមទៅតាមតម្រូវការនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ ការបម្លែងទៅជាប្រាក់រៀលខ្មែរត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុនា និងសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របស់ ក.ស.ភ បានប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការនាចុងការិយបរិច្ឆេទ និងអត្រាប្តូរប្រាក់ជាមធ្យមដូចខាងក្រោម៖

| | | អត្រាចុងការិយបរិច្ឆេទ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១ ដុល្លារអាមេរិក = | ៤.១១៧រៀល | ៤.០៨៧រៀល |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ១ ដុល្លារអាមេរិក = | ៤.០៧៤រៀល | ៤.០៦៨រៀល |

ចំនួនប្រាក់រៀលខ្មែរទាំងនេះតំណាងឱ្យព័ត៌មានបន្ថែម និងមិនត្រូវបានយកមកបកស្រាយជាអំណះ-អំណាងថា ប្រាក់ដុល្លារអាមេរិកតំណាងឱ្យ ឬត្រូវបានប្តូរទៅជាប្រាក់រៀលខ្មែរ តាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតទេ។

## ៥. ទ្រព្យសកម្មសម្បទាន

| | ចំណតផែពហុបំណង | សំណង់កំពុងសាងសង់ | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ***ថ្លៃដើម*** | | | |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | - | - | - |
| ការបន្ថែម | ៤.៨៨៨.៨៣៥ | ៣.២៤៦.២៥៨ | ៨.១៣៥.០៩៣ |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ៤.៨៨៨.៨៣៥ | ៣.២៤៦.២៥៨ | ៨.១៣៥.០៩៣ |
| **តម្លៃពិតគណនេយ្យ** | | | |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៤.៨៨៨.៨៣៥** | **៣.២៤៦.២៥៨** | **៨.១៣៥.០៩៣** |
| *(គិតជាពាន់រៀល)* | *២០.១២៧.៣៣៤* | *១៣.៣៦៤.៨៤៤* | *៣៣.៤៩២.១៧៨* |

(ក) នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ ក.ស.ភ និង ក្រុមហ៊ុន ភីធីអិលអេស ខូអបភើរេសិន ខូអិលធីឌី (“ភីធីអិលអេស”) បានចុះកិច្ចព្រមព្រៀង ស្តីពីកិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណងTS១១។ យោងតាមកិច្ចព្រមព្រៀង ភាគីទាំងពីរយល់ព្រមសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង TS១១ ដែលហៅថា TS១១ ដែលមានទីតាំងស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយក.ស.ភ ចូលរួមតាមរយៈការផ្តល់ទីតាំងដីតាមគម្រោងប្លង់មេអភិវឌ្ឍន៍ កេរ្តិ៍ឈ្មោះជំនួញ និងការផ្តល់នូវសិទ្ធិអនុញ្ញាតឱ្យសាងសង់ និងដំណើរការចំណតផែ ហើយភីធីអិលអេសនឹងបោះទុនវិនិយោគ ចំនួន៩លានដុល្លាអាមេរិក សម្រាប់អនុវត្តគម្រោងសាងសង់ចំណតផែ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធគាំទ្រផ្សេងទៀតនៃចំណតផែ។ នៅក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង រយៈពេលនៃកិច្ចសហការវិនិយោគគឺ ៤០ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី៨ ខែវិច្ឆកា ឆ្នាំ២០២១ ដល់ថ្ងៃទី៨ ខែវិច្ឆកា ឆ្នាំ២០៦១។ ភីធីអិលអេស មានសិទ្ធិអាទិភាពក្នុងការបន្តកិច្ចសហការ សម្រាប់រយៈពេល១០ឆ្នាំបន្ថែមទៀត។

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ក.ស.ភ និង ភីធីអិលអេស បានចុះកិច្ចព្រមព្រៀងមួយទៀត ស្តីពីកិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង UM២ ។ យោងតាមកិច្ចព្រមព្រៀង ភាគីទាំងពីរយល់ព្រមសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង UM២ ដែលហៅថា UM២ ដែលមានទីតាំងស្ថិតនៅ ភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយក.ស.ភ ចូលរួមតាមរយៈការផ្តល់ទីតាំងដីតាមគម្រោងប្លង់មេអភិវឌ្ឍន៍ កេរ្តិ៍ឈ្មោះជំនួញ និងការផ្តល់នូវសិទ្ធិអនុញ្ញាតឱ្យសាងសង់ និងដំណើរការចំណតផែ ហើយភីធីអិលអេស នឹងបោះទុនវិនិយោគ ចំនួន ២៦.៥លានដុល្លាអាមេរិក សម្រាប់អនុវត្តគម្រោងសាងសង់ចំណតផែ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធគាំទ្រផ្សេងទៀតនៃចំណតផែ។ នៅក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង រយៈពេលនៃកិច្ចសហការវិនិយោគគឺ ៤០ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០៦២។ ភីធីអិលអេស មានសិទ្ធិអាទិភាពបន្តកិច្ចសហការ សម្រាប់រយៈពេល១០ឆ្នាំបន្ថែមទៀត។

**៥. ទ្រព្យសកម្មសម្បទាន (ត)**

អនុលោមតាមកិច្ចព្រមព្រៀងខាងលើ ភាគីទាំងពីរនឹងគ្រប់គ្រងប្រតិបត្តិការនៃចំណតផៃ។ ក.ស.ភ និង ភីធីអិលអេស ទទួលយកការបែងចែក ៥១% និង ៤៩% រៀងៗខ្លួន នៃប្រាក់ចំណេញ ឬខាតដែលកើតឡើងពីប្រតិបត្តិការចំណតរណប។ ក.ស.ភ យល់ព្រមធានាការចំណាយលើប្រតិបត្តិការជាមុន។ នៅក្នុងព្រឹត្តិការណ៍ដែល ភីធីអិលអេស មិនមានលទ្ធភាព ទូទាត់សងនូវចំណែកភាគរយនៃការខាតបង់របស់ខ្លួន ក.ស.ភ មានសិទ្ធិគិតការប្រាក់លើចំណែកដែលនៅសល់នៃការខាតបង់ដោយផ្អែកលើអត្រាការប្រាក់ទីផ្សារ ឬកាត់បន្ថយការកាន់កាប់ភាគហ៊ុនរបស់ ភីធីអិលអេស ។

ភីធីអិលអេស នឹងផ្ទេរនូវទ្រព្យសកម្មទាំងអស់ដែលរួមមាន ចំណតផែរណប និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធគាំទ្រផ្សេងទៀតនៃចំណតផែរណប នាចុងបញ្ចប់នៃរយៈពេលកិច្ចសហការ។

ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវការទីតាំងចំណតផែសម្រាប់បម្រើផលប្រយោជន៍សាធារណៈ មុនផុតកំណត់សុពលភាពនៃកិច្ចព្រមព្រៀង ក.ស.ភ នឹងត្រូវទទួលខុសត្រូវក្នុងការរំលស់សងដោយគ្មានការប្រាក់ទៅ ភីធីអិលអេស លើការចំណាយដើមទុនវិនិយោគ ដោយគ្មានការប្រាក់សម្រាប់រយៈពេលនៅសល់ក្រោយរដ្ឋាភិបាលដកយកទីតាំង។

(ខ) ទ្រព្យសកម្មសម្បទានរួមមានចំណតផែពហុបំណង TS១១ និង UM២ ដែលអនុវត្តដោយក.ស.ភ និង ភីធីអិលអេស ។

(គ) ទ្រព្យសកម្មសម្បទានត្រូវបានវាស់វែងជាដំបូងតាមថ្លៃដើម។ បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មសម្បទាន ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរនិងការខាតបង់ឱនភាពបង្គរ។

(ឃ) រំលស់ ត្រូវបានគណនា ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឱ្យនៅត្រឹមតម្លៃសំណល់ ដោយឈរលើមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន។ អាយុកាលរំលស់មានរយៈពេល៤០ឆ្នាំ។

(ង) សំណង់កំពុងសាងសង់ តំណាងឱ្យចំណតផែដែលស្ថិតនៅក្រោមការសាងសង់ និងមិនត្រូវបានរំលស់ទេរហូតដល់ពេលដែលទ្រព្យសកម្មរួចរាល់សម្រាប់ប្រើប្រាស់។

## ៦. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីធ្លី<br>ដុល្លារអាមេរិក | កុំព្យូទ័រ<br>ដុល្លារអាមេរិក | សម្ភារៈការិយាល័យ និងឧបករណ៍ផ្សេងៗ<br>ដុល្លារអាមេរិក | សង្ហារឹម និងបរិក្ខារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | គ្រឿងចក្រ និងម៉ាស៊ីន<br>ដុល្លារអាមេរិក | ចំណតនាវា និងអគារ<br>ដុល្លារអាមេរិក | សំណង់កំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ៣០.៩៣០.៥០៨ | ១.២៧៣.៤០១ | ១.០៧៨.២២៥ | ៦៤.៨១៧ | ១.៩២០.៩៣៣ | ២៣.០៤២.៣២៧ | ៤៥.១៣៨.៥៨៤ | ៦.៧៧៧.២៥៨ | ១១០.២២៦.០៥៣ |
| ការទិញបន្ថែម | ៤.០០០.០០០ | ១០.៣៩៣ | ៦៩.៥២៦ | - | ១៥.៧២៨ | - | ៥២.៩០៨ | ១៣.៥៣៩.៥៥៧ | ១៧.៦៨៨.១១២ |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | ៩២១.៧០០ | ១២២.៩៦៧ | ១៥.៩៤១ | - | - | ៥.០៥៤.៦៨៦ | ១១.៣៥៩.៤១៤ | (១៧.៤៧៤.២០៨) | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៣៥.៨៥២.២០៨ | ១.៤០៦.២៦១ | ១.១៦៣.៦៩២ | ៦៤.៨១៧ | ១.៩៣៦.៦៦១ | ២៨.០៩៧.០១៣ | ៥៦.៥៥០.៩០៦ | ២.៨៤២.៦០៧ | ១២៧.៩១៤.១៦៥ |
| ការទិញបន្ថែម | ១៩៨.២៧៤ | ៣៩.១៤០ | ៤.៧១៨ | - | ២១៦.៨០៩ | - | - | ៧.២៣៨.០២១ | ៧.៦៩៦.៩៦២ |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | ៩៣៥.០១៣ | ៩៨.៣២៩ | ៣២៥.០៣១ | - | - | ១.៤៨៦.៩៨១ | ២.១៣១.២៨៧ | (៤.៩៧៦.៦៤១) | - |
| ការលក់ | - | - | - | - | - | (១៥៣.៩៧៨) | - | - | (១៥៣.៩៧៨) |
| ការផ្ទេរពីទ្រព្យសម្បត្តិវិនិយោគ (កំណត់សម្គាល់លេខ ៨) | ៣៧០.៦៦៦ | - | - | - | - | - | - | - | ៣៧០.៦៦៦ |
| ការជម្រះចេញពីបញ្ជី | - | (៤៥.៧៩៤) | (៤៥.៤៩២) | (៣.២២៩) | (៨៨.០២២) | - | - | - | (១៨២.៥៣៧) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ៣៧.៣៥៦.១៦១ | ១.៤៩៧.៩៣៦ | ១.៤៤៧.៩៤៩ | ៦១.៥៨៨ | ២.០៦៥.៤៤៨ | ២៩.៤៣០.០១៦ | ៥៨.៦៨២.១៩៣ | ៥.១០៣.៩៨៧ | ១៣៥.៦៤៥.២៧៨ |

## ៦. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដីធ្លី ដុល្លារអាមេរិក | កុំព្យូទ័រ ដុល្លារអាមេរិក | សម្ភារៈការិយាល័យ និងឧបករណ៍ផ្សេងៗ ដុល្លារអាមេរិក | សង្ហារឹម និងបរិក្ខារ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | គ្រឿងចក្រ និងម៉ាស៊ីន ដុល្លារអាមេរិក | ចំណតនាវា និងអគារ ដុល្លារអាមេរិក | សំណង់កំពុងសាងសង់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| *រំលស់បង្គរ* | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | - | ៦៨៥.៥២៣ | ៣៥៨.៩០៣ | ៥៨.៥៦៦ | ៦៥៨.៦៦៥ | ៨.៥៥៨.៩៤៤ | ១១.០៧៥.៥៨៩ | - | ២១.៣៩៦.១៩០ |
| រំលស់ក្នុងឆ្នាំ | - | ១៦៤.១៦៤ | ៧៥.០០៩ | ១.៩៩៦ | ១២៦.១៧៨ | ១.៧២៨.០៦៤ | ១.០៩៤.១៨៩ | - | ៣.១៨៩.៦០០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | - | ៨៤៩.៦៨៧ | ៤៣៣.៩១២ | ៦០.៥៦២ | ៧៨៤.៨៤៣ | ១០.២៨៧.០០៨ | ១២.១៦៩.៧៧៨ | - | ២៤.៥៨៥.៧៩០ |
| រំលស់ក្នុងឆ្នាំ | - | ១៧៥.៩៩៨ | ៩២.៧៨៩ | ១.៤៨០ | ១៣៩.១២៣ | ១.៩៩៩.៦១៥ | ១.៣៣០.៤៥៤ | - | ៣.៧៣៩.៤៥៩ |
| ការលក់ | - | - | - | - | - | (១៣៨.៦៩៣) | - | - | (១៣៨.៦៩៣) |
| ការជម្រះចេញពីបញ្ជី | - | (៤៥.៧៩៤) | (៤២.៥៣៥) | (៣.២២៩) | (៨២.៦៧០) | - | - | - | (១៧៤.២២៨) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | - | ៩៧៩.៨៩១ | ៤៨៤.១៦៦ | ៥៨.៨១៣ | ៨៤១.២៩៦ | ១២.១៤៧.៩៣០ | ១៣.៥០០.២៣២ | - | ២៨.០១២.៣២៨ |
| *តម្លៃពិតគណនេយ្យ* | | | | | | | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៣៧.៣៥៦.១៦១** | **៥១៨.០៤៥** | **៩៦៣.៧៨៣** | **២.៧៧៥** | **១.២២៤.១៥២** | **១៧.២៨២.០៨៦** | **៤៥.១៨១.៩៦១** | **៥.១០៣.៩៨៧** | **១០៧.៦៣២.៩៥០** |
| *(គិតជាពាន់រៀល)* | *១៥៣.៧៩៥.៣១៥* | *២.១៣២.៧៩១* | *៣.៩៦៧.៨៩៥* | *១១.៤២៥* | *៥.០៣៩.៨៣៤* | *៧១.១៥០.៣៤៨* | *១៨៦.០១៤.១៣៣* | *២១.០១៣.១១៤* | *៤៤៣.១២៤.៨៥៥* |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៣៥.៨៥២.២០៨ | ៥៥៦.៥៧៤ | ៧២៩.៧៨០ | ៤.២៥៥ | ១.១៥១.៨១៨ | ១៧.៨១០.០០៥ | ៤៤.៣៨១.១២៨ | ២.៨៤២.៦០៧ | ១០៣.៣២៨.៣៧៥ |
| *(គិតជាពាន់រៀល)* | *១៤៦.០៦១.៨៩៥* | *២.២៦៧.៤៨២* | *២.៩៧៣.១២៤* | *១៧.៣៣៥* | *៤.៦៩២.៥០៧* | *៧២.៥៥៧.៩៦០* | *១៨០.៨០៨.៧១៥* | *១១.៥៨០.៧៨២* | *៤២០.៩៥៩.៨០០* |

## ៦. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

(ក) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ត្រូវបានកត់ត្រាតាមថ្លៃដើម។ ក្រោយការទទួលស្គាល់ជាលើកដំបូង ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពបង្គរ ប្រសិនបើមាន។

រំលស់ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឱ្យនៅត្រឹមតម្លៃសំណល់ ដោយផ្អែកតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ពួកវា។ រយៈពេលនៃគោលការណ៍រំលស់មានដូចខាងក្រោមៈ

| | |
|---|---|
| កុំព្យូទ័រ | ៥ - ១៥ឆ្នាំ |
| សម្ភារៈការិយាល័យ និងឧបករណ៍ដទៃទៀត | ៥ - ១៥ឆ្នាំ |
| សង្ហារឹម និងបរិក្ខារ | ៥ឆ្នាំ |
| យានយន្ត | ៨ - ១៥ឆ្នាំ |
| គ្រឿងចក្រ និងម៉ាស៊ីន | ១០ - ១៥ឆ្នាំ |
| ចំណតនាវា និងអគារ | ១០ - ៥០ឆ្នាំ |

ដីធ្លី មានអាយុកាលមិនកំណត់ និងមិនត្រូវបានគេធ្វើរំលស់នោះទេ។
សំណង់កំពុងសាងសង់រួមមាន ចំណតនាវា និងអគារកំពុងស្ថិតនៅក្រោមការសាងសង់។ សំណង់កំពុងសាងសង់មិនត្រូវបានគេរំលស់រហូតដល់ពេលដែលទ្រព្យសកម្មរួចរាល់សម្រាប់ប្រើប្រាស់។

(ខ) រំលស់ត្រូវបានបែងចែកដូចខាងក្រោមៈ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដើមនៃសេវាកម្ម | ៣.១៥១.០៦៧ | ១២.៨៧៨.៤១១ | ២.៦៤១.៣៨១ | ១០.៧៤៥.១៣៨ |
| ចំណាយរដ្ឋបាល | ៥៨៨.៣៩២ | ២.៤០៤.៧៥៨ | ៥៤៨.២១៩ | ២.២៣០.១៥៥ |
| | ៣.៧៣៩.៤៥៩ | ១៥.២៨៣.១៦៩ | ៣.១៨៩.៦០០ | ១៣.៦២៨.៨៩៣ |

(គ) ប័ណ្ណកម្មសិទ្ធិទៅលើដីធ្លីដែលមានតម្លៃពិតគណនេយ្យ ២.៣៨៤.៥៥៩ដុល្លារអាមេរិក (២០២១ៈ ១.៤៤៣.០១២ដុល្លារអាមេរិក) កំពុងស្ថិតក្នុងដំណើរការចេញដោយអាជ្ញាធរ។

## ៧. ភតិសន្យា

**ក.ស.ភ ក្នុងនាមជាភតិកៈ**

**សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម**

| **តម្លៃពិតគណនេយ្យ** | **ដីធ្លី** |
|---|---|
| | **ដុល្លារអាមេរិក** |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | - |
| ការជួលបន្ថែម | ៣.៧៦១.៥២៤ |
| រំលស់ | (១០០.៥៣២) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៣.៦៦០.៩៩២ |
| ការជួលបន្ថែម | ៥.០៧១.៩៨៥ |
| ការកើនឡើង | ២.០៩៤.៨១៣ |
| ការលុបចោលការទទួលស្គាល់ | (៤.៩៦៦.២៧៤) |
| រំលស់ | (៩៤.៥២១) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៥.៧៦៦.៩៩៥** |
| *(គិតជាពាន់រៀល)* | *២៣.៧៤២.៧១៨* |

**បំណុលភតិសន្យា**

| **តម្លៃពិតគណនេយ្យ** | **ដីធ្លី** |
|---|---|
| | **ដុល្លារអាមេរិក** |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ២.៨៨២.៥៥៩ |
| ការជួលបន្ថែម | ៣.៧៦១.៥២៤ |
| ចំណាយការប្រាក់ | ២៦៨.១១១ |
| ការទូទាត់ភតិសន្យា | (១២៤.០៤៩) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៦.៧៨៨.១៤៥ |
| ការជួលបន្ថែម | ៥.០៧១.៩៨៦ |
| ចំណាយការប្រាក់ | ៣០៨.៤៧៦ |
| ការទូទាត់ភតិសន្យា | (៥៤៥.៤១០) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១១.៦២៣.១៩៧** |
| *(គិតជាពាន់រៀល)* | *៤៧.៨៥២.៧០២* |

| តំណាងដោយៈ | **២០២២** | | **២០២១** | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** |
| បំណុលរយៈពេលខ្លី | ៥៦.៣៩៦ | ២៣២.១៨២ | ៩.២៦១ | ៣៧.៧២៩ |
| បំណុលរយៈពេលវែង | ១១.៥៦៦.៨០១ | ៤៧.៦២០.៥២០ | ៦.៧៧៨.៨៨៥ | ២៧.៦១៧.១៧៧ |
| | ១១.៦២៣.១៩៧ | ៤៧.៨៥២.៧០២ | ៦.៧៨៨.១៤៦ | ២៧.៦៥៤.៩០៦ |

## ៧. ភតិសន្យា (ត)

(ក) សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងដំបូងតាមថ្លៃដើម ដែលរួមមានតម្លៃដំបូងនៃបំណុលភតិសន្យា បន្ទាប់ពីកាត់កងនូវការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា។

ក្រោយពីការទទួលស្គាល់ជាលើកដំបូង សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពបង្គរ ប្រសិនបើមាន និងបានធ្វើការកែតម្រូវសម្រាប់ការវាស់វែងឡើងវិញនៃបំណុលភតិសន្យា។

សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានគេធ្វើរំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ផ្អែកលើរយៈពេលមួយណាដែលបញ្ចប់មុនគេ រវាងអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ឬចុងបញ្ចប់នៃអាយុកាលភតិសន្យា។ អាយុកាលភតិសន្យានៃសិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម គឺ ៣០ឆ្នាំ និង ៤០ឆ្នាំ (២០២១៖ ៤០ឆ្នាំ)។

(ខ) ការកើនឡើងនូវសិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ក្នុងអំឡុងការិយបរិច្ឆេទ គឺដោយសារការបញ្ចប់ភតិសន្យាបន្ត។

ក.ស.ភ បានទទួលស្គាល់ខាត ចំនួន ១.០៤៦.៩៦៦ដុល្លារអាមេរិក លើការទទួលស្គាល់នូវសិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្មដែលទាក់ទងនឹងការបញ្ចប់ភតិសន្យាបន្ត ដែលបានកត់ត្រាជា "ការខាតបង់លើការបញ្ចប់ភតិសន្យាបន្ត" ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ២៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ការលុបចោលការទទួលស្គាល់នូវសិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ក្នុងអំឡុងការិយបរិច្ឆេទគឺដោយសារ ចុះកិច្ចព្រមព្រៀងភតិសន្យាបន្ត។

ក.ស.ភ បានទទួលស្គាល់ប្រាក់ចំណេញចំនួន ២.៧៦៣.៤២២ដុល្លារអាមេរិក លើការលុបចោលការទទួលស្គាល់នូវសិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្មដែលទាក់ទងនឹងភតិសន្យាបន្ត ដែលបានកត់ត្រាជា "ចំណូលពីការវិនិយោគសុទ្ធលើភតិសន្យាបន្ត" ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ២៤ នៃរបាយការណ៍ហិរញ្ញវត្ថុ។

(ឃ) ខាងក្រោមនេះជាចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត៖

| | **២០២២**<br>**ដុល្លារអាមេរិក** | **២០២១**<br>**ដុល្លារអាមេរិក** |
|---|---:|---:|
| រំលស់សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម (រួមបញ្ចូលក្នុងការចំណាយទូទៅ និងរដ្ឋបាល) | ៩៤.៥២១ | ១០០.៥៣២ |
| ចំណាយការប្រាក់លើបំណុលភតិសន្យា (រួមបញ្ចូលនៅក្នុងចំណាយហិរញ្ញវត្ថុ) | ៣០៨.៤៧៦ | ២៦៨.១១១ |
| | ៤០២.៩៩៧ | ៣៦៨.៦៤៣ |

(ង) នៅចុងការិយបរិច្ឆេទ ក.ស.ភ បានទូទាត់នូវសាច់ប្រាក់ចំពោះបំណុលភតិសន្យាចំនួន ៥៤៥.៤១០ ដុល្លារអាមេរិក (២០២១៖ ១២៤.០៤៩ដុល្លារអាមេរិក)។

## ៧. ភតិសន្យា (ត)

(ច) តារាងខាងក្រោមសង្ខេបទម្រង់កាលកំណត់នៃការខ្ចីប្រាក់របស់ ក.ស.ភ នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សងតាមកិច្ចសន្យា ដែលមិនបានធ្វើអប្បហារ ដូចខាងក្រោមៈ

| | អត្រាកម្ចីកើនឡើងជាមធ្យមក្នុងមួយឆ្នាំ | តិចជាង ១ឆ្នាំ | ១ - ២ ឆ្នាំ | ២ - ៥ ឆ្នាំ | ច្រើនជាង ៥ឆ្នាំ | សរុប |
|---|---|---|---|---|---|---|
| **៣១ ធ្នូ ២០២២** | % | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| បំណុលភតិសន្យា | ៤,០០ | ៣៤៩.០៦០ | ៥៣៣.៦១៣ | ១.៦០៦.៥៥១ | ១៩.៨៦៧.១៦៦ | ២២.៣៥៦.៣៩០ |
| **៣១ ធ្នូ ២០២១** | | | | | | |
| បំណុលភតិសន្យា | ៤,០០ | ២៩០.៥៤៩ | ៥៩៣.៧២០ | ៩១៥.២២៨ | ១១.៩៥៥.៨៥៦ | ១៣.៧៥៥.៣៥៣ |

### ក.ស.ភ ក្នុងនាមជាភតិបតី

ក.ស.ភ បានចុះកិច្ចសន្យាជួលបន្តលើដីធ្លីប្រាំពីរចំណែក ដែលមានរយៈពេលចាប់ពី៣៦ឆ្នាំ ទៅ៤០ឆ្នាំ ក្នុងមួយចំណែកៗ ហើយនឹងអាចបន្តការជួលនេះទៀតដោយផ្តល់ដំណឹងមុនរយៈពេលពីរឆ្នាំនៃរយៈពេលកិច្ចសន្យាជួលបានបញ្ចប់។ ថ្លៃឈ្នួលប្រចាំខែ គឺថេរសម្រាប់រយៈពេល ២៣ឆ្នាំ និង ២៥ឆ្នាំដំបូង ហើយនឹងកើនឡើង៥% រៀងរាល់៥ឆ្នាំម្តង ហើយសម្រាប់រយៈពេល១៥ឆ្នាំចុងក្រោយ ថ្លៃឈ្នួលប្រចាំខែ នឹងត្រូវបានកំណត់ក្នុងតម្លៃថេរមួយ។

ក.ស.ភ បានសរុបនូវភតិសន្យាត្រូវទទួលនាពេលអនាគតអប្បបរមា នាចុងបញ្ចប់របាយការណ៍នីមួយៗ ដូចខាងក្រោមៈ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| តិចជាងមួយឆ្នាំ | ៣៨១.៨៥៧ | ១.៥៧២.១០៥ | ១៨៦.០៧៤ | ៧៥៧.៣២៣ |
| មួយឆ្នាំ ទៅពីរឆ្នាំ | ៣៨១.៨៥៧ | ១.៥៧២.១០៥ | ១៨៦.០៧៤ | ៧៥៧.៣២៣ |
| ពីរឆ្នាំ ទៅបីឆ្នាំ | ៤០០.៩៥០ | ១.៦៥០.៧១១ | ១៩៤.៦០៣ | ៧៩៧.១៦៨ |
| បីឆ្នាំ ទៅបួនឆ្នាំ | ៤០០.៩៥០ | ១.៦៥០.៧១១ | ១៩៥.៣៧៨ | ៧៩៥.១៨៩ |
| បួនឆ្នាំ ទៅប្រាំឆ្នាំ | ៤០០.៩៥០ | ១.៦៥០.៧១១ | ១៩៥.៣៧៨ | ៧៩៥.១៨៩ |
| ច្រើនជាងប្រាំឆ្នាំ | ១៥.៥១៨.៥៣២ | ៦៣.៨៨៩.៧៩៧ | ៧.៨៥០.៥៩៩ | ៣១.៩៥១.៩៣៨ |
| | ១៧.៤៨៥.០៩៦ | ៧១.៩៨៦.១៤០ | ៨.៨០៨.១០៦ | ៣៥.៨៤៤.១៣០ |
| ដកៈ ការប្រាក់មិនទាន់ទទួលស្គាល់ | (៨.៦១៤.៦១៣) | (៣៥.៤៦៦.៣៦២) | (៤.៤៩៧.៦៣២) | (១៥.៥៨៤.៩០២) |
| | ៨.៨៧០.៤៨៣ | ៣៦.៥១៩.៧៧៨ | ៤.៣១០.៤៧៤ | ២០.២៥៩.២២៨ |
| បានបង្ហាញដូចខាងក្រោមៈ | | | | |
| រយៈពេលខ្លី | ៣៤.៤៩៧ | ១៤២.០២៤ | ១៣.៨៨៦ | ៥៦.៥៧២ |
| រយៈពេលវែង | ៨.៨៣៥.៩៨៦ | ៣៦.៣៧៧.៧៥៤ | ៤.២៩៦.៥៨៨ | ១៧.៥០៤.៣០០ |
| | ៨.៨៧០.៤៨៣ | ៣៦.៥១៩.៧៧៨ | ៤.៣១០.៤៧៤ | ១៧.៥៦០.៨៧២ |

## ៨. ទ្រព្យសម្បត្តិវិនិយោគ

| | ដីធ្លី ដុល្លារអាមេរិក | អាគារ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| ***ថ្លៃដើម*** | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១/ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៨៣.៧០៥.៤៣៧ | ១.៤៨០.៥៧៨ | ៨៥.១៨៦.០១៥ |
| ការទិញបន្ថែម | - | ៣០.០០០ | ៣០.០០០ |
| ការផ្ទេរទៅទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (កំណត់សម្គាល់លេខ ៦) | (៣៧០.៦៦៦) | - | (៣៧០.៦៦៦) |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៨៣.៣៣៤.៧៧១ | ១.៥១០.៥៧៨ | ៨៤.៨៤៥.៣៤៩ |
| ***រំលស់បង្គរ*** | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | - | ៤៩៩.០១៥ | ៤៩៩.០១៥ |
| រំលស់ក្នុងការិយបរិច្ឆេទ | - | ៦០.១៣៧ | ៦០.១៣៧ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | - | ៥៥៩.១៥២ | ៥៥៩.១៥២ |
| រំលស់ក្នុងការិយបរិច្ឆេទ | - | ៥១.៥១០ | ៥១.៥១០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | - | ៦១០.៦៦២ | ៦១០.៦៦២ |
| ***តម្លៃពិតគណនេយ្យ*** | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៨៣.៣៣៤.៧៧១** | **៨៩៩.៩១៦** | **៨៤.២៣៤.៦៨៧** |
| *(គិតជាពាន់រៀល)* | *៣៤៣.០៨៩.២៥២* | *៣.៧០៤.៩៥៤* | *៣៤៦.៧៩៤.២០៦* |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៨៣.៧០៥.៤៣៧ | ៩២១.៤២៦ | ៨៤.៦២៦.៨៦៣ |
| *(គិតជាពាន់រៀល)* | *៣៤១.០១៥.៩៥០* | *៣.៧៥៣.៨៩០* | *៣៤៤.៧៦៩.៨៤០* |
| ***តម្លៃទីផ្សារ*** | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ៤៣៩.៨៥១.៩៥០ | ៨២១.៩៩៧ | ៤៤០.៦៧៣.៩៤៧ |
| *(គិតជាពាន់រៀល)* | *១.៨១០.៨៧០.៤៧៨* | *៣.៣៨៤.១៦២* | *១.៨១៤.២៥៤.៦៤០* |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ១៣៦.៩២២.៣៩២ | ៧៣៩.២២៧ | ១៣៧.៦៦១.៦១៩ |
| *(គិតជាពាន់រៀល)* | *៥៥៧.៨២១.៨២៥* | *៣.០១១.៦១១* | *៥៦០.៨៣៣.៤៣៦* |

(ក) ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកត់ត្រាតាមថ្លៃដើម ដែលរួមបញ្ចូលថ្លៃប្រតិបត្តិការ។ បន្ទាប់ពីការទទួលស្គាល់ជាលើកដំបូង ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងឱនភាពខាតបង់បង្គរដទៃទៀត។

(ខ) ដីធ្លី គឺគ្មានអាយុកាលកំណត់ និងមិនមានរំលស់។ គោលការណ៍រំលស់សម្រាប់អគារ មានចន្លោះពី ៥ ទៅ ៥០ឆ្នាំ (២០២១៖ ៥ ទៅ ៥០ឆ្នាំ)។

## ៨. ទ្រព្យសម្បត្តិវិនិយោគ (ត)

(គ) តម្លៃទីផ្សារនៃទ្រព្យសម្បត្តិវិនិយោគ សម្រាប់ការលាតត្រដាង ដែលជាតម្លៃទីផ្សារថ្នាក់ទី៣ ត្រូវបានចេញដោយអភិបាលដោយផ្អែកលើការប៉ាន់ស្មានពីព័ត៌មានទីផ្សារដែលមាន និង/ឬកំណត់ដោយអ្នកវាយតម្លៃអចលនទ្រព្យខាងក្រៅ និងឯករាជ្យ។

(ឃ) ប័ណ្ណកម្មសិទ្ធលើដីធ្លីដែលមានតម្លៃតគណនេយ្យ ១.៣៤៧.៣០០ដុល្លារអាមេរិក (២០២១៖ ១.៣៤៧.៣០០ដុល្លារអាមេរិក) កំពុងស្ថិតក្នុងដំណើរការចេញដោយអាជ្ញាធរ។

## ៩. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| ប្រាក់កក់ | ៧០.២៨៩ | ២៨៩.៣៨០ | ៦៧.៥៨៥ | ២៧៥.៣៤១ |
| **គណនីអតិថិជនពាណិជ្ជកម្ម** | | | | |
| ភាគីទីបី | ៥.៤៦៤.៩៦៦ | ២២.៤៩៩.២៦៥ | ៤.៤១៨.១៨២ | ១៧.៩៩៩.៦៧៣ |
| ដកៈ ឱនភាព | | | | |
| - ភាគីទីបី | (១.៣៧៧.៤១៩) | (៥.៦៧០.៨៣៤) | (៧៩០.៦៧៣) | (៣.២២១.២០១) |
| | ៤.០៨៧.៥៤៧ | ១៦.៨២៨.៤៣១ | ៣.៦២៧.៥០៩ | ១៤.៧៧៨.៤៧២ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| ភាគីទីបី | ៨០.៨៤៧ | ៣៣២.៨៤៧ | ៤៤៧.៥៤៤ | ១.៨២៣.២៩៤ |
| បុរេប្រទាន | ២៣.៥៦៣ | ៩៧.០០៩ | ៧៦.១៤១ | ៣១០.១៩៨ |
| ប្រាក់កក់ | ១១៣.៧២៩ | ៤៦៨.២២២ | ៧.៣០៧ | ២៩.៧៦៩ |
| គណនីត្រូវទទួលផ្សេងៗ | ៣.៨២៩.៤៣៦ | ១៥.៧៦៥.៧៨៩ | ៤២២.៩៨៩ | ១.៧២៣.២៥៨ |
| | ៤.០៤៧.៥៧៥ | ១៦.៦៦៣.៨៦៧ | ៩៥៣.៩៨១ | ៣.៨៨៦.៥១៩ |
| **គណនីត្រូវទទួលសរុប** | ៨.១៣៥.១២២ | ៣៣.៤៩២.២៩៨ | ៤.៥៨១.៤៩០ | ១៨.៦៦៤.៩៩១ |
| ការបង់មុន | ១៦៣.៦២៥ | ៦៧៣.៦៤៣ | ៥៥៣.០៣១ | ២.២៥៣.០៤៨ |
| | ៨.២៩៨.៧៤៧ | ៣៤.១៦៥.៩៤១ | ៥.១៣៤.៥២១ | ២០.៩១៨.០៣៩ |

(ក) គណនីត្រូវទទួលសរុប ត្រូវបានចាត់ថ្នាក់ជា ទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាមថ្លៃដើមដករំលស់។

(ខ) គណនីអតិថិជនពាណិជ្ជកម្ម គឺមិនទទួលបានការប្រាក់ និងលក្ខខណ្ឌឥណទានពាណិជ្ជធម្មតា ដែលផ្តល់ដោយ ក.ស.ភ គឺមានរយៈពេល ៣០ថ្ងៃ (២០២១៖ ៣០ថ្ងៃ)។ គណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានទទួលស្គាល់តាមចំនួនវិក្កយប័ត្រដើមដែលតំណាងដោយតម្លៃទីផ្សារ លើការទទួលស្គាល់ដំបូង។

## ៩. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ (ត)

(គ) គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក។

(ឃ) ចំពោះឱនភាពនៃគណនីអតិថិជនពាណិជ្ជកម្ម ដែលមិនមានសមាសធាតុហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ ក.ស.ភ បានអនុវត្ត ស.រ.ហ.អ.ក ៩ ដោយផ្អែកលើវិធីសាស្ត្រសាមញ្ញ (“Simplified approach”) ដោយប្រើសំវិធានធននៃការខាតបង់ឥណទានរំពឹងទុករយៈពេលវែងសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម។ ដើម្បីវាស់វែងការខាតបង់ ឥណទាន ដែលផ្អែកលើមូលដ្ឋានសមូហកម្ម គណនីអតិថិជនពាណិជ្ជកម្មត្រូវបានបែងចែកដោយផ្អែកលើហានិភ័យឥណទាន និងអាយុកាល។ អត្រារំពឹងទុកនៃការខាតបង់ គឺផ្អែកលើប្រវិត្តិនៃការខាតបង់ឥណទានខាតបង់របស់ ក.ស.ភ។ ប្រវត្តិនៃអត្រាខាតបង់ គឺត្រូវបានកែតម្រូវសម្រាប់បច្ចុប្បន្ន និងព័ត៌មានអនាគតលើកត្តាម៉ាក្រូសេដ្ឋកិច្ច ដែលប៉ះពាល់ដល់អតិថិជនរបស់ ក.ស.ភ។

គណៈគ្រប់គ្រងរបស់ ក.ស.ភ បានអនុវត្តការវិនិច្ឆ័យក្នុងការកំណត់លទ្ធភាពសងរបស់គណនីអតិថិជនពាណិជ្ជកម្ម និងពត៌មានសមស្របពេលអនាគត។

ការខាតបង់លើសំវិធានធនសម្រាប់គណនីអតិថិជនពាណិជ្ជកម្មមានដូចខាងក្រោម៖

| | **១-៣០ ថ្ងៃ** | **៣១-៦០ ថ្ងៃ** | **៦១-៩០ ថ្ងៃ** | **៩១-១២០ ថ្ងៃ** |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | |
| ការរំពឹងទុកអត្រាខាតបង់ | ៤,៨៥% | ៦,៥១% | ១៣,៨០% | ២៨,២៣% |
| ចំនួនដុលសរុប (ដុល្លារអាមេរិក) | ២.៣២២.៨២៨ | ៧៤៨.៦៤៨ | ៧៩៤.៨៣៨ | ២៣៨.២៦៥ |
| ឱនភាព (ដុល្លារអាមេរិក) | ១២៦.៨២៤ | ៤៨.៧៥៨ | ៨២.០២៨ | ៦៦.១៥៣ |

| | **១២១-១៥០ ថ្ងៃ** | **១៥១-១៨០ ថ្ងៃ** | **លើសពី ១៨០ ថ្ងៃ** | **សរុប ដុល្លារអាមេរិក** |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | |
| ការរំពឹងទុកអត្រាខាតបង់ | ៤៤,២០% | ៧៤,៣៥% | ១០០,០០% | |
| ចំនួនដុលសរុប (ដុល្លារអាមេរិក) | ៤៧.៤៤៩ | ១០៤.៧១៧ | ១.២០៨.២២១ | ៥.៤៦៤.៩៦៦ |
| ឱនភាព (ដុល្លារអាមេរិក) | ១៨.៤២២ | ៧៧.៨៥៦ | ៩៥៧.៣៧៨ | ១.៣៧៧.៤១៩ |

| | **១-៣០ ថ្ងៃ** | **៣១-៦០ ថ្ងៃ** | **៦១-៩០ ថ្ងៃ** | **៩១-១២០ ថ្ងៃ** |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | | |
| ការរំពឹងទុកអត្រាខាតបង់ | ៤,២០% | ៥,៦៧% | ១៣,០៨% | ២៣,៩៩% |
| ចំនួនដុលសរុប (ដុល្លារអាមេរិក) | ២.១៣២.៨៥៦ | ១.២៧៣.៥០៦ | ២៨៧.០៣៧ | ១១៣.៥៣៨ |
| ឱនភាព (ដុល្លារអាមេរិក) | ៧៩.៧២៤ | ៧២.១៥៣ | ៣៧.៥៣៤ | ២៧.២៣៣ |

| | **១២១-១៥០ ថ្ងៃ** | **១៥១-១៨០ ថ្ងៃ** | **លើសពី ១៨០ ថ្ងៃ** | **សរុប ដុល្លារអាមេរិក** |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | | |
| ការរំពឹងទុកអត្រាខាតបង់ | ៣៨,០៧% | ៧០,៣៤% | ១០០% | |
| ចំនួនដុលសរុប (ដុល្លារអាមេរិក) | ៤៨.៥៥១ | ២២.៩៨៩ | ៥៣៩.៧០៥ | ៤.៤១៨.១៨២ |
| ឱនភាព (ដុល្លារអាមេរិក) | ១៨.៤៨៣ | ១៥.៨៤១ | ៥៣៩.៧០៥ | ៧៩០.៦៧៣ |

ក្នុងអំឡុងការិយបរិច្ឆេទ ក.ស.ភ មិនត្រូវបានចរចារឡើងវិញនូវលក្ខខណ្ឌនៃគណនីអតិថិជនពាណិជ្ជ-កម្មឡើយ។

## ៩. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ (ត)

(ង) បម្រែបម្រួលប្តូរសំវិធានធនលើឱនភាពសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម មានដូចខាងក្រោម៖

| | ២០២២<br>ដុល្លារអាមេរិក | ២០២១<br>ដុល្លារអាមេរិក |
|---|---|---|
| នៅថ្ងៃទី១ ខែមករា | ៧៩០.៦៧៣ | ៨៧២.១០១ |
| គិតបន្ថែមសម្រាប់ការិយបរិច្ឆេទ | ៦៦៤.៤៣១ | ៤១៥.៥០៣ |
| ឱនភាពដែលបានប្រែត្រឡប់មកវិញ | (៧៧.៦៨៥) | (៤៩៦.៩៣១) |
| នៅថ្ងៃទី៣១ ខែធ្នូ | ១.៣៧៧.៤១៩ | ៧៩០.៦៧៣ |

(ច) ឱនភាពសម្រាប់គណនីត្រូវទទួលផ្សេងៗ ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទូទៅ (“General approach”) របស់ ស.រ.ហ.អ.ក ៩ ដែលប្រើគំរូនៃការខាតបង់ឥណទានរំពឹងទុកទៅខាងមុខ។ វិធីសាស្ត្រនេះត្រូវបានប្រើដើម្បីកំណត់ចំនួនឱនភាព ថាតើវាមានការកើនឡើងហានិភ័យឥណទានគួរឱ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុដែរ ឬទេ។ ចំពោះហានិភ័យទាំងឡាយ ដែលក្នុងនោះហានិភ័យឥណទានមិនបានកើនឡើងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះទេ នោះការខាតបង់ឥណទានរំពឹងទុកក្នុងរយៈពេល១២ខែ រួមជាមួយចំណូលការប្រាក់ដុលត្រូវបានទទួលស្គាល់។ សម្រាប់ហានិភ័យឥណទាន ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នោះ ការខាតបង់ឥណទានដែលរំពឹងទុករយៈពេលវែង រួមជាមួយនិងចំណូលការប្រាក់ដុលត្រូវបានទទួលស្គាល់។ ចំពោះហានិភ័យឥណទាន ដែលត្រូវបានកំណត់ថាមានឱនភាពឥណទាន ការខាតបង់ឥណទានរំពឹងក្នុងរយៈពេលវែង រួមជាមួយចំណូលការប្រាក់ចំណេញលើមូលដ្ឋានសុទ្ធត្រូវបានទទួលស្គាល់។

## ១០. ពន្ធពន្យារ

សមាសធាតុ និងបម្រែបម្រួលគណនីពន្ធពន្យារទ្រព្យសកម្ម/(បំណុល)មានដូចខាងក្រោម៖

| | គិតត្រឹមថ្ងៃទី<br>១ មករា ២០២២<br>ដុល្លារអាមេរិក | ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត (កំណត់សម្គាល់លេខ២៧)<br>ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី<br>៣១ ធ្នូ ២០២២<br>ដុល្លារអាមេរិក |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (២.៨២៣.៨៤២) | (៤១៣.៣១១) | (៣.២៣៧.១៥៣) |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ៩១.១៦៨ | (៤៤.០០១) | ៤៧.១៦៧ |
| ចំណូលពន្យារ | ២.៧៣០.០០០ | (៦០.០០០) | ២.៦៧០.០០០ |
| ឱនភាពលើគណនីត្រូវទទួល | ១៥៨.១៣៥ | ១១៧.៣៤៩ | ២៧៥.៤៨៤ |
| ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | (១៥.០៨៥) | (១១.៦៤៣) | (២៦.៧២៨) |
| | ១៤០.៣៧៦ | (៤០១.៧៧៤) | (២៧១.២៣០) |
| *(គិតជាពាន់រៀល)* | | | *(១.១១៦.៦៥៤)* |

## ១០. ពន្ធពន្យារ (ត)

| | គិតត្រឹមថ្ងៃទី ១ មករា ២០២១ ដុល្លារអាមេរិក | របាយការណ៍ ចំណេញ ឬខាត (កំណត់សម្គាល់ លេខ២៧) ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០២១ ដុល្លារអាមេរិក |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (២.៧០២.៩៥៩) | (១២០.៨៨៣) | (២.៨២៣.៨៤២) |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១០៨.៣៥៩ | (១៧.១៩១) | ៩១.១៦៨ |
| ចំណូលពន្យារ | ២.៨៥០.០០០ | (១២០.០០០) | ២.៧៣០.០០០ |
| ឱនភាពលើគណនីត្រូវទទួល | ១៧៤.៤២០ | (១៦.២៨៥) | ១៥៨.១៣៥ |
| ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | ១០.១៧១ | (២៥.២៥៦) | (១៥.០៨៥) |
| | ៤៣៩.៩៩១ | (២៩៩.៦១៥) | ១៤០.៣៧៦ |
| *(គិតជាពាន់រៀល)* | | | *៥៧១.៨៩២* |

## ១១. សន្និធិ

| | ២០២២ ដុល្លារអាមេរិក | ២០២២ គិតជាពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|
| ប្រេងម៉ាស៊ូត | ១២៣.៧៧០ | ៥០៩.៥៦២ | - | - |
| ប្រេងរំអិល | ៣២.២០៣ | ១៣២.៥៨០ | - | - |
| គ្រឿងបន្លាស់ | ៥៥៣.៣០៦ | ២.២៧៧.៩៦១ | - | - |
| សម្ភារៈការិយាល័យ | ៥.៧០៣ | ២៣.៤៧៨ | - | - |
| | ៧១៤.៩៨២ | ២.៩៤៣.៥៨១ | - | - |

(ក) ថ្លៃដើមនៃសន្និធិ កំណត់ដោយប្រើប្រាស់មូលដ្ឋានជាមធ្យម និងត្រូវបានវាស់វែងតាមតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃលក់ពិត។

(ខ) ក្នុងអំឡុងការិយបរិច្ឆេទ សន្និធិរបស់ ក.ស.ភ ត្រូវបានទទួលស្គាល់ថាជាថ្លៃដើមសេវកម្ម មានចំនួន ៣.៣០១.០០១ដុល្លារអាមេរិក។

## ១២. សាច់ប្រាក់ និងសមតុល្យនៅធនាគារ

| | ២០២២ ដុល្លារអាមេរិក | ២០២២ គិតជាពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៦.៧៤៦ | ២៧.៧៧៤ | ២.១៥១ | ៨.៧៦៣ |
| សាច់ប្រាក់នៅធនាគារ | ៥.០៩៤.៩១៧ | ២០.៩៧៥.៧៧៣ | ៥.៦០៧.៤៤៤ | ២២.៨៤៤.៧២៧ |
| ប្រាក់បញ្ញើ | ១៧.១០១.១៧២ | ៧០.៤០៥.៥២៥ | ១៣.០០៥.១០៥ | ៥២.៩៨២.៧៩៨ |
| កំណត់បង្ហាញនៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ | ២២.២០២.៨៣៥ | ៩១.៤០៩.០៧២ | ១៨.៦១៤.៧០០ | ៧៥.៨៣៦.២៨៨ |
| ដកៈ | | | | |
| ប្រាក់បញ្ញើ (កាលកំណត់ច្រើនជាង ៣ខែ) | (១៦.១០០.០០០) | (៦៦.២៨៣.៧០០) | (១២.០០០.០០០) | (៤៨.៨៨៨.០០០) |
| កំណត់បង្ហាញនៅក្នុងរបាយការណ៍ លំហូរសាច់ប្រាក់ | ៦.១០២.៨៣៥ | ២៥.១២៥.៣៧២ | ៦.៦១៤.៧០០ | ២៦.៩៤៨.២៨៨ |

## ១២. សាច់ប្រាក់ និងសមតុល្យនៅធនាគារ (ត)

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានចាត់ថ្នាក់ជា ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាម ថ្លៃដើមដករំលស់។

(ខ) ប្រាក់បញ្ញើមានកាលកំណត់ជាមួយធនាគារដែលមានអាជ្ញាប័ណ្ណរបស់ ក.ស.ភ មានកាលកំណត់ ១ខែ ដល់ ២៤០ខែ (២០២១៖ ១ខែ ដល់ ២៤០ខែ)។

(គ) ទម្រង់សាច់ប្រាក់នៃសាច់ប្រាក់ និងសមតុល្យធនាគារមានដូចខាងក្រោម៖

| | **២០២២** **ដុល្លារអាមេរិក** | **២០២១** **ដុល្លារអាមេរិក** |
|---|---|---|
| ដុល្លារអាមេរិក | ២២.០៧០.៣០៤ | ១៨.៤៤៥.០៩៣ |
| ខ្មែររៀល | ១៣២.៥៣១ | ១៦៩.៦០៧ |
| | ២២.២០២.៨៣៥ | ១៨.៦១៤.៧០០ |

ឃ) អត្រាការប្រាក់ប្រសិទ្ធិភាពជាមធ្យម នៃប្រាក់បញ្ញើជាមួយធនាគារដែលមានអាជ្ញាប័ណ្ណនៃ ក.ស.ភ នៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗមានដូចខាងក្រោម៖

| | **២០២២** **%** | **២០២១** **%** |
|---|---|---|
| អត្រាថេរ | ៦,៨០ | ៦,២៥ |

## ១៣. ដើមទុន

| | **២០២២** ចំនួន | **២០២២** ដុល្លារអាមេរិក | **២០២១** ចំនួន | **២០២១** ដុល្លារអាមេរិក |
|---|---|---|---|---|
| ភាគហ៊ុនមានសិទ្ធិបោះឆ្នោត នៃ ១ដុល្លារអាមេរិក៖ | | | | |
| ប្រភេទ ក | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ |
| ប្រភេទ ខ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ |
| | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ភាគហ៊ុនមិនមានសិទ្ធិបោះឆ្នោត នៃ ១ដុល្លារអាមេរិក៖ | | | | |
| ប្រភេទ គ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ |
| | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | | *៤៥៧.៨១៣.៩៤០* |

## ១៣. ដើមទុន (ត)

ដើមទុនសរុប ១១៤.៤៥៣.៤៨៥ ដុល្លារអាមេរិក ត្រូវបានបែងចែក ជា១១៤.៤៥៣.៤៨៥ ភាគហ៊ុន នៃតម្លៃចារឹកក្នុងមួយភាគហ៊ុន ៤.០០០រៀល (សមមូលទៅ ១ដុល្លារអាមេរិក) ហើយត្រូវបានបែងចែងជា៣ ប្រភេទៈ

(ក) ៤.១៣៦.៨៧៣ ភាគហ៊ុនប្រភេទ “ក” (មានសិទ្ធិបោះឆ្នោត) (៣,៦១%) ជាមួយតម្លៃ ៤.១៣៦.៨៧៣ ដុល្លារអាមេរិក (សមមូលទៅ ១៦.៥៤៧.៤៩២.០០០រៀល)

(ខ) ១៦.៥៤៧.៤៩២ ភាគហ៊ុនប្រភេទ “ខ” (មានសិទ្ធិបោះឆ្នោត) (១៤,៤៦%) ជាមួយតម្លៃ ១៦.៥៤៧.៤៩២ដុល្លារអាមេរិក (សមមូលទៅ ៦៦.១៨៩.៩៦៨.០០០រៀល)

(គ) ៩៣.៧៦៩.១២០ ភាគហ៊ុនប្រភេទ “គ” (មិនមានសិទ្ធិបោះឆ្នោត) (៨១,៩៣%) ជាមួយតម្លៃ ៩៣.៧៦៩.១២០ដុល្លារអាមេរិក (សមមូលទៅ ៣៧៥.០៧៦.៤៨០.០០០រៀល)។

ភាគហ៊ុនិកប្រភេទ “ក” នឹងទទួលបានការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹង ៥%ក្នុង១ឆ្នាំ ដោយគិតតាមថ្លៃលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ សម្រាប់រយៈពេលយ៉ាងហោច៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ ២០២១។ តម្លៃបច្ចុប្បន្ននៃការធានាបង់ភាគលាភនេះ មានចំនួន ៩៣៦.១៤៥ដុល្លារអាមេរិក ហើយត្រូវបានរំពឹងទុកថានឹងធ្វើការទូទាត់ក្នុងរយៈពេល៥ឆ្នាំ។

ភាគហ៊ុនិកប្រភេទ “គ” ពុំមានសិទ្ធិទទួលបាននូវភាគលាភពី ក.ស.ភ នោះទេ ប៉ុន្តែមានសិទ្ធិអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិរបស់ ក.ស.ភ នៅក្នុងករណីដែលក្រុមហ៊ុនជម្រះបញ្ជី។

ភាគហ៊ុនិកប្រភេទ “ក” និង “ខ” ត្រូវទទួលបានភាគលាភ នៅពេលមានការប្រកាសពី ក.ស.ភ និងមានសិទ្ធិទទួលបានការបោះឆ្នោតមួយសន្លឹក ក្នុងមួយភាគហ៊ុនធម្មតាក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ ក.ស.ភ។ ភាគហ៊ុនធម្មតាទាំងអស់មានចំណាត់ថ្នាក់ដូចគ្នា ជាមួយនឹងទ្រព្យសកម្មដែលនៅសល់របស់ ក.ស.ភ។

## ១៤. បុព្វលាភភាគហ៊ុន

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ ទទួលបានជោគជ័យនៅការចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា (“ផ.ម.ក”)។ ចំនួនភាគហ៊ុនសរុប (មានសិទ្ធិបោះឆ្នោត) មានចំនួន ២០.៦៨៤.៣៦៥ភាគហ៊ុន ដែលមាន ៤.១៣៦.៨៧៣ ជាភាគហ៊ុនប្រភេទ “ក” ដែលមានតម្លៃចារឹក ៤.០០០រៀលក្នុងមួយភាគហ៊ុន។ បន្ទាប់ពីបានចុះបញ្ជីចំនួន៨០% នៃភាគហ៊ុនសរុបត្រូវបានកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក.ស.ភ បានទទួលសាច់ប្រាក់ពីការលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈបានចំនួន ៥.១៩៣.៩១៥ដុល្លារអាមេរិក និងចំណាយប្រតិបត្តិការចំនួន ៩០១.៥៤០ដុល្លារអាមេរិក។

បុព្វលាភភាគហ៊ុន សំដៅលើចំនួនទឹកប្រាក់លើសពីតម្លៃចារឹក នៃភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនទទួលបានពីការបោះផ្សាយលក់ភាគហ៊ុន និងបន្ទាប់ពីកាត់កងនូវចំណាយប្រតិបត្តិការផ្សេងៗ ដែលកើតចេញផ្ទាល់ពីការបោះផ្សាយភាគហ៊ុន។

# ១៥. ទុនបម្រុង

| | ទុនបម្រុងតាមច្បាប់<br>ដុល្លារអាមេរិក | ទុនបម្រុងទូទៅ<br>ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍<br>សហគ្រាស<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ២.៥៣៩.០៥៤ | ២.៥៣៩.០៥៤ | ៤០.៧៨៣.២៧២ | ៤៥.៨៦១.៣៨០ |
| ការផ្ទេរពីចំណេញរក្សាទុក | ៦៣៥.៣៩២ | ៦៣៥.៣៩២ | ១០.៣៣៤.៥៣៣ | ១១.៦០៥.៣១៧ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ៣.១៧៤.៤៤៦ | ៣.១៧៤.៤៤៦ | ៥១.១១៧.៨០៥ | ៥៧.៤៦៦.៦៩៧ |
| *(គិតជាពាន់រៀល)* | *១៣.០៦៩.១៩៤* | *១៣.០៦៩.១៩៤* | *២១០.៤៥២.០០៣* | *២៣៦.៥៩០.៣៩១* |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ២.០៤៦.០១០ | ២.០៤៦.០១០ | ៣២.៤៤៧.៥៨៦ | ៣៦.៥៣៩.៦០៦ |
| ការផ្ទេរពីចំណេញរក្សាទុក | ៤៩៣.០៤៤ | ៤៩៣.០៤៤ | ៨.៣៣៥.៦៨៦ | ៩.៣២១.៧៧៤ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ២.៥៣៩.០៥៤ | ២.៥៣៩.០៥៤ | ៤០.៧៨៣.២៧២ | ៤៥.៨៦១.៣៨០ |
| *(គិតជាពាន់រៀល)* | *១០.៣៤៤.១០៦* | *១០.៣៤៤.១០៦* | *១៦៦.១៥១.០៥០* | *១៨៦.៨៣៩.២៦២* |

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានអនុម័តនូវការផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុង ចំនួន ១១.៦០៥.៣១៧ដុល្លារអាមេរិក។

យោងតាមលក្ខន្តិកៈរបស់ ក.ស.ភ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ប្រការ៦៦ បានចែងថាប្រាក់ចំណេញរបស់ ក.ស.ភ បន្ទាប់ពីកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ទុនបម្រុងតាមច្បាប់ ៥%
- សម្រាប់ទុនបម្រុងទូទៅ ៥%
- សមតុល្យនៅសល់សម្រាប់ភាគលាភ និងមូលនិធិសម្រាប់អភិវឌ្ឍន៍សហគ្រាស

## ១៦. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| **គណនីត្រូវបង់ផ្សេងៗ** | | | | |
| ប្រាក់កក់ | ៣៥.១៤៥ | ១៤៤.៦៩២ | ៣៣.៧៩៣ | ១៣៧.៦៧៣ |
| **រយៈពេលខ្លី** | | | | |
| **គណនីអ្នកផ្គត់ផ្គង់** | | | | |
| ភាគីទីបី | ៦២៩.២១៦ | ២.៥៩០.៤៨២ | ៤៨៧.២៩១ | ១.៩៨៥.២២៤ |
| **គណនីត្រូវបង់ផ្សេងៗ** | | | | |
| ការប្រាក់ត្រូវបង់ | ២៧៥.៣០៧ | ១.១៣៣.៤៣៩ | ៣០៥.៨៩៦ | ១.២៤៦.២២០ |
| ប្រាក់កក់ | ៤៩៥.០០១ | ២.០៣៧.៩១៩ | ២៣៦.៤៤២ | ៩៦៣.២៦៥ |
| ពន្ធត្រូវបង់ផ្សេងៗ | ២១៣.២១៩ | ៨៧៧.៨២៣ | ២៤៨.៤០៣ | ១.០១១.៩៩៤ |
| បំណុលត្រូវបង់ផ្សេងៗ | ១.៦២០.៤៥៩ | ៦.៦៧១.៤៣០ | ១.១១៥.៨៧៥ | ៤.៥៤៦.០៧៥ |
| | ២.៦០៣.៩៨៦ | ១០.៧២០.៦១១ | ១.៩០៦.៦១៦ | ៧.៧៦៧.៥៥៤ |
| | ៣.២៣៣.២០២ | ១៣.៣១១.០៩៣ | ២.៣៩៣.៩០៧ | ៩.៧៥២.៧៧៨ |

(ក) គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ វាស់-វែងតាមថ្លៃដើមដករំលស់។

(ខ) គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម គឺមិនត្រូវបានគិតការប្រាក់ ហើយលក្ខខណ្ឌឥណទានពាណិជ្ជកម្មធម្មតា ដែលផ្តល់ដល់ ក.ស.ភ មានរយៈពេលចាប់ពី១ខែ ដល់២ខែ (២០២១៖១ខែ ដល់ ២ខែ)។

(គ) ទម្រង់ហានិភ័យរូបិយប័ណ្ណនៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗមានដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ដុល្លារអាមេរិក | ១.៦០៦.០៥៣ | ១.១៣៩.២៨១ |
| ខ្មែររៀល | ១.៦៦២.២៩៤ | ១.២៨៨.៤១៩ |
| | ៣.២៦៨.៣៤៧ | ២.៤២៧.៧០០ |

(ឃ) ទម្រង់កាលបរិច្ឆេទនៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗរបស់ ក.ស.ភ នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សង ដែលមិនទាន់ធ្វើអប្បហារ ត្រូវសងត្រឡប់តាមតម្រូវការ ឬក្នុងរយៈពេលមួយឆ្នាំ លើកលែងតែប្រាក់កក់រយៈពេលវែងដូចដែលបានកត់ត្រាខាងលើ។

## ១៧. ប្រាក់កម្ចី

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| ចំណាតផែភ្នំពេញ - គម្រោងស្ថានីយថ្មី ("PPPNCTP") ឬ ចំណតផែកុងតឺន័រ LM១៧ | ១៦.៥៥៩.៧៩៣ | ៦៨.១៧៦.៦៦៨ | ១៨.៦២៩.៧៦៧ | ៧៥.៨៩៧.៦៧១ |
| **រយៈពេលខ្លី** | | | | |
| ចំណតផែកុងតឺន័រ LM១៧ | ២.០៦៩.៩៧៤ | ៨.៥២២.០៨៣ | ២.០៦៩.៩៧៤ | ៨.៤៣៣.០៧៤ |
| | ១៨.៦២៩.៧៦៧ | ៧៦.៦៩៨.៧៥១ | ២០.៦៩៩.៧៤១ | ៨៤.៣៣០.៧៤៥ |

(ក) ចំណតផែកុងតឺន័រ LM១៧ តំណាងឱ្យកិច្ចព្រមព្រៀងខ្ចីបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក.ស.ភ សម្រាប់ការខ្ចីប្រាក់បានមកពី The Import-Export Bank of China ("the Eximbank") ស្ថិតនៅក្រោមកិច្ចព្រមព្រៀងកម្ចីឥណទានអតិថិជនដែលពេញចិត្ត (Preferred Buyer) លេខ (២០១០)២៩ (១៣៦) នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ សម្រាប់ការសាងសង់ចំណតផែកុងតឺន័រ LM១៧។ ចំនួនទឹកប្រាក់ដែលបានប្រគល់ឱ្យ ក.ស.ភ ខ្ចីបន្តនេះ ត្រូវបានចាត់ទុកថាបានឱ្យ ក.ស.ភ នៅថ្ងៃដូចគ្នាតាមរូបិយប័ណ្ណ និងក្នុងចំនួនទឹកប្រាក់ដូចដែលបានបើកដោយធនាគារ Eximbank សម្រាប់កម្មវត្ថុផ្តល់ហិរញ្ញប្បទានដើម្បីអនុវត្តគម្រោង។ ក.ស.ភ បង់ការប្រាក់រៀងរាល់ពាក់កណ្តាលឆ្នាំម្តង ដោយអត្រាការប្រាក់ ៤%ក្នុង១ឆ្នាំ។ ប្រាក់កម្ចីបន្តនេះ គឺសម្រាប់រយៈពេល ២០ឆ្នាំ រួមបញ្ចូលទាំងថេរវេលាអនុគ្រោះមិនលើសពី៧ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាកិច្ចព្រមព្រៀងកម្ចីនេះ។

(ខ) កម្ចី ត្រូវបានចាត់ថ្នាក់ ជាបំណុលហិរញ្ញវត្ថុបានវាស់វែងតាម ថ្លៃដើមដករំលស់។

(គ) កម្ចី ត្រូវសងពីរដងក្នុងមួយឆ្នាំ គឺនៅថ្ងៃទី២០ ខែកុម្ភៈ និងថ្ងៃទី២០ ខែសីហា ដែលចាប់ផ្តើមទូទាត់ប្រាក់ដើមពីខែកុម្ភៈ ឆ្នាំ២០១៨ តទៅ។

(ឃ) តម្លៃទីផ្សារ នៃកម្ចីរបស់ ក.ស.ភ ជាកម្រិត៣ នៅក្នុងឋានានុក្រមតម្លៃទីផ្សារ។ មិនមានការផ្លាស់ប្តូររវាងកម្រិតនៅក្នុងឋានានុក្រមក្នុងអំឡុងពេលនៃឆ្នាំហិរញ្ញវត្ថុទេ។

បច្ចេកទេសវាយតម្លៃ ត្រូវបានប្រើ និងធាតុចូលសំខាន់ៗ ដើម្បីវាយតម្លៃលើកម្ចី ដែលបានវាស់វែងនៅកម្រិតទី៣ ត្រូវបានពិពណ៌នាដូចខាងក្រោម៖

| បំណុលហិរញ្ញវត្ថុ | ការវាយតម្លៃ និង បច្ចេកទេសប្រើ | ធាតុចូលដែល មិនអាចអង្កេត | អន្តរទំនាក់ទំនងរវាងធាតុចូលដែលមិនសំខាន់ និងតម្លៃទីផ្សារ |
|---|---|---|---|
| កម្ចី | វិធីសាស្ត្រអប្បហារនៃលំហូរសាច់ប្រាក់ | ៨,០០% | អត្រាអប្បហារខ្ពស់ ធ្វើឱ្យតម្លៃទីផ្សារនៃបំណុលហិរញ្ញវត្ថុមានតម្លៃទាប |

(ង) កម្ចី ដែលមិនត្រូវបានធ្វើឡើងដោយតម្លៃទីផ្សារ និងចំនួនដែលត្រូវបានគេចាត់ទុកជាតម្លៃពិតគណនេយ្យនៃតម្លៃទីផ្សារមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | តម្លៃពិតគណនេយ្យ ដុល្លារអាមេរិក | តម្លៃទីផ្សារ ដុល្លារអាមេរិក | តម្លៃពិតគណនេយ្យ ដុល្លារអាមេរិក | តម្លៃទីផ្សារ ដុល្លារអាមេរិក |
| កម្ចី (អត្រាថេរ) | ១៨.៦២៩.៧៦៧ | ១៧.២៤៩.៧៩២ | ២០.៦៩៩.៧៤១ | ១៩.១៦៦.៤២៧ |

## ១៧. ប្រាក់កម្ចី (ត)

(ច) តារាងខាងក្រោមនេះបង្ហាញពីតម្លៃពិតគណនេយ្យរបស់កម្ចី ដោយបង្ហាញពីអត្រាការប្រាក់ប្រសិទ្ធិភាពជាមធ្យមគិតត្រឹមចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ និងកាលកំណត់ដែលនៅសល់នៃកម្ចីរបស់ ក.ស.ភ ដែលត្រូវបានប៉ះពាល់នឹងហានិភ័យអត្រាការប្រាក់៖

| ៣១ ធ្នូ ២០២២ | អត្រាការប្រាក់ដែលមានប្រសិទ្ធិភាពអាត្រាក្នុងមួយឆ្នាំ % | តិចជាង ១ឆ្នាំ ដុល្លារអាមេរិក | ១ - ២ ឆ្នាំ ដុល្លារអាមេរិក | ២ - ៥ ឆ្នាំ ដុល្លារអាមេរិក | ច្រើនជាង ៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **កម្ចី** | | | | | | |
| អត្រាថេរ | ៤,០០ | ២.០៦៩.៩៧៤ | ២.០៦៩.៩៧៤ | ៦.២០៩.៩២២ | ៨.២៧៩.៨៩៧ | ១៨.៦២៩.៧៦៧ |
| **៣១ ធ្នូ ២០២១** | | | | | | |
| **កម្ចី** | | | | | | |
| អត្រាថេរ | ៤,០០ | ២.០៦៩.៩៧៤ | ២.០៦៩.៩៧៤ | ៦.២០៩.៩២២ | ១០.៣៤៩.៨៧០ | ២០.៦៩៩.៧៤០ |

(ឆ) តារាងខាងក្រោមសង្ខេបទម្រង់កាលកំណត់នៃការខ្ចីប្រាក់របស់ ក.ស.ភ នៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សងតាមកិច្ចសន្យាដែលមិនបានធ្វើអប្បហារដូចខាងក្រោម៖

| ៣១ ធ្នូ ២០២២ | តាមតម្រូវការ ឬ ក្នុងរយៈពេលមួយឆ្នាំ ដុល្លារអាមេរិក | ពីមួយទៅប្រាំឆ្នាំ ដុល្លារអាមេរិក | លើសពីប្រាំឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| កម្ចី | ២.៧៩៤.៤៦៥ | ១០.៣៤៩.៨៧០ | ៩.០២៥.០៨៧ | ២២.១៦៩.៤២២ |
| **៣១ ធ្នូ ២០២១** | | | | |
| កម្ចី | ២.៨៧៧.២៦៤ | ១០.៦៨១.០៦៦ | ១១.៤៨៨.៣៥៦ | ២៥.០៤៦.៦៨៦ |

(ជ) កម្ចីទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

## ១៨. សំវិធានធនលើកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** |
| **កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍** | | | | |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ២៣៥.៨៣៥ | ៩៧០.៩៣៣ | ៤៥៥.៨៤២ | ១.៨៥៧.១០០ |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) | ១២៦.១៨៨ | ៥១៩.៥១៦ | ៩៩.៩៨៧ | ៤០៧.៣៤៧ |
| បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៣៦២.០២៣ | ១.៤៩០.៤៤៩ | ៥៥៥.៨២៩ | ២.២៦៤.៤៤៧ |

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងអំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| នាថ្ងៃទី១ ខែមករា | ៤៥៥.៨៤២ | ៥៤១.៧៩៥ |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៣៥.០៨៩ | ៤៤.៧៣១ |
| ចំណាយការប្រាក់ | ២៦.៥៥៨ | ៣២.០៤៣ |
| ប្រាក់ចំណាយលើសេវាកម្មពីអតីតកាល | - | (២៣.២០៤) |
| អត្ថប្រយោជន៍បានបង់ | (២៩.៨៩៤) | (២២.៥៥៨) |
| ការវាយតម្លៃឡើងវិញ | (២៥១.៧៦០) | (១១៦.៩៦៥) |
| នាថ្ងៃទី៣១ ខែធ្នូ | ២៣៥.៨៣៥ | ៤៥៥.៨៤២ |
| *(គិតជាពាន់រៀល)* | *៩៧០.៩៣៣* | *១.៨៥៧.១០០* |

បម្រែបម្រួលនៅក្នុងអត្ថប្រយោជន៍ផ្សេងទៀតដែលបានកំណត់ក្នុងអំឡុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** |
| នាថ្ងៃទី១ ខែមករា | ៩៩.៩៨៧ | ៧៤.៦២៧ |
| ចំណាយបន្ថែម | ២៦.២០១ | ២៥.៣៦០ |
| នាថ្ងៃទី៣១ ខែធ្នូ | ១២៦.១៨៨ | ៩៩.៩៨៧ |
| *(គិតជាពាន់រៀល)* | *៥១៩.៥១៦* | *៤០៧.៣៤៧* |

## ១៨. សំវិធានធនលើកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

ចំណាយតម្លៃដែលបានទទួលស្គាល់ជាមួយ ប្រាក់បៀវត្សរ៍ ប្រាក់កម្រៃ និងចំណាយដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ មានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍** | | | | |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៣៥.០៨៩ | ១៤៣.៤០៩ | ៤៤.៧៣១ | ១៨១.៩៦៦ |
| ចំណាយការប្រាក់ | ២៦.៥៥៨ | ១០៨.៥៤៣ | ៣២.០៤៣ | ១៣០.៣៥១ |
| ប្រាក់ចំណាយលើសេវាកម្មពីអតីតកាល | - | - | (២៣.២០៤) | (៩៤.៣៩៤) |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| ចំណាយបន្ថែម | ២៦.២០១ | ១០៧.០៨៣ | ២៥.៣៦០ | ១០៣.១៦៤ |
| | ៨៧.៨៤៨ | ៣៥៩.០៣៥ | ៧៨.៩៣០ | ៣២១.០៨៧ |

(ក) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

ការសន្មត់លើការគណនា actuarial ត្រូវបានកំណត់ដូចខាងក្រោម៖

| | |
|---|---|
| អត្រាអប្បហារ (១) | ៦,៣០% (ឆ្នាំ២០២១៖ ៦,០០%) |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | ១៦% (ឆ្នាំ២០២១៖ ១៧%) ក្នុង១ឆ្នាំ និងថយចុះតាមលំដាប់៥% រាល់ឆ្នាំរហូតដល់ឆ្នាំ២០៣៤ សម្រាប់បៀវត្សរ៍គោល និងបៀវត្សរ៍សរុប |
| អត្រាមរណភាព (២) | តារាងអាយុរបស់ប្រទេសថៃឆ្នាំ២០១៧ |
| ពិការភាព | ១០% (ឆ្នាំ២០២១៖ ១០%) នៃអត្រារស់រាន |
| អត្រាបម្រែបម្រួលបុគ្គលិក | ១,១% (ឆ្នាំ២០២១៖ ១,១%) |

(១) អត្រាអប្បហារ

ដោយសារព័ត៌មានអំពីប័ណ្ណបំណុលពាណិជ្ជកម្ម ឬប័ណ្ណបំណុលរបស់រាជរដ្ឋាភិបាល មិនទាន់មាន ដូច្នេះ ក.ស.ភ បានកំណត់អត្រាអប្បហារ ដោយប្រើប្រាស់អត្រាការប្រាក់បញ្ញើរយៈពេលវែងជាមធ្យមរបស់ធនាគារចម្បងៗនៅកម្ពុជា។

(២) អត្រាមរណភាព

ការសន្មតនៃអាយុរស់នៅនាពេលអនាគត គឺផ្អែកលើតារាងស្ថិតិអាយុដែលបានផ្សាយជាសាធារណៈ។ ដោយសារតែតារាងនេះមិនមាននៅក្នុងប្រទេសកម្ពុជា ក.ស.ភ បានប្រើប្រាស់តារាងស្ថិតិអាយុរបស់ប្រទេសថៃ ឆ្នាំ២០១៧ ដោយមិនមានកែប្រែឡើយ (សូមមើលព័ត៌មានការប្រៀបធៀបខាងក្រោម)។ អត្រានេះ គឺបានបោះពុម្ពផ្សាយនៅឆ្នាំ២០១៧។ ដោយសារតែនិយោជិតដែលធ្វើការក្នុងវិស័យផ្លូវការ មានអាយុកាលរស់នៅល្អជាងប្រជាជនទូទៅហេតុដូចនេះ សំវិធានធនត្រូវបានធ្វើឡើង។

## ១៨. សំវិធានធនលើមូលនិធិសោធននិវត្តន៍ (ត)

<u>ការវិភាគរំញោច</u>

- ការថយចុះនូវអត្រាអប្បហារចំនួន០,២៥% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន១,៦៣% (២០២១៖ ២,៥៩%)។ ការកើនឡើងនូវអត្រាអប្បហារចំនួន០,២៥% អាចធ្វើឱ្យថយចុះគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន១,៥៧% (២០២១៖ ២,៤៩%)។
- ការថយចុះនូវអត្រាកើនឡើងនៃប្រាក់បៀវត្សរ៍ចំនួន០,៥០% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន០,១២% (២០២១៖ ៤,២៦%)។ ការកើនឡើងនូវអត្រានៃប្រាក់បៀវត្សរ៍ចំនួន០,៥០% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ ដែលបានកំណត់ចំនួន ០,១៤% (២០២១៖ ៤,៥៧%)។

ខ) អត្ថប្រយោជន៍ផ្សេងៗ

ក.ស.ភ បានកាត់ទុកចំនួន ៣%នៃមូលដ្ឋានប្រាក់បៀវត្សរ៍ប្រចាំខែ សម្រាប់បង់ទៅឱ្យបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ជាប្រចាំឆ្នាំ។ បន្ទាប់ពីចូលនិវត្តន៍និយោជិតកម្មករ និងទទួលបានប្រាក់ចូលនិវត្តន៍ប្រចាំខែ ពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលវិញ។

## ១៩. កិច្ចសន្យាបំណុល

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **បំណុលរយៈពេលវែង** | | | | |
| ចំណូលពន្យារ | ១៣.៣៥០.០០០ | ៥៤.៩៦១.៩៥០ | ១៣.៦៥០.០០០ | ៥៥.៦១០.០០ |
| **បំណុលរយៈពេលខ្លី** | | | | |
| ចំណូលពន្យារ | ៣០០.០០០ | ១.២៣៥.១០០ | ៣០០.០០០ | ១.២២២.២០០ |

ក) កិច្ចសន្យាបំណុល គឺជាចំណូលពន្យារ ដែលកើតឡើងពីកិច្ចសន្យាជួលដែលមានរយៈពេល៥០ឆ្នាំ ជាមួយក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប។ តម្លៃសរុប ត្រូវបានកាត់បន្ថយដោយប្រើរំលស់ថេរសម្រាប់រយៈពេល៥០ឆ្នាំ(២០២១៖ ៥០ឆ្នាំ)។

ខ) ចំណូលនេះនឹងរំពឹងទុកថា នឹងអាចទទួលស្គាល់នៅពេលអនាគត ដែលទាក់ទងទៅនឹងកាតព្វកិច្ចអនុវត្តដែលមិនបានអនុវត្តទាំងស្រុង (ឬបានខ្លះ) នៅចុងការិយបរិច្ឆេទនៃរបាយការណ៍គឺចំនួន ៣០០.០០០ ដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ។

## ២០. ចំណូលពន្យារ

| | ចំណតផែពហុបំណង ដុល្លារអាមេរិក |
|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១/ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | - |
| បំណុលត្រូវបានទទួលស្គាល់រួមជាមួយទ្រព្យសកម្មសម្បទាន | ៨.១៣៥.០៩៣ |
| ការបែងចែកចំណេញ ឬខាត | ៤៣.១៩៩ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៨.១៧៨.២៩២** |
| *(គិតជាពាន់រៀល)* | *៣៣.៦៧០.០២៨* |

ចំណូលពន្យារ គឺទាក់ទងនឹងទ្រព្យសម្បត្តិសម្បទានដែលកើតចេញពីការអភិវឌ្ឍចំណតផែពហុបំណង TS១១និង UM២ ដូចបានបង្ហាញក្នុងកំណត់សម្គាល់លេខ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ២១. ចំណាយជាប់កិច្ចសន្យា

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយជាប់កិច្ចសន្យានៃការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារៈ បានចុះកិច្ចសន្យាប៉ុន្តែមិនបានផ្តល់ | ១.៨៩៦.១៤៥ | ៧.៨០៦.៤២៨ | ១.០៣១.១១១ | ៤.២០០.៧៤៦ |

## ២២. ចំណូល

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលលើកដាក់ក្រោមដងយោង | ១៦.០៣៣.១៨១ | ៦៥.៥២៧.៦១១ | ១៣.៦២៤.៤២២ | ៥៥.៤២៤.១៤៩ |
| ចំណូលលើកដាក់លើទីលាន | ១២.៦៩៩.០៧៦ | ៥១.៩០១.១២៤ | ១១.១០៦.៦៥២ | ៤៥.១៨១.៨៦០ |
| ចំណូលពីកិច្ចការផែ | ៤.៣២៩.៨០១ | ១៧.៦៩៥.៨៩៧ | ៣.៥៥៨.៩៧៥ | ១៤.៤៧៧.៩១០ |
| ចំណូលពីច្រកទ្វារ | ១.០៦៥.៣៤៥ | ៤.៣៥៤.០៦៥ | ៨៨៨.៥៥៩ | ៣.៦១៤.៦៥៨ |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៩៩៧.៤៨០ | ៤.០៧៦.៧០១ | ៨២៥.០៩៧ | ៣.៣៥៦.៤៩៥ |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ១៩.៦១៣ | ៨០.១៥៨ | ១០.១១២ | ៤១.១៣៦ |
| ចំណូលពីការរើ រៀបទំនិញ | ២៦.០០០ | ១០៦.២៦២ | ៣១.៩៨៨ | ១៣០.១២៧ |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ២.៦៥២ | ១០.៨៣៨ | ៣១.០៨៩ | ១២៦.៤៧០ |
| ចំណូលពីការស្នងមតិ | - | - | ៣.០០០ | ១២.២០៤ |
| ចំណូលពីការដឹកជញ្ជូន | ៩៥១.៨៩៤ | ៣.៨៩០.៣៩១ | ៤២៦.០៥១ | ១.៧៣៣.១៧៥ |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ២៨៦.៨៩០ | ១.១៧២.៥១៩ | ២៧៧.៧៧០ | ១.១២៩.៩៦៨ |
| | ៣៦.៤១១.៩៣២ | ១៤៨.៨១៥.៦៦៧ | ៣០.៧៨៣.៧១៥ | ១២៥.២២៨.១៥២ |

ចំណូលដែលបានមកពីសេវាកម្ម គឺត្រូវទទួលស្គាល់នៅពេលដែលសេវាកម្ម ត្រូវបានផ្តល់ជូន និងទទួលយកដោយអតិថិជន។

មិនមានសមាសធាតុហិរញ្ញប្បទានសំខាន់ៗ នៅក្នុងចំណូលដែលកើតឡើងពីសេវាកម្ម ដែលបានផ្តល់ឱ្យនោះទេ ដោយសេវាកម្មដែលត្រូវបានធ្វើឡើងនៅលើលក្ខខណ្ឌឥណទានធម្មតាដែលមិនលើសពី១២ខែ។

## ២៣. ថ្លៃដើមសេវាកម្ម

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដងយោង | ៣.២៦០.៧៩៣ | ១៣.៣២៦.៨៦១ | ២.៣៧២.៤៤៩ | ៩.៦៥១.១២៣ |
| រំលស់ | ៣.១៥១.០៦៧ | ១២.៨៧៨.៤១១ | ២.៦៤១.៣៨១ | ១០.៧៤៥.១៣៨ |
| ប្រេងឥន្ធនៈ | ១.៨២៦.៣៥៣ | ៧.៤៦៤.៣០៥ | ៩៦១.៨៤៩ | ៣.៩១២.៨០២ |
| ប្រាក់បៀវត្សរ៍ និង ប្រាក់ឈ្នួល | ២.០៧០.៤០១ | ៨.៤៦១.៧២៩ | ១.៧៣៩.៦៨៧ | ៧.០៧៧.០៤៧ |
| ចំណាយការថែទាំ និងជួសជុល | ១.៣៩៤.៣២១ | ៥.៦៩៨.៥៩០ | ១.២៣៧.៣៤០ | ៥.០៣៣.៤៩៩ |
| ចំណាយលើការគ្រប់គ្រងអាជីវកម្មខ្សាច់ | - | - | ៤.៦២៥ | ១៨.៨១៥ |
| ចំណាយពីសេវាភ័ស្តុភារកម្ម | ២៨២.០៤៥ | ១.១៥២.៧១៨ | ២៧៣.៨៣០ | ១.១១៣.៩៤០ |
| ចំណាយផ្សេងៗ | ៤៥៨.៨៣៨ | ១.៨៧៥.២៧១ | ៥៨០.១៥៦ | ២.៣៦០.០៧៥ |
| | ១២.៤៤៣.៨១៨ | ៥០.៨៥៧.៨៨៥ | ៩.៨១១.៣១៧ | ៣៩.៩១២.៤៣៩ |

## ២៤. ចំណូលផ្សេងៗ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលពីការជួល | ៧៤៨.២៣០ | ៣.០៥៨.០១៦ | ៩៩៣.៨០២ | ៤.០៤២.៧៨៧ |
| ចំណូលពីការប្រាក់៖ | | | | |
| - ប្រាក់បញ្ញើជាមួយស្ថាប័នហិរញ្ញវត្ថុ | ១.០២៥.១៧៥ | ៤.១៨៩.៨៩០ | ១.៣០៩.១០៥ | ៥.៣២៥.៤៣៩ |
| - ភតិសន្យាត្រូវទទួល | ២៤៥.៨៣១ | ១.០០៤.៧១១ | ១៥៥.៨៩៤ | ៦៣៤.១៧៧ |
| ផលប៉ះពាល់នៃប្រាក់កក់ត្រូវបង់រយៈពេលវែង | ២.៧០៤ | ១១.០៥១ | ២.៥៩៩ | ១០.៥៧៣ |
| ការប្រែត្រឡប់នៃឱនភាពនៃការខាតបង់ គណនីត្រូវទទួលដែលបានកត់ត្រា | ៧៧.៦៨៥ | ៣១៧.៤៩០ | ៤៩៦.៩៣១ | ២.០២១.៥១៥ |
| ចំណូលពីការវិនិយោគសុទ្ធលើភតិសន្យាបន្ត | ២.៧៦៣.៤២២ | ១១.២៩៤.១០៦ | - | - |
| ចំណូលផ្សេងៗ | ៣៤១.៧២១ | ១.៣៩៦.៦២២ | ៣៧៥.៧៦០ | ១.៥២៨.៥៩២ |
| | ៥.២០៤.៧៦៨ | ២១.២៧១.៨៨៦ | ៣.៣៣៤.០៩១ | ១៣.៥៦៣.០៨៣ |

(ក) ចំណូលពីការជួល

ចំណូលពីការជួល ត្រូវបានទទួលស្គាល់តាមមូលដ្ឋានតម្លៃថេរ ធៀបនឹងរយៈពេលជួលសរុបនៃរយៈពេលជួលដែលកំពុងបន្ត។

(ខ) ចំណូលពីការប្រាក់

ចំណូលពីការប្រាក់ ត្រូវបានទទួលស្គាល់នៅពេលវាត្រូវបានបង្ករ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព។

## ២៥. ចំណាយទូទៅ និងចំណាយរដ្ឋបាល

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ | ៤.៣៩០.១៦៥ | ១៧.៩៤២.៦០៤ | ៣.៩៦៥.៦៤៧ | ១៦.១៣២.២៥២ |
| ចំណាយទឹក ភ្លើង និងប្រេងឥន្ធនៈ | ៦៧១.១៥៤ | ២.៧៤៣.០០៦ | ៥៤៥.០១៥ | ២.២១៧.១២១ |
| រំលស់ | ៧៣៤.៤២៣ | ៣.០០១.៥៨៧ | ៧០៨.៨៨៨ | ២.៨៨៣.៧៥៦ |
| កម្រៃសម្រាប់ក្រុមប្រឹក្សាភិបាល | ២៤៦.៣៣១ | ១.០០៦.៧៥៥ | ២៤៧.៨០៩ | ១.០០៨.០៨៧ |
| ប្រទានកម្ម | ៥៧១.៤១៤ | ២.៣៣៥.៣៦៩ | ៤៥០.៣៤០ | ១.៨៨៤.៧០៣ |
| ចំណាយផ្គត់ផ្គង់សម្ភារៈការិយាល័យ | ២០៣.៥៣៨ | ៨៣១.៨៦០ | ២២៦.១៧៤ | ៩២០.០៧៦ |
| ចំណាយលើការកំសាន្ត | ២២០.៨២១ | ៩០២.៤៩៥ | ១០១.២០២ | ៤១១.៦៩០ |
| ចំណាយការជួសជុល និងថែទាំ | ១៦០.៦៩១ | ៦៥៦.៧៤៤ | ១៦៣.៥៨៤ | ៦៦៥.៥០០ |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៦៩.០៩១ | ២៨២.៣៧៥ | ៧០.៩២៤ | ២៨៨.៥១៩ |
| ចំណាយលើថ្លៃវិជ្ជាជីវៈ | ៤៥.៦៨៩ | ១៨៦.៧៧២ | ៤៣.២៧១ | ១៧៦.០២៦ |
| ចំណាយលើការធ្វើដំណើរ | ៦៦.០៩៧ | ២៧០.១៣៨ | ៦១.៧៣២ | ២៥១.១២៦ |
| ចំណាយពន្ធផ្សេងៗ | ៧៩.៧១៩ | ៣២៥.៨១២ | ២៤៥.១៥៦ | ៩៩៧.២៩៥ |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ១១.៩៣០ | ៤៨.៧៥៨ | - | - |
| ការខាតបង់លើការបញ្ចប់ភតិសន្យាបន្ត | ១.០៤៦.៩៦៦ | ៤.២៧៨.៩៥០ | - | - |
| ការជម្រះចេញពីបញ្ជីទ្រព្យសម្បត្តិ រោង-ចក្រ និងបរិក្ខារ | ៨.៣០៩ | ៣៣.៩៥៩ | - | - |
| ឱនភាពលើគណនីអតិថិជនពាណិជ្ជកម្ម | ៦៦៤.៤៣១ | ២.៧១៥.៥២៩ | ៤១៥.៥០៣ | ១.៦៩០.២៦៦ |
| ចំណាយផ្សេងៗ | ៤៤៥.៩១២ | ១.៨២២.៤៤២ | ១៦៦.១១០ | ៦៧៥.៧៣៥ |
| | ៩.៦៣៦.៦៩១ | ៣៩.៣៨៥.១៥៥ | ៧.៤៥១.៣៦៥ | ៣០.៣១២.១៥២ |

## ២៦. ចំណាយហិរញ្ញវត្ថុ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើ៖ | | | | |
| - កម្ចី | ៧៧៦.៧១០ | ៣.១៧៤.៤១៤ | ៨៧៣.៣៧៥ | ៣.៥៥២.៨៩០ |
| - បំណុលភតិសន្យា | ៣០៨.៤៧៦ | ១.២៦០.៧៤១ | ២៦៨.១១១ | ១.០៩០.៦៧៥ |
| ផលប៉ះពាល់នៃ៖ | | | | |
| - ប្រាក់កក់ត្រូវទទួលរយៈពេលវែង | ១.៣៥២ | ៥.៥២៦ | ១.៣០០ | ៥.២៨៨ |
| | ១.០៨៦.៥៣៨ | ៤.៤៤០.៦៨១ | ១.១៤២.៧៨៦ | ៤.៦៤៨.៨៥៣ |

## ២៧. ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | | |
| ពន្ធប្រាក់ចំណេញក្នុងគ្រា | ៣.៧៣៥.៤៤៦ | ១៥.២៦៦.៧៦៨ | ២.៦៧៤.៧៣៧ | ១០.៨៨០.៨៣០ |
| (លើស)/ខ្វះទទួលស្គាល់ចំណាយពន្ធ កាលពីឆ្នាំមុន | (១០.៦៨២) | (៤៣.៦៥៦) | ៣០.១៥៥ | ១២២.៦៧១ |
| | ៣.៧២៤.៧៦៤ | ១៥.២២៣.១១២ | ២.៧០៤.៨៩២ | ១១.០០៣.៥០១ |
| ពន្ធពន្យារ (កំណត់សម្គាល់លេខ៩)៖ | | | | |
| ដើម និងការត្រឡប់នៃភាពខុសគ្នា បណ្តោះអាសន្ន | ៤១១.៦០៦ | ១.៦៨២.២៣២ | ២៩៩.៦១៥ | ១.២១៨.៨៣៣ |
| | ៤.១៣៦.៣៧០ | ១៦.៩០៥.៣៤៤ | ៣.០០៤.៥០៧ | ១២.២២២.៣៣៤ |

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក.ស.ភ មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% (២០២១៖ ២០%) លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា១% (២០២១៖ ១%) នៃចំណូលសរុប ប្រសិនបើមួយណាមានចំនួនច្រើនជាង។

តួលេខក្នុងការសម្របសម្រួលរវាងចំណាយពន្ធ និងផលគុណនៃប្រាក់ចំណេញគណនេយ្យនឹងអត្រាពន្ធដាររបស់ ក.ស.ភ មានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៨.៤៤៩.៦៥៣ | ៧៥.៤០៣.៧៣៣ | ១៥.៧១២.៣៣៨ | ៦៣.៩១៧.៧៩១ |
| ពន្ធគណនាតាមអត្រាពន្ធស្របច្បាប់ ២០% (២០២១៖ ២០%) | ៣.៦៨៩.៩៣១ | ១៥.០៨០.៧៤៨ | ៣.១៤២.៤៦៨ | ១២.៧៨៣.៥៦០ |
| ឥទ្ធិពលពន្ធដារទៅលើ៖ | | | | |
| ចំណាយដែលមិនអាចកាត់កងបាន | ៦១៥.៩១០ | ២.៥១៧.២២៤ | ២១០.១៥២ | ៨៥៤.៨៩៨ |
| ចំណូលដែលមិនអាចកាត់កងបាន | (១៥៨.៧៨៩) | (៦៤៨.៩៧២) | (៣១.៦៩៨) | (១២៨.៩៤៧) |
| ពន្ធលើកទឹកចិត្តនឹងប្រាក់ឧបត្ថម្ភ | - | - | (៣៤៦.៥៧០) | (១.៤០៩.៨៤៧) |
| | ៤.១៤៧.០៥២ | ១៦.៩៤៩.០០០ | ២.៩៧៤.៣៥២ | ១២.០៩៩.៦៦៤ |
| សំវិធានធន(លើស)/ខ្វះក្នុង ការិយបរិច្ឆេទមុន ចំណូលពន្ធ | (១០.៦៨២) | (៤៣.៦៥៦) | ៣០.១៥៥ | ១២២.៦៧១ |
| ចំណាយពន្ធសរុប | ៤.១៣៦.៣៧០ | ១៦.៩០៥.៣៤៤ | ៣.០០៤.៥០៧ | ១២.២២២.៣៣៤ |

## ២៨. ចំណេញក្នុងមួយភាគហ៊ុន

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិក ធម្មតា | ១៤.៥៦៥.០៤៣ | ៥៩.៥២៧.៣៣២ | ១២.៦៨៦.៧៩៧ | ៥១.៦០៩.៨៩១ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់ គិតជាមធ្យម | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០,៧០ | ២,៨៨ | ០,៦១ | ២,៥០ |
| ចំណេញក្នុងមួយភាគហ៊ុនដែលថយចុះ | ០,៧០ | ២,៨៨ | ០,៦១ | ២,៥០ |

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមានដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមការិយបរិច្ឆេទនេះ ក.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជា ភាគហ៊ុនធម្មតានោះទេ។ ដូចនេះចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយ ភាគហ៊ុនជាមូលដ្ឋាន។

## ២៩. ភាគលាភ

ក្នុងអំឡុងពេលនៃមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំលើកទី ៧ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ក.ស.ភ បានអនុម័តបែងចែកភាគលាភទាក់ទងនឹងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ទៅម្ចាស់ភាគហ៊ុននៃភាគហ៊ុននីមួយៗដូចខាងក្រោម៖

- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ “ក” ទទួលបានភាគលាភចំនួន ៣៤០.១៩០ដុល្លារអាមេរិក (សមមូលទៅនឹង១.៣៧៦.៧៥១.៣៣៤ រៀល)។
- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ “ខ” ទទួលបានភាគលាភសរុបចំនួន ៧៤១.២៩០ដុល្លារអាររមេរិក (សមមូលទៅនឹង ៣.០០០.០០០.០០០រៀល)។

ភាគលាភទាំងនេះត្រូវបានទូទាត់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។

## ៣០. ការលាតត្រដាងពីភាគីពាក់ព័ន្ធ

(ក) ភាគីមួយត្រូវបានចាត់ទុកថាជាសម្ព័ន្ធញាតិជាមួយ ក.ស.ភ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ឬមានឥទ្ធិពលជាខ្លាំងលើភាគីមួយទៀតក្នុងការសម្រេចចិត្តហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬបើ ក.ស.ភ និងភាគីនោះស្ថិតក្រោមការគ្រប់គ្រង ឬមានឥទ្ធិពលជាខ្លាំង។ សម្ព័ន្ធញាតិ អាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។

ថ្នាក់ដឹកនាំសំខាន់ៗរបស់ ក.ស.ភ រួមមានបុគ្គលទាំងឡាយណា (រួមបញ្ចូលទាំងក្រុមប្រឹក្សាភិបាល ក.ស.ភ) ដែលមានសិទ្ធិ និងទំនួលខុសត្រូវក្នុងការគ្រោង ដឹកនាំ និងគ្រប់គ្រង សកម្មភាពរបស់ ក.ស.ភ ដោយផ្ទាល់ ឬដោយប្រយោល។

## ៣០. ការលាតត្រដាងពីភាគីពាក់ព័ន្ធ (ត)

(ខ) ក.ស.ភ មានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោមៈ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ញាតិសម្ព័ន្ធ | | | | |
| ក.ស.ហ | | | | |
| ចំណាយការប្រាក់ | ៧៧៦.៧១០ | ៣.១៧៤.៤១៤ | ៨៥៩.៤៩៩ | ៣.៤៩៦.៤៤២ |
| ទូទាត់ការប្រាក់ | ៨០៧.២៩៩ | ៣.២៩៩.៤៣១ | ៨៩០.០៨៩ | ៣.៦២០.៨៨២ |
| ការទូទាត់ប្រាក់ដើម | ២.០៦៩.៩៧៤ | ៨.៤៥៩.៩៨៤ | ២.០៦៩.៩៧៤ | ៨.៤២០.៦៥៤ |
| ក.ស.ហ និង ក.ស.ជ | | | | |
| ប្រទានកម្ម និងសប្បុរស | ២៩.៧២៧ | ១២១.៤៩៥ | ៣៨.៩៥៩ | ១៥៨.០៧៩ |

តុល្យការជាមួយភាគីពាក់ព័ន្ធនៅចុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ១៧ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធខាងលើត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌពាណិជ្ជកម្មចរចារ។

(គ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ

អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ អំឡុងការិយបរិច្ឆេទមានដូចខាងក្រោមៈ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| អត្ថប្រយោជន៍និយោជិតក្នុងរយៈពេលខ្លី | ២៤៦.៣៣១ | ១.០០៦.៧៥៤ | ២៤៧.៨០៩ | ១.០០៨.០៨៧ |

## ៣១. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ

(ក) ការគ្រប់គ្រងមូលធន

កម្មវត្ថុបឋមរបស់ ក.ស.ភ ក្នុងការគ្រប់គ្រងមូលធន គឺដើម្បីធានាបានថា ក.ស.ភ អាចបន្តប្រតិបត្តិ-ការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយស្របពេល ជាមួយគ្នានេះធ្វើឱ្យមានកំណើនផលលាភដល់ភាគហ៊ុនិក តាមរយៈការធ្វើឱ្យប្រសើរឡើងនូវអនុបាតបំណុល និងមូលធន។ ពុំមានការផ្លាស់ប្តូរយុទ្ធសាស្ត្រទូទៅរបស់ក្រុមហ៊ុនទេ។

ក.ស.ភ បានរៀបចំរចនាសម្ព័ន្ធ និងធ្វើនិយ័តកម្មលើមូលធនរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា ឬធ្វើនិយ័តកម្មលើរចនាសម្ព័ន្ធមូលធន ក.ស.ភ អាចធ្វើនិយ័ត-កម្មលើការចំណាយភាគលាភទៅលើភាគហ៊ុនិក បង្វិលភាគហ៊ុនឱ្យទៅភាគហ៊ុនិក ឬបោះផ្សាយភាគហ៊ុនថ្មី។ ពុំមានការប្រែប្រួលលើកម្មវត្ថុគោលនយោបាយ ឬដំណើរការផ្សេងៗទេនៅក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ក.ស.ភ គ្រប់គ្រង និងថែរក្សា ដោយប្រុងប្រយ័ត្ននូវបំណុលសរុប និងធានាឱ្យបាននូវអនុលោមភាពនៃតម្រូវការមូលធនផ្នែកខាងក្រៅ។

## ៣១. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធិភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបង្កើតគោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាច ត្រួតពិនិត្យការកំណត់ការទទួលខុសត្រូវ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ក.ស.ភ ត្រូវបានផ្សារភ្ជាប់យ៉ាងចម្បងទៅនឹងហានិភ័យអត្រាការប្រាក់ ហានិភ័យឥណទាន និងហានិភ័យសន្ទនីយភាព និងលំហូរសាច់ប្រាក់។ ព័ត៌មានស្តីពីការគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធមានដូចខាងក្រោមៈ

(១) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលនៃអត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ ក.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងទៅនឹងប្រាក់បញ្ញើ។ ក.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើអត្រាការប្រាក់ទីផ្សារ។ ក.ស.ភ ពុំបានប្រើប្រាស់ឧបករណ៍និស្សន្ទហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់កាតព្វកិច្ចបំណុលដែលត្រូវសងនោះទេ។

<u>ការវិភាគរំញោចសម្រាប់ហានិភ័យអត្រាការប្រាក់</u>

តារាងខាងក្រោមបង្ហាញពីការវិភាគរំញោចសម្រាប់ហានិភ័យអត្រាការប្រាក់របស់ ក.ស.ភ នៅចុងការិយបរិច្ឆេទ ដោយឈរលើគោលការណ៍បម្រែបម្រួល ០,១% និងកត្តាអថេរផ្សេងទៀតមិនមានការប្រែប្រួលៈ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** |
| **ផលចំណេញបន្ទាប់ពីកាត់ពន្ធ** | | | | |
| - កំណើន ០,១% (២០២១៖ ០,១%) | (៤.៧២៨) | (១៩.២៣៤) | (៣.១៨៩) | (១២.៩៧៣) |
| - តំហយ ០,១% (២០២១៖ ០,១%) | ៤.៧២៨ | ១៩.២៣៤ | ៣.១៨៩ | ១២.៩៧៣ |

(២) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ ក.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ ក.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា ក.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

## ៣១. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(២) ហានិភ័យឥណទាន (ត)

ហានិភ័យឥណទានដែល ក.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីអតិថិជនពាណិជ្ជកម្មពីអតិថិជន។ ក.ស.ភ គ្រប់គ្រងហានិភ័យឥណទានដែលបានមកពីការផ្តល់សេវា ដោយធានាថាអតិថិជនទាំងនោះមានហិរញ្ញវត្ថុ និងប្រវត្តិឥណទានល្អ។ ក.ស.ភ បានស្វែងរកការវិនិយោគលើទ្រព្យសកម្មសាច់ប្រាក់ដោយមានសុវត្ថិភាព និងផ្តល់ផលចំណេញជាមួយស្ថាប័នហិរញ្ញវត្ថុស្របច្បាប់។

ក.ស.ភ កំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងលំនាំដើម នៅពេលដែលការសន្យាទូទាត់មិនបានអនុវត្ត និងពេលដែលមានព័ត៌មានពីខាងក្នុង និងខាងក្រៅបញ្ជាក់ថាទ្រព្យសកម្មនោះមិនអាចទទួលបានមកវិញ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលុបចោលនៅពេលដែលគ្មានការរំពឹងទុកសមហេតុផលនៃការទទួលនូវសាច់ប្រាក់តាមកិច្ចសន្យា។

<u>ការប្រឈមមុខចំពោះហានិភ័យឥណទាន និងទម្រង់នៃការគិតគូរលើហានិភ័យឥណទាន</u>

ការប្រឈមនឹងហានិភ័យឥណទានធំបំផុតរបស់ ក.ស.ភ តំណាងដោយតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ។

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ ប្រមាណ៦៣% (២០២១៖ ៦១%) គណនីអតិថិជនពាណិជ្ជកម្មរបស់ ក.ស.ភ គឺជំពាក់ដោយបី (២០២១៖ បី) អតិថិជនចម្បង។

ក.ស.ភ មិនបានរំពឹងទុកថា តម្លៃគណនេយ្យដែលបានកត់ត្រានៅចុងការិយបរិច្ឆេទនៃរបាយ-ការណ៍នីមួយៗ អាចនឹងមានតម្លៃខុសពីអ្វីដែលនឹងត្រូវបានទទួលនោះទេ។

(៣) ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ ក.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល ក.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក.ស.ភ គ្រប់គ្រងលំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក.ស.ភ រក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ ក.ស.ភ។

## ៣២. ចម្រៀកនៃព័ត៌មាន

ផ្នែកប្រតិបត្តិការ ត្រូវបានរាយការណ៍តាមរបៀបដែលត្រូវគ្នា ជាមួយនឹងរបាយការណ៍ផ្ទៃក្នុងដែលបានផ្តល់ ក.ស.ភ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ អ្នកដែលទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃលទ្ធផលនៃផ្នែកប្រតិបត្តិការ ត្រូវបានកំណត់ថាជាគណៈគ្រប់គ្រង។ ក.ស.ភ បានធ្វើប្រតិបត្តិការនៅក្នុងផ្នែកមួយដែលជាអាជីវកម្មដែលទាក់ទងនឹងផែ។

## ៣៣. ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទ

(ក) នៅនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ក្រុមហ៊ុន មេគង្គ អូរីហ្សា ត្រេឌីង ខូអិលធីឌី (“មេគង្គ”) បានផ្ទេរសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងលក្ខខណ្ឌនានាដែលបានកំណត់នៅក្នុងកិច្ចសន្យាជួលបន្តរវាង ក.ស.ភ និង ក្រុមហ៊ុន មេគង្គ អូរីហ្សា ត្រេឌីង ខូអិលធីឌី ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ទៅក្រុមហ៊ុន ភីធីអិលអេស ខូអបភើរេសិន ខូអិលធីឌី (“ភីធីអិលអេស”)។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២ មេគង្គ និងភីធីអិលអេស បានចុះកិច្ចព្រមព្រៀងផ្សេងទៀតលើការផ្ទេរសិទ្ធិជួល (ដែល ក.ស.ភ ជាសាក្សី) ដោយបានកាត់បន្ថយ ទំហំដីធ្លីពី ១៧.០០០ ម៉ែត្រការ៉េ ទៅ ១៥.៥២០ ម៉ែត្រការ៉េ។

(ខ) នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ក.ស.ភ បានចុះកិច្ចព្រមព្រៀងជួលរយៈពេល ៣០ឆ្នាំ ជាមួយលោក ជំទាវឧកញ៉ា សេង គាង ដើម្បីជួលដីធ្លីស្ថិតនៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមាន ទំហំ៣៨.៣៦២ ម៉ែត្រការ៉េ ដែលការប្រគល់ដីធ្លីមកឱ្យ ក.ស.ភ ប្រព្រឹត្តិទៅនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២២។

(គ) នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ការសាងសង់ចំណតផែពហុបំណង TS១១ ដែលមានទីតាំងនៅ គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ ភ្នំពេញ ត្រូវបានចាប់ផ្តើម និងរំពឹងបញ្ចប់ក្នុងឆ្នាំ២០២៣។

(ឃ) ក.ស.ភ និង ភីធីអិលអេស បានចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគសម្រាប់ការអភិវឌ្ឍន៍ ចំណតផែពហុបំណង UM២ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២។ ភាគីទាំងពីរបានយល់ព្រមសហការ ក្នុងការវិនិយោគលើការអភិវឌ្ឍន៍ចំណតផែពហុបំណង UM២ ដែលស្ថិតនៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

(ង) នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ក្រុមហ៊ុន ហ៊្វយ បាង អ៊ិនធើណេសិនណល អ៊ីនវេសមេនគ្រុប ខូអិលធីឌី (“ហ៊្វយ បាង”) និង ក.ស.ភ បានធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងជួលរយៈពេល ៤០ ឆ្នាំ ចុះ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដែលក្រុមហ៊ុន ហ៊្វយ បាង បានប្រគល់ដីធ្លីដំណាក់កាលទី ១ ស្ថិតនៅសង្កាត់ គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ ដែលមានទំហំ ៩.០៥៧ ម៉ែត្រការ៉េ និងតាមបណ្តោយផ្លូវជាតិលេខ ៤ សង្កាត់លេខ ១ ក្រុងព្រះសីហនុ ដែលមានទំហំ ៩.៧៨០ ម៉ែត្រការ៉េ ទៅឱ្យ ក.ស.ភ វិញ។ បន្ថែមពីនេះ ក្បាលដីធ្លីដំណាក់កាលទី២ ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ សង្កាត់លេខ១ ក្រុងព្រះសីហនុ ដែលមានទំហំ ១៨.៦៧៩ម៉ែត្រការ៉េ ត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុន ហ៊ុយ បាង។ ថ្ងៃដែលវិសោធនកម្ម មានប្រសិទ្ធិភាពគឺ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

(ច) នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ក.ស.ភ បានចុះកិច្ចសន្យាជួលរយៈពេល ៣៦ ឆ្នាំជាមួយលោកស្រី លី ចាន់នី ដើម្បីជួលដីធ្លីដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៤ សង្កាត់លេខ ១ ក្រុង ព្រះសីហនុ មានទំហំ ៩.៧៨០ ម៉ែត្រការ៉េ។

(ឆ) នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ក.ស.ភ បានចុះកិច្ចសន្យាជួលរយៈពេល ៣៦ ឆ្នាំជាមួយក្រុមហ៊ុន ភីធីអិលអេស ដើម្បីជួលដីធ្លីដែលមានទីតាំងស្ថិតនៅសង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ ដែលមាន ទំហំ ៩.០៥៧ ម៉ែត្រការ៉េ។

## ៣៤. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍

នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ ក្បាលដីផ្លូវស្ថិតនៅសង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ មានទំហំ ៣.៤៦៦ ម៉ែត្រការ៉េ ត្រូវបានប្រគល់ទៅឱ្យ ក.ស.ភ ស្របតាមកិច្ចសន្យាជួលរយៈពេល ៤០ឆ្នាំ ដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ហ្វ្រីនត្រេដ ខូអិលធីឌី នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ។

## ៣៥. យថាភាពនៃពន្ធ

នៅក្នុងប្រទេសកម្ពុជា បទបញ្ញត្តិស្តីពីពន្ធដារ រួមមាន អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ ដែលជារឿយៗតែងមានការកែតម្រូវតាមរយៈការធ្វើវិសោធនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលកត្តានេះអាចនាំឱ្យភាគីពាក់ព័ន្ធ អាចនឹងធ្វើការបកស្រាយផ្សេងៗពីគ្នា ទៅលើបទដ្ឋានគតិយុត្តិទាំងនោះ។ តាមនីតិវិធីច្បាប់ មន្ត្រីពន្ធដារនឹងចុះធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីធ្វើការផាកពិន័យ តាមកំរិតទោសទណ្ឌ និងការពិន័យលើការប្រាក់ជាដើម ចំពោះបទល្មើសពាក់ព័ន្ធនឹងពន្ធដារ។ កាលប្រែប្រួលជាញឹកញាប់នៃច្បាប់ពន្ធដារ អាចនាំឱ្យកើតមានជាហានិភ័យយ៉ាងខ្ពស់ ចំពោះអង្គភាពនាពេលខាងមុខ។ ថ្នាក់គ្រប់គ្រងជឿជាក់ថា ខ្លួនមានហេតុផលសមរម្យ និងគ្រប់គ្រាន់សម្រាប់សំវិធានធនលើបំណុលពន្ធ ដោយផ្អែកលើការបកស្រាយរបស់បទបញ្ញត្តិនៃពន្ធនាពេលបច្ចុប្បន្ន។

## ៣៦. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី

### ៣៦.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ

ក.ស.ភ បានអនុវត្តនូវវិសោធនកម្មក្នុងការិយបរិច្ឆេទដូចខាងក្រោម៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| ការកែលម្អប្រចាំឆ្នាំលើស្តង់ដារ ស.រ.ហ.អ.ក ២០១៨ - ២០២០ | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ឯកសារយោងទៅនឹងក្របខណ្ឌគណនេយ្យ* | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.គ.អ.ក ១៦ *ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ - ចំណូលពីការលក់មុននឹងមានបំណងក្នុងការប្រើប្រាស់* | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.គ.អ.ក ៣៧ *កិច្ចសន្យាស្មុគស្មាញ - ចំណាយនៃការបំពេញកិច្ចសន្យា* | ១ មករា ២០២២ |

ការដាក់ឱ្យប្រើប្រាស់នូវវិសោធនកម្មខាងលើមិនមានឥទ្ធិពលទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ។

## ៣៦. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៦.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្ត៖

| | **ថ្ងៃចូលជាធរមាន** |
|---|---|
| ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០២៣ |
| *ពាក្យស្នើសុំដំបូងនៃ ស.រ.ហ.អ.ក ១៧ និង ស.រ.ហ.អ.ក ៩ - ព័ត៌មានប្រៀបធៀប* (វិសោធន-កម្មលើ ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង) | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង - ការពង្រីកការលើកលែងជាបណ្តោះអាសន្នពីការអនុវត្ត ស.ក.អ.ហ.រ. ៩* | ១ មករា ២០២៣ |
| *ការលាតត្រដាងគោលនយោបាយគណនេយ្យ* (វិសោធនកម្មលើស..គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ)* | ១ មករា ២០២៣ |
| *ការលាតត្រដាងការប៉ាន់ស្មានគណនេយ្យ* (វិសោធនកម្មលើស..គ.អ.ក ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង)* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.គ.អ.ក ១២ *ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលមកពីប្រតិបត្តិការតែមួយ* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ *បំណុលភតិសន្យាក្នុងការលក់ និងជួលត្រលប់* | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.គ.អ.ក ១ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង* | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.គ.អ.ក ១ *បំណុលរយៈពេលវែង ជាមួយការព្រមព្រៀងជាផ្លូវការ* | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស គ.អ.ក.២៨ *ការលក់ ឬការចែកចាយនៃទ្រព្យរវាងសហគ្រិន និងញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ពន្យារ |

ក.ស.ភ កំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្មទាំងនេះ ដោយហេតុថាក្រុមប្រឹក្សាភិបាលពុំទាន់មានជំហរ ដើម្បីសន្និដ្ឋានលើផលប៉ះពាល់ដែលមានសក្តានុពលលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក.ស.ភ នៅឡើយទេ។




### ចំណតផែរណបពហុបំណងទន្លេបិទ UM២
Sub-Feeder Multipurpose Terminal Tonle Bet-UM2
ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
Tonle Bet Village, Tonle Bet Commune, Tboung Khmum District, Tboung Khmum Province

### ចំណតផែរណបពហុបំណង UM១
Sub-Feeder Multipurpose Terminal UM1
ផ្លូវជាតិលេខ ៦A, ភូមិកណ្ដាល,ឃុំព្រែកអញ្ចាញ, ស្រុកមុខកំពូល, ខេត្តកណ្ដាល
National Road No. 6A, Kandal Village, Prek Anhchanh Commune, Mok Kampul District, Kandal Province

### ចំណតផែពហុបំណង TS៣
Multipurpose Terminal TS3
#៦៤៩ មហាវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
#649, Preah Sisowath Street, Sras Chork Commune, Daun Penh District, Phnom Penh

### ចំណតផែអ្នកដំណើរ និងទេសចរ TS១
Passenger and Tourist Terminal TS1
មហាវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Preah Sisowath Street, Wat Phnom Commune, Daun Penh District, Phnom Penh

### ចំណតផែរណបពហុបំណង TS១១
Sub-Feeder Multipurpose Terminal TS11
ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
National Road 5, Spean Khpos Village, Kilometer 6 Commune, Reusseykeo District, Phnom Penh

### ចំណតផែកុងតឺន័រ LM១៧ និងដីលានស្តុកទុកកុងតឺន័រ
Container Terminal LM17 /ICD-LM១៧/ and Inland Container Depot ICD-LM17
ភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល
Kandal Leu Village, Bantey Dek Commune, Kien Svay District, Kandal Province

### ចំណតផែរណបពហុបំណង LM២៦
Sub-Feeder Multipurpose Terminal LM២៦
ភូមិកោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង
Koh Roka Village, Koh Roka Commune, Peam Chor District, Prey Veng Province

### ទំនាក់ទំនង/ Contact
Email ppapmpwt@online.com.kh
Tel/Fax +855 23 427 802
Website www.ppap.com.kh
Headquarter's Address #649, Preah Sisowath Street, Sras Chork Commune, Daun Penh District, Phnom Penh